


# ទស្សនាវដ្តី

# វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម












ឆ្នាំទី២
លេខ១

ចេញផ្សាយប្រចាំឆមាស
ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ខែមករា - មិថុនា
ឆ្នាំ២០២៣

# និពន្ធនាយក

ឯកឧត្តមបណ្ឌិត **ផុន កសិកា**

រៀបចំចងក្រងដោយ៖

លោក **យិន ពោ**

រចនាក្របដោយ៖

លោក **ហ៊ាង សុចិត្រា**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ (ស្ថិតក្នុងបរិវេណសាកលវិទ្យាល័យភ្នំពេញ២)

គេហទំព័រ (Website) ៖ https://ihss.rac.gov.kh

ហ្វេសប៊ុក (Facebook) ៖ https://web.facebook.com/ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

យូធូប (Youtube) ៖ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម IHSS

# **កថាមុខ**

រាជបណ្ឌិត្យសភាកម្ពុជាជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្តុំដោយបញ្ញវន្ត និងអ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។ រាជបណ្ឌិត្យសភាកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីផ្តល់ជាធាតុចូលជូនរាជរដ្ឋាភិបាលក្នុងការបម្រើដល់កិច្ចការស្តារ និង អភិវឌ្ឍសេដ្ឋកិច្ចសង្គម។

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនដូចជា ស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម រួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួន ក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាពភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជបណ្ឌិត្យសភា កម្ពុជា។

ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្របានបង្កើតទស្សនាវដ្តីមួយដែលមានឈ្មោះថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» ដើម្បីរៀបចំចងក្រង និងបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថាន អ្នកស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្ត្រពីគ្រប់មជ្ឈដ្ឋានផងដែរ។

"**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**" ប្រមូលផ្តុំដោយអត្ថបទទាក់ទងនឹងប្រធានបទណាមួយ របកគំហើញថ្មីៗ និងអត្ថបទទស្សនៈរបស់អ្នកនិពន្ធជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹងទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជាអ្នកអានទូទៅ។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជា ពិតជាផ្តល់នូវមូលដ្ឋានឯកសារសម្រាប់និស្សិត ក៏ដូចជាអ្នកស្រាវជ្រាវទូទៅធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។

ថ្ងៃពុធ ១២កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព. ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣

**ប្រធានវិទ្យាស្ថាន**

**បណ្ឌិត ផុន កសិកា**

# មាតិកា

ទំព័រ

១-នរវិទ្យា ៖ មូលដ្ឋានចំណេះដឹង និង ការប្រើប្រាស់...........................................................................១

បណ្ឌិត អ៊ុំ ប៉ុម

២-ប្រវត្តិ និង សារៈសំខាន់នៃពុទ្ធិកសិក្សានៅកម្ពុជា.........................................................................១៥

លោកស្រីបណ្ឌិត ជា វណ្ណី

៣-ប្រវត្តិរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា....................................................................................២៤

បណ្ឌិត ហែម ឡាច

៤-ប្រាសាទឯកភ្នំក្នុងបរិបទប្រវត្តិសាស្ត្រនិងទេសចរណ៍....................................................................៣៦

លោក សួ ប៊ុណ្ណារ៉ាត់

៥-តម្លៃនៃជីវិតរបស់មនុស្ស.............................................................................................................៥៨

បណ្ឌិត ហែម ឡាច

៦-ការអនុវត្តការងាររដ្ឋបាលអប់រំនៃវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីកក្នុងខេត្តត្បូងឃ្មុំ.....៨០

លោក ប៉ាន់ សំណាង

៧-នានាភាពនៃអក្សរសិល្ប៍សម័យអាណានិគមនិយមបារាំង.................................................................១០៨

បណ្ឌិត ឃិន យ៉ង់

៨-ការអប់រំ និងឧក្រិដ្ឋកម្ម..........................................................................................................១២៣

បណ្ឌិត សូ សុធីរ

៩-បច្ចុប្បន្នភាពនៃយេនឌ័រ និង តួនាទីយេនឌ័រនៅកម្ពុជា................................................................១៣៦

លោកស្រីបណ្ឌិត ជា វណ្ណី

១០-ប្រជាសាស្ត្រតំបន់ឆ្នេរសមុទ្រកម្ពុជា..........................................................................................១៤៥

លោក ហៃ សុគន្ធា

១១-ការប្រតិបត្តិសីលធម៌ក្នុងគ្រួសារខ្មែរបច្ចុប្បន្ន...........................................................................១៦១

លោក ឈុន ផារ៉េង

១២-ប្រវត្តិសាកលវិទ្យាល័យភូមិន្ទកំពង់ចាម(ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧០)...........................................២០២

បណ្ឌិត សុង ស៊ីណា

# នរវិទ្យាៈ មូលដ្ឋានចំណេះដឹង និង ការប្រើប្រាស់

*ដោយៈ បណ្ឌិត* **អ៊ុំ ម៉ុម**
*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

*ដោយមើលឃើញពីភាពចាំបាច់នៃមុខវិជ្ជានរវិទ្យាចំពោះស្ថានភាពបច្ចុប្បន្នក៏ដូចជាគោលដៅស្រាវជ្រាវប្រកបដោយគតិបណ្ឌិតរបស់វិទ្យាស្ថានក្នុងឆ្នាំ២០២២ រូបខ្ញុំផ្ទាល់បានខិតខំចំណាយពេលវេលាដ៏មានតម្លៃនៃឆ្នាំថ្មីនេះ ដើម្បីរួមវិភាគទានជាមួយស្ថាប័នចង់ក្រងជាអត្ថបទនេះឡើងដោយប្រើប្រាស់ចំណេះដឹងបន្តិចបន្តួច ដែលធ្លាប់ទទួលបានពីនរវិទ្យានាពេលកន្លងមកដើម្បីទុកជាឯកសារអនុស្សាវរីយ៍សម្រាប់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ប្រើប្រាស់ជាគុណប្រយោជន៍សាធារណៈតទៅ។ ដោយឡែក ក្នុងដំណើរសិក្សាស្វែងយល់ពីមុខវិជ្ជានេះទៀតសោតខ្ញុំបានប្រមូលផ្តុំយកចិត្តទុកដាក់បង្ហាញជូនតែទៅលើអ្វីដែលជាចំណេះដឹងមូលដ្ឋានរបស់នរវិទ្យាព្រមទាំងការប្រើប្រាស់ជាសារប្រយោជន៍នៃមុខវិជ្ជានេះ ចំពោះជីវភាពរស់នៅក៏ដូចជាដំណោះស្រាយបញ្ហាលំបាកក្នុងការរស់នៅរបស់មនុស្សជាតិបច្ចុប្បន្នដែលកំពុងចោទឡើង ស្ទើរគ្រប់វិស័យនិងគ្រប់ទិសទីនៅលើសកលលោកយើងតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ សូមប្រិយមិត្តអ្នកអាន ចូលរួមស្វែងយល់ពីចំណុចអស់ទាំងនោះ ជាមួយនឹងរូបខ្ញុំ តាមខ្លឹមសារបន្តបន្ទាប់ដូចតទៅៈ*

## ១. និយមន័យនរវិទ្យា (Definition of Anthropology)

*បើតាមន័យទូទៅពាក្យ «នរវិទ្យា» ត្រូវនឹងពាក្យអង់គ្លេសថា* **Anthropology**។ *ពាក្យនេះ មានប្រភព ដើមមកពីពាក្យក្រិក ពីរម៉ាត់ថា:* **Anthropos** និង **Logos** ។

**Anthropos = Man**

**Logos = Study**

**==> Anthropology is the man study.**

*-តាមវចនានុក្រមសម្តេចសង្ឃរាជ ជួនណាត បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧ បានពន្យល់យ៉ាងដូច្នេះថា នរវិទ្យា មកពីពាក្យ:*

*នរ: + វិទ្យា*

*នរ: = មនុស្ស*

*វិទ្យាឬវិជ្ជា = ចំណេះការចេះដឹង សេចក្តីដឹងច្បាស់*

*សរុបន័យមកវិញ នរវិទ្យាជាចំណេះដឹងស្តីពីមនុស្ស។*

## ២. ប្រវត្តិនរវិទ្យា

*-តាមការស្រាវជ្រាវរបស់លោក ហាដដុន*(**Haddon**)*ពាក្យ នរវិទ្យា ត្រូវបានលើកយកមកប្រើប្រាស់ដំបូងគេបង្អស់ ដោយអ្នកនិពន្ធក្រិកនិងរ៉ូម៉ាំង តាំងតែពីសម័យបុរាណមកម្ល៉េះ។ ជាក់ស្តែង:*

*-អារីស្តូត ក៏ធ្លាប់បានយកពាក្យនេះមកប្រើក្នុងន័យ"មនុស្សនិយាយពីខ្លួនឯង"* (Man who talk about himself)។

*-បន្ទាប់មកនៅឆ្នាំ១៦៥៩ មានអ្នកនិពន្ធម្នាក់ទៀត ដែលគេមិនស្គាល់ឈ្មោះ បាន ចាប់អារម្មណ៍សរសេរពីមូលន័យសង្ខេបរបស់នរ វិទ្យា* (Anthropology abstract) *ដោយរៀបរាប់អំពី "ប្រវត្តិនៃធម្មជាតិមនុស្ស"។*

*-ក្រោយមកទៀត លោកដាកវីន* (Darwin ១៨០៩-១៨៨២) *បានសរសេរពី "ការវិវត្តនៃពូជ"* (Evolu-tion of species)។

*ជាបន្តបន្ទាប់ នរវិទ្យា បានលូតលាស់រហូតមកដល់សព្វថ្ងៃ សំខាន់គឺនៅប្រទេសបារាំង និងសហរដ្ឋអាម៉េរិក។ ដោយឡែកចំពោះប្រទេសបារាំងនាពេលកន្លងមកគេបានយកនរវិទ្យាទៅប្រើប្រាស់ភាគច្រើនក្នុងគោលដៅនយោបាយ។ ឧទាហរណ៍:មុននឹងដាក់អាណានិគមត្រួតត្រាលើប្រទេសណាមួយ គេតែងតែបញ្ជូនពួកបេសកជនសាសនា ដែលជានរវិទូឱ្យទៅសិក្សាពីមនុស្ស ពីទំនៀមទម្លាប់ពីរបៀបរបបគ្រប់គ្រងនៃបណ្តាប្រទេសទាំងនោះជាមុនសិន បន្ទាប់មកទើបគេបញ្ជូនកងទ័ពក្នុងកម្រិតណាមួយចូលទៅកាន់កាប់ប្រទេសនោះតែម្តង។*

## ៣. កម្មវត្ថុសិក្សា

*តើនរវិទ្យាមានកម្មវត្ថុសិក្សាបែបណាខ្លះ? ជារួម នរវិទ្យា បានប្រមូលផ្តុំសិក្សាទៅលើកម្មវត្ថុសំខាន់ពីរគឺ៖*

*-ការវិវត្តន៍*[១] *និងការប្រែប្រួល*[២] *របស់មនុស្ស* (Human Evolution and human var-iation) *តាំងពីមនុស្សដើមរហូតដល់មនុស្សទំនើបឬអូម៉ូសាព្យាង* (From prim-itive to modern homosapien)

- *ភាពដូចគ្នា និងភាពខុសគ្នា* (**The Likeness and the difference**) *នៃមនុស្សដើមរហូតដល់មនុស្សទំនើប។*

*គួរកត់សម្គាល់ថា ការវិវត្តន៍និងការប្រែប្រួល ភាពដូចគ្នានិងភាពខុសគ្នា សំដៅតែទៅលើចរិតលក្ខណ:ខាងជីវ:វប្បធម៌ និងចរិតលក្ខណ:ខាងសង្គម*[៣] *តែប៉ុណ្ណោះដោយ*

---

[១] *ការរីកចម្រើនជាលំដាប់។*

[២] *ការផ្លាស់ប្តូរទៅតាមលក្ខខណ្ឌធម្មជាតិ។*

[៣] *កិរិយា និងទំនាក់ទំនងសង្គម។*

ផ្អែកទៅលើកាលនិងលំហ(**Time and Space**) ដែលមនុស្សទាំងនោះរស់នៅ មិនចំពោះថា ពេលណា ឬ ទីកន្លែងណារបស់ពិភពលោកនោះឡើយ។




## ៤. ទីលាននរវិទ្យា (Fields of Anthropology)

ជាទូទៅ នរវិទ្យាមានទីលានសិក្សាសំខាន់ពីរគឺៈ នរវិទ្យារូបសាស្ត្រ ឬនរវិទ្យាជីវៈ និងនរវិទ្យាវប្បធម៌។ នរវិទ្យា វប្បធម៌អាចចែកចេញជាៈ បុរាណវិទ្យា នរវិទ្យាភាសា និងជាតិពន្ធុវិទ្យាឬនរវិទ្យាសង្គមវប្បធម៌ **(Socio cultural anthropology)**។ មានឯកសារខ្លះទៀតបានចែកលម្អិតនរវិទ្យាវប្បធម៌ ជាបុរាណវិទ្យាបុរេប្រវត្តិ នរវិទ្យាភាសា និងជាតិពន្ធុវិទ្យា ហើយជាតិពន្ធុវិទ្យាក៏អាចចែកបន្តជាជាតិពន្ធុសាស្ត្រ(**Ethnography**) ជាតិពន្ធុវិទ្យា (តាមន័យចង្អៀត) និងនរវិទ្យាសង្គម[៨] (សូមមើលរូបភាពទី១ និងទី២)។

[៨] សិក្សាពីស្ថាប័នសង្គម។

• រូបភាពទី១ :




• រូបភាពទី២ :




**៤.១.នរវិទ្យារូបសាស្ត្រ ឬនរវិទ្យាជីវៈ:** (Physical Anthropology)

នេះជាមែកធាងទី១នៃទីលានរបស់នរវិទ្យា ប្រមូលផ្តុំសិក្សាទៅលើការវិវត្តប្រែប្រួលខាងរូបរាងកាយនិងជីវៈរាប់លានឆ្នាំមកហើយ តាំងពីមនុស្សដើមកកើតឡើងរហូតដល់មនុស្សទំនើបៗ ខាងក្រោមនេះគឺជាគំនូររូបភាពបង្ហាញពីការវិវត្តប្រែប្រួលរបស់ពូជមនុស្សនៅលើផែនដីយើង ដោយកំណត់យកចន្លោះពី៥លានឆ្នាំ-៣,៥លានឆ្នាំមុន រហូតដល់៣០០០០ឆ្នាំកន្លងមកហើយ។




• *រូបភាពទី៣: មែកធាងនៃការវិវត្តប្រែប្រួលរបស់មនុស្ស* **(Hominid tree evolution)** *តាមសៀវភៅ* **Anthropology Introduction របស់លោក Michael Alan** *ឆ្នាំ១៩៦៨*

### ៤.២. នរវិទ្យាវប្បធម៌ (Cultural anthropology)

*ជាមែកធាងទី២ របស់នរវិទ្យាដែលសិក្សាទៅលើទំនៀមទម្លាប់ ឬ អាកប្បកិរិយារបស់មនុស្ស។ នរវិទ្យាវប្បធម៌ បែកចេញជាមែកធាងតូចៗបីទៀតគឺ:*

#### ៤.២.១. បុរាណវត្ថុវិទ្យា (Archaeology)

*បុរាណវិទ្យា សិក្សាពីសម្ភារៈដែលមនុស្សបន្សល់ទុកតាំងពីអតីតកាល ឆ្លងតាមនោះ គេអាចពិពណ៌នារៀបរាប់ និង ពន្យល់បានពីអាកប្បកិរិយារបស់មនុស្សក្នុងសម័យកាលនោះ។*

#### ៤.២.២.ភាសាវិទ្យា(Linguistic Anthropology)

*ជាមែកធាងមួយទៀតរបស់នរវិទ្យាវប្បធម៌ដែលសិក្សាពីភាសារបស់មនុស្ស (ភាសានិយាយ និងភាសា សរសេរ)។ ពួកនរវិទូ ចាំបាច់ត្រូវរៀនភាសារបស់ក្រុមមនុស្សទាំងឡាយដែលខ្លួនគេចុះទៅសិក្សាស្រាវជ្រាវដើម្បីបានដឹងព័ត៌មានកាន់តែស៊ីជម្រៅថែមទៀតពីបែបបទរស់នៅ។*

#### ៤.២.៣.ជាតិពន្ធុវិទ្យា (Ethnology)

*គេអាចហៅជាតិពន្ធុវិទ្យាថា ជានរវិទ្យាសង្គមវប្បធម៌ក៏បាន។*

*-តាមន័យទូលាយ ជាតិពន្ធុវិទ្យាសិក្សាតែទៅលើវប្បធម៌បច្ចុប្បន្ន ដោយធ្វើការប្រៀបធៀបជាមួយនឹង វប្បធម៌ដើមឬទស្សនៈប្រវត្តិសាស្ត្រ* (historical point of view) *។ ជាតិពន្ធុវិទ្យាក៏សិក្សាផងដែរ ទៅលើអាកប្បកិរិយារបស់មនុស្សដែលគេបានជួបប្រទះ ឬ បានពិសោធន៍ជាក់លាក់ ព្រមទាំងបានជជែកពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយអ្នកដែលបានយល់ដឹងពីបញ្ហានោះថែមទៀត ដើម្បីឱ្យមានភាពប្រាកដប្រជា។*

*-តាមន័យចង្អៀត : ជាតិពន្ធុវិទ្យាសិក្សា និង វិភាគអំពីភាពដូចគ្នា ភាពខុសគ្នាក្នុងចំណោមវប្បធម៌ទាំងឡាយ ដូចជា ប្រវត្តិ*

នៃការអភិវឌ្ឍរបស់វប្បធម៌ ក៏ដូចជាទំនាក់ទំនងរវាងវប្បធម៌ និងវប្បធម៌។

## ៥. និយមន័យវប្បធម៌តាមបែបនវិទ្យា

### ៥.១. និយមន័យទូលាយ

វប្បធម៌ ជាអាកប្បកិរិយាបានមកដោយការរៀនសូត្រពីសង្គម(Culture is the behavior acquired through social learning)។

### ៥.២. និយមន័យរបស់លោកថាយល័រ (Tylor ១៨៧១)

លោកបានឱ្យនិយមន័យវប្បធម៌បែបនេះថា វប្បធម៌ជា "ភាពចម្រុះ រួមមានទាំងចំណេះដឹង ជំនឿសិល្បៈ សីលធម៌ ច្បាប់ ទំនៀមទម្លាប់ ទម្លាប់បុគ្គលលទ្ធភាពដទៃទៀត ដែលបានមកពីមនុស្សក្នុងនាមជាសមាជិកសង្គម" (...The complex whole which includes knowledge, belief, art, morals, laws, custom and any capabilities and habits acquired by man as a member of society) ។

### ៥.៣. និយមន័យរបស់លោក លីនតុន(Linton ១៩៤០)

លោកបានផ្តល់និយមន័យវប្បធម៌យ៉ាងដូច្នេះថា វប្បធម៌គឺជា "ភាពសរុបនៃចំណេះដឹង ឥរិយាបថ និងអាកប្បកិរិយាគំរូជាទម្លាប់ ត្រូវបានចែកចាយនិងបញ្ជូនបន្តដោយសមាជិកសង្គមដោយឡែកណាមួយ" (The sum total of knowledge, attitude and habitual behavior pattern shared and transmitted by the member of a particular society)។

ដូច្នេះ បើតាមនិយមន័យរបស់លោកទាំងពីរ គេអាចទាញចេញជានិយមន័យសំយោគបែបនេះថា វប្បធម៌គឺជាចំណេះដឹងផងហើយក៏ជាជំនឿទំនៀមទម្លាប់ ច្បាប់ សីលធម៌ផងដែរ ដែលត្រូវបានចែករំលែក និងបញ្ជូនបន្តដោយមនុស្សជាសមាជិកក្នុងសង្គមដោយឡែកណាមួយ។

### ៥.៤. និយមន័យអាកប្បកិរិយាវប្បធម៌ (Cultural behavior)

ជារួម អាកប្បកិរិយាវប្បធម៌ ត្រូវផ្អែកលើចរិតលក្ខណៈបួនយ៉ាងគឺ:

-អាកប្បកិរិយានោះ ត្រូវបានរៀនសូត្រ (It must be learned)

-អាកប្បកិរិយានោះ ត្រូវជាប់ទាក់ទងជាមួយនឹងបញ្ញត្តិទាំងឡាយទូទៅនីយកម្ម អរូបិយកម្មនិងគំនិត (It must involve concepts,generalization,abstractions, ideas)

-អាកប្បកិរិយានោះ ត្រូវបានចែករំលែកបន្ត ឆ្លងតាមការបញ្ជូនហ្សែនមកក្រៅ (It must be shared through extra-genetic transmission)

-អាកប្បកិរិយានោះ ត្រូវលេចជារូបរាងឡើងឆ្លងតាមការប្រើនូវឧបករណ៍បុរាណ ទាំង

រូបិយនិងអរូបិយ[៥] (It must be realized through the use of artifacts, both concrete and abstract).

### ៥.៥. គំរូជាសាកលរបស់វប្បធម៌

**(Universal Pattern of Culture)**

លោកវីស្លែរ(១៩២៣)(Wissler1923) បានចែកគំរូជាសកលរបស់វប្បធម៌ជា៩ ប្រភេទ ដូចតទៅនេះ៖

-ការនិយាយ : ភាសា ប្រព័ន្ធសំណេរ ចំណូលចិត្តនៃការនិយាយ

-លក្ខណ:សម្ភារ:(Material Trait) ម្ហូបអាហារ ទីជម្រក ការដឹកជញ្ជូន និងមុខរបរវិជ្ជាជីវ: ការធ្វើដំណើរ ការស្លៀកពាក់ គ្រឿងប្រដាប់ចម្អិនអាហារ ឧបករណ៍ប្រើប្រាស់ដោយដៃគ្រឿងសាស្ត្រាវុធ

-សិល្ប: : ចម្លាក់ គំនូរ ការគូសវាសផ្សេងៗតន្ត្រី

-ទេវវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រ

-ការប្រតិបត្តិសាសនា : ទម្រង់ពិធីកម្ម ការព្យាបាលជម្ងឺ ពិធីបុណ្យសព

-គ្រួសារនិងប្រព័ន្ធសង្គម : ទម្រង់អាពាហ៍ពិពាហ៍ វិធីភ្ជាប់ទំនាក់ទំនង ការទទួលមរតកត្រួតពិនិត្យសង្គម កីឡា និងល្បែងផ្សេងៗ

-កម្មសិទ្ធិ : របស់ជាសង្ហារឹម និងរបស់ជាប់នឹងខ្លួន ស្តង់ដាតម្លៃ ការដោះដូរ ការធ្វើជំនួញ

-រដ្ឋាភិបាល : ទម្រង់នយោបាយ នីតិវិធីតុលាការនិងនីតិវិធីច្បាប់

-សង្គ្រាម

* ក្រៅពីលោកវីស្លែរ គេអាចឃើញមានការចែកគំរូសាកលរបស់វប្បធម៌ជា៨ ប្រភេទដោយក្នុងនោះគេពុំឃើញមានស្ថាប័នរដ្ឋាភិបាលនិងសង្គ្រាមឡើយ ដោយគេយល់ថា សង្គ្រាមពុំមែនជាវប្បធម៌សកលទេ ប៉ុន្តែជាវប្បធម៌របស់ក្រុមអ្នកខ្លាំងដែលមានមហិច្ឆតាវាតទឹកដីនិងត្រួតត្រាពិភពលោកតែប៉ុណ្ណោះៗ ម្យ៉ាងទៀត សង្គ្រាមក៏មានគោលដៅ ដោះស្រាយបញ្ហាកំណើនប្រជាជន ការជំពាក់បំណុលប្រទេសក្រៅធូន់ធ្ងរ ការបំបាត់ពូជសាសន៍ ការយកប្រទេសផ្សេងជាចំណុះ បំបាត់វប្បធម៌ ការយកឧត្តមភាពខាងភាសា ក៏ដូចជាការប្រមូលធនធានលើដីក្រោមដីរហូតដល់ធនធានមនុស្សថែមទៀតៗ តទៅនេះ ជាគំរូសកលទាំង៨នៃវប្បធម៌នោះរួមមាន៖

-សម្ភារ:វប្បធម៌ : បានដល់ម្ហូបអាហារ ការស្លៀកពាក់ ការសង់លំនៅដ្ឋាន...

-ស្ថាប័នសេដ្ឋកិច្ច : ផលិតកម្មការដោះដូរ ទស្សនាទានកម្មសិទ្ធិ

[៥] Michael Alan Park, Anthropology An Introduction, Printed in the United States of America 1986, p.135

-ស្ថាប័នសង្គម : វ័យ ភេទ អាពាហ៍ពិពាហ៍ និងគ្រួសារ

-ត្រួតពិនិត្យសង្គម : ច្បាប់ ធម្មចរិយា សីលធម៌

-លោកទស្សនៈ : ចំណេះដឹង ទស្សនវិជ្ជា សាសនា និងមន្តអាគម

-សិល្បៈនិងល្បែងកំសាន្ត

-ភាសា

-ការអប់រំ ឬការបញ្ជូនវប្បធម៌ : អាចធ្វើដាច់ដោយឡែកជាមួយវ័យឬជាមួយគ្រួសារ។

## ៦. លក្ខណៈវិទ្យាសាស្ត្ររបស់នរវិទ្យា

មុខវិជ្ជានីមួយៗតែងមានលក្ខណៈវិទ្យាសាស្ត្ររបស់ខ្លួន។ មុននឹងស្វែងយល់ពីលក្ខណៈវិទ្យាសាស្ត្ររបស់នរវិទ្យា គេគប្បីស្វែងយល់ពីលក្ខណៈទូទៅរបស់វិទ្យាសាស្ត្រជាមុនសិន។

### ៦.១.លក្ខណៈទូទៅរបស់វិទ្យាសាស្ត្រ

លក្ខណៈនេះ បានប្រមូលផ្តុំទៅលើ៖

- ការពិនិត្យសង្កេត (Observation)

- ការពន្យល់ហេតុការណ៍ ដោយប្រើសំណួរជំនួយទាំង៦៖ ជាអ្វី?(What) ជានរណា?(Who) ពេលណា? (When) ទីណា(Where)? យ៉ាងដូចម្តេច(How)? ពីព្រោះអ្វី? (Why)។

-ការធ្វើចំណាត់ថ្នាក់នៃហេតុការណ៍: ហេតុការណ៍ទាំងនោះ អាចជាហេតុការណ៍នយោបាយ? សេដ្ឋកិច្ច?សង្គម? ឬ ហេតុការណ៍អ្វីផ្សេង?

-កសាងគោលការណ៍ច្បាប់សម្រាប់អនុវត្ត។ នេះជាដំណោះស្រាយបន្ទាប់ពីធ្វើចំណាត់ថ្នាក់នៃហេតុការណ៍

### ៦.២. លក្ខណៈវិទ្យាសាស្ត្ររបស់នរវិទ្យា

លក្ខណៈវិទ្យាសាស្ត្ររបស់នរវិទ្យាផ្អែកជាសំខាន់ទៅលើវិធីជាមូលដ្ឋានដែលគេយកមកប្រើប្រាស់ គឺវិធីពិនិត្យសង្កេត ដោយចូលរួមផ្ទាល់ (Participant observati-on) ទៅលើទីលានប្រតិបត្តិ(អនុវត្ត)។ វិធីនេះមានជំហានអនុវត្តបីដំណាក់ :

-បង្កើតឡើងជាសម្មតិកម្មឱ្យស្របទៅនឹងប្រធានបទស្រាវជ្រាវ (Establishing a hyp-othesis)។ សម្មតិកម្មអាចមានច្រើនមូលហេតុ។

-កំណត់មធ្យោបាយដើម្បីសាកល្បងសម្មតិកម្ម (Determining Ways to test hyp-othesis) មធ្យោបាយនេះភាគច្រើនគឺចុះទៅសម្ភាសផ្ទាល់ទៅលើទីលានតាមរយៈកម្រងសំណួរដែលបានរៀបចំ។

-សាកល្បងសម្មតិកម្មតាមរយៈការស្រាវជ្រាវនិងពិនិត្យសង្កេតសាចុះសាឡើងច្រើនដង (Testing the hypothesis through research and further observations) ដើម្បីស្វែងរកចម្លើយពិតនៃបញ្ហាស្របទៅ នឹងប្រធាន

*បទ។ ជាចុងក្រោយ ធ្វើការសន្និដ្ឋាន និង ដាក់ចេញជាគោលការណ៍ឬវិធានការអនុវត្ត។*

## ៧. ទ្រឹស្តីគោលប្រើប្រាស់ក្នុងនរវិទ្យា

*មានទ្រឹស្តីគោលប្រាំយ៉ាង ដែលគេយកមកប្រើប្រាស់ក្នុងនរវិទ្យា នោះគឺ:*

**៧.១.សកលនិយម** (Universalism)

*ភាពជាមនុស្សដោយស្មើភាពគឺជាលក្ខណៈសកលរបស់មនុស្ស។ ក្នុងឋានៈជាមនុស្ស មនុស្សម្នាក់ៗមានសិទ្ធិបីយ៉ាងប្រចាំកាយ គឺសិទ្ធិមានជីវិត សិទ្ធិទទួលផលកម្រៃ សិទ្ធិទទួលការអប់រំ ពោល គឺមនុស្សម្នាក់ៗសុទ្ធតែចង់រស់រានមានជីវិត ហើយជីវិតរបស់ខ្លួនមិនអាចត្រូវរំលោភបំពានបានឡើយ។ ក្រៅពីនោះ មនុស្សម្នាក់ៗមានសិទ្ធិទទួលផលកម្រៃ និងទទួលបាននូវការអប់រំរៀនសូត្រពេញមួយជីវិត។ ចំពោះស្មើភាពវិញ គឺស្មើភាពខាងនយោបាយ និងស្មើភាពខាងវប្បធម៌ ដោយមិនអាចចាត់ទុកជាក្រុមមនុស្សមួយ ជាក្រុមមនុស្សអារ្យជនប្រកបដោយវប្បធម៌ខ្ពង់ខ្ពស់ ហើយក្រុមមួយទៀតជាក្រុមអនារ្យជនជាមនុស្សព្រៃ គ្មានវប្បធម៌របស់ខ្លួននោះឡើយ។*

**៧.២. សន្តនិយម** (Hlism or Holism)

*ត្រូវយល់ដឹងពីមនុស្សក្នុងទិដ្ឋភាពពីរយ៉ាងគឺទិដ្ឋភាពវប្បធម៌ និងទិដ្ឋភាព សង្គម។*

**៧.៣. សមាហរណកម្ម** (Integration)

*គ្រប់ទិដ្ឋភាពវប្បធម៌ តែងតែផ្សារភ្ជាប់គ្នា និងទាក់ទងគ្នាទៅវិញទៅមក*(Interrelated)។

**៧.៤. ការតម្រូវតាម**(Adaptation)

*មនុស្សទទួលរងឥទ្ធិពលពីបរិស្ថាន។ ដើម្បីរក្សាខ្លួន និងរស់បានតទៅទៀត មនុស្សត្រូវមានមធ្យោបាយតម្រូវឬសម្របតាមបរិស្ថាននោះ វិស័យដូចជាស្វាមនុស្ស(ស្វាឪ) ពេលដែលធម្មជាតិប្រែប្រួលទៅដោយគ្រោះរាំងស្ងួត ពពួកស្វាមនុស្សទាំងនោះ ក៏បង្ខំចិត្តចុះពីលើដើមឈើមកនៅលើដីរករបស់របរចិញ្ចឹមជីវិត រហូតដល់ចេះដើរជើងពីរ* (Homo-habilis) *និងដើរត្រង់ខ្លួន* (Homorectism) *ហើយបានក្លាយទៅជាមនុស្សចាប់ពីចន្លោះ២លាន៥សែនឆ្នាំមកដល់ ១,៥លាន៥សែនឆ្នាំមុន។*

**៧.៥.វប្បធម៌មិនដាច់ខាត**(Culture relativism): *ទ្រឹស្តីនេះផ្អែកទៅលើការវិនិច្ឆ័យ ឬបកស្រាយនូវអាកប្បកិរិយា និងជំនឿរបស់អ្នកផ្សេងដោយប្រៀបធៀបទៅនឹងលក្ខណៈជាទំនៀមទម្លាប់ ក៏ដូចជាបទពិសោធន៍របស់ខ្លួន(មិនមានជំហឬអាកប្បកិរិយាដាច់ណាត់ថាខ្លួនឯងខ្ពស់ឆ្ងាយពីគេឯង។ អាកប្បកិរិយាបែបនេះ អាចលុបបំបាត់នូវជាតិពន្ធនិយម* (Ethnocentrism) និង*ជាតិនិយមជ្រុល*(Chauvinism)។

## ៨. ទំនាក់ទំនងរវាងនរវិទ្យា និងមុខវិជ្ជាដទៃទៀត

គេមិនអាចនឹងបញ្ជាក់នូវទង្វើអ្វីមួយឱ្យជាក់ច្បាស់បានទេ បើសិនជាគេប្រើប្រាស់នៅលើទីលានស្រាវជ្រាវតែជំនាញខាងនរវិទ្យា។ នៅលើទីលានស្រាវជ្រាវគេគប្បីសហការណ៍ប្រើប្រាស់នូវជំនាញនៃមុខវិជ្ជាដទៃទៀត។ ជាក់ស្តែង នរវិទ្យាមានទំនាក់ទំនងជាមួយមុខវិជ្ជាដទៃចំនួន១៣ទៀតទើបគ្រប់គ្រាន់។




រូបភាពទី៤: ទំនាក់ទំនងនៃនរវិទ្យា និង មុខវិជ្ជាដទៃ

## ៩. សារប្រយោជន៍របស់នរវិទ្យា

**(Utility of anthropology)**

រៀននរវិទ្យាអាចជួយដោះស្រាយបញ្ហាមួយចំនួនក្នុងសង្គមដែលយើងកំពុងរស់នៅ ដូចជា៖

### ៩.១. បញ្ហាជាតិសាសន៍ (Racial Issue)

#### ៩.១.១. ដើមកំណើតជាតិសាសន៍

ដូនតារួមរបស់មនុស្ស គឺពពួកស្វាមនុស្ស ប៉ុន្តែមកដល់មនុស្សទំនើប( Homosapien ) មនុស្សបានបង្កើតជាអំបូរ ពូជសាសន៍ជាច្រើនទៀត។ ឧទាហរណ៍ ជនជាតិខ្មែរ ឋិតក្នុងអំបូរមន-ខ្មែរដែលបានមកពីការផ្សំកាត់រវាងពួកឥណ្ឌូនេស៊ីយាង ជាមួយពួកម៉េឡានេស៊ីយាង មានអរិយធម៌ វប្បធម៌ដោយខ្លែករបស់ខ្លួនមុនពួកឥណ្ឌានាំវប្បធម៌របស់គេមកដល់។ ខ្មែរមានក្បាលរាងមូល(Brachycephalic) មិនដូចពួកអឺរ៉ុបដែលមានក្បាលពយ (Dolichocephalic)នោះទេ។ មានកម្ពស់ចន្លោះ ១៥០ស.មទៅ១៦១ស.ម, សម្បុរសណ្តែកបាយប្រស្រី-ក្អែកខ្មៅ សក់ខ្មៅរួញអង្គារដីបបូរមាត់មិនក្រាស់ពេកមិនស្តើងពេក ច្រមុះឡើងត្រង់និងទូលាយ (droit et large)សន្ទស្សន៍លលាដ៍ក្បាល៨៤,៥។ មានក្រុមឈាម A-B-Oនិងមានអេម៉ូគ្លោប៊ីន E។ ជាជាតិសាសន៍មានសន្តានចិត្តទូលាយ ស្មោះត្រង់ ឧស្សាហ៍ព្យាយាមមានគំនិតច្នៃប្រឌិតខ្ពស់។ ពួកគេជឿលើព្រលឹង គោរពបូជាព្រះអាទិត្យ ព្រះចន្ទ ព្រះគង្គា ព្រះធរណី មានមុខរបរភាគច្រើនជាកសិករ។ ជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយច្រើនប្រកាន់យកខ្សែស្រឡាយខាងម្តាយ និងគោរពស្ត្រីជាធំ។

### ៩.១.២. ដោះស្រាយបញ្ហាប្រកាន់ពូជសាសន៍ (Racism)

-ជាតិពន្ធុនិយម ឬការប្រកាន់យកទស្សនៈថា វប្បធម៌ជាតិសាសន៍មួយខ្ពង់ខ្ពស់ដាច់ស្រឡះពីជាតិសាសន៍ដទៃនាំទៅដល់ការប្រកាន់ពូជសាសន៍។

-ការប្រកាន់ពូជសាសន៍នាំដល់ការស្អប់ជាតិសាសន៍ដទៃ ដូច ហ៊ីត្លែរ ស្អប់ជាតិសាសន៍ជីហ្វនិងស្លាវ ហើយលើកតម្កើងជាតិសាសន៍ អាល្លឺម៉ង់រហូតដាក់ពាក្យស្លោកមួយថា "ចូរលើកតម្កើងជាតិសាសន៍អាល្លឺម៉ង់" (Dominez la race allemande!)។

-ការប្រកាន់ពូជសាសន៍នាំទៅដល់ការស្អប់ជាតិសាសន៍ដទៃ។

-ការស្អប់ជាតិសាសន៍ដទៃនាំទៅដល់អំពើប្រល័យពូជសាសន៍។

ជាតិពន្ធុនិយម (Ethnocentrism) ⟶ ប្រកាន់ពូជសាសន៍និយម(Genocide) ⟶ ប្រល័យពូជសាសន៍ (Racism)។

-ជាតិនិយមជ្រុល(Chauvinism) ក៏អាចធ្លាក់ទៅក្នុងអំពើប្រកាន់ពូជសាសន៍ដែរ ហើយអាចធ្លាក់ទៅដល់អំពើប្រល័យពូជសាសន៍ដូចគ្នា។

### ៩.២.ទប់ស្កាត់នូវទំនាក់ទំនងមិនល្អរវាងវប្បធម៌ និងវប្បធម៌

-នរវិទ្យាវប្បធម៌ ជួយយើងឲ្យមានការគោរពគ្នា ដោយស្មើភាពក្នុងនាមជាមនុស្ស

-នរវិទ្យាវប្បធម៌ ជួយយើងឲ្យយល់ដឹងពីវប្បធម៌ដោយឡែកៗរបស់ក្រុមមនុស្សនីមួយៗ

-នរវិទ្យាវប្បធម៌ ជួយយើងឲ្យស្វែងយល់ពីគ្នាឱ្យបានកាន់តែច្រើនឡើងហើយនាំមកនូវការយល់ដឹងពីគ្នាចង់មិត្តភាពជាមួយគ្នា និងបង្កើតនូវកិច្ចសហប្រតិបត្តិការរវាងគ្នានិងគ្នា ក្នុងនាមជាមនុស្សដែលមានភពផែនដី ជាផ្ទះរួម (Commune habitat)។

សាកលនិយម (Universalism) ⟶ សន្តនិយម (Holism) ⟶ សមាហរណកម្ម(Integration) ⟶ ការយោគយល់គ្នា( Comprehension) ⟶ មិត្តភាព( Friendship) ⟶ សហប្រតិបត្តិការ (Cooperation)។

### ៩.៣. ការអភិវឌ្ឍបច្ចេកវិទ្យា

(Technological development)

-សតវត្សរ៍ទី២១ ជាសតវត្សរ៍នៃបច្ចេកវិទ្យាទំនើប។ ប្រទេសនីមួយៗត្រូវយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍមនុស្សឱ្យទៅជាមូលធនមនុស្ស(Human Capital)។

-ប្រទេសកំពុងអភិវឌ្ឍត្រូវប្រកាន់យកគោលការណ៍ស្ទឹម (S.T.E.M) ដែលជាគោលការណ៍ផ្អែកទៅលើវិទ្យាសាស្ត្រ (Science) បច្ចេក

វិទ្យា (Technology) វិស្វកម្ម (Engineering) និង គណិតវិទ្យា (Mathematic) ដើម្បីអភិវឌ្ឍប្រទេស។

-ផ្សារភ្ជាប់ទៅនឹងបញ្ហានេះ ប្រទេសកម្ពុជាក៏កំពុងអភិវឌ្ឍឆ្ពោះទៅរកសហគ្រាសធុនតូច និងមធ្យម (S. M.E) នេះដែរដើម្បីបង្កើនផលិតផលនាំចេញនិងលើកកំពស់ចំណូលរបស់ប្រជាជនដោយសម្រេចឱ្យបាននូវចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

-ប៉ុន្តែនរវិទ្យា ហាមប្រាមមិនឲ្យលង់លក់ទៅលើកតម្កើងបច្ចេកវិជ្ជាជាធំ(Techno-cracy) និងជ្រុលហួសហេតុនោះដែរ។

-ត្រូវគ្រប់គ្រងបច្ចេកវិជ្ជាឲ្យបានម៉ឺងម៉ាត់ ដើម្បីជានាបាននូវការអភិវឌ្ឍន៍សង្គមមួយប្រកបដោយសីលធម៌។

-ត្រូវចេះគួបផ្សំឲ្យបានល្អ រវាងវប្បធម៌បុរាណ និងវប្បធម៌ទំនើប ដើម្បីរក្សាវប្បធម៌និងប្រពៃណីជាតិឲ្យបានគង់វង្សនោះទើបហៅថា អូម៉ូសាព្យាំងទំនើបដ៏ឈ្លាសវៃ (Smart Modern Homosapien) ទៅបាន។

### ៩.៤- នគរូបនីយកម្ម (Urbanization)

បញ្ហានគរូបនីយកម្ម ជាបញ្ហាសំខាន់សម្រាប់មនុស្សអូម៉ូសាព្យាំងទំនើប។ ដូច្នេះវិធានការល្អបំផុតនោះគឺ៖

-ត្រូវអភិវឌ្ឍទីក្រុងនិងជនបទឲ្យទៅតាមប្លង់គោលមួយដែលបានកំណត់ត្រឹមត្រូវធានាបាននូវសុវត្ថិភាពសង្គម និងបរិស្ថានប្រកបដោយនិរន្តរភាព។

-ដោយឡែក ចំពោះរចនាបទសំណង់ត្រូវតែធានាឱ្យបានច្រើនបំផុតនូវចរិតវប្បធម៌របស់ជាតិ។ បើពុំនោះសោតទេ គេនឹងបាត់បង់ដោយឥតដឹងខ្លួននូវអត្តសញ្ញាណជាតិ គួរឲ្យសោកស្តាយបំផុត។

### ៩.៥. បញ្ហាសន្តិភាព (Peace)

-សន្តិភាព ជាបញ្ហាស្នូលនៃការរស់នៅរបស់មនុស្សតទៅអនាគត

-ស្ថិរភាព សន្តិភាព និងការអភិវឌ្ឍជាអង្គបីដែលជាប់ពាក់ព័ន្ធគ្នាជាវិចារវិទ្យា (Dialectic)

-ត្រូវធ្វើឲ្យសន្តិភាពក្លាយទៅជាវប្បធម៌សកលសម្រាប់មនុស្សជាតិ ដោយយកចិត្តទុកដាក់អប់រំជាប់ជាប្រចាំអំពីសិទ្ធិមនុស្ស (សិទ្ធិមានជីវិត សិទ្ធិទទួលផល និងសិទ្ធិទទួលការអប់រំអស់មួយជីវិត)។ អប់រំអំពីទស្សនាទានពិតប្រាកដរបស់ប្រជាធិបតេយ្យការយោគយល់គ្នាជាអន្តរជាតិ ការអត់ឱនអធ្យាស្រ័យគ្នា និងទំនាក់ទំនងគ្នាក្នុងលក្ខណៈអន្តរវប្បធម៌។

### ៩.៦. ការប្រែប្រួលអាកាសធាតុ

(Climate Change)

នៅដើមសតវត្សរ៍ទី២១ យើងនេះមនុស្សបានចាប់ផ្តើមទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរអំពីការប្រែ- ប្រួលអាកាសធាតុដែលបណ្តាលមកពីការបាត់បង់លំនឹងរវាង

*ជាតុទឹក ជាតុដី ជាតុភ្លើង ជាតុខ្យល់ដែលទ្រទ្រង់ផែនដី។ ការបាត់បង់លំនឹងទាំងនេះអាចបណ្ដាលមកពីភាពអវិជ្ជារបស់មនុស្សក៏ដូចជាការរំលោភបំពានរបស់មនុស្សទៅលើក្រឹត្យក្រមធម្មជាតិ ដោយសារចង់មានចង់បានហួសហេតុ ហើយនាំគ្នាទៅបំផ្លិចបំផ្លាញធម្មជាតិ។*

*-ការប្រែលប្រួលអាកាសធាតុនាំឱ្យកើតមានកង្វះទឹក (គ្រោះរាំងស្ងួត) ដែលបណ្ដាលមកពីការបាត់បង់ប្រព័ន្ធអេកូឡូស៊ីទាក់ទងនឹងទឹកដូចជា ភ្នំព្រៃឈើ ដីសើមស្ទឹង ស្រទាប់ថ្មមានទឹកនិងបឹងបួរ កង្វះខាតស្បៀងនិងកង្វះខាតអគ្គិសនីប្រើប្រាស់។*

*ដូច្នេះ មនុស្សត្រូវរិះរកមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីរស់បានក្នុងកង្វះខាតបែបនេះ។ ឧទាហរណ៍: បើខ្វះខាតទឹក មនុស្សត្រូវជ្រើសរើសពូជស្រូវ ឬពូជដំណាំដែលធន់នឹងកង្វះទឹក ទើបដោះស្រាយបញ្ហាកង្វះខាតស្បៀងបាន។ បើខ្វះខាតអគ្គិសនី មនុស្សត្រូវចេះទាញអគ្គិសនីចេញពីពន្លឺព្រះអាទិត្យ ឧស្ម័នធម្មជាតិ រ៉ែ(អ៊ុយរ៉ានីញ៉ូម) និងខ្យល់បក់។ ប៉ុន្តែត្រូវកាត់បន្ថយឲ្យនៅតិចបំផុត ការប្រើប្រាស់រ៉ែធ្យូងថ្ម ដើម្បីផលិតអគ្គិសនី ព្រោះនាំឲ្យពុលបរិស្ថាន។*

### ៩.៧. ទេសចរណ៍ (Tourism)

*ទេសចរណ៍ ជាវិស័យឧស្សាហកម្មគ្មានផ្សែង ហើយទទួលបាននូវផលកម្រៃច្រើនសម្រាប់ប្រទេសនីមួយៗ។ នៅពេលចំណូលរបស់ប្រជាជនចាប់ផ្ដើមកើនឡើង មនុស្សចង់ធ្វើទេសចរណ៍ដើរកំសាន្តទៅគ្រប់ទីកន្លែងផ្សេងៗរបស់ពិភពលោក ហើយបរិមាណទេសចរតាមប្រទេសនីមួយៗអាចមានការកើនឡើង។ ដូច្នេះ ដើម្បីបង្កើនចំណូលដល់ប្រទេសជាតិ មនុស្សត្រូវចេះរិះរកប្រភពចំណូលពីធម្មជាតិ ពីវប្បធម៌រូបិយ និងពីវប្បធម៌ សម្ភារៈផ្សេងៗទៀតរបស់ប្រទេសដើម្បីបម្រើឱ្យវិស័យទេសចរណ៍។*

### ៩.៩. បញ្ហាជំងឺរាតត្បាត

*តាំងពីឆ្នាំ២០១៩មក ពិភពលោកបានជួបប្រទះនឹងជម្ងឺដ៏កាចសាហាវថ្មីមួយមានឈ្មោះថា "កូវីដ១៩"* **(Covid 19)** *ធ្វើឱ្យបាត់បង់អាយុជីវិតមនុស្សអស់ជាងប្រាំលាននាក់រួចមកហើយ។ ដូច្នេះ ដើម្បីទប់ទល់នឹងជម្ងឺ ដ៏កាចសាហាវទាន់ហន់មួយនេះ មនុស្សទំនើបត្រូវចេះរកវិធីទប់ទល់នឹងជម្ងឺនេះ ដោយប្រើប្រាស់បច្ចេកវិជ្ជា និង ការគិតពិចារណាជាលក្ខណៈវិទ្យាសាស្ត្ររបស់ខ្លួនដើម្បីផលិតនូវវ៉ាក់សាំងសម្រាប់ព្យាបាលមនុស្សដូចគ្នាឱ្យ ឆាប់ជាសះស្បើយនិងមានភាពស៊ាំអាចទប់ទល់នឹងជំងឺដ៏កាចសាហាវប្រភេទ*

*នេះ ព្រមទាំងអប់រំគ្នា ឱ្យចេះរស់នៅតាមគន្លងបែបបទថ្មី ដោយគោរពតាមវិន័យម៉ឺងម៉ាត់ព្រមទាំងរក្សាអនាម័យផ្ទាល់ខ្លួនតាមវិធីសុខាភិបាល"បីការពារ"និង"បីកុំ"ឱ្យបានខ្ជាប់ខ្ជួនបំផុត។ បើពុំនោះសោតទេ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសនិងគ្រួសារ អាចធ្លាក់ចុះដុនដាប ជីវិតមនុស្សក៏អន្តរាយ ភាពក្រីក្រក៏កើតមាន ហើយបញ្ហាសង្គមគ្រប់បែបយ៉ាងក៏អាចនឹងកើតមានទៅតាមនោះ ជាក់ជាមិនខាន។*

## សេចក្តីសន្និដ្ឋាន

*សរុបមក នរវិទ្យា គឺជាមុខវិជ្ជាវិទ្យាសាស្រ្តមួយដែលទាមទារចាំបាច់ឱ្យមានការយល់ដឹងក្នុងកាលៈទេសៈ ដែលពិភពលោកកំពុងប្រែប្រួលឆ្ពោះទៅរកផលអវិជ្ជមាន។ ចេះនរវិទ្យា និងប្រើប្រាស់នរវិទ្យាបានត្រឹមត្រូវ នាំឱ្យមនុស្សមានការយល់ដឹងកាន់តែច្បាស់ពីប្រភពនៃជាតិកំណើត វប្បធម៌ ប្រពៃណីទំនៀមទម្លាប់របស់ខ្លួន និងជាតិសាសន៍ដទៃដោយមិនរើសអើង បង្កើតបានជាបរិយាកាសសុខដុមរមនា ចេះយោគយល់គ្នា ចងមិត្តភាពជាមួយគ្នា ធ្វើសហប្រតិបត្តិការរវាងគ្នានិងគ្នាប្រកបដោយផលប្រយោជន៍ក្នុងនាមជាមនុស្សដូចគ្នា សហការគ្នាការពារផែនដី ដែលជាផ្ទះរួមរបស់ខ្លួនឱ្យស្ថិតក្នុងស្ថានភាពមានលំនឹង និងរក្សាបាននូវស្ថិរភាព សន្តិភាព និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ចៀសផុតពីមហន្តរាយផ្សេងៗ។*

## គន្ថនិទ្ទេស


១-*វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួនណាត ភាគទី១-២ បោះពុម្ពគ្រាទី៥ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៦៧*

២-*អ្នកស្រី ត្រឹង ង៉ា អរិយធម៌ខ្មែរ, ការផ្សាយរបស់អ្នកនិពន្ធ បោះពុម្ពលើកទី៣ ឆ្នាំ ១៩៧៤*

៣- **A. Haviland William,** *Anthropology,* Printed in the United States of America, Seventh Edition, 1994

៤- **C. Howard Michael,** *Contemporary Cultural Anthropology,* Printed in the United States of America, Fifth Edition, 1996

៥- **M. Keesing Felix,** *Cultural Anthropology,* the Science of Custom, Printed in the United States of America, 1962.

# ប្រវត្តិ និង សារៈសំខាន់នៃពុទ្ធិកសិក្សានៅកម្ពុជា

*ដោយ៖ លោកស្រីបណ្ឌិត* **ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និង យេនឌ័រ,វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា*

*វិស័យអប់រំផ្នែកពុទ្ធិកសិក្សាជាវិស័យមួយដែលបានចូលរួមចំណែកបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា។ វិស័យនេះបានចាប់បដិសន្ធិជាច្រើនសតវត្សរ៍មកហើយ គឺនៅមុនរជ្ជកាលនៃការគ្រប់គ្រងរបស់អតីតព្រះមហាវីរក្សត្រ និងមានការរីកចម្រើនខ្លាំងនៅសម័យសង្គមរាស្ត្រនិយម ក្រោមការដឹកនាំប្រទេសរបស់ព្រះករុណាព្រះមហាវីរក្សត្រ នរោត្តម* ***សីហនុ*** *ដែលនៅសម័យនោះ វិស័យអប់រំផ្នែកពុទ្ធិកសិក្សានេះ ត្រូវបានប្រទេសកាន់ព្រះពុទ្ធសាសនាលើពិភពលោកទទួលស្គាល់ផងដែរ។*

*តាមការសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជាមួយចំនួនបានលើកឡើងថា* ***វិស័យអប់រំផ្នែកពុទ្ធិកសិក្សាបានកកើតដំបូងនៅឆ្នាំ១៩០៩ ក្នុងរជ្ជកាលនៃព្រះបាទស៊ីសុវត្ថិ*** *និងបើផ្អែកតាមឯកសារប្រវត្តិពុទ្ធិកសិក្សាដែលចងក្រងដោយគណៈកម្មការស្រាវជ្រាវនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយនៅឆ្នាំ២០០៦ បានសរសេរថា* ***សាលាពុទ្ធិកសិក្សាដែលចាប់បដិសន្ធិដំបូងមានឈ្មោះថា "បរមពុទ្ធវចនបរិយត្តិបសាទ" ដែលមានទីតាំងស្ថិតនៅខេត្តសៀមរាប ហើយជាបន្តបន្ទាប់ វិស័យនេះបានរីកចម្រើនបន្តិចម្តងៗ។*** *តែទោះជាយ៉ាងណា អ្នកសិក្សាផ្នែកព្រះពុទ្ធសាសនាសង្កេតឃើញថា វិស័យអប់រំផ្នែកពុទ្ធិកសិក្សាដែលរីកចម្រើនបំផុតនោះ គឺនៅអំឡុងទសវត្សរ៍ទី៥០និង៦០ ក្រោមការគ្រប់គ្រងប្រទេសនៃអតីតព្រះមហាវីរក្សត្រ គឺព្រះបាទ* ***នរោត្តមសីហនុ។***

*បើតាមសង្ឃដីកាអគ្គាធិការរងពុទ្ធិកសិក្សាជាតិ ដែលជាសមាជិកថេរសភា និងជាព្រះចៅអធិការវត្តវិមានតេជះ (ហៅស្រះចក) សម្តេចធម្មចរិយា* ***ឈឹង ប៊ុនឈា*** *ព្រះតេជគុណមានថេរដីកាថា ដំបូងឡើយក្នុងការអប់រំផ្នែកពុទ្ធិកសិក្សា គេសិក្សាផ្តោតសំខាន់តែទៅលើភាសាបាលីនិងធម៌អាថ៌ទេ។ តែក្រោយមកសម័យសង្គមរាស្ត្រនិយម ទើបគេឃើញមានបញ្ចូលវិជ្ជាផ្នែកខាងអាណាចក្រ*

ដើម្បីឱ្យអ្នកសិក្សា បានយល់ដឹងទាំងពីរផ្នែក គឺផ្លូវលោក និងផ្លូវធម៌ «ពេលមកជំនាន់សង្គមរាស្ត្រនិយមហ្នឹង គឺមានការឱ្យរៀនសូត្រហ្នឹងទាំងគេហៅថា ធម្មវិជ្ជា លោកវិជ្ជា។ មានន័យថា ផ្នែកខាងវិជ្ជាផ្លូវលោកក៏មាន វិជ្ជាផ្លូវធម៌ក៏មាន ភាសាបាលីសំស្ក្រឹតក៏មាន ខាងផ្នែកមុខវិជ្ជាដែលជាចំណេះដឹងទូទៅទាំងប៉ុន្មានយើងយកមករៀនទាំងអស់។ ហេតុដូចម្ដេចបានជាក្នុងសម័យនោះ បានតម្រូវឱ្យរៀនបែបហ្នឹង? ជាទី១ ចង់ឱ្យព្រះសង្ឃហ្នឹងបានចេះវិជ្ជាទាំងផ្លូវលោក ទាំងផ្លូវធម៌ ភាសាផ្នែកបាលីសំស្ក្រឹតផង ផ្នែកវិន័យព្រះពុទ្ធសាសនាផង ហើយនិងឱ្យចេះវិជ្ជាផ្លូវលោកផង ប្រៀបបីដូចជាភ្នែកមានពីរអីចឹង ត្រូវឱ្យភ្លឺទាំងពីរ។ មិនត្រូវឱ្យភ្លឺតែមួយទេ»។ បន្ថែមលើនេះ ព្រះតេជគុណក៏មានថេរដីកាបញ្ជាក់ថា នៅមុនទសវត្សទី៥០ គេសម្គាល់ឃើញថា សាលាបាលីមានតែពីរកម្រិតទេ គឺថ្នាក់ពុទ្ធិកបឋមសិក្សា និងពុទ្ធិកមធ្យមសិក្សាបឋមភូមិ ឬហៅថា ឱបូមសាលាបាលី ឬហៅម្យ៉ាងទៀតថា សាលាបាលីជាន់ខ្ពស់។ តែក្រោយមកចាប់ពីឆ្នាំ១៩៥៤ ពុទ្ធិកសិក្សាបានបង្កើនថែមពីរកម្រិតទៀត គឺពុទ្ធិកមធ្យមសិក្សាទុតិយភូមិ និងពុទ្ធិកមហាវិទ្យាល័យ។

ក្រោមការឧបត្ថម្ភរបស់ព្រះបាទនរោត្តមសីហនុ ក្រៅពីការបង្កើតពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដែលមានទីតាំងស្ថិតនៅក្បែរសាលចតុមុខ រាជធានីភ្នំពេញនោះ ពុទ្ធិកអនុវិទ្យាល័យចំនួនពីរត្រូវបានសាងសង់ គឺពុទ្ធិកអនុវិទ្យាល័យព្រះសុរាម្រឹត បង្កើតឡើងនៅឆ្នាំ១៩៥៥ និងពុទ្ធិកអនុវិទ្យាល័យ អ៊ឹង ធួង ដែលមានទីតាំងស្ថិតនៅខេត្ត ក៏ត្រូវបង្កើតឡើងដែរ។ ចំណែកក្រសួងធម្មការនិងសាសនានាសម័យនោះ ក៏បានរៀបចំប្រព័ន្ធគ្រប់គ្រងលើវិស័យអប់រំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់បន្ថែមទៀត ដែលនាំឱ្យប្រទេសកាន់ពុទ្ធសាសនាលើពិភពលោក ទទួលស្គាល់គុណភាពនៃការអប់រំនេះផងដែរ។ បើតាមការលើកឡើងរបស់ព្រះតេជគុណ ឈឹង ប៊ុនឈា «វិស័យពុទ្ធិកសិក្សានៅជំនាន់ហ្នឹងមានការរីកចម្រើនណាស់ មែនទែនទៅរហូតដល់ថាល្បីល្បាញនៅក្នុងអាស៊ីអាគ្នេយ៍ ដែលតាមឯកសារអាត្មាបានស្រាវជ្រាវទៅឃើញថា មានការទទួលស្គាល់នៅអាស៊ីហ្នឹង គឺទទួលស្គាល់ប្រព័ន្ធពុទ្ធិកសិក្សាស្រុកខ្មែរយើងហ្នឹង រហូតដល់ប្រទេសសិរីលង្កា ក៏ទទួលស្គាល់ប្រព័ន្ធពុទ្ធិកសិក្សាយើងថា មានគុណភាពខ្ពស់ ហើយខាងថៃ ខាងភូមា និងប្រទេសឡាវ រហូតដល់យកប្រព័ន្ធសិក្សារបស់យើងទៅរៀបចំនៅស្រុកគេ»។

ទាក់ទងនឹងប្រវត្តិអប់រំផ្នែកពុទ្ធិសិក្សានេះដែរ អនុប្រធានផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយឧត្តមសិក្សា នៃអគ្គាធិការពុទ្ធិកសិក្សាជាតិ និងជាព្រះចៅអធិការវត្តនន្ទមុនី ព្រះតេជគុណ សុខ ប៊ុនធឿន ព្រះអង្គបានមាន

ថេរដីកា ហៅការរីកចម្រើននាសម័យសង្គមរាស្ត្រនិយមថាយុគមាស។ នេះមានន័យថា ជាសម័យដែលចក្រទាំងពីរ គឺពុទ្ធចក្រនិងអាណាចក្របានរីកចម្រើនទន្ទឹមគ្នា។ ព្រះតេជគុណបានលើកឡើងដូច្នេះថា«**ការរីកចម្រើនវិស័យពុទ្ធិកសិក្សានៅសម័យនោះ យើងថាឈានដល់កំពូលក៏ថា បានពីព្រោះនៅសម័យនោះ មានអ្នកប្រាជ្ញមួយចំនួន រហូតដល់អ្នកប្រាជ្ញបរទេស គេស្ញើចសរសើរនៅសម័យនោះថា ជាសម័យមាស ដោយសារការកើតឡើងរបស់អ្នកប្រាជ្ញព្រះពុទ្ធសាសនា អ្នកប្រាជ្ញខាងសង្គមក្តី គឺកើតឡើងព្រមគ្នា**»។

ដោយសារតែវិស័យអប់រំផ្នែកពុទ្ធិកសិក្សារីកចម្រើន និងលូតលាស់ខ្លាំងប្រកបដោយគុណភាពនេះហើយ បានធ្វើឱ្យប្រទេសកម្ពុជាសម្បូរទៅដោយធនធានមនុស្សប្រកបដោយសមត្ថភាព ហើយធនធានព្រះសង្ឃនិងគ្រហស្ថ ដែលសម័យសង្គមរាស្ត្រនិយមបានផលិតនោះ បានបន្សល់ទុកកេរមត៌កជាច្រើន ដែលមនុស្សជំនាន់ថ្មីពុំទាន់អាចធ្វើបាន។ ជាក់ស្តែង ការបកប្រែគម្ពីរព្រះត្រៃបិដក ការរៀបរៀង និងបង្កើតវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** និងក្បួនច្បាប់សម្រាប់សិក្សាជាច្រើនបន្ថែមទៀត។ សូមបញ្ជាក់ផងដែរថា ក្រៅពីការពង្រឹងវិន័យ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពហើយនោះ រាជរដ្ឋាភិបាលបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើជីវភាពគ្រូបង្រៀន គឺរដ្ឋាភិបាលបានផ្តល់ប្រាក់ខែយ៉ាងសមរម្យដល់សាស្ត្រាចារ្យ ដែលកាលពីសម័យនោះ គឺបាន៧.០០០រៀលក្នុង១ខែគឺជិតស្មើនឹងតំណាងរាស្ត្រដែលទទួលបាន១០.០០០រៀល។ ចំណែកគ្រូបង្រៀន ថ្នាក់ក្រោមៗបន្ទាប់នោះ គឺទទួលបាន៣.៥០០រៀល (បើគិតជាមាស១ខែស្មើរ១តម្លឹង) ហើយដែលចាយវាយគ្រប់គ្រាន់ក្នុង១គ្រួសារ។

នៅមុនសម័យសង្គមរាស្ត្រនិយម សាលាពុទ្ធិកសិក្សាមានចំនួនជិត២០០សាលា។ ក៏ប៉ុន្តែក្រោយសម័យនោះបន្តិច គឺ នៅសម័យសង្គមរាស្ត្រនិយម សាលាពុទ្ធិកសិក្សាបានកើនឡើងដល់ជិត៧០០ សាលាដែលមានសមណសិស្សសិក្សាជិត១១.០០០នាក់។ បន្ថែមលើនេះទៀត ស្ថាប័ន និងគណៈកម្មការមួយចំនួនត្រូវបានរដ្ឋាភិបាលបង្កើតឡើង ដើម្បីជាជំនួយវិស័យពុទ្ធិកសិក្សាផងដែរ តួយ៉ាងដូចជា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គិលានដ្ឋានសម្រាប់ព្យាបាលសមណនិស្សិត ដែលត្រូវរដ្ឋាភិបាលស្ថាបនាឡើងនៅបរិវេណ នៃពុទ្ធិកអនុវិទ្យាល័យព្រះសុរាម្រឹត មន្ទីរសង្គ្រោះ សមណនិស្សិត ដែលត្រូវរដ្ឋាភិបាលបង្កើតឡើងដើម្បីជំនួយទំនុកបម្រុងនិស្សិតចេញទៅរៀន និងស្វែងយល់ពីបទពិសោធន៍នៅបរទេស និងគណៈកម្មការមួយចំនួន ដូចជា ក្រុមជំនុំព្រះត្រៃបិដក គណៈកម្មការត្រួតពិនិត្យសៀវភៅគ្រប់ប្រភេទមុននឹងអនុញ្ញាតឱ្យបោះពុម្ពផ្សាយព្រមទាំង គណៈកម្មការទ្រទ្រង់អក្សរសាស្ត្រជាតិជាដើម។

បន្ទាប់ពីទទួលជ័យជំនះលើរបបកម្ពុជាប្រជាធិបតេយ្យនាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពោល គឺក្រោយពេលដែលពួកខ្មែរក្រហមត្រូវបានបណ្ដេញចេញពីអំណាចដោយកងទ័ពវៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា វិស័យព្រះពុទ្ធសាសនាត្រូវបានដំណើរការឡើងវិញ។ ឆ្នាំ១៩៨៩ លេខាមជ្ឈិមបក្សនៃរដ្ឋកម្ពុជា ប្រកាសលេខ២៩២ដ.ខមប ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៨៩ អនុញ្ញាតឱ្យបើកពុទ្ធិកបឋមសិក្សាឡើងវិញ។ ឆ្នាំ១៩៩២ រដ្ឋសភាបានអនុម័តច្បាប់បង្កើតក្រសួងធម្មការឡើងវិញដើម្បីគ្រប់គ្រងនិងដឹកនាំវិស័យសាសនា វិស័យពុទ្ធិកសិក្សា និងស្ដារឡើងវិញនូវពុទ្ធសាសនបណ្ឌិត្យ។

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩២ រដ្ឋាភិបាលបានប្រកាសឱ្យក្រសួងធម្មការបង្កើតឡើងវិញនូវពុទ្ធិកសិក្សា ហើយពុទ្ធិកមធ្យមសិក្សាដែលត្រូវបានបង្កើតឡើងវិញនេះដំបូងឡើយ ធ្វើនៅទីក្រុងភ្នំពេញ គឺពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត។ បន្ទាប់ពីនោះមកសាលាពុទ្ធិសិក្សា នានាត្រូវបានបើកជាបន្តបន្ទាប់ទូទាំងប្រទេសដូចជា នៅខេត្តបាត់ដំបង ព្រៃវែង និងកំពង់ចាម ជាដើម។

សំណើរលេខ ៧៤៣/៩៦ ក.ធ.ស ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៦ សុំបើកពុទ្ធិកមហាវិទ្យាល័យ**ព្រះសីហនុរាជ**ឡើងវិញ។ ថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៩៧ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ត្រូវបានអនុញ្ញាតឱ្យបើកឡើងវិញតាមសេចក្ដីសម្រេច ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧។

តាមអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០០៦ បានប្ដូរ **ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ** ទៅជា **ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ** ដែលក្នុងនោះមានដូចជា ពុទ្ធិកមហាវិទ្យាល័យទស្សនវិជ្ជានិងសាសនា ពុទ្ធិកមហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ និងព័ត៌មានវិទ្យា ពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹតនិងភាសាបរទេស ពុទ្ធិកមជ្ឈមណ្ឌលគរុកោសល្យ ជាពិសេសផ្នែកអក្សរសាស្ត្រ ដែលសាលាបាលី ឬសាលាពុទ្ធិកសិក្សាទាំងនេះ បានបំពេញតួនាទីយ៉ាងសំខាន់ក្រៃលែងសម្រាប់ព្រះពុទ្ធសាសនា ក៏ដូចជាសម្រាប់វប្បធម៌ និងអក្សរសាស្ត្រជាតិ ហើយបានបណ្ដុះឱ្យមានសមណៈនិស្សិតថ្នាក់បរិញ្ញាបត្រជាច្រើនអង្គជារៀងរាល់ឆ្នាំ។ ស្ថាប័នដែលជាដៃគូដ៏ប្រសើរបំផុតរបស់សាលាបាលី ឬសាលពុទ្ធិកសិក្សា គឺព្រះរាជបណ្ណាល័យ និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។ ស្ថាប័នទាំង៣នេះត្រូវបានគេមើលឃើញថា ជាត្រីមុំ (ជ្រុង៣) សម្រាប់វប្បធម៌និងអក្សរសាស្ត្រជាតិខ្មែរតាំង

ពីសម័យអាណានិគមបារាំងរៀងមក។ ព្រះរាជបណ្ណាល័យ ត្រូវបានបង្កើតឡើងតាមប្រកាសចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩២៥។ ប៉ុន្តែ ដើមឡើយ បណ្ណាល័យនេះមានឈ្មោះថា «**ខេមរបណ្ណាល័យ**» បង្កើតឡើងតាមព្រះរាជប្រកាសចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩២១ ហើយត្រូវបានប្រគល់ទៅឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរពុទ្ធសាសនបណ្ឌិត្យ និងបានប្រែឈ្មោះថា «**បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ**» តាមរាជប្រកាសចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៤៣។ ចំណែកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៣០[១]។

បច្ចុប្បន្ននេះវិស័យពុទ្ធិកសិក្សាចាប់ពីកម្រិតធម្មវិន័យបឋមមធ្យមឧត្តមនិងក្រោយឧត្តមគឺជាឆ្អឹងខ្នងដ៏រឹងមាំរបស់ព្រះពុទ្ធសាសនា។ ហេតុនេះវិស័យនេះត្រូវតែកែទម្រង់ឱ្យបានស៊ីជម្រៅក្នុងគ្រប់កម្រិតដើម្បីធានានូវគុណភាព សមណសិស្ស និស្សិតឱ្យក្លាយជាធនធានមនុស្សប្រកបដោយចំណេះ ជំនាញនិងមានគុណធម៌ពិតប្រាកដ នេះបើយោងតាមប្រកាសសង្ឃដែលបានផ្សព្វផ្សាយជាសាធារណៈនៅថ្ងៃទី៣១ខែមករាឆ្នាំ២០១៧។ ក្រៅពីកែទម្រង់លើវិស័យសិក្សាប្រកាសសង្ឃបានជំរុញឱ្យមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ និងព្រះសង្ឃគ្រប់អង្គត្រូវពង្រឹងសមត្ថភាព ផ្នែកវិជ្ជាពុទ្ធសាសនាដូចជា៖ ភាសាបាលីសំស្ក្រឹត ទ្រឹស្តីព្រះធម៌វិន័យជាពុទ្ធវចនៈ និងលោកវិជ្ជាដើម្បីពង្រឹងស្ថាប័នព្រះពុទ្ធសាសនាផ្សព្វផ្សាយព្រះធម៌ឱ្យបានទូលំទូលាយភាពក្រឹត្យក្រមនៃការគោរពធម៌វិន័យ និងពង្រីកធនធានព្រះសង្ឃក្នុងទិសដៅធានាភាពស្ថិតស្ថេរចីរភាពរបស់ព្រះពុទ្ធសាសនាខ្មែរ។ បន្ថែមពីលើនេះ សង្ឃប្រកាសបានណែនាំដល់មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ និងព្រះសង្ឃគ្រប់អង្គ ត្រូវបន្តយកចិត្តទុកដាក់លើការអប់រំសីលធម៌ដល់កុមារ និងយុវជនដែលជាទំពាំងស្នងឫស្សី ដោយបញ្ជ្រាបទស្សនវិជ្ជា ឬព្រះធម៌ដែលជាទ្រឹស្តីរបស់ ព្រះពុទ្ធដល់សាធារណជន ជាពិសេសនៅគ្រប់សាលារៀនសាធារណៈ ក៏ដូចជាជំរុញឱ្យចៅអធិការអាចារ្យ និងគណៈកម្មការវត្តទាំងអស់ត្រូវយកចិត្តទុករៀបចំវត្តអារ៉ាមឱ្យក្លាយជាទីកន្លែងសក្ការៈដ៏ជ្រះថ្លា ដោយមានដាំដើមឈើ រក្សាអនាម័យ និងសណ្តាប់ធ្នាប់សំណង់ក្នុងវត្តជាដើម។

សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ និងជាព្រះសកលវិទ្យាធិការនៃសាកលវិទ្យាល័យព្រះសីហមុនីរាជា **បួរ គ្រី** បានមានថេរដីកាថា ***ពុទ្ធិកសិក្សាមានសារ***

[១] (7) Wisemen – Posts | Facebook (ដកស្រង់ពីឯកសារស្រាវជ្រាវរបស់សាស្ត្រាចារ្យ ស៊ិន សុវណ្ណនិ ទំព័រ២៦)

**សំខាន់ណាស់នាពេលបច្ចុប្បន្ន ដើម្បីអភិវឌ្ឍធនធានមនុស្ស។** សម្តេចមានថេរដីកាបន្តថា **ប្រទេសនៅលើពិភពលោកគ្មានប្រទេសណាមួយ ដែលមិនបានអភិវឌ្ឍធនធានមនុស្ស ហើយរីកចម្រើននោះទេ។** ម្យ៉ាងទៀតសម្តេចមានថេរដីកាបញ្ជាក់ថា ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនវិទ្យាសាស្ត្រនាពេលបច្ចុប្បន្ននេះ មនុស្សចាំបាច់ត្រូវទទួលការអប់រំបានខ្ពស់ ទើបអាចរត់ទាន់តម្រូវការសង្គម។ មួយវិញទៀត សម្តេចមានថេរដីកាថា ពុទ្ធិកសិក្សាបានដើរតួនាទីយ៉ាងសំខាន់ដើម្បីផ្តល់ឱកាសដល់កូនអ្នកក្រីក្រមកពីខេត្តនានាទទួលបានឱកាសសិក្សាបន្តដើម្បីក្លាយជាធនធានមនុស្សដ៏ពិតប្រាកដជួយអភិវឌ្ឍប្រទេសជាតិ។

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាស្ថិតនៅវត្តស្វាយពពែ សង្កាត់ទន្លេ បាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញដែលមានបង្រៀនថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិត។ ពុទ្ធិកសាកលវិទ្យាល័យនេះត្រូវបង្កើតឡើងនាឆ្នាំ២០០៥ដោយសម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ **បួរ គ្រី**។ បច្ចុប្បន្ន ពុទ្ធិកសាកលវិទ្យាល័យនេះ មានប្រាំមហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ ទស្សនវិជ្ជា អក្សរសាស្ត្រអង់គ្លេស ព័ត៌មានវិទ្យា និងនីតិសាស្ត្រ។

ការរៀននៅពុទ្ធិកសិក្សាពីមុនៗមក គេធ្លាប់ឃើញមានតែព្រះសង្ឃរៀន គេមិនសូវឃើញឃរាវាស(អ្នកមិនបួស)រៀនឡើយ។ ប៉ុន្តែបច្ចុប្បន្ន កូនអ្នកស្រែ អ្នកចម្ការជាច្រើនបានរៀននៅពុទ្ធិកសិក្សាដូចព្រះសង្ឃដែរ។ ពុទ្ធិកសិក្សា ជាកន្លែងផ្តល់ការអប់រំដល់ព្រះសង្ឃដែលមានមុខវិជ្ជាសម្រាប់សិក្សាទាំងពុទ្ធចក្រ និងអាណាចក្រ។ ម្យ៉ាងទៀត ពុទ្ធិកសិក្សាមានគ្រប់កម្រិតគឺចាប់ពីថ្នាក់ពុទ្ធិកបឋមរហូតដល់ពុទ្ធិកសាកលវិទ្យាល័យ។

បច្ចុប្បន្នពុទ្ធិកសិក្សាគឺស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងធម្មការ និងសាសនា ដែលក្នុងនោះមានៈ[២]

-**ធម្មវិន័យ**ៈ មានចំនួន៥៣៦សាលា ៧៦៣ថ្នាក់ និងមានចំនួនសិស្ស១១.០១៧នាក់ ដែលក្នុងនោះថ្នាក់ត្រី (ទី១) មាន៤៦២ថ្នាក់ មានសិស្សចំនួន៧០៩៥នាក់ ថ្នាក់ទោ (ទី២) មាន១៨៩ថ្នាក់ មានសិស្សចំនួន២៤១៤នាក់ និងថ្នាក់ឯក(ទី៣)មាន១១៦ថ្នាក់ មានសិស្សចំនួន១៥០៨នាក់។

-**ពុទ្ធិកបឋមសិក្សា**ៈ មានចំនួន១០០៥សាលា ១៤៣៧ថ្នាក់ និងមានចំនួនសិស្ស ២៤.៩១៩នាក់ ដែលក្នុងនោះថ្នាក់ត្រី(ទី១) មាន៨៦២ថ្នាក់ មានសិស្សចំនួន១៥.៣៧៥នាក់ថ្នាក់ទោ(ទី២)មាន៣២៩ថ្នាក់មានសិស្សចំនួន៥.៤៨០នាក់ និងថ្នាក់ឯក(ទី៣) មាន២៤៦ថ្នាក់ មានសិស្សចំនួន៤០៨២នាក់។

---

[២] ក្រសួងធម្មការនិងសាសនា អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ **ស្ថិតិពុទ្ធិកសិក្សាទូទៅប្រទេសឆ្នាំ២០២០-២០២១** ឆ្នាំ២០២០។

***-ពុទ្ធិកអនុវិទ្យាល័យ៖*** មានចំនួន៣៨ សាលា១៤៩ថ្នាក់ និងមានចំនួនសិស្ស៥.៦៣៣នាក់ ដែលក្នុងនោះ ថ្នាក់ត្រី (ទី១) មាន ៥៣ថ្នាក់ មានសិស្សចំនួន២.៤២១នាក់ ថ្នាក់ទោ (ទី២) មាន៥២ថ្នាក់ មានសិស្ស ១.៧៨៥ នាក់ និងថ្នាក់ឯក(ទី៣) មាន៤៤ថ្នាក់ មានសិស្ស ១.៤២៧នាក់។

***.ពុទ្ធិកវិទ្យាល័យ៖*** មានចំនួន១៤ សាលា៥៨ថ្នាក់ និងមានចំនួនសិស្ស១.៩៣៧នាក់ ដែលក្នុងនោះ ថ្នាក់ត្រី(ទី១)មាន២១ ថ្នាក់ មានសិស្សចំនួន៩២២នាក់ ថ្នាក់ទោ(ទី២) មាន១៨ថ្នាក់ មានសិស្សចំនួន៥៣២នាក់ និងថ្នាក់ឯក(ទី៣)មាន១៩ថ្នាក់ មានសិស្ស ចំនួន៤៨៣នាក់។

-ពុទ្ធិកសាកលវិទ្យាល័យទូទាំងប្រទេសមានចំនួនប្រាំ។ នៅរាជធានីភ្នំពេញមានចំនួន២ គឺសាកលវិទ្យាល័យព្រះសីហនុរាជ(ទីតាំងគោល)និងសាកលវិទ្យាល័យព្រះសីហនុមុនីរាជា។ នៅខេត្តកំពង់ឆ្នាំងមាន១ គឺសាកលវិទ្យាល័យព្រះសីហនុរាជកំពង់ឆ្នាំង។ នៅខេត្តបាត់ដំបងមាន១ គឺសាកលវិទ្យាល័យព្រះសីហនុរាជបាត់ដំបង និងនៅខេត្តកំពង់ចាមមាន១ គឺសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** (ស្ថិតក្នុងវត្តជ្រោយថ្ម)។ សាកលវិទ្យាល័យទាំង៥ មានការបណ្តុះបណ្តាលចំនួន២កម្រិត គឺថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

ថ្នាក់បរិញ្ញាបត្រ

| ពុទ្ធិកសកលវិទ្យាល័យ | ថ្នាក់មូលដ្ឋាន | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | សរុប | ចំនួនសាលា | ចំនួនគ្រូ |
|---|---|---|---|---|---|---|---|
| ព្រះសីហនុរាជ | ២១៤ | ១៥២ | ១២៨ | ១០៤ | ៥៨៧ | ១ | ១០៧ |
| កំពង់ឆ្នាំង | ១៦១ | ១៦៩ | ១៨៦ | ១៨២ | ៦៩៨ | ១ | ៦១ |
| បាត់ដំបង | ១៤២ | ១៦៤ | ១៦៦ | ៨១ | ៥៥៣ | ១ | ៧០ |
| ព្រះសីហមុនីរាជា | ៥១៤ | ៤១២ | ៣៩៤ | ៣០៤ | ១៦២៤ ១ | | ១៤៤ |
| សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | ៦៣ | ១៤៨ | ១៤១ | ១៥៨ | ៥១០ | ១ | ៥៦ |

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| ពុទ្ធិកសកលវិទ្យាល័យ | ឆ្នាំទី១ | ឆ្នាំទី២ | សាលា | គ្រូ |
|---|---|---|---|---|
| ព្រះសីហនុរាជ | ៥១ | ៦៧ | ១ | ១៦ |
| កំពង់ឆ្នាំង | ០ | ១០៣ | ១ | ០ |
| បាត់ដំបង | ០ | ១២៤ | ១ | ១០ |
| ព្រះសីហមុនីរាជា | ៥០ | ៤៥ | ១ | ០ |
| សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន (ជ្រោយថ្ម) | ៧៦ | ០ | ១ | ១៦ |

តាមរយៈទិន្នន័យខាងលើ យើងឃើញថា ពុទ្ធិកសិក្សាមានសមិទ្ធផលក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សបានច្រើន សក្ដិសមនឹងប្រយោគមួយឃ្លាដែលគេលើកឡើងថា **ពុទ្ធិកសិក្សាមានសារៈសំខាន់ណាស់នៅក្នុងសង្គម ។**

**តើពុទ្ធិកសិក្សាមានសារៈសំខាន់យ៉ាងណាខ្លះនៅក្នុងសង្គម?**

គ្រប់សាលាទាំងអស់ មិនថាពុទ្ធិកៈមិនថាសាលាចំណេះទូទៅទាំងរដ្ឋនិងឯកជន គឺសុទ្ធតែមានសារៈសំខាន់ទាំងអស់ ដោយសារៈសំខាន់ជាច្រើនដូចជា៖

-ជាកន្លែងដែលមនុស្សរៀនពីរបៀបអាន របៀបសរសេរ របៀបគិត និងការធ្វើគណិតវិទ្យាជាដើម។

-ជាកន្លែងរៀនសូត្រពីរបៀបប្រព្រឹត្ត និងរបៀបដែលនាំឱ្យពួកគេក្លាយជាពលរដ្ឋល្អ ពោលគឺសាលាមានសារៈសំខាន់ក្នុងការផ្ដល់ការអប់រំដល់មនុស្សជាតិ។

-ជាកន្លែងអប់រំជួយមនុស្សឱ្យគិតប្រកបដោយការត្រិះរិះពិចារណា និងប្រកបដោយភាពច្នៃប្រឌិត និងធ្វើឱ្យពួកគេជាអ្នកដោះស្រាយបញ្ហាដែលជួបប្រទះនៅក្នុងជីវិតកាន់តែប្រសើរ។

-ជាកន្លែងជួយផ្ដល់ការអប់រំ ការរៀបចំមនុស្សឱ្យមានចំណេះដឹង មានការងារល្អ និងអាជីពការងារល្អ។ ការអប់រំនាំឱ្យមនុស្សស្វែងយល់អំពីពិភពលោកជុំវិញខ្លួន ក៏ដូចជាការអភិវឌ្ឍជំនាញ ដែលពួកគេត្រូវការដើម្បីទទួលបានជោគជ័យក្នុងជីវិតរបៀបនៃដំណើរការជីវិត ដើម្បីទទួលបានចំណេះដឹងថ្មីៗ ជួបមនុស្សថ្មី និងការងារថ្មី ក៏ដូចជាការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់បុគ្គលខ្លួន គឺការពង្រីកចំណេះដឹង ពង្រឹងសមត្ថភាពឱ្យមានការរីកចម្រើនជាងមនុស្សផ្សេងទៀត និងបានដឹងគោលដៅនៃជីវិតរបស់ខ្លួន ដោយធ្វើយ៉ាងណា ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់ការប្រកបរបរចិញ្ចឹមជីវិតដើម្បីប្រកួតប្រជែងដោយបញ្ញា ដោយស្វែងយល់អំពីវប្បធម៌និងសាសនាផ្សេងៗដែលមាននៅជុំវិញខ្លួន។

-ជាកន្លែងដែលមានសារៈសំខាន់ក្នុងសង្គមព្រោះវាជួយអប់រំមនុស្សនិងរៀបចំពួកគេសម្រាប់កម្លាំងពលកម្ម។ វាក៏បង្រៀនពួកគេពីរបៀបក្លាយជាសមាជិកដែលមានទំនួលខុសត្រូវក្នុងសង្គមផងដែរ វាជួយមនុស្សឱ្យរៀនអំពីពិភពលោកជុំវិញពួកគេ។ ពួកគេរៀនគិតពិចារណា ដោះស្រាយបញ្ហា និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ដែលជំនាញទាំងនេះមានសារៈសំខាន់សម្រាប់ភាពជោគជ័យនៅក្នុងមហាវិទ្យាល័យ និងក្នុងកម្លាំងការងារ។

ដូច្នេះ សាលា គឺជាស្ថាប័នបណ្ដុះបណ្ដាលដ៏សំខាន់បំផុតមួយនៅក្នុងសង្គមខ្មែរ ដែលជាកន្លែងរៀនពីមូលដ្ឋានគ្រឹះឆ្ពោះទៅរកភាពជោគជ័យក្នុងជីវិត។ មានរឿងសំខាន់ជាច្រើនដែលត្រូវរៀននៅក្នុងសាលាប៉ុន្តែសំខាន់

បំផុតមួយ គឺរបៀបគិតត្រិះរិះពិចារណា។ ការរៀនសួរសំណួរ និងគិតដោយខ្លួនឯងមានសារៈសំខាន់សម្រាប់ភាពជោគជ័យក្នុងវិស័យណាមួយ។ អ្វីដែលសំខាន់បំផុតក្នុងការរៀននៅសាលា គឺរបៀបគិតពិចារណា និងសួរសំណួរដែលនាំឱ្យសិស្សអភិវឌ្ឍគំនិត និងគំនិតផ្ទាល់ខ្លួនរបស់ពួកគេ ហើយអាចពិភាក្សា ដោយឆ្លាតវៃជាមួយអ្នកដទៃ។

សរុបមក សាលាមានសារៈសំខាន់ ព្រោះវាផ្តល់ឱ្យបុគ្គលគ្រប់រូបនូវជំនាញ និងចំណេះដឹងដែលពួកគេត្រូវការ ដើម្បីជោគជ័យក្នុងជីវិត។ សាលានឹងជួយពួកគេអភិវឌ្ឍជំនាញសង្គម និងការប្រាស្រ័យទាក់ទង ហើយវាបង្រៀនពួកគេពីរបៀបគិតពិចារណា និងដោះស្រាយបញ្ហា។ សាលាក៏ជាកន្លែងមួយដែលបុគ្គលអាចបង្កើតមិត្តភក្តិ ពង្រីកទំនាក់ទំនងនិងស្វែងយល់ពីវប្បធម៌ផ្សេងៗ។ ជាចុងក្រោយ សាលារៀនគឺជាកន្លែងដែលបុគ្គលម្នាក់ៗអាចរៀនអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ពួកគេ ហើយស្វែងយល់ ថាតើពួកគេចង់ធ្វើអ្វីក្នុងជីវិតរបស់ពួកគេ ជាពិសេសការសិក្សានៅសាលាពុទ្ធិកៈ គឺបុគ្គលគ្រប់រូបបានទទួលបានទាំងចំណេះដឹងផ្លូវលោក និងចំណេះដឹងផ្លូវធម៌ ពោលគឺពុទ្ធិកសិក្សាជាវិស័យអប់រំតាមបែបព្រះពុទ្ធសាសនា ដែលបានបង្កើតតាំងពីសម័យដើមមកដើម្បី បណ្តុះបណ្តាលធនធានព្រះសង្ឃ និងកាត់បន្ថយអត្រាអនក្ខរភាពក្នុងសង្គម តាមរយៈការផ្តល់ចំណេះដឹង និងសីលធម៌ ដែលជាគ្រឹះរួមចំណែកក្នុងការលើកកម្ពស់សង្គមជាតិនិងតម្លៃព្រះពុទ្ធសាសនាដែលជាប្រទីបបំភ្លឺផ្លូវដល់ជន្នានុជនរស់ក្នុងភាពចម្រុងចម្រើន និងសុខដុមរមនា។

## ឯកសារពិគ្រោះ


១- គណៈកម្មការស្រាវជ្រាវនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ***ប្រវត្តិពុទ្ធិកសិក្សា*** ឆ្នាំ២០០៦។

២- ក្រសួងធម្មការ និង សាសនា អគ្គាធិកាដ្ឋានពុទ្ធិកសិក្សាជាតិ ***ស្ថិតិពុទ្ធិកសិក្សាទូទាំងប្រទេសឆ្នាំ២០២០-២០២១*** ឆ្នាំ២០២០។

៣- (7) Wisemen – Posts | Facebook

៤- https://www.bing.com

៥- https://newsroomcambodia.com

# ប្រវត្តិរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

ដោយៈ បណ្ឌិត **ហែម ឡាច**
មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ,វិទ្យាស្ថានមនុស្សសាស្ត្រ
និងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា

*ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែល ព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និង តាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ជារដ្ឋឯក រាជ្យអធិបតេយ្យអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូល បក្សសម្ព័ន្ធ មានទីតាំងស្ថិតនៅក្នុងភូមិភាគអាស៊ី ប៉ែកអាគ្នេយ៍ និងមានផ្ទៃក្រឡា១៨១.០៣៥ គីឡូម៉ែត្រការ៉េ។ ភ្នំពេញ ជារាជធានីនៃព្រះរាជា ណាចក្រកម្ពុជា។ ភាសា និងអក្សរ ដែលប្រើជាផ្លូវ ការ គឺភាសា និងអក្សរ ខ្មែរ។ បច្ចុប្បន្ន ប្រទេសកម្ពុ ជា មានរាជធានី១ ខេត្ត២៤ ក្រុង២៨ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១.៤០៦ សង្កាត់២៤៦ ភូមិ១៤.៣៩៤ និងមានប្រជាជនសរុប១៥.៥៥២.២១១នាក់(ជំរឿន ទូទៅប្រជាជននៅព្រះរាណាចក្រកម្ពុជាឆ្នាំ២០១៩)។*

*អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ហើយអំណាចបែងចែងដាច់ពីគ្នារវាងអំណាច នីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាច តុលាការ។*

## ១. ប្រវត្តិរដ្ឋសភាមុនឆ្នាំ១៩៩៣

*ព្រះរាជាណាចក្រកម្ពុជាត្រូវបានអាណានិគមនិយមបារាំងត្រួតត្រាពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣។ ក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មានព្រះរាជបញ្ញត្តិមួយចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩១៣ សម្រេចបង្កើតសភាពិគ្រោះយោបល់ ដែលមានសមាជិក៣៩រូប តំណាងឱ្យ១០ខេត្ត ក្រុង។ នេះជាសញ្ញាណដំបូងនៃការកកើត សភា។*

*ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤០ សភាពិគ្រោះ យោបល់ បានកែប្រែទៅជា សភាតំណាងប្រជាជន កម្ពុជា ក្រោមរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស។*

*ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៤៥ មានការបង្កើត សភាពិគ្រោះយោបល់ ដែលមានសមាជិក៣៧រូប តំណាងឱ្យ១៤ខេត្ត ក្រុង។*

*ខែវិច្ឆិកា ឆ្នាំ១៩៤៥ មានការបង្កើត គណៈកម្មការបារាំង ខ្មែរ មួយ ដើម្បីរៀបរៀង សេចក្តីព្រាងរដ្ឋធម្មនុញ្ញដំបូង។*

*ឆ្នាំ១៩៤៦ មានព្រះរាជក្រម៤ សម្រេច ផ្តល់សេរីភាពសារព័ត៌មាន សេរីភាពបង្កើត សមាគម សេរីភាពបង្កើតគណបក្សនយោបាយ និងឱ្យប្រើច្បាប់បោះឆ្នោតជាសកលជ្រើសតាំង រដ្ឋសភាបណ្តោះ អាសន្ន (សភាធម្មនុញ្ញ)។*

ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៦ មានការបោះឆ្នោតជាសកលលើកដំបូងនៅកម្ពុជា ជ្រើសតាំងសមាជិកសភាធម្មនុញ្ញ៦៧រូប ដែលមានបេសកកម្មតាក់តែងរដ្ឋធម្មនុញ្ញទី១នៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧។ សមាសភាពសភាធម្មនុញ្ញដែលកើតចេញពីការបោះឆ្នោតថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៦នេះមាន៦៧រូប មកពីគណបក្សប្រជាធិបតេយ្យ៥០រូប គណបក្សសេរីភាព១៤រូប និងគណបក្សឯកច្ឆ័ន្ទ៣រូប។

ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៧ មានការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាដែលមាន៧៥អាសនៈ។ គណបក្សប្រជាធិបតេយ្យទទួលបាន៥៤អាសនៈ ហើយគណបក្សសេរីភាពទទួលបាន២១អាសនៈ[1]។

ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៥១ មានការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាដែលមាន៧៨អាសនៈ។ គណបក្សប្រជាធិបតេយ្យទទួលបានអាសនៈភាគច្រើនដាច់ខាត(៥៤អាសនៈ)។

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ មានការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាដែលមាន៩១អាសនៈ ហើយគណបក្សសង្គមរាស្ត្រនិយមទទួលបានអាសនៈទាំងអស់នៅក្នុងរដ្ឋសភា។

ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៥៨ មានការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាដែលមាន៦១អាសនៈ ហើយគណបក្សសង្គមរាស្ត្រនិយមទទួលបានអាសនៈទាំងអស់នៅក្នុងរដ្ឋសភាដដែល។

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦២ មានការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាដែលមាន៧៧អាសនៈ។ ដោយគ្មានគណបក្សផ្សេងទៀតឈរឈ្មោះ គណបក្សសង្គមរាស្ត្រនិយមទទួលបានអាសនៈទាំងអស់នៅក្នុងរដ្ឋសភា[2]។

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៦ មានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិថ្មី។ មានបេក្ខជនទាំងអស់៤១៥នាក់ប្រជែងគ្នាយកអាសនៈ៨២នៅក្នុងរដ្ឋសភា។ គណបក្សសង្គមរាស្ត្រនិយមទទួលបានអាសនៈទាំងអស់។

សភាជាតិ សម័យសាធារណរដ្ឋខ្មែរ កើតចេញពីការបោះឆ្នោតថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧២។ គណបក្សរបស់លោក លន់ នល់ ឈ្នះឆ្នោត ហើយទទួលបានអាសនៈទាំង១២៦នៅក្នុងរដ្ឋសភា។

នៅសម័យកម្ពុជាប្រជាធិបតេយ្យមានការបោះឆ្នោតជ្រើសតាំងសភាតំណាងប្រជាជនកម្ពុជានៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ដែលមានសមាជិកទាំងអស់២៥០នាក់ ក្នុងនោះតំណាងកសិករមាន១៥០នាក់ តំណាងកម្មករ

[1] ឃឹម ឈុនអ៊ី ប្រវត្តិសភាកម្ពុជា៖ ឯកសារបង្រៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រនិងវិទ្យាសាស្ត្រនយោបាយ, សាកលវិទ្យាល័យបៀលប្រាយ, ២០០៩។

[2] ឃឹម ឈុនអ៊ី ប្រវត្តិសភាកម្ពុជា៖ ដ.ឯ.ម.។

និងពលករផ្សេងទៀតមាន៥០នាក់ និងតំណាងកងទ័ពបដិវត្តន៍កម្ពុជា៥០នាក់។

គណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជារួមមានៈ នួន ជា (ប្រធាន) ង៉ួន កង(អនុប្រធានទី១) ពៅស៊ូ(អនុប្រធានទី២) រស់ នឹម សស៊ាន ម៉ីផាំ ខេង សុខ ម៉ាត់ លី ថង ស៊ី និង រស់ ព្រាប(សមាជិក)[3]។

សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា រដ្ឋសភាជាតិ ជាស្ថាប័នកំពូលរបស់រដ្ឋ និងជាស្ថាប័នតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេសនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ដែលមានសមត្ថកិច្ចតែងតាំង និងអនុម័តច្បាប់។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា មិនបានចែងឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌនៃបេក្ខជនដែលមានសិទ្ធិឈរឈ្មោះនោះទេ។ នីតិវិធីបោះឆ្នោតត្រូវបានកំណត់ក្នុងច្បាប់បោះឆ្នោត។

តំណាងរាស្ត្រ ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងដោយសម្ងាត់។ រដ្ឋសភាដែលកើតចេញពីការបោះឆ្នោត ថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៨១ មាន១១៧អាសនៈ។ បេក្ខជនទាំងអស់សុទ្ធតែត្រូវបានជ្រើសតាំង និងមានការឯកភាពពីរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ រដ្ឋសភា បានអនុម័តរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ ហើយត្រូវបានក្រុមប្រឹក្សារដ្ឋប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ ក្រុមប្រឹក្សារដ្ឋបានចេញក្រឹត្យប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញកែប្រែ«រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា»ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃដដែលនោះ។

## ២. រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣-២០២៣)

រដ្ឋសភាជាអង្គការកំពូលតំណាងប្រជាពលរដ្ឋដែលមានអំណាចនីតិប្បញ្ញត្តិ។ តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងប្រជាជាតិខ្មែរទាំងមូលដែលកើតចេញពីការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះនិងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ នីតិកាលរបស់រដ្ឋសភាមានកំណត់៥ឆ្នាំហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។

### ២.១. តួនាទីសំខាន់ៗរបស់រដ្ឋសភា

រដ្ឋសភាបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន។ រដ្ឋសភាមានតួនាទីសំខាន់ៗដូចជាៈ

#### ២.១.១. ការអនុម័ត

-សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។ តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់។

-រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចីការ

[3] ឌី ខាំបូលី៖ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, ១៩៧៥-១៩៧៩, មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៧។

សន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ។

-រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល។

-រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។ រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។ ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**២.១.២. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល**

-រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

-តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយមកបំភ្លឺរដ្ឋសភា អំពីបញ្ហាដែលមានសារៈសំខាន់ពិសេស។

-រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល។ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួន៣០នាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។

-តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។ ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូបអាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។ ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយកមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ។

-រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍សម្រាប់ការឆ្លើយសំណួរ។

**២.១.៣. ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ**

តំណាងរាស្ត្រធ្វើការងារក្នុងរដ្ឋសភាបីខែ មានវិស្សមកាលបីខែ។ តំណាងរាស្ត្រត្រូវចុះសួរសុខទុក្ខ ជួយដោះស្រាយបញ្ហាសំណូមពររបស់ប្រជាពលរដ្ឋតាមមណ្ឌលរៀងខ្លួន ឬតាមខេត្តទាំងឡាយទូទាំងប្រទេសឱ្យអស់ពីលទ្ធភាព និងត្រូវទាក់ទងជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

**២.២. អំពីវិសមិតភាព និងអភ័យឯកសិទ្ធិសភា**

តំណាងរាស្ត្រមិនអាចបំពេញមុខងារជាសមាជិករដ្ឋសភាផង ជាសមាជិកព្រឹទ្ធសភាផង ស្របពេលតែមួយបានឡើយ។ សមាជិកសភាមានវិសមតិភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ វៀរលែងតែបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរដ្ឋាភិបាល។ ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា

ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា។

ដើម្បីឱ្យសមាជិកសភាបំពេញតួនាទីជាតំណាងប្រជាពលរដ្ឋ និងប្រជាជាតិបានល្អ រដ្ឋធម្មនុញ្ញបានផ្តល់អភ័យឯកសិទ្ធិសភាជូនសមាជិកសភា។ តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ អភ័យឯកសិទ្ធិនេះ ជានាឯកពជ្យភាពរបស់សមាជិកសភា។ តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ[4]។

## ២.៣. គណៈកម្មាធិការអចិន្ត្រៃយ៍

គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាត្រូវបានបង្កើតឡើង ដើម្បីជានាដំណើរការរដ្ឋសភាក្នុងចន្លោះសម័យប្រជុំ និងសម្រេចពីរបៀបវារៈប្រជុំពេញអង្គ និងកិច្ចការធំៗរបស់រដ្ឋសភា។

សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍មានដូចតទៅៈ

-ប្រធានរដ្ឋសភា

-អនុប្រធានទាំងពីរ

-ប្រធានគណៈកម្មការនានានៃរដ្ឋសភា។

រដ្ឋសភាបង្កើតគណៈកម្មការជំនាញនានាចំនួន១០ ដើម្បីទទួលពិនិត្យសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នានានិងជាពិសេសទទួលបន្ទុកទៅតាមមុខជំនាញរបស់ខ្លួនក្នុងការត្រួតមើលកិច្ចការរបស់រាជរដ្ឋាភិបាល។ សមាសភាពនៃគណៈកម្មការជំនាញនីមួយៗមានចំនួន៧រូបយ៉ាងតិច។

គណៈកម្មការជំនាញទាំង១០នោះគឺៈ

-គណៈកម្មការការពារសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

-គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

-គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ

-គណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

-គណៈកម្មការនីតិកម្ម និងយុត្តិធម៌

-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

-គណៈកម្មការសាធារណៈការដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគររូបនីយកម្ម និងសំណង់

---

[4] ក្រុមប្រឹក្សាធម្មនុញ្ញៈ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការផ្សាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ២០១៥

-គណៈកម្មការអង្កេត បោសសម្អាត និង ប្រឆាំងអំពើពុករលួយ។

## ៣. រដ្ឋសភា(១៩៩៣-២០២៣)

### ៣.១. នីតិកាលទី១(១៩៩៣-១៩៩៨)

ដំណោះស្រាយវិវាទនៅកម្ពុជា តាមរយៈកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានកំណត់ឱ្យមានការបោះឆ្នោតដើម្បីកសាងនីតិរដ្ឋនិងបង្កើតស្ថាប័នគ្រប់គ្រងប្រទេស។ ក្នុងស្មារតីនេះ ការបោះឆ្នោតលើកទី១ បានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ នៅទូទាំងប្រទេសជ្រើសរើសសភាធម្មនុញ្ញ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញ មួយ។ ក្នុងឱកាសនោះ មានគណបក្សនយោបាយចំនួន២០ បានចូលរួមប្រកួត សម្រាប់មណ្ឌល២១ ដើម្បីជ្រើសរើសតំណាង រាស្ត្រ១២០រូប។ រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញាឆ្នាំ១៩៩៣ ហើយត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញាឆ្នាំ១៩៩៣។ ក្នុងពេលជាមួយគ្នានោះដែរ សភាធម្មនុញ្ញក៏បានត្រឡប់ទៅជារដ្ឋសភាជាតិ សម្រាប់អាណត្តិទី១ ដែលមានរយៈពេល៥ឆ្នាំ(១៩៩៣-១៩៩៨)។

នៅក្នុងអាណត្តិទី១នេះ មានគណបក្សនយោបាយចំនួន៤ ដែលទទួលបានអាសនៈនៅក្នុងសភា៖

-គណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបាន ៥៨ អាសនៈ

-គណបក្សប្រជាជនកម្ពុជា ទទួលបាន ៥១ អាសនៈ

-គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ទទួលបាន ១០ អាសនៈ

-គណបក្សម៉ូលីណាកានិងអ្នក តស៊ូខ្មែរដើម្បីសេរីភាព ទទួលបាន១ អាសនៈ[5]។

ចំណែកគណបក្សដែលបានចូលរួមការបោះឆ្នោតមានដូចតទៅ៖

-គណបក្សប្រជាជនកម្ពុជា

-គណបក្សសម្ព័ន្ធសាធារណរដ្ឋ

-គណបក្សសាធារណរដ្ឋអភិវឌ្ឍសេរី

-គណបក្សខ្មែរអព្យាក្រឹត

-គណបក្សសាមគ្គីធម៌ប្រជាជាតិ

-គណបក្សកម្ពុជាអព្យាក្រឹតប្រជាធិបតេយ្យ

-គណបក្សប្រជាធិបតេយ្យ

-គណបក្សកម្ពុជាសេរីឯករាជ្យប្រជាធិបតេយ្យ

-គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា(លោកតា សឺន សាន)

-គណបក្សសេរីបង្រួបបង្រួមជាតិ

-គណបក្សហ្វ៊ុនស៊ិនប៉ិច

-គណបក្សកម្ពុជារស់ឡើងវិញ

-គណបក្សប្រជាធិបតេយ្យនិងអភិវឌ្ឍន៍

-គណបក្សខ្មែរជាតិនិយម

-គណបក្សសាធារណរដ្ឋសេរីនិយម

-គណបក្សកសិករប្រជាធិបតេយ្យខ្មែរ

[5] អគ្គលេខាធិការដ្ឋានរដ្ឋសភា៖ **រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ឆ្នាំ២០០៣។

-គណបក្សម៉ូលីណាកានិងអ្នកតស៊ូខ្មែរដើម្បីសេរីភាព

-គណបក្សប្រជាធិបតេយ្យសេរី

-គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ

-គណបក្សសភាជាតិខ្មែរ

**៣.២. នីតិកាលទី២**(**១៩៩៨-២០០៣**)

ការបោះឆ្នោតលើកទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ដែលមានគណបក្សនយោបាយចំនួន៣៩បានចូលរួមប្រកួត សម្រាប់១២២អាសនៈនៅក្នុងរដ្ឋសភា។

នៅក្នុងអាណត្តិទី២នេះ មានគណបក្សនយោបាយចំនួន៣ ដែលទទួលបានអាសនៈនៅក្នុងសភា៖

-គណបក្សប្រជាជនកម្ពុជា ទទួលបាន ៦៤ អាសនៈ

-គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ៤៣ អាសនៈ

-គណបក្សសម រង្ស៊ី ទទួលបាន១៥ អាសនៈ

គណបក្សទាំង៣៩ដែលបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ១៩៩៨៖

-គណបក្សសំបុកឃ្មុំ សង្គមប្រជាធិបតេយ្យ

-គណបក្សចំរើននិយមខ្មែរ

-គណបក្សសាធារណរដ្ឋសេរី

-គណបក្សនគរវត្ត

-គណបក្សខ្មែរអង្គរ

-គណបក្សប្រជាធិបតេយ្យសេរី

-គណបក្សពន្លឺសេរីភាពលោកថាច់ រ៉េង

-គណបក្សសម្ព័ន្ធសាធារណរដ្ឋ

-គណបក្សខ្មែរជាតិនិយម

-គណបក្សកម្ពុជាសេរីឯករាជ្យប្រជាធិបតេយ្យ

-គណបក្សកម្ពុជាអព្យាក្រឹតប្រជាធិបតេយ្យ

-គណបក្សសង្គមថ្មី

-គណបក្សកសាងជាតិ

-គណបក្សនាងនាគនារីខ្មែរ

-គណបក្សខ្មែរជីវិតថ្មី

-គណបក្សអភិវឌ្ឍន៍កសិករកម្ពុជា

-គណបក្សសាមគ្គីធម៌ប្រជាជាតិ

-គណបក្សសម រង្ស៊ី

-គណបក្សរួបរួមជាតិ

-គណបក្សសាធារណរដ្ឋអភិវឌ្ឍន៍សេរី

-គណបក្សប្រជាធិបតេយ្យខ្មែរ

-គណបក្សប្រជាធិបតេយ្យសេរីសង្គ្រោះជាតិ

-គណបក្សរាស្ត្រនិយម

-គណបក្សស្ត្រីកម្ពុជា

-គណបក្សកូនខ្មែរ

-គណបក្សសេរីនិយមព្រះពុទ្ធសាសនា

-គណបក្សកសិករ

-គណបក្សកម្ពុជាថ្មី

-គណបក្សកម្ពុជាអព្យាក្រឹត

-គណបក្សលោកតាសឺន សាន

-គណបក្សស្ត្រីសង្គ្រោះកម្ពុជា

-គណបក្សពលរដ្ឋខ្មែរ

-គណបក្សទ្រទ្រង់ជាតិកម្ពុជា

-គណបក្សហ៊្វុនស៊ិនប៉ិច

-គណបក្សប្រជាជនកម្ពុជា

-គណបក្សឯកភាពខ្មែរ

-គណបក្សស្ថាបនាជាតិ

-គណបក្សធម្មាធិបតេយ្យស្ត្រីនិងជាតិ

-គណបក្សម៉ូលីណាកានិងអ្នកតស៊ូខ្មែរដើម្បីសេរីភាព

**៣.៣. នីតិកាលទី៣**(**២០០៣-២០០៨**)

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣ បានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០០៣ ដែលមានគណបក្សនយោបាយចំនួន២៣បានចូលរួមប្រកួត សម្រាប់១២៣អាសនៈនៅក្នុងរដ្ឋសភា។

នៅក្នុងអាណត្តិទី៣នេះ ក៏មានតែគណបក្សនយោបាយចំនួន៣ ដែលទទួលបានអាសនៈនៅក្នុងសភា៖

-គណបក្សប្រជាជនកម្ពុជា ទទួលបាន ៧៣ អាសនៈ

-គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ២៦ អាសនៈ

-គណបក្សសម រង្ស៊ី ទទួលបាន ២៤ អាសនៈ

គណបក្សដែលបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ មានដូចតទៅ៖

-គណបក្សសាមគ្គីធម៌ប្រជាជាតិ

-គណបក្សម៉ូលីណាកា និងអ្នកតស៊ូខ្មែរដើម្បីសេរីភាព

-គណបក្សខ្មែរជួយខ្មែរ

-គណបក្សកម្ពុជាសេរីឯករាជ្យប្រជាធិបតេយ្យ

-គណបក្សស្រូវ

-គណបក្សរណសិរ្សជនជាតិខ្មែរ

-គណបក្សខ្មែរអង្គរ

-គណបក្សអភិវឌ្ឍន៍កម្ពុជា

-គណបក្សបារាំងដាវ៉ាចលនាប្រជាធិបតេយ្យ

-គណបក្សព្រលឹងខ្មែរ

-គណបក្សប្រជាធិបតេយ្យខ្មែរ

-គណបក្សពលរដ្ឋខ្មែរ

-គណបក្សឥន្ទបត្តបុរី

-គណបក្សខ្មែរជាតិនិយម

-គណបក្សនរោត្តមចក្រពង្សព្រលឹងខ្មែរ

-គណបក្សឯកភាពខ្មែរ

-គណបក្សប្រជាជនកម្ពុជា

-គណបក្សកូនខ្មែរ

-គណបក្សស្ត្រីកម្ពុជា

-គណបក្សសម រង្ស៊ី

-គណបក្សប្រជាធិបតេយ្យសេរី

-គណបក្សកសិករ

-គណបក្សហ៊្វុនស៊ិនប៉ិច

**៣.៤. នីតិកាលទី៤**(**២០០៨-២០១៣**)

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤ បានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨។នៅពេលនោះមានគណបក្សនយោបាយចំនួន១១បានចូលរួមប្រកួតសម្រាប់១២៣អាសនៈនៅក្នុងរដ្ឋសភាដូចអាណត្តិទី៣ដែរ។

នៅក្នុងអាណត្តិទី២នេះ មានគណបក្សនយោបាយចំនួន៩ បានទទួលអាសនៈនៅក្នុងសភា៖

-គណបក្សប្រជាជនកម្ពុជា ទទួលបាន ៩០ អាសនៈ

-គណបក្សសមរង្ស៊ី ទទួលបាន២៦អាសនៈ

-គណបក្សសិទ្ធិមនុស្សទទួលបាន៣អាសនៈ

-គណបក្សនរោត្តមរណឫទ្ធិ ទទួលបាន២អាសនៈ

-គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន២អាសនៈ

គណបក្សដែលបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅអាណត្តិទី២នេះ មានដូចតទៅ៖

-គណបក្សនរោត្តម រណឫទ្ធិ

-គណបក្សប្រជាធិបតេយ្យខ្មែរ

-គណបក្សខ្មែរសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

-គណបក្សប្រជាជនកម្ពុជា

-គណបក្សខ្មែរឈប់ក្រ

-គណបក្សខ្មែរសាធារណរដ្ឋ

-គណបក្សសង្គមយុត្តិធម៌

-គណបក្សហ៊្វុនស៊ិនប៉ិច

-គណបក្សសម រង្ស៊ី

-គណបក្សហង្សដាវ៉ាចលនាប្រជាធិបតេយ្យ

-គណបក្សសិទ្ធិមនុស្ស

### **៣.៥. នីតិកាលទី៥** (២០១៣-២០១៨)

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ បានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។ នៅក្នុងអាណត្តិទី៥នេះ មានគណបក្សនយោបាយចំនួន៨បានចូលរួមប្រកួត សម្រាប់១២៣អាសនៈនៅក្នុងរដ្ឋសភាដូចអាណត្តិទី៣ និងអាណត្តិទី២ដែរ។

មានគណបក្សនយោបាយចំនួន២ បានទទួលអាសនៈនៅក្នុងរដ្ឋសភាអាណត្តិទី៥នេះ៖

-គណបក្សប្រជាជនកម្ពុជា ទទួលបាន ៦៨ អាសនៈ

-គណបក្សសង្គ្រោះជាតិ ទទួលបាន ៥៥ អាសនៈ

គណបក្សដែលបានដាក់បញ្ជីបេក្ខជនចូលរួមក្នុងការប្រកួតប្រជែង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅអាណត្តិទី៥នេះ មានដូចតទៅ៖

-គណបក្សសញ្ជាតិកម្ពុជា

-គណបក្សហ៊្វុនស៊ិនប៉ិច

-គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ

-គណបក្សប្រជាជនកម្ពុជា

-គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច

-គណបក្សខ្មែរឈប់ក្រ

-គណបក្សសង្គ្រោះជាតិ

-គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

បន្ទាប់ពីគណបក្សសង្គ្រោះជាតិត្រូវបានរំលាយ (១៧ វិច្ឆិកា ២០១៧)អាសនៈទាំង៥៥របស់គណបក្សនេះ ត្រូវបានបែងចែកទៅឱ្យគណបក្សផ្សេងៗទៀតដែលបានចូលរួមប្រកួតប្រជែង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥នេះ។

គណបក្សនយោបាយដែលបានទទួលអាសនៈនៅក្នុងរដ្ឋសភានៅពេលនោះមាន៖

-គណបក្សប្រជាជនកម្ពុជា ទទួលបាន ៧៩ អាសនៈ

-គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ៤១ អាសនៈ

-គណបក្សសញ្ញាតិកម្ពុជា ទទួលបាន ២ អាសនៈ

-គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ទទួលបាន ១ អាសនៈ

សូមបញ្ជាក់ថា គណបក្សខ្មែរឈប់ក្រ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ មិនទទួលយកអាសនៈរបស់គណបក្សសង្គ្រោះជាតិទេ។

**៣.៦. នីតិកាលទី៦**(**២០១៨-២០២៣**)

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ បានប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨។ នៅក្នុងអាណត្តិទី៦នេះ មានគណបក្សនយោបាយចំនួន២០បានចូលរួមប្រកួតប្រជែង ដណ្តើមអាសនៈ១២៥ នៅក្នុងរដ្ឋសភា។ គណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈទាំងអស់នៅក្នុងការបោះឆ្នោតអាណត្តិទី៦នេះ។

គណបក្សដែលបានដាក់បញ្ជីបេក្ខជនចូលរួមក្នុងការប្រកួតប្រជែង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ២០១៨នេះ មានដូចតទៅ៖

-គណបក្សខ្មែររួបរួមជាតិ

-គណបក្សមាតុភូមិយើង

-គណបក្សពន្លឺថ្មី

-គណបក្សសញ្ញាតិកម្ពុជា

-គណបក្សខ្មែរក្រោក

-គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ

-គណបក្សប្រជាធិបតេយ្យ មូលដ្ឋាន

-គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ

-គណបក្សរស្មីខេមរា

-គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

-គណបក្សខ្មែរសាធារណរដ្ឋ

-គណបក្សខ្មែរឈប់ក្រ

-គណបក្សហ៊្វុនស៊ិនប៉ិច

-គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច

-គណបក្សយុវជនកម្ពុជា

-គណបក្សធម្មាធិបតេយ្យ

-គណបក្សឆន្ទៈខ្មែរ

-គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា

-គណបក្សខ្មែរតែមួយ

-គណបក្សប្រជាជនកម្ពុជា

ខាងក្រោមនេះ គឺជាតារាងស្តីពីប្រវត្តិរបស់រដ្ឋសភាកម្ពុជាតាំងពីការកកើតដំបូង រហូតមកដល់បច្ចុប្បន្ន។

| ល.រ. | រដ្ឋសភា រយៈកាល | ចំនួនគណបក្ស | ចំនួនអាសនៈ | កាលបរិច្ឆេទបោះឆ្នោត |
|---|---|---|---|---|
| ១ | សភាធម្មនុញ្ញ១៩៤៦-១៩៤៧ | ៣ហុបក្ស | ៦៧ | ១-៩-១៩៤៦ |

| | | | | |
|---|---|---|---|---|
| ២ | រដ្ឋសភា១៩៤៧-១៩៥១ | ពហុបក្ស | ៧៥ | ២១-១២-១៩៤៧ |
| ៣ | រដ្ឋសភា១៩៥១-១៩៥៣ | ពហុបក្ស | ៧៨ | ៩-៩-១៩៥១ |
| ៤ | រដ្ឋសភា១៩៥៥-១៩៥៨ | បក្សតែមួយ | ៩១ | ១១-៩-១៩៥៥ |
| ៥ | រដ្ឋសភា១៩៥៨-១៩៦២ | បក្សតែមួយ | ៦១ | ២៣-៩-១៩៥៨ |
| ៦ | រដ្ឋសភា១៩៦២-១៩៦៦ | បក្សតែមួយ | ៧៧ | ១០-៦-១៩៦២ |
| ៧ | រដ្ឋសភា១៩៦៦-១៩៧២ | បក្សតែមួយ | ៨២ | ១១-៩-១៩៦៦ |
| ៨ | សភាជាតិ សាធារណរដ្ឋខ្មែរ១៩៧២-១៩៧៥ | បក្សតែមួយ | ១២៦ | ៣-៩-១៩៧២ |
| ៩ | សភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យ | បក្សតែមួយ | ២៥០ | ២០-៣-១៩៧៦ |
| ១០ | រដ្ឋសភាសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា១៩៧៩-១៩៩៣ | បក្សតែមួយ | ១១៧ | ១-៥-១៩៨១ |
| ១១ | សភាធម្មនុញ្ញ ១៩៩៣ | ៤/២០ | ១២០ | (២៣-២៨)-៥-១៩៩៣ |
| ១២ | រដ្ឋសភានីតិកាលទី១៖១៩៩៣-១៩៩៨ | ៤/២០ | ១២០ | (២៣-២៨)-៥-១៩៩៣ |
| ១៣ | រដ្ឋសភានីតិកាលទី២៖១៩៩៨-២០០៣ | ៣/៣៩ | ១២២ | ២៦-៧-១៩៩៨ |
| ១៤ | រដ្ឋសភានីតិកាលទី៣៖២០០៣-២០០៨ | ៣/២៣ | ១២៣ | ២៧-៧-២០០៣ |
| ១៥ | រដ្ឋសភានីតិកាលទី៤៖២០០៨-២០១៣ | ៥/១១ | ១២៣ | ២៧-៧-២០០៨ |
| ១៦ | រដ្ឋសភានីតិកាលទី៥៖២០១៣-២០១៨ | ២/៨ | ១២៣ | ២៨-៧-២០១៣ |
| ១៧ | រដ្ឋសភានីតិកាលទី៦៖២០១៨-២០២៣ | ១/២០ | ១២៥ | ២៩-៧-២០១៨ |

# ឯកសារយោង


១-ក្រុមប្រឹក្សាធម្មនុញ្ញ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការផ្សាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ២០១៥

២-គេហទំព័រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឆ្នាំ២០១៨

៣-ឃីម ឈុនអ៊ី៖ ប្រវត្តិសភាកម្ពុជា ឯកសារបង្រៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ, សាកលវិទ្យាល័យបៀលប្រាយ, ២០០៩

៤-ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនាបណ្ឌិត្យឆ្នាំ១៩៦៧

៥-ឌី ខាំបូលី៖ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, ១៩៧៥-១៩៧៩, មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៧

៦-ហួត វុទ្ធី៖ ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៤៧-២០០៧៖ ភ្នំពេញ ឆ្នាំ២០០៧

៧-ហែម ឡាច៖ ស្ថាប័ននយោបាលកម្ពុជាបច្ចុប្បន្ន៖ សាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០២២

៨-អគ្គលេខាធិការដ្ឋានរដ្ឋសភា៖ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣។

# ប្រាសាទឯកភ្នំក្នុងបរិបទប្រវត្តិសាស្ត្រនិងទេសចរណ៍

## Ek Phnom Temple in Historical and Tourism Context

*ដោយ៖ លោក* **សួ ប៉ុណ្ណារ៉ាត់**

*ប្រធាននាយកដ្ឋានប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រនយោបាយ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា*

### ១. សេចក្តីផ្តើម

*ប្រទេសកម្ពុជា ជាប្រទេសមួយស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ ដែលមានធនធានសក្តានុពលទេសចរណ៍យ៉ាងច្រើន ដូចជាធនធានវប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិជាដើម។ ធនធានទាំងនោះគឺមានស្ទើតែគ្រប់ខេត្តក្រុងទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា តួយ៉ាងដូចជាខេត្តបាត់ដំបង ជាខេត្តមួយដែលមានធនធានវប្បធម៌ ប្រវត្តិសាស្ត្រ ធនធានធម្មជាតិ និងធនធានកែច្នៃជាច្រើន ហើយធនធានទាំងនោះជាសក្តានុពលយ៉ាងសំខាន់សម្រាប់វិស័យទេសចរណ៍។ ធនធានសក្តានុពលទាំងនោះបាននិងកំពុងទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិមកទស្សនាជារៀងរាល់ថ្ងៃ។ តួយ៉ាងដូចជាប្រាសាទឯកភ្នំដែលបច្ចុប្បន្នកំពុងក្លាយជាកន្លែងទាក់ទាញភ្ញៀវទេសចរជាតិ និង អន្តរជាតិឱ្យមកទស្សនាកាន់តែច្រើនឡើងៗ។ ភាពសម្បូរបែបនៃសមិទ្ធផលដ៏សំខាន់ៗទាំងនេះ ដែលជាកេរមរតកពីបុរាណ បានធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានមោទនភាពយ៉ាងក្រៃលែងចំពោះធនធានទាំងនោះ។ តួយ៉ាងដូចជាប្រាសាទឯកភ្នំដែលស្នាដៃបុព្វបុរសខ្មែរបានបន្សល់ទុកឱ្យ គឺជាធនធានសក្តានុពលវប្បធម៌ប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់ដែលត្រូវបានកសាងឡើងក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ នាសតវត្សរ៍ទី១១ ក្នុងសម័យរុងរឿងនៃចក្រភពខ្មែរ។ ក្នុងសម័យកាលនោះកិត្តិនាមនៃអាណាចក្រខ្មែរ មានភាពល្បីរន្ទឺសុះសាយនៅអាស៊ីអាគ្នេយ៍ និងសកលលោក។ ភាពល្បីរន្ទឺនេះគឺដោយសារសមិទ្ធិយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាក់ស្តែងដូចជាមានប្រាសាទរាប់ពាន់ និងវប្បធម៌ផ្សេងៗទៀតដូចជាសិល្បៈ ទំនៀមទម្លាប់ ប្រពៃណី សាសនា។ល។ ដោយសារតែកេរមរតកដ៏ច្រើនបែបនេះធ្វើឱ្យសកលលោកទទួលស្គាល់ថា ប្រទេសកម្ពុជាជាប្រទេសអ្នកមានខាងសម្បត្តិវប្បធម៌ដែលមកទល់និងបច្ចុប្បន្នសមិទ្ធិទាំងនេះកំពុងក្លាយជាវត្ថុដ៏មានតម្លៃ និងជាសក្តានុពលមួយយ៉ាងសំខាន់សំរាប់ទាក់ទាញភ្ញៀវទេសចរជាហេតុធ្វើឱ្យវិស័យទេសចរណ៍មានការរីកចម្រើន។ ជាកាពិតការរីកចម្រើននៃវិស័យទេសចរណ៍របស់*

ព្រះរាជាណាចក្រកម្ពុជា គឺកើតចេញពីកត្តាសន្តិភាពក្នុងតំបន់ ពិសេសក្រោយពីការបញ្ចប់សង្គ្រាមស៊ីវិលពោលគឺនយោបាយឈ្នះឈ្នះនៅអំឡុងឆ្នាំ១៩៩៨។ កត្តាសន្តិភាពក្នុងតំបន់នេះពិតបានធ្វើឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិមានភាពទំនុកចិត្តក្នុងដំណើរកម្សាន្តរបស់គេនៅតាមរមណីយដ្ឋាននានា។ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យទេសចរណ៍ជាមុខព្រួញមួយយ៉ាងសំខាន់ក្នុងការស្តារខឿនសេដ្ឋកិច្ចជាតិ ឱ្យមានការរីកចម្រើនរីកលូតលាស់ទាំងថ្នាក់ជាតិនិងថ្នាក់តំបន់ ដោយបានពង្រីកខ្លួនចូលទៅក្នុងទីផ្សារទេសចរណ៍។ ដើម្បីឱ្យវិស័យទេសចរណ៍កម្ពុជាកាន់តែរីកចម្រើន គឺយើងត្រូវជានាឱ្យបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព មានតម្លាភាពនិងប្រសិទ្ធភាពកាន់តែប្រសើរថែមទៀត។ ភាពអំណោយផលនៃធនធានទេសចរណ៍បានធ្វើឱ្យប្រទេសកម្ពុជាទាក់ទាញនូវភ្ញៀវទេសចរគ្រប់ទិសទី និងគ្រប់ជាតិសាសន៍ឱ្យមកទស្សនានៅព្រះរាជាណាចក្រកម្ពុជា។ ធនធានសក្តានុពលដែលទាក់ទាញភ្ញៀវទេចរខ្លាំងជាងគេ គឺធនធានវប្បធម៌ប្រវត្តិសាស្ត្រ។ តួយ៉ាងដូចជាប្រាសាទឯកភ្នំសព្វថ្ងៃត្រូវបានគេយកមកប្រើប្រាស់ក្នុងវិស័យទេសចរណ៍។ ក្នុងពេលបច្ចុប្បន្ននេះ ប្រាសាទឯកភ្នំផ្តល់ផលប្រយោជន៍យ៉ាងខ្លាំងដល់ វិស័យទេសចរណ៍សម្រាប់អនាគតនឹងផ្តល់ផលប្រយោជន៍ដល់សហគមន៍ថែមទៀតផង។

## ២. ស្ថានភាពភូមិសាស្ត្រ

ខេត្តបាត់ដំបងមានសក្តានុពល សេដ្ឋកិច្ចខ្លាំងពិសេសវិស័យកសិកម្ម។ បច្ចុប្បន្នខេត្តមានចំងាយ២៩១គម ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន១១៧ ៤៨ គីឡូម៉ែត្រការ៉េ មានក្រុង ១ គឺស្រុកចំនួន១៣ ឃុំចំនួន៩២ សង្កាត់ចំនួន ១០ ភូមិចំនួន៨០៩ មានប្រជាពលរដ្ឋសរុបចំនួន ១.២៦៨.១៩០នាក់ ស្ត្រីចំនួន៦៣៩.៦៨០នាក់ និង២៦៣.៤៣៥គ្រួសារ[១]។ ដង់ស៊ីតេប្រជាជនមាន១០៤.៩២នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា ហើយកម្លាំងពលកម្មជាសក្តានុពល ចាប់ពីអាយុ ១៨ឆ្នាំដល់អាយុ៣៥ឆ្នាំមានចំនួន៥៦ ភាគរយ ចំនួនប្រជាពលរដ្ឋប្រកបមុខរបបរកសិកម្មមាន ៧២.២០ភាគ រយ។

ដោយឡែកប្រាសាទឯកភ្នំជាប្រាសាទស្ថិតនៅក្នុងស្រុកមួយក្នុងចំណោមស្រុកទាំង ១៣នៅក្នុង ខេត្តបាត់ដំបង ដែលមានឈ្មោះថា ស្រុកឯកភ្នំ។ ប្រាសាទនេះមានទីតាំងស្ថិតក្នុង ភូមិតាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង មានចម្ងាយ១៤គីឡូម៉ែត្រពីទីប្រជុំជន ខេត្តបាត់ដំបង ដែលត្រូវធ្វើដំណើរតាមផ្លូវមួយស្របនឹងដងស្ទឹងសង្កែបន្តដល់ទីប្រជុំជនដូនទាវ និងបន្តដំណើរតាមមាត់ព្រែករហូតទៅដល់ប្រាសាទតែម្តង។ ម្យ៉ាងទៀត គេអាចធ្វើដំណើរចេញពីទីប្រជុំជននៃខេត្តតាមផ្លូវក្រោះទើប

[១] សក្តានុពលនិងឱកាសវិនិយោគរបស់រដ្ឋបាលខេត្តបាត់ដំបង ឆ្នាំ២០១៨ទំព័រ៦។

បង្កើតថ្មីក៏បាន។ ស្រុកឯកភ្នំមានទីតាំងស្ថិតនៅប៉ែកខាងជើងខេត្តបាត់ដំបង[២]។ ស្រុកឯកភ្នំមានផ្ទៃដី សរុប ៦៣៥,១៦ គីឡូម៉ែត្រការ៉េស្មើនឹង ៦៣.៥ ១៦ ហិចតា មានព្រំប្រទល់៖

-ខាងជើង ទល់នឹងស្រុកមង្គលបូរី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ និងស្រុកក្រឡាញ់ ស្រុកពួក ខេត្តសៀមរាប។

-ខាងត្បូង ទល់នឹងស្រុកសង្កែ ស្រុកមោងឫស្សីនិងមណ្ឌលដីគោកខេត្តពោធិសាត់។

-ខាងកើត ទល់នឹងបឹងទន្លេសាប ស្រុកសៀមរាប ខេត្តសៀមរាប។

-ខាងលិច ទល់នឹងស្រុកថ្មគោល និងស្រុកបាត់ដំបង ខេត្តបាត់ដំបង។

---

[២] Etienne Aymonier, ***Le Cambodge***, Paris, 1901, p. 298.

## ស្រុកឯកភ្នំមាន៧ឃុំ ៤៩ភូមិ និង៧៤២ក្រុម[៣]។

| ឃុំពាមឯក | ឃុំព្រែកនរិន្ទ | ឃុំសំរោងក្នុង | ឃុំព្រែកខ្ពប | ឃុំព្រែកហ្លួង | ឃុំព្រៃចាស់ | ឃុំកោះជីវាំង |
|---|---|---|---|---|---|---|
| -ភូមិសួសអី<br>-ភូមិដូនទាវ<br>-ភូមិព្រែកខ្ពោរ<br>-ភូមិពាមឯក<br>-ភូមិគង់ទុំ<br>-ភូមិករហាល<br>-ភូមិតាគម<br>-ភូមិគោកដូង | -ភូមិព្រែកតាប្រែង<br>-ភូមិព្រែកក្រូច<br>-ភូមិស្វាយជ្រុំ<br>-ភូមិស្តី<br>-ភូមិរហាល់សួង<br>-ភូមិដួងមា<br>-ភូមិរាជដូនកែវ<br>-ភូមិអន្សងសក<br>-ភូមិព្រែកត្រប់<br>-ភូមិព្រែកនរិន្ទ | -ភូមិសំរោងក្នុង<br>-ភូមិសំរោងតាកុក<br>-ភូមិសំរោងអូរទ្រា<br>-ភូមិសំរោងស្នោ<br>-ភូមិកំពង់សំបួរ | -ភូមិព្រែកស្នោ<br>-ភូមិស្នាពីមុខ<br>-ភូមិខ្វិត<br>-ភូមិព្រែកខ្ពប<br>-ភូមិអូរកំបុត | -ភូមិព្រែកហ្លួង<br>-ភូមិស្តីលើ<br>-ភូមិស្តីក្រោម<br>-ភូមិបាក់អំរែក<br>-ភូមិរហាល់<br>-ភូមិដូនឥន្ទ<br>-ភូមិបាក់រទេះ | -ភូមិព្រៃចាស់<br>-ភូមិបាក់ព្រា<br>-ភូមិពាមសីហា<br>-ភូមិអន្ទង់សណ្ដាន់<br>-ភូមិកោះជីវាំង | -ភូមិថ្នាង<br>-ភូមិកំពុងប្រហុក<br>-ភូមិអន្ទង់តាអួរ<br>-ភូមិព្រែកទាល់<br>-ភូមិក្បាលតោល |

[៣] ក្រសួងមហាផ្ទៃ៖ *ចំនួនឈ្មោះខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ ភូមិទូទាំងព្រះរាជាណាចក្រកម្ពុជា* ទំព័រ ២២៨១។




ផែនទីបង្ហាញទីតាំងប្រាសាទវត្តឯកភ្នំ




រូបភាពពីលើអាកាសបង្ហាញទីតាំងប្រាសាទវត្តឯកភ្នំ (ប្រភព៖ Google Earth)

## ២.២. សណ្ឋានដីស្រុកឯកភ្នំ

ខេត្តបាត់ដំបង ផ្ទៃដីសម្រាប់កសិកម្មមានចំនួន៦៩៩.៩៤៤ហិចតា ហើយដីទាំងនោះ ត្រូវបានចែកជា៣ប្រភេទ៖

-ផ្ទៃដីសម្រាប់ស្រូវឡើងទឹកមាន ២១.២៩៥ហិចតា

-ផ្ទៃដីសម្រាប់ស្រូវស្រុកមាន ៣៨០.៧០៧ ហិចតា

-ផ្ទៃដីសម្រាប់ចំការមាន ២៩៧.៣១២ហិចតា[៤]។ ខេត្តបាត់ដំបងស្រុកដែលនៅជាប់ទំនាបបឹងទន្លេសាប មានដូចជា ស្រុកឯកភ្នំ ស្រុកមោងឫស្សី ស្រុកសង្កែ និងស្រុកថ្មគោល។

ស្រុកឯកភ្នំជាស្រុកដែលសណ្ឋានដីមានលក្ខណៈជាដីគោកផង និងលិចទឹកផង។ ដីមួយភាគជាដីគោក និងដីមួយភាគទៀតជាដីលិចទឹកនៅរដូវវស្សា ពិសេសតំបន់ដែលស្ថិតនៅជាប់មាត់បឹងទន្លេសាប។ កត្តាទាំងនេះហើយទើបយើងអាចបែងចែកដីជាពីរប្រភេទគឺ៖

(ក)-ប្រភេទដីលិចទឹក៖ជាប្រភេទដីដែលត្រូវលិចទឹកដោយសារទឹកជំនន់បឹងទន្លេសាប ស្ទឹង ព្រែក អូរ ជាដើម។ ភូមិភាគទាំងនេះគេអាចធ្វើស្រូវឡើងទឹក ឬ ស្រូវវារព្រោះភូមិភាគនេះយើងពុំអាចដាំស្រូវស្រុកបានទេ។ ស្រូវឡើងទឹកអាចធ្វើបានចាប់ពីជម្រៅទឹកពី២ម៉ែត្រដល់៤ ឬ៥ម៉ែត្រ។ ប្រភេទស្រែស្រូវវារ គេពុំត្រូវការភ្ជួរស្រែទេ ព្រោះស្រែទាំងនោះអាចធ្វើបាននៅកន្លែងណាដែលមានទឹកជ្រៅ។

(ខ)-ប្រភេទដីមិនលិចទឹក៖ ជាប្រភេទដីដែលនៅជាប់នឹងភូមិដែលប្រជាពលរដ្ឋធ្វើស្រូវ ស្រុកមានស្រូវស្រាល ស្រូវធ្ងន់ និងធ្វើចម្ការ។ ប្រជាពលរដ្ឋធ្វើកសិកម្មលើដីប្រភេទនេះ ពឹងផ្អែកលើទឹកភ្លៀង និងទឹកជំនន់ ចំណែកឯរបៀបធ្វើគឺខុសពីស្រូវវារ គឺស្រែត្រូវមានភ្ជួរខ្ទាត់ខ្វៃថែទាំជិតដល់ និងទាមទារការប្រើដី។ ដីមិនលិចទឹកសំដៅទៅលើដីដែលមិនទទួលការគំរាមកំហែងនៃទឹកទន្លេ ប៉ុន្តែមានកន្លែងខ្លះត្រូវលិចដោយទឹកទន្លេដែលមានសភាព ពក់គឺវាអំណោយផលដល់ស្រូវ ស្រុកដំណាំចម្ការ និងដំណាំឧស្សាហកម្ម។

## ២.៣. អាកាសធាតុ

ខេត្តបាត់ដំបង ក៏ដូចជាខេត្តដទៃមួយចំនួននៅប្រទេសកម្ពុជាទាំងមូលដែរ ដោយប្រទេសកម្ពុជាទទួលឥទ្ធិពលនៃខ្យល់មូសុងធ្វើឱ្យប្រទេសនាំឱ្យមានរដូវពីរច្បាស់លាស់គឺ រដូវប្រាំងពីខែវិច្ឆិកាដល់ខែមេសា និងរដូវវស្សាពីខែឧសភាដល់ខែតុលា មានលក្ខណៈអំណោយ

[៤] សក្ដានុពលនិងឱកាសវិនិយោគរបស់រដ្ឋបាលខេត្តបាត់ដំបង ឆ្នាំ២០១៨-ជ-ឯ-ម- ទំព័រ១២។

ផលដល់ដំណាំកសិកម្ម រុក្ខជាតិ និង ដំណើរកម្សាន្តរបស់ភ្ញៀវទេសចរ។ អាកាសធាតុក្តៅបំផុតនៅរដូវប្រាំងមានរហូតដល់៣៩អង្សាសេ ត្រជាក់បំផុតដល់២០អង្សាសេ ហើយអាកាសធាតុមានការប្រែប្រួលទៅតាមរដូវកាលនីមួយៗកម្ពស់ទឹកភ្លៀងជាមធ្យម ១១៨១.៤មីលីម៉ែត្រក្នុងមួយឆ្នាំ[៥]។

អាកាសធាតុនៅនៅបាត់ដំបងក៏ដូចក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលដែរ គឺមានការប្រែប្រួលទៅតាមតំបន់នីមួយៗ ហើយពុំដែលជួបប្រទះនូវរដូវរងាខ្លាំង ឬក្តៅខ្លាំងទេ។ គឺ រដូវទាំងពីរនេះធ្វើឱ្យប្រជាពលរដ្ឋចាំច្បាស់ ដើម្បីជាជំនួយក្នុងរបរកសិកម្មរបស់គេ។ នៅរដូវប្រាំងព្រះរាជាណាចក្រកម្ពុជាមានភ្ញៀវទេសចរបរទេស ធ្វើដំណើរមកទស្សនាច្រើន ព្រោះស្របពេលរដូវវិស្សមកាលនៅស្រុកគេផង។ កត្តាលក្ខណៈអាកាសធាតុល្អប្រសើរនេះ ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាពុំសូវជួបប្រទះគ្រោះរាំងស្ងួត និងទឹកជំនន់ធ្ងន់ៗជាប់គ្នា និងពុំដែលជួបប្រទះនូវខ្យល់ព្យុះ និងការធ្លាក់ទឹកកកឡើយ។ រដូវប្រាំងនៅប្រទេសកម្ពុជាចែកជាពីរគឺ ៖ រដូវក្តៅ និងរដូវរងារ។ ពួកអឺរ៉ុបអាម៉េរិក ពួកគេសប្បាយរីករាយនឹងមកលេងប្រទេសកម្ពុជា ដោយសារតែមានអាកាសធាតុល្អបំផុតសំរាប់គេ គឺមានសីតុណ្ហភាពមធ្យម២៤អង្សាសេ សន្សើមធ្លាក់នៅខែមីនា និងខែមេសា។ ភ្លៀងធ្លាក់ដំបូងនៅចុងខែមេសា ដំណាំស្រូវ និងដំណាំផ្សេងៗទៀតគេចាប់ផ្តើមដាំ។

## ២.៤. វិស័យសុខាភិបាល

សុខាភិបាលនៅស្រុកឯកភ្នំជានាបាននូវសុខមាលភាព និងសុខភាពដល់ប្រជាពលរដ្ឋគ្រប់រូប និងមានកម្មវិធីចាក់ថ្នាំបង្ការជំងឺដល់កូនចៅប្រជាពលរដ្ឋ និងចាក់ថ្នាំបង្ការជំងឺដល់សត្វពាហនៈរបស់ប្រជាពលរដ្ឋ។ នៅតាមបណ្តាឃុំមួយចំនួន គឺមានមណ្ឌលសុខភាពមួយនៅប្រចាំទីនោះ ដូចជាឃុំពាមឯក ឃុំព្រែក នរិន្ទ និងឃុំកោះជីវាំង ជាដើម។ មណ្ឌលសុខភាពទាំងនោះ បានបង្កលក្ខណៈងាយស្រួលដល់ប្រជាជនក្នុងសហគមន៍ និងភ្ញៀវទេសចរ។

សកម្មភាពសុខាភិបាលនៅស្រុកឯកភ្នំ គឺមន្ត្រីសុខាភិបាលបានចុះតាមភូមិដ្ឋានរបស់ប្រជាពលរដ្ឋ ណែនាំពីអនាម័យទឹកស្អាត ការពារជំងឺឆ្លង បំបាត់ជម្រកមូស និង សកម្មភាពណែនាំអំពីសេវាពន្យាកំណើត និង ណែនាំអំពីជំងឺឆ្លងនានាដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

[៥] សក្តានុពលនិងឱកាសវិនិយោគរបស់រដ្ឋបាលខេត្តបាត់ដំបង ឆ្នាំ២០១៨ -ជ-ឯ-ម- ទំព័រ៦។

## ២.៥. គមនាគមន៍

បណ្តាញគមនាគមន៍ពីខេត្ត ទៅរមណីយដ្ឋានប្រាសាទឯកភ្នំមានភាពល្អប្រសើរ ថ្នល់ក្រាលកៅស៊ូស្អាតល្អ ពោលគឺគេអាចធ្វើដំណើរទៅរមណីដ្ឋានដែលមានផ្លូវគមនាគមន៍ច្រើនខ្សែ គឺបង្ករភាពងាយស្រួលដល់ភ្ញៀវទេសចរ រួមផ្សំជាមួយហេដ្ឋារចនា សម្ព័ន្ធនិងបរិស្ថានដ៏ស្រស់ត្រកាលតាមដងផ្លូវ។ តាមដងផ្លូវចាប់ពីទីប្រជុំជនដូនទាវ យើងឃើញមានប្រឡាយទឹករៀបចំថ្មីចាក់បេតុងយ៉ាងស្អាតល្អ ដែលជាជំនួយថវិកាពីសាធារណរដ្ឋកូរ៉េ។ ប្រឡាយទឹកដែលរៀបចំជួសជុលថ្មីនេះ មានសារៈប្រយោជន៍សម្រាប់ប្រជាពលរដ្ឋក្នុងការយកទឹកប្រើប្រាស់បញ្ចូលស្រែនិងស្រោចដំណាំ។



រូបភាពប្រព័ន្ធប្រឡាយទឹកតាមដងផ្លូវ

## ២.៦. វិស័យសាសនា

ប្រជាពលរដ្ឋខ្មែរភាគច្រើនមានជំនឿសាសនាលើព្រះពុទ្ធសាសនា ដែលជាសាសនាមានមរតកតាំងពីបុរាណរហូតមកបច្ចុប្បន្ន ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាសាសនារបស់រដ្ឋ។ ស្រុកឯកភ្នំមានវត្ត២៤ ព្រះសង្ឃ៤២៧អង្គ ភិក្ខុ២២៤អង្គ សាមណេរ២០៣អង្គ តាជី៧៧៨នាក់ ដូនជី១៣៩នាក់ ក្មេងវត្ត១៤២នាក់ អាចារ្យ២៤នាក់ គណៈកម្មការវត្ត១៨៤នាក់។ បន្ទាប់ពីព្រះពុទ្ធសាសនាមានប្រជាជនមួយចំនួនទៀតមានជំនឿលើសាសនាគ្រិស្ត និងមូស្លីមជាដើម។ ស្រុកឯកភ្នំមានវិហារសាសនាគ្រិស្តចំនួន៣ និង វិហារមូស្លីមចំនួន១[៦]។



រូបភាពព្រះវិហារវត្តឯកភ្នំ

## ២.៧. សន្តិសុខ

ក្រោយពីការធ្វើសមាហរណកម្មរបស់រាជរដ្ឋាភិបាល យើងឃើញថាទូទាំងប្រទេសមានសន្តិសុខបរិបូរ គ្រប

---

[៦] Battambang province, Department of Planning, ***Battambang data base 1999***, p.1.

ដណ្ដាប់ទូទាំងស្រុកទាំងមូល។ រយៈពេលកន្លងមក តំបន់នេះ(ស្រុកឯកភ្នំ)តែងតែទទួលរងការយាយីពីពួកខ្មែរក្រហមធ្វើឱ្យតំបន់នេះជួបនូវអសន្តិសុខ។ រហូតសព្វថ្ងៃតំបន់នេះជានាបាននូវសន្តិសុខ សុវត្ថិភាពធ្វើឱ្យប្រជាជន និងភ្ញៀវទេសចរមានទំនុកចិត្ត និងពុំមានការព្រួយបារម្ភនូវបញ្ហាពីសន្តិសុខឡើយ។ កត្តាទាំងនេះគឺអាស្រ័យដោយការយកចិត្តទុកដាក់ពីអាជ្ញាធរខេត្ត ដោយមានការចុះបង្ក្រាបនូវរាល់បទល្មើសនានា និងការជួញដូរថ្នាំញៀនជាដើម។

## ៣. សក្ដានុពលផ្នែកវប្បធម៌និងធម្មជាតិ

ប្រាសាទឯកភ្នំដែលជាធនធានវប្បធម៌មួយយ៉ាងសំខាន់សម្រាប់វិស័យទេសចរណ៍ បន្ទាប់ពីប្រាសាទក៏មានព្រះវិហារដែលជាសំណង់បែបព្រះពុទ្ធសាសនា(វត្តឯកភ្នំ) មានក្បាច់រចនាយ៉ាងល្អវិចិត្រសម្រាប់បម្រើឱ្យវិស័យទេសចរណ៍ផងដែរ។ ប្រាសាទឯកភ្នំជាសំណង់សិល្បៈខ្មែរមួយដ៏សំខាន់កសាងក្នុងសម័យមហានគរដែលមានអាយុកាលច្រើនឆ្នាំមកហើយ។ ភាពលេចធ្លោរបស់ប្រាសាទឯកភ្នំ គឺក្បាច់ចម្លាក់ដ៏រស់រវើកដែលមាននិទានរឿងរ៉ាវផ្សេងៗទាក់ទងទេវកថានិងសាសនា។ សម្រាប់ស្រុកឯកភ្នំទាំងមូលសក្ដានុពលផ្នែកធម្មជាតិសម្រាប់បម្រើឱ្យវិស័យទេសចរណ៍ មានច្រើនប្រភេទដូចជាៈ ភូមិបណ្ដែតទឹករាប់ពាន់ខ្នង ការនេសាទព្រៃលិចទឹកនិងបន្ទាយសត្វស្លាបទឹក។ នៅទីតាំងបរិវេណប្រាសាទឯកភ្នំផ្នែកធម្មជាតិដែលទាក់ទាញមានដូចជាៈ ដើមឈើធំៗផ្ដល់ម្លប់ត្រឈឹងត្រឈៃដល់ភ្ញៀវទេសចរ និងទេសភាពវាលស្រែជាដើម។

### ៣.១. ប្រវត្តិប្រាសាទឯកភ្នំ

ប្រាសាទឯកភ្នំ ជាប្រាសាទដែលត្រូវបានកសាងក្នុងសម័យរុងរឿងនៃចក្រភពខ្មែរនាសម័យអង្គរក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (១០០២-១០៥០) ហើយសំណង់ប្រាសាទនេះស្ថិតក្នុងរចនាបថឃ្លាំង ចុងសតវត្សរ៍ទី១០និងពាក់កណ្ដាលទី១នៃសតវត្សរ៍ទី១១ គឺជាការវិវត្តន៍ពីការកសាងប្រាសាទពីឥដ្ឋមកថ្មភក់និងថ្មបាយក្រៀមវិញ។ លក្ខណៈទ្រង់ទ្រាយនៃប្រាសាទជាប្រាសាទភ្នំមានទ្រង់ទ្រាយពេញលេញ។ រូបបដិមាមានឥរិយាបទថ្មីង ទទួលឥទ្ធិពលអំពីសម័យប្រែរូបនិងបន្ទាយស្រី ប្រកបដោយទឹកមុខស្ងួតបួត។

ប្រាសាទនេះមានឈ្មោះដើមថា ព្រះស្រីនរេន្ទ្រគ្រាម (ប្រាសាទឯកភ្នំ) តួប្រាសាទសាងអំពីថ្មភក់ និងកំពែងព័ទ្ធជុំវិញប្រាសាទធ្វើអំពីថ្មបាយក្រៀម ផ្ដែរនិងហោជាងបំពាក់ទៅដោយក្បូរក្បាច់យ៉ាង

ល្អវិចិត្រព្រមទាំងមានរឿងរ៉ាវទាក់ទង ទៅនឹងទេវកថាទៀតផង។



រូបភាព ប្លង់ប្រាសាទឯកភ្នំ

### * ប្រវត្តិនៃប្រាសាទឯកភ្នំ [៧]

កាលពីយូរណាស់មកហើយ មានក្រុមជាងស្រីមួយក្រុម ប្រុសមួយក្រុមបានសន្មតគ្នាសង់ប្រាសាទមួយ ប្រណាំងគ្នា។ ក្រុមជាងប្រុសៗចាត់ចែង កសាងវត្តឯកភ្នំ ចំណែកឯក្រុមស្រីៗ កសាងប្រាសាទអង្គរវត្ត។

ក្រុមទាំងសងខាងបានណាត់គ្នា ជាមុនថា ការកសាងនេះត្រូវធ្វើតែវេលា យប់ ហើយត្រូវបញ្ចប់កិច្ចការ នៅពេល ដែលផ្កាយព្រឹករះឡើង។ ទាំងពីរក្រុម ក្រោយពីយល់ព្រមតាមពាក្យសន្មត ក៏ ចាប់ផ្ដើមកិច្ចការសំណង់។ ក្រុមស្រីៗគេ ឆ្លាតជាងពួកប្រុសៗ គេបង្ហោះគោម ហោះទៅលើអាកាសរាល់ៗយប់។ ចំណែក ពួកប្រុសៗ កាលបើបានឃើញគោម ហោះក៏នឹកស្មានថា ជាផ្កាយព្រឹកក៏ បញ្ឈប់កិច្ចការរៀងៗខ្លួនតាមការសន្មត។ ពួកស្រីៗគេនៅតែបន្តកិច្ចការរហូតដល់ ហើយជាស្ថាពរ។ ដោយដឹងខ្លួនថាចាញ់ បោកស្រីៗ ពួកប្រុសៗក៏នាំគ្នាបោះបង់ ចោលប្រាសាទ ដែលខ្លួនកំពុងសង់នោះ ចោលទៅ។ ដូច្នេះបានជាយើងឃើញ ប្រាសាទវត្តឯកភ្នំនៅមិនទាន់សង់ហើយ រហូតដល់សព្វថ្ងៃ។

ប្រាសាទឯកភ្នំមានទស្សនៈផ្សេងៗ គ្នាជាច្រើនក្នុងការឱ្យឈ្មោះប្រាសាទ នេះ។

អ្នកខ្លះថាប្រាសាទឯកភ្នំពីដើម មានឈ្មោះថា "ប្រាសាទឯក" គឺបាន សេចក្ដីថាមានតែប្រាសាទមួយគត់នៅ ក្នុងមណ្ឌលនោះ ក្រោយមកគេហៅថា "ប្រាសាទឯកភ្នំ" ។

ប្រាសាទឯកភ្នំ ជាប្រាសាទសាង ឡើងដើម្បីតម្កល់សិវលិង្គមានឈ្មោះថា "វាកកេស្វរៈ" (Vàkakeçara) ក្រោយមកគេ ហៅថា ប្រាសាទឯករហូតមកទល់ បច្ចុប្បន្នគេហៅថា ប្រាសាទឯកភ្នំ[៨]។

---

[៧] Dam Chhoeurn, *Monographie de Vat Ek Phnom*, 1970, p.29.

[៨] ប្រសាសន៍ឯ.ឧ ជុច គឿន អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។



រូបភាពប្រាសាទឯកភ្នំ

## ៣.២. លក្ខណៈប្រាសាទឯកភ្នំ

(ក)-សិលាចារឹក ៖ គ្រប់ប្រាសាទបុរាណខ្មែរដែលបានស្ថាបនាឡើងភាគច្រើនសុទ្ធតែបានចារភ្ជាប់ជាមួយនូវសិលាចារឹក ដែលបានចុះកាលបរិច្ឆេទ និយាយពីរាជស្តេច និងរឿងរ៉ាវផ្សេងៗ ដែលជាប់ពាក់ព័ន្ធទៅនឹងប្រាសាទ។ ប្រាសាទឯកភ្នំមានសិលាចារឹកមួយផ្ទាំង (K211)មាន១១បន្ទាត់ ផ្ទាំងថ្មសិលាចារឹកមានបណ្តោយ ៥២ស.ម និង ទទឹង ២៩ ស.ម បានចារនៅស៊ុមទ្វារខាងកើតនៃប្រាសាទឯកភ្នំ មានចារសិលាចារឹកភាសាខ្មែរ និងភាសាសំស្ក្រឹតនៅរហូតដល់សព្វថ្ងៃ។ សិលាចារឹកនេះបានសរសេរចុះកាលបរិច្ឆេទប្រហែលក្នុងឆ្នាំ ៩៥៩ មហាសករាជ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ក្នុងកំឡុងសតវត្សរ៍ទី១១។

សិលាចារឹកប្រាសាទឯកភ្នំមានខ្លឹមសារ ដូចតទៅ៖ ក្នុងឆ្នាំ៩៥៩ មហាសករាជ មានព្រះ vrah kamratein An Çriyogiç-vara បណ្ឌិតនៅស្រុក vnur kamdvàt វិស័យខេត្តវ្យាធបុរៈ ដែលជាអាចារ្យ ស្ថាបនករព្រះវិហារកំរតែងអញសិវលិង្គនៅឯស្រុកព្រះស្រីនរិន្ទគ្រាម បានជូនខ្ញុំមួយដែលធ្វើពីលោហធាតុ (hamira) ជូនដំបួយទឹក មួយមានមុខបួន មានជាន់បីជាន់ ជូន mukhavas មានទម្ងន់៧ជឹង (jyan) ជូនបាត ជួងមួយមានទម្ងន់២ ជឹង លិង្គ១៥ ហើយជំនូននៅស្រុកជាគ្រាម ក្នុងតំបន់អាមូខៈបុរៈមានអង្ករស៤ខ្ទាំងមានប្រេងទម្ងន់១មាឌ មានឆ័ត្រសមួយ ទង់មួយសំរាប់សិស្ស និងពួកមន្ត្រី anak sânjak ដែលមានសទ្ធាជ្រះថ្លាថែរក្សា និងអភិវឌ្ឍន៍សំណង់នេះ សូមឱ្យជាតិក្រោយបានសោយផលជាមួយព្រះកម្តែងស្រីយូគីស្វរៈបណ្ឌិត តទៅពុំអាចហៅពួកអ្នកស្រុកនៅវត្តជាគ្រាមធ្វើការងារ ពុំអាចទារបន្ទាស់ប្រេងល្ហុងខ្ទង់ ហើយសូមឱ្យផ្តល់ អំណោយជាមាសនេះឡើង ដល់ព្រះវិហារដែលបានកសាងឡើងដោយព្រះ កម្តែងអញ ស្រីយូគីស្វរៈបណ្ឌិត នៅស្រុកជាគ្រាម។

ហើយព្រះកម្តែងស្រីសូរ្យវរ្ម័នបានប្រើឱ្យមានដី ហើយសង់គោល ព្រមទាំងឱ្យខ្ញុំផងទាំងឡាយជាព្រះអំណោយដល់ស្ថាបនករ គឺដល់ព្រះកំរតេងអញស្រីយូគីស្វរៈបណ្ឌិត ដីភូមិនៅខាងកើតចូល

*រហូតដល់ស្ពុកច័ន្ទ នៅខាងត្បូង (ទក្សិណា) ជាប់ជាមួយភ្នំសករៈបព៌តនៅខាងលិច ទល់ជាមួយដីគូបនៅខាងជើង ទល់ជាមួយត្រពាំងស្វាយ។*

*+ សំស្រ្កឹត*

*អ្នកប្រាជ្ញ ព្រះព្រហ្មទេវៈ ស្រីយូគីស្វរៈបណ្ឌិត ដែលបានថ្វាយរូបបដិមាសូរ្យស្វរៈនូវទាននេះ ដែលប្រកបដោយក្បាច់រចនាព្រះគីស្វរៈ បណ្ឌិតចេះសាស្ត្រ ចេះចំណេះវិជ្ជា ចេះគម្ពីរវេទ ជាអ្នកសិក្សាវិធី សក្ការៈបូជាដល់អាទិទេពជាមហាឥសីបានត្រូវ គោរពដោយព្រះបាទសូរ្យវរ្ម័ន ដែលផ្តល់ឋានន្តរសិក្តជាអាចារ្យស្ថាបនករ[៩]។*



*សិលាចារឹកប្រាសាទឯកភ្នំ*

*(ខ)-ផ្តែរ៖ ផ្តែរទ្វារជាគ្រឿងតុបតែងលំអស្ថាបត្យកម្មមានរាងបួនជ្រុងទ្រវែង ឬ ចតុកោណកែង។ គេច្រើនយកផ្តែរទ្វារទៅលំអនៅខាងក្រៅលើច្រកចេញចូល។ នៅលើផ្តែរទ្វារនេះមានរចនាក្បាច់ជាលំអ ជួនកាលមានឆ្លាក់ជារឿងរ៉ាវផ្សេងៗដែលមានទំនាក់ទំនងទៅនឹងទេវកថា។*

**៣.៣. ក្បាច់ចម្លាក់ផ្តែរប្រាសាទឯកភ្នំ**

*តាមផ្តែរនិងហោជាងនៃប្រាសាទមានបំពាក់ទៅដោយក្បាច់រចនាយ៉ាងល្អវិចិត្រមានលក្ខណៈ រស់រវើក និងថែមទាំងមានដំណាលរឿងរ៉ាវតាមទេវកថាដូចជា៖*

*-ព្រះគ្រឹស្ណៈប្រយុទ្ធជាមួយនាគក្បាលមួយ អង្គុត់ធ្នូខ្នាក់ចេញពីមាត់រាហូលំអដោយកម្រងមែកឈើ និងរំយោលធ្លាក់ចុះមកក្រោមជារាងទម្លក់ ហើយដៃទាំងពីររបស់រាហូកាន់គល់អង្គុត់ធ្នូស្មើគ្នា។*

*-ព្រះគ្រឹស្ណៈប្រយុទ្ធជាមួយសេះកេសិន អង្គុត់ធ្នូខ្នាក់ចេញពីមាត់រាហូលំអដោយកំរងមែកឈើ ដៃទាំងពីររបស់រាហូកាន់គល់អង្គុត់ធ្នូស្មើគ្នាមានរំយោលជាកំរងមែកឈើ ធ្លាក់ចុះ ជារាង ទម្លក់នៅព័ទ្ធជុំវិញផ្តែរឿងរបស់ផ្តែរទ្វារមានស៊ុមលំអដោយក្បាច់ផ្កាភ្ញី។*

---

[៩] *សិលាចារឹកនេះត្រូវបានបកប្រែដោយបណ្ឌិតសាស្ត្រាចារ្យ ឡុងសៀម ថ្ងៃទី២១ កុម្ភៈ២០០៣។*



ផ្តែរខាងកើតរូបព្រះគ្រឹស្នៈប្រយុទ្ធជាមួយសេះកេសិន

-បង្ហាញពីរឿងកូរសមុទ្រទឹកដោះ។

-មានរូបទេពមួយអង្គឈរញែកជើងចេញពីគ្នាបន្តិច។ នៅជិតជើងស្តាំរបស់គាត់មានរូបស្រីម្នាក់ អង្គុយនៅខាងឆ្វេង និងមានរូបសេះមួយឈរដោយជើងក្រោយ។ បង្ហាញពីរឿងព្រះ គ្រឹស្នៈប្រយុទ្ធជាមួយសេះកេសិន។ ឆាកប្រយុទ្ធនេះស្ថិតនៅលើក្បាលរាហូដែលមានអង្គត់ធ្នូខ្ទាក់ចេញ នូវកម្រងមែកឈើនិងមានរំយោលធ្លាក់ចុះមកក្រោមជារាងទម្លក់។

-មានរូបព្រះសិវៈ និងរូបនាងឱមានៅលើភ្លៅខាងឆ្វេងព្រះសិវៈគង់លើគោនន្ទិន ហើយក្បាល គោងើយទៅលើសំដៅទៅឋានកៃឡាស់។

ផ្តែរនៅប្រាសាទឯកភ្នំធ្វើឡើងដោយលក្ខណៈស៊ីមេទ្រីគ្នា ហើយបង្ហាញពីភាពទុក្ខព្រួយរបស់អង្គអវតា។ ក្បាច់រចនាធ្វើឱ្យយើងមានភាពសប្បាយរីករាយ។ ក្បាច់រចនានីមួយៗបានរចនានៅលើក្បាលរបស់កាឡា ក្បាច់រចនាមានភាពរស់រវើក ទន់ភ្លន់ ធ្លាក់ដោយយកចិត្តទុកដាក់ និងប្រិតប្រៀង ។



ផ្តែរខាងជើង រូបព្រះសិវៈ និងរូបនាងឱមានៅលើភ្លៅគង់លើគោនន្ទិន

(គ)-ហោជាង ជាកន្លែងលំអយ៉ាងសំខាន់ក្នុងស្ថាបត្យកម្មខ្មែរ។ ហោជាងភាគច្រើនមានរចនាលំអតាមឆាកទេវកថាឬរឿងកថាសាសនាផ្សេងៗ។ ហោជាងជាច្រើនសង់នៅលើផ្តែរទ្វារ។

ហោជាងនៅតួប៉មទិសខាងត្បូងនៃប្រាសាទឯកភ្នំបង្ហាញពីការចាប់កំណើតរបស់ព្រះព្រហ្ម។ ក្នុងផ្ទៃនៃរឿងនេះ មានព្រះនរាយណ៍ ផ្ទុំនៅលើនាគអនន្ត។ ខាងក្រោមក្បាលនាគមានក្រពើមួយរស់នៅក្នុងទឹក។ ព្រះនរាយណ៍មានដៃបួនកាន់កេតនភ័ណ្ឌ ដូចជា “ ដំបងស័ង្ខ កងចក្រ និងដុំដី”។ នៅចុងជើងព្រះនរាយណ៍ មាន ព្រះនាងលក្ស្មី និងនាងភូមិទេវី។ នៅលើព្រះនរាយណ៍មានផ្កាឈូកដុះចេញពីផ្ចិត មានព្រះព្រហ្មអង្គុយនៅលើ។ ផ្នែកគែមនៃហោជាង

មានលំអដោយក្បាច់វល្លិ៍ឈើ ផ្នែកចុង លំអដោយនាគក្បាល៥ ដែលខ្លាក់ចេញ ពីមាត់រាហូមានដងខ្លួនដូចពស់លូន អង្កួញ៉ៗជួបគ្នានៅផ្នែកកន្ទុយ។ ចម្លាក់រឿងការកកើតរបស់ព្រះព្រហ្មនេះស្ថិតនៅចំកណ្ដាលហោជាងដែលរុំព័ទ្ធដោយកម្រងមែកឈើរាងជាត្រីកោណ។



រូបភាពស្ដីពីកំណើតព្រះព្រហ្ម

ហោជាងនៅតួប៉មកណ្ដាលនៃផ្លូវចូលខាងកើត បង្ហាញពីរឿងរាមកេរ្តិ៍ និយាយពីហនុមានត្រឡប់មកជួបនាងសីតា ដែលជាប់ឃុំឃាំងនៅក្រុងលង្កា។ នៅកណ្ដាលហោជាងនេះ មានពស់មួយរុំព័ទ្ធដើមឈើ និង សត្វកំប្រុកតូចមួយ។ នៅខាងស្ដាំនាងសីតា មានស្រ្ដីអង្គុយបញ្ឈរជង្គង់ ដៃស្ដាំច្រត់ដី និងដៃឆ្វេងទប់ក្បាលរបស់នាង។ នៅពីក្រោយនាងសីតាមានហនុមានអង្គុយលុតជង្គង់លើកដៃទៅលើសំពះ។

ហោជាងនៅទិសខាងកើត បង្ហាញពីសិវៈរាំមានដៃដប់។ អាទិទេពនេះមានសម្លៀកបំពាក់ខ្លី ផ្នត់ជំទូលាយប្រកបដោយគ្រឿងអលង្ការ។ ព្រះសិវៈរាំនៅលើជើងទ្រខាងឆ្វេងមានស្រ្ដីម្នាក់មានដៃបួនដែលដៃស្ដាំផ្នែកខាងលើមានកងចក្រ ឯដៃឆ្វេងត្រូវបាក់មើលមិនដឹងពីកាយវិការ។ ដៃពីរទៀតផ្នែកខាងក្រោមកាន់វត្ថុមួយភ្ជាប់និងដើមទ្រូង។ ចំណែកនៅខាងស្ដាំព្រះសិវៈមានរូបមនុស្សពីរផ្សេងគ្នាទៀត គឺនាងកានែកនៅខាងស្ដាំ និងនាងឱមានៅខាងឆ្វេង។

ហោជាងខាងក្នុង និងខាងក្រៅស្ថិតក្នុងសភាពខូចខាតដែលគេមិនអាចជួសជុល ឬទ្វាក់កែលំអវិញបាន អ្វីដែលនៅសេសសល់អាចឱ្យយើងដឹងថាមានភាពខុសប្លែកគ្នាពីរបែប[១០]៖(១)ជាប្រភេទលំអដោយក្បាច់ស្លឹក (២)ជាប្រភេទដែលលំអដោយក្បាច់ផ្កាផ្នែកខាងចុងនៃRam-pant យើងឃើញមានរូបក្បាលអក្ខរា។

(ឃ)-ចម្លាក់៖ ជាសិល្បៈដែលខ្មែរបុរាណ និងបច្ចុប្បន្នយកមកប្រើប្រាស់នៅរាល់ការសាងសំណង់។ ចម្លាក់មានតួនាទីសំខាន់ក្នុងការតុបតែងប្រាសាទ ឬសំណង់ផ្សេងៗដើម្បីលើកសោភ័ណថែមទៀត។

បុព្វបុរសខ្មែរជំនាន់ដើមមានភាពឧស្សាហ៍ព្យាយាមក្នុងការរចនាចម្លាក់ប្រកបដោយភាពផ្ចិតផ្ចង់ ជាហេតុធ្វើឱ្យប្រាសាទបុរាណខ្មែរសំបូរដោយចម្លាក់

[១០] Dam Chhoeun, ***Monographie de Vat Ek Phnom***, p.26-27.

និងក្បាច់រចនាផ្សេងៗ។ ក្នុងសិល្បៈខ្មែរ ចម្លាក់បុរាណមានមុខងារសំខាន់ៗពីរ ៖ ចម្លាក់សម្រាប់បូជា ដូចជា រូបបដិមាព្រះពុទ្ធ ព្រះពោធិសត្វ ព្រះឥសូ ព្រះព្រហ្ម ព្រះនារាយណ៍ ជាដើម និងចម្លាក់សំរាប់លំអ ដូចជា រូបចម្លាក់សត្វខ្លះ ចម្លាក់ក្បាច់ក្បូរផ្សេងៗឬចម្លាក់ភ្ញីផ្កា។ល។ ក្បាច់ចម្លាក់នៅប្រាសាទឯកភ្នំ គឺជាប្រភេទក្បាច់ក្រឡោតទាប។

ស្ថាបត្យកម្មផ្នែកចម្លាក់ពោរពេញទៅដោយសោភ័ណភាពធ្វើឱ្យយើងចាប់អារម្មណ៍យ៉ាងខ្លាំង ដូចដែលយើងបានឃើញប្រាសាទអង្គរវត្តនិងប្រាសាទដទៃទៀត[១១]។

ប្រាសាទឯកភ្នំ ជាប្រាសាទដែលបានស្ថាបនាឡើងដោយព្រះមហាក្សត្រខ្មែរសម័យចក្រភពអង្គរជាប្រាសាទដែលមានលក្ខណៈជាប្រាសាទភ្នំ ដែលកសាងឡើងលើទីទួលខ្ពស់ ដែលមិនមែនជាភ្នំធម្មជាតិមានខឿនរាងពីរ៉ាមីតជាថ្នាក់ៗ។

តាមធម្មតាប្រាសាទទាំងឡាយមិនត្រូវបានសាងសង់ឡើងដើម្បីជាលំនៅឋាននៃព្រះមហាក្សត្រទេ គឺសម្រាប់ជាទីសក្ការបូជាចំពោះសាសនា និងសំរាប់ឧទ្ទិសដល់មាតាបិតា និងវរជនទាំងឡាយដែលបានមរណកាលទៅហើយ។ ប្រាសាទឯកភ្នំសាងឡើងក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១(១០០២-១០៥០) ដើម្បីឧទ្ទិសព្រះឥសូរតំណាងលោកទាំងបីមាន ទេវលោក មនុស្សលោក និងបាតាលលោក[១២]។ រាល់សំណង់ប្រាសាទក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ នាសតវត្សរ៍ទី ១១ ជាសំណង់ស្ថាបត្យកម្ម ចាប់ផ្តើមឱ្យតំលៃទៅលើអ័ក្ស។ ប្រាសាទឯកភ្នំមានប្លង់រាងចតុកោណកែងបែរមុខទៅទិសខាងកើតតាមទិសអ័ក្សពីខាងកើតទៅលិច មានខឿនធ្វើអំពីថ្មភក់លាយថ្មបាយក្រៀម។

(១)-ថ្មភក់ជាប្រភេទថ្មដែលមានគុណភាពល្អជាងគេបង្អស់សម្រាប់សំណង់ប្រាសាទ និងក្បាច់ចម្លាក់ផ្សេងៗ ដូចជាតួប៉មហោត្រៃទាំងមូល ផ្តែរទ្វារ ហោជាង សសរពេជ្រ បង្អួច ។ល។

(២)-ថ្មបាយក្រៀម ជាប្រភេទថ្មម្យ៉ាងដែលកើតនៅក្នុងដី មានលក្ខណៈរូបរាងជាប្រហោង ឬរន្ធតូចៗ។ ថ្មបាយក្រៀមកើតឡើងអំពីដីឥដ្ឋ ដែលមានជាតិដែក និងបំណែកក្វាតរបស់មីកា និងមានជាតុរ៉ែថ្មនៅក្នុងនោះផងដែរ។ ជាតុទាំងនោះសំរាប់ធ្វើឱ្យវារឹង។ ថ្មបាយក្រៀមមានតួនាទីសំរាប់សំណង់ហោត្រៃនៅសតវត្សរ៍ទី១០ ដូចជា ហោត្រៃប្រាសាទមេបុណ្យខាងកើត និងហោត្រៃប្រាសាទបន្ទាយស្រី បន្ទាប់មកគេយកមកធ្វើជញ្ជាំង និងដំបូល។

[១១] Henri Mouhot, ***Travels in Siam Cambodia and Laos (1858-1860)***, p.18-19.

[១២] *របាយការណ៍ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នាយកដ្ឋានបេតិកភណ្ឌ ទំព័រ១៤៤។*

ដូច្នេះ យើងឃើញថា សំណង់ប្រាសាទឯកភ្នំ សាងឡើងពីថ្មភក់ និងថ្មបាយក្រៀម។

(ង)-សសរពេជ្រ៖ សសរពេជ្រមានតួនាទីសំខាន់ក្នុងការតុបតែងលំអក្នុងស្ថាបត្យកម្ម និងទ្រទំងន់របស់ផ្តែរ។ សសរពេជ្រមានរាងប្រាំបីជ្រុងប្រវែង ២,៣០ម៉ែត្រ ផ្នែកគល់រាងបួនជ្រុង។

(ច)-សសរផ្អោប៖ សសរនេះមានមុខងារសំរាប់លំអ និងសំរាប់ទ្រហោជាងមានរាងបួនជ្រុងទ្រវែង ដាក់បញ្ឈរនៅអមសងខាងខ្លោងទ្វារ។ សសរផ្អោបលំអទៅដោយក្បាច់ផ្កាឈូក ក្បាច់សន្ទឹកក្ងី និងក្បាច់ពងត្រី មានប្រវែង២,៩២ម៉ែត្រ។

បន្ទាប់ពីសសរពេជ្រ និងសសរផ្អោបនៅតាមបង្អួចនីមួយៗមានចំរឹងបង្អួច ធ្វើពីថ្មភក់ពណ៌ផ្កាឈូក បង្អួចនីមួយៗមានចំរឹងប្រាំប្រវែង១,២៨ម៉ែត្រ។



ចំរឹងបង្អួចប្រាសាទឯកភ្នំ

ប្រាសាទឯកភ្នំជាប្រាសាទដែលមានវ័យចំណាស់មួយ ដែលកសាងឡើងនៅពាក់កណ្តាលទី១នៃសតវត្សរ៍ទី១១ គឺស្ថិតក្នុងរចនាបថឃ្លាំង[១៣]។

សិល្បៈខ្មែរបែងចែកជារចនាបថផ្សេងៗ ដែលរចនាបថនីមួយៗនិយាយពីផ្នែកផ្សេងៗគ្នា ដូចជា ផ្នែកស្ថាបត្យកម្ម ផ្នែកការតុបតែងលំអស្ថាបត្យកម្ម និងផ្នែកបដិមាសាស្ត្រ។ ចុងសតវត្សរ៍ទី១០ និងដើមសតវត្សរ៍ទី១១ ដែលស្ថិតក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ ចាត់ចូលក្នុងរចនាបថ"រចនាបថឃ្លាំង"។ សតវត្សរ៍ទី១១ប្រាសាទភ្នំមានការវិវត្តយ៉ាងខ្លាំងចំពោះផ្នែកចុងរចនាបថវិញ គេពុំសូវឃើញមានរូបក្បាលរាហូនៅខាងចុងហោជាងទេ គឺភាគច្រើននៅសល់តែក្បាលនាគដែលខ្ជាក់រំយោល។

* ផ្តែរទ្វារ មិនសូវរស់រវើក និងឆើតឆាយដូចប្រាសាទបន្ទាយស្រីទេ ក្បាច់កណ្តាលផ្តែរភាគច្រើនរូបក្បាលរាហូ ធ្លាក់ជាស្ទឹកឈើ។ កម្រងមែកឈើធ្លាក់ស្រុតចុះកាន់តែខ្លាំង មានរាងជាទម្ពក់គល់អង្កត់ផ្ចិតខ្ជាក់ចេញពីមាត់រាហូជួនកាលមានព្រះឥន្ទ្រជិះនៅលើដំរីឰរាវ័ន្ត។



ផ្តែរព្រះឥន្ទ្រជិះនៅលើដំរីឰរាវ័ន្ត

[១៣] ត្រឹង ងា៖ អរិយធម៌ខ្មែរ ភ្នំពេញ ១៩៧៤ ទំព័រ ១១៨។

*សសរពេជ្រ មិនសូវមានរចនាខ្លាំងទេ ប៉ុន្តែច្រើនជាចម្លាក់ប្រាំបីជ្រុង ដែលគេឆ្លាក់ជាក្បាច់ប៉ោង និងក្បាច់ផតនៅតាមក្បាច់លំអទៅដោយក្បាច់សន្ទឹកឈើល្អិតៗតូចៗដូចធ្មេញរណា។

*ហោជាង ក្របហោជាងលំអដោយក្បាច់ស្លឹកឈើច្រើនជាងការបង្ហាញនូវរឿងរ៉ាវផ្សេងៗ ខាងចុងក្របទ្វារមានរូបរាហូខ្ជាក់នាគ។ ខាងចុងនៃរចនាបថនេះ រូបរាហូមិនឃើញមានទេ គេឃើញមាន រូបនាគខ្ជាក់រំយោល។

* សសរផ្អោប មានលំអដោយក្បាច់ចង្វាយ ឬក្បាច់ចម្លាក់ជាផ្កាំងដូចអក្សរវេ(Λ) ផ្កាប់។

*បដិមាសាស្ត្រច្រើនមានលក្ខណៈស្លូតបូត ស្មៀកសំពត់ផ្នត់ល្អិតៗ ជាយសំពត់លើកឡើងលើបន្តិចខ្សែក្រវាត់សំប៉ែតៗ ទេវរូបភេទប្រុស មានផ្នត់វាងដូចហោប៉ៅត្រួតគ្នា។ ទេវរូបស្រី មានជាយសំពត់រាងកន្ទុយត្រីពីខាងមុខ។ រូបចម្លាក់គោនន្ទិនមានលក្ខណៈដូចធម្មតាបូកមិនសូវធំ ជើងខាងមុខច្រត់បំរុងនឹងងើបឈរ។

បន្ទាប់ពីប្រាសាទមានបណ្ណាល័យមួយនៅទិសខាងកើតឈៀងខាងត្បូង ដែលសង់អំពីថ្មភក់ និងថ្មបាយក្រៀម[១៤]។ តួប៉មប្រាសាទកណ្ដាលសាងលើខឿនខ្ពស់បំពាក់ដោយក្បាច់រចនាល្អវិចិត្រ ដូចជាហោជាង ផ្តែរទ្វារ សសរពេជ្រ សសរផ្អោប ចម្រឹងបង្អួច ក្បាច់ស្លឹកឈើ ផ្កាឈូកក្រពុំ ពងត្រី ។ល។



រូបភាពបណ្ណាល័យនៅប្រាសាទឯកភ្នំ

ប្រាសាទឯកភ្នំជាលក្ខណៈ: ប្រាសាទភ្នំគឺតំណាងឱ្យសាសនាព្រាហ្មណ៍សំណង់ ប្រាសាទភ្នំជាសំណង់ប្រាសាទសំរាប់រាជ្យ (Temple d'État) ដែលគេសង់ជារាងពីរ៉ាមីតថ្នាក់ៗ ឱ្យមានកំពស់ដូចភ្នំធម្មជាតិ ជានិមិត្តរូបនៃភ្នំព្រះសុមេរុ និងជាទីតាំងសំរាប់តម្កល់សិវលិង្គ ហើយសំរាប់ពិធីលទ្ធិទេវរាជនៅទីនោះទៀតផង។ ប្រាសាទនេះសាងឡើងក្នុងកំឡុងឆ្នាំ១០២៧[១៥]។ កំពែងសំណង់ប្រាសាទឯកភ្នំរាងបួនជ្រុង សង់ពីថ្មបាយក្រៀម មានរាងដូចម្កុដ មានកំពស់៣ម៉ែត្រ មានប្រវែង៦០ម៉ែត្រ បើគិតពីលិចទៅកើត និង៥៦ម៉ែត្រពីជើងទៅត្បូង ផ្នែកនីមួយៗនៃមុខមានទទឹកសំរាប់ធ្វើឱ្យទឹកហូរ[១៦]។

[១៤] របាយការណ៍ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នាយកដ្ឋានបេតិកភណ្ឌ ទំព័រ១៤៥។

[១៥] ***Battambang et son passé*** 1968, p.7

[១៦] Etienne Aymonier, ***Le Cambodge,*** Paris, 1901, p.299



*រូបភាពទទឹកប្រាសាទឯកភ្នំ*

### ៣.៣. សមាសភាពសំណង់ក្នុងបរិវេណប្រាសាទឯកភ្នំ

ប្រទេសកម្ពុជាក្រោយសម័យអង្គរ គេបានផ្លាស់ប្តូរពីព្រហ្មញ្ញសាសនាទៅព្រះពុទ្ធសាសនាវិញ។ ដោយសារការផ្លាស់ប្តូរសាសនានោះ ទើបបណ្តាលឱ្យគេស្ថាបនាឡើងវិញនូវសញ្ញាណស្ថាបត្យកម្មថ្មីមួយបែបទៀត ព្រមទាំងបានកែប្រែពីប្រាសាទមកជាវត្តអារាមបែបព្រះពុទ្ធសាសនាវិញ។

ព្រះវិហារជាកន្លែងទីសក្ការៈបូជារបស់ប្រជាពលរដ្ឋ ដែលគោរពប្រតិបត្តិពុទ្ធសាសនា។ ព្រះវិហារវត្ត ឯកភ្នំមានបណ្តោយ២១ម.ទទឹង១០ម. និងបរិវេណដីវត្ត និងប្រាសាទមានបណ្តោយ៣៥០ម និងទទឹង២០០ម.។ ព្រះវិហារវត្តឯកភ្នំសង់លើដីរាបស្មើ[១៧]។ នៅលើសំណង់វិហារតុបតែងលំអដោយក្បាច់រចនាស្អេកស្កុះ លាបពណ៌ចម្រុះលាយឡំគ្នាទាំងផ្នែកខាងក្នុង និងខាងក្រៅ។ នៅតាមជញ្ជាំងខាងក្នុង និងខាងក្រៅមានផ្ទាំងគំនូរដែលនិទានទាក់ទងទៅនឹងពុទ្ធប្រវត្តិ និងតាមលក្ខណៈបែបពុទ្ធសាសនា។ សំណង់វិហារសង់ឡើងដោយយកចិត្តទុកដាក់ជាងសំណង់ផ្សេងៗទៀត ដោយបានគិតលំអិតតាំងពីខ្នាតក្បាច់ចម្លាក់ ពណ៌ចាប់តាំងពីដំបូលរហូតដល់ខឿនជាប់នឹងដី។ ជាធម្មតាព្រះវិហារគេតែងតែកសាងបែរមុខទៅទិសខាងកើតព្រោះគេយល់ថាទិសខាងកើតជាទិសដែលព្រះពុទ្ធសាមណគោតមព្រះទ្រង់ត្រាស់[១៨]។

ព្រះវិហារចាស់(វត្តឯកភ្នំ)កសាងនៅសតវត្សរ៍ទី១៨ ព.ស២៣០០គ.ស ១៧៥៧ តែត្រូវខូចខាត ដោយចាស់ទ្រុឌទ្រោម និងត្រូវបំផ្លាញក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ចំណែកវិហារថ្មីសព្វថ្ងៃចាប់ផ្តើមកសាងពីឆ្នាំ១៩៩១-២០០១ ដោយពុទ្ធបរិស័ទក្នុងនិងក្រៅប្រទេស អស់ទឹកប្រាក់សរុប១៦៥.២៩៩ ដុល្លារអាម៉េរិក។ ខ្លោងទ្វារវិហារវត្តឯកភ្នំមានភាពស្រស់ស្អាតចម្លងតាមក្បាច់ចម្លាក់ប្រាសាទបន្ទាយស្រី[១៩]។ ក្នុងបរិវេណវិហារ មានសាលាឆាន់បីសំរាប់ប្រារព្ធពិធីបុណ្យទានផ្សេងៗ។ កុដិព្រះសង្ឃ មានកុដិធំៗចំនួន១០កុដិ និងកុដិតូចៗចំនួន៣ធ្វើអំពីឈើប្រក់ក្បឿង និងធ្វើពីឥដ្ឋប្រក់ក្បឿង។ កុដិយាយជីមានលក្ខណៈជាខ្ទម ធ្វើពីឈើប្រក់ស្លឹកមានយាយជី

[១៧] Henri Mouhot, *Travels in Siam Cambodia and Laos (1858-1860)*, p. 18

[១៨] *ក្បួនខ្នាតខ្លះៗនៃសំណង់ក្នុងបរិវេណអារាម* ២០០១ ទំព័រ ១៣។

[១៩] *ទស្សនាវដ្តី កល្យាណ* ២០០១។

ចំនួន៧នាក់ និងតាជី៥នាក់។ ចេតិយមានចំនួន៧នៅជុំវិញវិហារមានចំនួន៤ និងចេតិយតូចមានខាងក្នុងបរិវេណព្រះវិហារចំនួន៣សំរាប់អដ្ឋិធាតុ ហើយក៏មានម៉ុងចិនដែរ និងមានឈាបនដ្ឋានមួយដែលមានលក្ខណៈតូចៗ បណ្ណាល័យសំរាប់ដាក់សៀវភៅធម៌មួយ សាលាសំណាក់ពីរនៅជ្រុងឦសាន្តមួយ និងខាងកើតមួយ។ វិហារវត្តឯកភ្នំមានព្រះសង្ឃ៣២អង្គ ភិក្ខុ១៥អង្គ និងសាមណេ១៧អង្គ ឧបាសក៥នាក់ និងឧបាសិកា៧នាក់ ព្រមទាំងពុទ្ធបរិស័ទនៅជុំវិញវិហារដែលមកសុំសីលនិង ប្រារព្ធពិធីបុណ្យទានផ្សេងៗ។ ក្នុងបរិវេណវិហារមានសាលារបស់អង្គការមួយ គឺ អង្គការ (UNESCO) ដែលជួយបង្រៀនកូនចៅប្រជាពលរដ្ឋនៅតំបន់នោះឱ្យមានចំណេះវិជ្ជា ដូចជាវិជ្ជាកាត់ដេរ និងវិជ្ជាជីវៈផ្សេងៗទៀត។ នៅជិតប្រាសាទឯកភ្នំមានសាលាបឋមសិក្សាមួយគឺ សាលាបឋមសិក្សាឯកភ្នំ។ ជារួមស្រុកឯកភ្នំមានសាលាចំនួន៦៣ ថ្នាក់រៀន៤៣៣ មានសិស្សសរុបចំនួន១៤០៨៤នាក់ និងគ្រូសរុបចំនួន៥៧៥នាក់ ស្រី៣៣៧នាក់។ នៅខាងកើតព្រះវិហារ មានខ្ទមអ្នកតាមួយដែលប្រជាពលរដ្ឋស្រុកឯកភ្នំមានជំនឿលើអ្នកតា ដែលជាប្រពៃណីពីបុរាណរបស់ខ្មែរ។

**៣.៤. ទីធ្លាប្រាសាទឯកភ្នំ**

ទីធ្លាប្រាសាទឯកភ្នំមានលក្ខណៈធំទូលាយ ងាយស្រួលផ្ទុករថយន្ត និងមធ្យោបាយ ផ្សេងៗរបស់ភ្ញៀវដែលមកទស្សនានៅទីនេះ។ នៅជុំវិញខឿនវិហារមានដាំផ្កាចំរុះពណ៌ ដើម្បីលំអព្រះវិហារ។

ចំណែកនៅជុំវិញប្រាសាទមានដើមឈើធំៗ ផ្តល់នូវម្លប់ត្រឈឹងត្រឈៃ ដូចជាដើមច័ន្ទ ពោធិ៍ ដូង ទឹកដោះគោ ស្វាយ អំពិល ត្នោត ពោធិព្រឹក្ស ស្តៅ ។ល។ ប្រភេទដើមឈើទាំងនេះ ជាប្រភពផ្តល់នូវម្លប់ដល់ដំណើរ ទស្សនាកំសាន្តរបស់ភ្ញៀវទេសចរ។

**៣.៥. គូទឹក**

គូទឹកនៃប្រាសាទឯកភ្នំ មានរាងជាចតុកោណកែង ដោយមានច្រកចេញចូលនៅខាងកើត និងខាងលិច។ រាល់សមិទ្ធិដែលសាងឡើងក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ យើងតែងសង្កេតឃើញមានគូទឹកនៅជាប់ប្រាសាទ។ គូទឹកទាំងនោះមានទំហំធំល្មមមិនធំពេកទេ។ ទឹកថ្លាត្រជាក់ល្អសំរាប់ ប្រើប្រាស់ក្នុងវត្ត ក្នុងទឹកមានចក ដើមឈូក ស្មៅដុះលើទឹក។ រហូតមកដល់បច្ចុប្បន្ន គូទឹកនេះមានសភាពរាក់ ដោយយើងពុំបានស្តារដីបាតស្រះ ហើយក្នុងទឹកមានត្រី...។ ស្រះទឹក (គូទឹក) ប្រាសាទឯកភ្នំពីលិចទៅកើតមានប្រវែង៤០០ម៉ែត្រ និងពីជើងទៅត្បូងមានប្រវែង២០០ម៉ែត្រ។

## ៤. សេវាកម្មទេសចរណ៍

ទេសចរណ៍ គឺជាវិស័យមួយដែលមានសក្តានុពលល្អបំផុតសំរាប់កំណើនសេដ្ឋកិច្ចជាតិ រមណីយដ្ឋានប្រាសាទឯកភ្នំ ជាតំបន់ទេសចរណ៍អាចនាំមកនូវការងារ និងចំណូលឱ្យបានដល់តំបន់ជនបទដាច់ស្រយាល។ សព្វថ្ងៃប្រាសាទឯកភ្នំកំពុងមានការចាប់អារម្មណ៍យ៉ាងខ្លាំងសម្រាប់ផ្នែកទេសចរណ៍វប្បធម៌។ រមណីយដ្ឋានប្រាសាទឯកភ្នំមានកន្លែងជាច្រើនសំរាប់បម្រើឱ្យវិស័យទេសចរណ៍ ដូចជាប្រាសាទឯកភ្នំ វិហារវត្តឯកភ្នំ ទេសភាពវាលស្រែសំរាប់កសិកម្មដ៏ស្រស់ត្រកាល ដំណាំកសិកម្មភូមិរបស់ប្រជាពលរដ្ឋ កន្លែងធ្វើសំបកណែមជាដើម។ សព្វថ្ងៃប្រាសាទឯកភ្នំមានភ្ញៀវទេសចរអន្តរជាតិទៅទស្សនារៀងរាល់ថ្ងៃ ជាមធ្យមមានភ្ញៀវទេសចរជាតិមកទស្សនាពី៨ទៅ១០នាក់ និងភ្ញៀវទេសចរអន្តរជាតិពី៧ទៅ៨នាក់។ នៅថ្ងៃបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ រមណីយដ្ឋានប្រាសាទឯកភ្នំមានប្រជាពលរដ្ឋទៅទស្សនាច្រើន គណៈកម្មការអាចារ្យវត្តបានបង្កើតកម្មវិធីលែងល្បែងប្រជាប្រិយជាច្រើនមុខ ដើម្បីឱ្យកម្មវិធីកាន់តែអធិកអធម។ រាល់ថ្ងៃបុណ្យឆ្នាំខ្មែរ តាមដងផ្លូវចាប់ពីទីប្រជុំជនផ្សារដូនទាវ មានមនុស្សច្រើនកុះករ បណ្តាលឱ្យស្ទះចរាចរណ៍ថែមទៀតពេលនោះ យុវជននិងយុវតីបង្ករភាពសប្បាយរីករាយក្នុងការលេងបាចទឹកនិងលាបម្សៅ។



រូបភាពសិប្បកម្មសំបកណែម

## សន្និដ្ឋាន

រមណីយដ្ឋានឯកភ្នំជាកន្លែងកម្សាន្ត ដ៏ស្រស់ត្រកាល និងទាក់ទាញភ្ញៀវទេសចរដែលស្ថិតនៅក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង និងជារមណីយដ្ឋានដែលយើងត្រូវបន្តយកចិត្តទុកដាក់រៀបចំឱ្យមានសោភ័ណភាព សណ្តាប់ធ្នាប់ឱ្យបានល្អព្រោះរមណីយដ្ឋាននេះជាកន្លែង កំសាន្តដ៏សំខាន់របស់ខេត្ត។ យោងទៅលើការសិក្សាស្រាវជ្រាវកត្តាដែលជំរុញឱ្យភ្ញៀវទេសចរមកទស្សនា ដោយសារតំបន់ឯកភ្នំ មានធនធានសក្តានុពលសំរាប់ទាក់ទាញភ្ញៀវទេសចរ គឺផ្នែកវប្បធម៌ប្រវត្តិសាស្ត្រ និងធម្មជាតិ។ ដោយសារលក្ខណៈអំណោយផលពីធម្មជាតិ និងកេរដំណែលប្រវត្តិសាស្ត្របែបនេះ ទើបជំរុញឱ្យមានការរៀបចំអភិវឌ្ឍន៍នៅតំបន់ទាំងនោះ។

ទន្ទឹមនេះដែរ យើងអាចចាត់ទុកវិស័យទេសចរណ៍ ជាចក្ខុវិស័យសេដ្ឋកិច្ចដ៏មានប្រជា ប្រិយភាពនាំមកនូវចំណូលច្រើនសន្ធឹកសន្ធាប់ ទាំងចំណូលផ្ទាល់ និងចំណូលដោយមិនផ្ទាល់។

ពេលអនាគត រមណីយដ្ឋានឯកភ្នំពិតជាកន្លែងកំសាន្ត មួយទាក់ទាញភ្ញៀវទេសចរនិងថែមទាំងធ្វើឱ្យអ្នកទាំងនោះចាប់អារម្មណ៍ទៅលើរមណីយដ្ឋាននេះកាន់តែខ្លាំង ធ្វើឱ្យវិស័យទេសចរណ៍នៅខេត្តបាត់ដំបង ក៏ដូចជាមណ្ឌលឯកភ្នំមានភាពរីកចំរើននិងថែមទាំងធ្វើឱ្យរមណីយដ្ឋានដ៏ស្រស់ត្រកាលនេះ និងជាកន្លែងកម្សាន្តដ៏សប្បាយរីករាយសម្រាប់អ្នកទេសចរ ហើយរមណីយដ្ឋាននេះនឹងជួយលើកស្ទួយសេដ្ឋកិច្ចជាតិ ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជននៅក្នុងស្រុកឯកភ្នំទាំងមូល។

## គន្ថនិទ្ទេស


១-សាលាខេត្តបាត់ដំបង"របាយការណ៍បូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០០២ របស់ខេត្តបាត់ដំបង"

២-ក្រសួងមហាផ្ទៃ"ចំនួនឈ្មោះខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ ភូមិ ទូទាំងព្រះរាជាណាចក្រកម្ពុជា ៣០ មេសា ២០០១

៣-ខេត្តបាត់ដំបង " ផែនការអភិវឌ្ឍខេត្ត៥ឆ្នាំ ២០០១-២០០៥" កក្កដា ២០០០

៤-ខេត្តបាត់ដំបង "ផែនការវិនិយោគសំរាប់អភិវឌ្ឍន៍ខេត្តបីឆ្នាំ ២០០២-២០០៤" សីហា ២០០១

៥-ខេត្តបាត់ដំបង " ទិន្នន័យមូលដ្ឋាន ឆ្នាំ២០០០" ធ្នូ ២០០០

៦-ឡុង សៀម "ស្ថាននាមវិទ្យាខ្មែរ" ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស.២៥៤១ គ.ស ១៩៩៧

៧-ម. ត្រាណេ " ប្រវត្តិសាស្ត្រកម្ពុជាពីបុព្វសម័យដល់សតវត្សទី៨" ១៩៩៦

៨-ត្រឹង ង៉ា " ប្រវត្តិសាស្ត្រខ្មែរ" ភ្នំពេញ ១៩៧៣

៩-លោកស្រី ត្រឹង ង៉ា " អរិយធម៌ខ្មែរ" បោះពុម្ពលើកទី៣ ភ្នំពេញ ១៩៧៤

១០-តូច ឈួង " បាត់ដំបងសម័យលោកម្ចាស់" ១៩៧៤

១១-Aymonier Etienne, Le Cambodge, ernest leroux éditeur, Paris, 1901

១២-Chandler David P., The land and people of Ccambodia, Harper Collins Publisher, Jacket, 1991

១៣-Chanton De Médouard, Le tour du mondes, 1863

១៤-Delaprte L., Voyage au Cambodge, Librairie Ch. delagrave, Paris, 1880

១៥-Dam Chhœum, Monographie de Vat Ek Phnom,

១៦-Le Ministère de l'Information, Battambang et son passé, Phnom Penh, 1968

# តម្លៃនៃជីវិតរបស់មនុស្ស

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋាននីតិសាស្ត្រ ,វិទ្យាស្ថាន*
*មនុសាស្ត្រនិងវិទ្យាសង្គម,រាជបណ្ឌិត្យសភាកម្ពុជា*

*ភាពឧត្តុង្គឧត្តមរបស់មនុស្សបានមកពីការស្គាល់តម្លៃខ្លួនឯង និងតម្លៃរបស់អ្នកដែលរស់នៅជុំវិញខ្លួនហើយតម្លៃនោះមាននៅក្នុងជម្រៅចិត្តគំនិតរបស់បុគ្គលម្នាក់ៗ។ តម្លៃធំបំផុតរបស់មនុស្សគឺជីវិតរស់នៅ ប៉ុន្តែនៅក្នុងជីវិតរស់នៅ មនុស្សត្រូវរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ កិត្តិយស និងភាពសុខដុមរមនាក្នុងឧត្តមភាពនៃមនុស្ស ពិសេសគឺប្រកបដោយគុណធម៌។*

*ដើម្បីទទួលបាននូវភាពសុខសាន្តភាពសុខដុមរមនានៃជីវិតនោះ មនុស្សចាំបាច់ត្រូវតែប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវសីលធម៌ ព្រហ្មវិហារធម៌ សច្ចធម៌ អហិង្សាធម៌ ខន្តីធម៌ សុចរិតធម៌ សាមគ្គីធម៌ សុជីវធម៌ សង្គហធម៌ និងទសពិធរាជធម៌។*

## ១. សីលធម៌

### ១.១.និយមន័យសីលធម៌

*សីលធម៌ គឺជាធម៌របស់មនុស្សដែលមនុស្សគ្រប់រូបត្រូវតែប្រកាន់ឱ្យខ្ជាប់ខ្ជួនជាប្រក្រតី។ ការសិក្សាពីសីលធម៌ គឺជាការសិក្សាអប់រំចិត្តដែលបង្កើតឡើងក្នុងគោលបំណងឱ្យមនុស្សចេះអត់ឱន អធ្យាស្រ័យ មិនប្រកាន់ពូជសាសន៍ និងមិនរំលោភសិទ្ធិអ្នកដទៃជាដើម។ សីលធម៌បានជួយដល់មនុស្សយើងឱ្យចេះដឹងនូវអ្វីល្អអាក្រក់ ខ្ពស់ទាប ខ្មៅ សនិងចេះស្គាល់បាបបុណ្យ។ កត្តាសំខាន់នោះធ្វើឱ្យមនុស្សយើងហ៊ានទទួលខុសត្រូវនូវអ្វីដែលខ្លួនបានប្រព្រឹត្ត។*

*ជាក់ស្តែងនៅក្នុងសង្គមបច្ចុប្បន្នទង្វើខុសឆ្គងរបស់មនុស្សមានច្រើនណាស់ ប៉ុន្តែមានមនុស្សមួយចំនួនពុំព្រមទទួលសារភាពកំហុសរបស់ខ្លួនទេ ថែមទាំងបញ្ចេញសំដីនិងឫកពាមិនសមរម្យទៅលើមនុស្សដែលត្រឹមត្រូវ។ អាកប្បកិរិយាបែបនេះ គឺជាទង្វើដែលអសីលធម៌ចំពោះមនុស្សត្រឹមត្រូវ។ ការអត់ឱនលើកលែងមិនប្រកាន់ទៅលើកំហុសអ្នកដទៃទើបអាចក្លាយជាបុគ្គលមានការអធ្យាស្រ័យនិងការសន្តោសប្រណីបាន។*

**១.២.មូលដ្ឋានគ្រឹះនៃសីលធម៌**

*មូលដ្ឋានគ្រឹះនៃសីលធម៌ គឺនិច្ចសីល ឬបញ្ចសីលដែលមនុស្សគ្រប់រូបត្រូវប្រតិបត្តិជាអចិន្ត្រៃយ៍។*

*បញ្ចសីលឬសីល៥ គឺមាន៥ចំណុច ៖*

*-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ : ប្រែថា ៖ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើនូវសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។*

*-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ : ប្រែថា ៖ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុដែលគេមិនបានឱ្យ ដោយកាយឬដោយវាចា។*

*-កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ : ប្រែថា ៖ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។*

*-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ : ប្រែថា ៖ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។*

*-សុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណី សិក្ខាបទំ សមាទិយាមិ : ប្រែថា ៖ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាជាទីតាំងនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ។*

**១.៣.ប្រភេទសីលធម៌**

*សីលធម៌មានការបែងចែកជាច្រើនប្រភេទផ្សេងៗគ្នាដូចជា :*

*-សីលធម៌ផ្ទាល់ខ្លួន*

*-សីលធម៌ក្នុងគ្រួសារ*

*-សីលធម៌ក្នុងវិជ្ជាជីវៈ*

*-សីលធម៌ក្នុងសង្គម។*

***ក-សីលធម៌ផ្ទាល់ខ្លួន***

*-ដឹងខុសត្រូវ*

*-ស្គាល់ល្អស្គាល់អាក្រក់*

*-តាំងខ្លួនជាម្ចាស់ចិត្តរបស់ខ្លួន*

*-ទទួលខុសត្រូវនឹងអំពើរបស់ខ្លួន*

*-ក្លាហានក្នុងផ្លូវត្រូវ។*

***ខ-សីលធម៌ក្នុងគ្រួសារ***

*-ម្តាយឪពុកចិញ្ចឹមកូនដោយពុំនឹកគិតដល់ការសងគុណតបមកវិញ*

*-ធ្វើឱ្យមានភាពស្មើៗគ្នា*

*-រៀបចំកូនឱ្យបានក្លាយទៅជាពលរដ្ឋល្អ*

*-អប់រំនិងហាមឃាត់កូនមិនឱ្យប្រព្រឹត្តអំពើអាក្រក់។*

***គ-សីលធម៌ក្នុងវិជ្ជាជីវៈ***

*-មានមនសិការការងារក្នុងវិជ្ជាជីវៈរបស់ខ្លួន*

*-ធ្វើការតាមសមត្ថភាពនិងសម្មាជីវោ*

*-មិនរំលោភបំពាន ឬបៀតបៀនអ្នកដទៃ*

-មិនធ្វើការហួសកម្លាំងដែលនាំឱ្យប៉ះពាល់ដល់សុខភាព

-មិនយកអំណាច ឥទ្ធិពល ឬជំនាញរបស់ខ្លួនប្រើប្រាស់ក្នុងផ្លូវអបាយមុខ។

**ឃ-សីលធម៌ក្នុងសង្គម**

-មិនញុះញង់បំបែកបំបាក់សាមគ្គីភាព

-ស្រលាញ់យុត្តិធម៌សង្គម

-រាប់អានមនុស្សទូទៅដោយមិនមានការរើសអើងព័ណ៌សម្បុរ ឬជាតិសាសន៍

-ទទួលស្គាល់ទុក្ខវេទនារបស់អ្នកដទៃដោយមិនមើលងាយមនុស្សផងគ្នា

-មិនឈ្លានពានបូរណភាពបុគ្គល និង សង្គម។

## ២. ព្រហ្មវិហារធម៌

### ២.១.និយមន័យព្រហ្មវិហារធម៌

ព្រហ្មវិហារធម៌ជាធម៌ក្រាលចិត្តឱ្យមនុស្សចេះសន្ដោសប្រោសប្រណីចំពោះមនុស្ស សត្វដោយគ្មានការរើសអើងគឺជាធម៌ប្រតិបត្តិដើម្បីឱ្យមនុស្សរស់នៅបានប្រសើរ និងជាធម៌ប្រកបដោយវិមលភាពក្នុងការជំរុញមនុស្សឱ្យចេះសាមគ្គីគ្នានិងជំរុញឱ្យមានភាពសុខក្សេមក្សាន្តក្នុងគ្រួសារក៏ដូចជាសង្គម។

### ២.២.ធាតុនៃព្រហ្មវិហារធម៌

តាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាពិសេសនៅសម័យអង្គរ បុព្វបុរសខ្មែរបានស្ថាបនាបូជនីយដ្ឋានធំៗជាច្រើនដែលបានសង់ឡើងអំពីថ្មមានកំពូលខ្ពស់ស្កឹមស្កៃនិងមានទំហំបរិវេណច្រើនគីឡូម៉ែត្រ។ ក្នុងចំណោមប្រាសាទទាំងនោះ ប្រាសាទអង្គរធំជាប្រាសាទដ៏ល្បីល្បាញមួយក្នុងចំណោមប្រាសាទជាច្រើនដែលគេបានកសាងព្រះសិរព្រះព្រហ្មមានព្រះភក្ត្របួន។ ព្រះភក្ត្រទាំងបួននេះបែរទៅរកទិសទាំង៤ដែលជាតំណាងឱ្យព្រហ្មវិហារធម៌ទាំង៤នោះគឺ មេត្តា ករុណា មុទិតា និងឧបេក្ខា[១]។

**ក-មេត្តាធម៌**

-ការមានចិត្តស្រឡាញ់រាប់អានអ្នកដទៃក្នុងសង្គមដោយការគ្មានការរើសអើង និងប្រកបទៅដោយការបើកចិត្តឱ្យទូលាយ និងសន្ដានចិត្តកក្តី។

-មេត្តាជាថាមពលនៃធម៌ដែលមានអានុភាពបំផុត អាចផ្សព្វផ្សាយដោយគ្មានការរើសអើងទៅកាន់បុគ្គលដែលជាទីស្រឡាញ់របស់យើង ឬអ្នកដទៃដោយមិនមែនជាក្រុមញាតិមិត្ត ឬទៅកាន់បច្ចាមិត្រទៀតផង។

-មេត្តាមានន័យថា ស្និទ្ធស្នាល ការប្រតិបត្តិប្រកបដោយមេត្តា គឺសត្រូវទាំងអស់ប្រែត្រឡប់មកជាមិត្ត មិនអាចស្អប់ និងចងពៀរវេរាជាមួយយើងបានយូរឡើយ។

---

[១] សាកលវិទ្យាល័យបៀលប្រាយ ៖ សិល្បៈនៃការរស់នៅ គ. ស. ២០១២ ទំព័រ៣

### ខ-ករុណាធម៌

-ធម៌ករុណា គឺការមានចិត្តអាណិតអាសូរដោយគ្មានការច្រណែនឈ្នានីសយកត្រូវតែខ្លួនឯងមើលឃើញតែកំហុសរបស់អ្នកដទៃ។

-ការអាណិតអាសូរចំពោះមនុស្សទាំងអស់ ដែលទទួលរងទុក្ខលំបាកវេទនាផ្សេងៗ ដោយចង់ឱ្យពួកគេរួចផុតពីទុក្ខទាំងនោះទទួលបាននូវសេចក្តីសុខដូចខ្លួន។

-មនុស្សត្រូវចេះជួយគ្នានៅក្នុងគ្រាដែលមានអាសន្នអន្តរាយក្រទោះជាកើតឡើងដោយសារសង្គ្រាមក្តីកើតឡើងដោយគ្រោះធម្មជាតិក្តី។ ពិសេសគឺធម៌ករុណានេះនឹងនាំមនុស្សឱ្យចេះធ្វើការបរិច្ចាគ ហើយបញ្ឈប់នូវការគាបសង្កត់ការរំលោភគ្រប់បែបយ៉ាង។

### គ-មុទិតាធម៌

ធម៌មុទិតា គឺជាកម្រងធម៌ឬក្រមធម៌ដែលជំរុញឱ្យមនុស្សមានចិត្តទន់ភ្លន់ មិនសាហាវព្រៃផ្សៃ ពិសេស គឺមានចិត្តអបអរសាទរចំពោះសេចក្តីសុខចម្រើនរបស់អ្នកដទៃ ដោយពុំរើសមុខ និងចង់ឱ្យពួកគេទទួលបាននូវសេចក្តីសុខ សុវត្ថិភាព ដោយគ្មានការច្រណែនឈ្នានីសនោះទេ។

### ឃ-ឧបេក្ខាធម៌

-ធម៌ឧបេក្ខា គឺជាធម៌មួយដែលធ្វើឱ្យមនុស្សតាំងចិត្តជាកណ្តាលមិនលំអៀងទៅខាងណាពោលគឺការតាំងចិត្តជាអព្យាក្រឹត។

-មិនមានចិត្តត្រេកអរហួសប្រមាណ មិនមានសេចក្តីខឹងក្រេវក្រោធចំពោះអ្នកដទៃ។ បំណងសំខាន់ គឺចង់ឱ្យពួកគេរស់នៅតាមលទ្ធភាព សមត្ថភាព និងសេរីភាពរបស់ពួកគេ។

-គ្មានចិត្តលោភលន់ ឬព្រួយកង្វល់ចំពោះអ្នកជិតខាងដែលគេមានទ្រព្យសម្បត្តិច្រើនជាងខ្លួននោះទេ។

-ជាធម្មតាមនុស្សតែងតែមានសេចក្តីលោភលន់ចង់មានចង់បានមិនចេះស្កប់ស្កល់ហើយមើលឃើញអ្នកដទៃមិនល្អ មិនត្រូវ ដោយផ្អែកទៅលើទស្សនៈរបស់ខ្លួន បើគេមានជាងខ្លួន ធ្វើឱ្យមានការច្រណែនឈ្នានីសជាដើម។ ដើម្បីជៀសវាងបាននូវលក្ខណៈខាងលើនេះ មនុស្សគប្បីប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវព្រហ្មវិហារធម៌នេះព្រោះវាជាប្រភព ឬជាមពលជំរុញឱ្យសង្គមមានស្ថេរភាព សន្តិភាព និងវឌ្ឍនភាព។

## ៣. សច្ចធម៌

### ៣.១.និយមន័យសច្ចធម៌

-សច្ចៈ គឺជាសេចក្តីពិត ដំណើរទៀងទាត់ ដំណើរទៀងត្រង់ ការពិតប្រាកដមែន។

-ធម៌ឬធម្មៈជាសភាវៈទ្រទ្រង់សត្វលោក គឺបុណ្យ សុចរិត ហេតុសភាពការណ៍រីកចម្រើន ការរិះគន់ ការប្រៀនប្រដៅ និងអ្វីៗដែលទ្រទ្រង់ធ្វើឱ្យស្ថិតស្ថេរ ជាដំបូន្មាន

ផ្តល់ឱ្យមនុស្សក្នុងការរំដោះខ្លួន ចេញពីទុក្ខ ដើម្បីលើកស្ទួយតម្លៃមនុស្ស។

ដូច្នេះសច្ចធម៌សំដៅទៅលើគុណភាពពិតប្រាកដមិនក្លែងបន្លំ ទៀងត្រង់ពិតប្រាកដ មិនលម្អៀងអ្វីៗដែលប្រាកដមែនមិនក្លែងកុហក។ សច្ចធម៌ជាបញ្ញត្តិមួយយ៉ាងល្បីល្បាញ ដែលបានសង្ខេបខ្លឹមសារនៃពុទ្ធលទ្ធិតាំងពីលទ្ធិសាសនានេះបានចាប់កំណើតមកម៉្លេះ និងជាធម៌អះអាងពីអ្វីៗដែលមានពិត ឬសច្ចៈ និងអះអាងពីអ្វីៗដែលត្រូវហាមមិនឱ្យប្រព្រឹត្ត។ ការពិតតាមពុទ្ធលទ្ធិ ជាការពិតដែលមានការគិតសមហេតុផល និងមានប្រត្យក្សភាព។

## ៣.២.ទស្សនៈផ្សេងៗស្តីពីសច្ចធម៌

### ក-សច្ចធម៌ក្នុងព្រះពុទ្ធសាសនា

-សច្ចធម៌របស់ព្រះពុទ្ធសាសនា ខុសពីពាហិរសាសនាផ្សេងៗដែលឱ្យតម្លៃនៃសច្ចភាពទៅលើការកំណត់របស់អាទិទេពនោះ ហើយទ្រឹស្តីបែបសច្ចៈដែលសំខាន់ គឺ អរិយសច្ចៈទាំងបួន។

-ទុក្ខអរិយសច្ចៈ គឺជាសេចក្តីពិតដែលកើតមានឡើងចំពោះមនុស្សគ្រប់រូបដែលមិនអាចមាននរណាម្នាក់គេចវេសបាន ឬ ចៀសវាងពីសេចក្តីទុក្ខនោះបានឡើយ។

-សមុទយអរិយសច្ចៈគឺជាសេចក្តីពិតដែលមានកើតឡើងបណ្តាលកមពីហេតុពិតប្រាកដ ហេតុដែលនាំឱ្យមនុស្សកើតទុក្ខនោះ គឺ អវិជ្ជានិងតណ្ហា។

-និរោធអរិយសច្ចៈ ពិតជាមានហេតុដែលនាំឱ្យកើត វាជាការពិតណាស់ ប៉ុន្តែសេចក្តីទុក្ខនេះពិតជាមានមធ្យោបាយ ឬវិធីទប់ស្កាត់វា ឬរំលាយវាបានពិតប្រាកដមែនក្នុងករណីណាដែលគេកាត់បន្ថយឬរំលត់ឱ្យបាននូវលោភៈ ទោសៈ មោហៈ នោះសេចក្តីទុក្ខក៏ត្រូវបានបញ្ចប់ផងដែរ។

-មគ្គអរិយសច្ចៈគឺជាមាគ៌ានៃការរំលត់ទុក្ខមានពិតប្រាកដមែន។ ទុក្ខអាចរំលត់បានតាមរយៈផ្លូវទាំងប្រាំបីរបស់ព្រះពុទ្ធ ដែលផ្លូវទាំង៨នោះ ចែកចេញជាបីក្រុម គឺ សីល សមាធិ និងបញ្ញា។

### ខ-សច្ចធម៌ក្នុងពាហិរសាសនា

ក្រុមពាហិរសាសនាអះអាងថា សច្ចធម៌ស្ថិតនៅលើព្រះអាទិទេព ដែលបានកំណត់ផ្លូវឱ្យមនុស្សគោរព។ សាសនិកម្នាក់ៗនៃសាសនានីមួយៗតែងតែមានជំនឿយ៉ាងមុតមាំទៅលើព្រះរបស់ខ្លួន ហើយមាគ៌ារបស់ព្រះបានបង្ហាញធម៌ប្រកបដោយភាពសច្ចៈ។ហេតុនេះហើយទើបគេឃើញសាសនិកទាំងនោះខិតខំគោរពប្រតិបត្តិដើម្បីបានជួបព្រះដែលជាតួអង្គប្រកាន់សច្ចធម៌ពិតប្រាកដ។

### គ-សច្ចធម៌របស់សូក្រាត

ទស្សនៈរបស់លោកសូក្រាត គឺសច្ចធម៌ពិតដោយលោកសុខចិត្តលះបង់ជីវិតប្រសើជាងការបាត់បង់នូវសេចក្តីពិតទៀងត្រង់។ សច្ចធម៌របស់លោកផ្អែកទៅលើគំនិត " ត្រូវស្គាល់ខ្លួនឯងដោយខ្លួនឯង"។បើយើង

ស្គាល់ខ្លួនយើងច្បាស់ យើងមិនងាយប្រព្រឹត្តខុសនោះទេ។ ការស្គាល់ខ្លួនឯងធ្វើឱ្យមនុស្សចេះទទួលខុសត្រូវនិងចេះអៀនខ្មាសចំពោះអំពើអាក្រក់ អំពើអសីលធម៌ ហើយមនុស្សនឹងមានភាពស្មោះត្រង់ចំពោះខ្លួនឯង[២]។

**ឃ-សច្ចធម៌របស់អ្នកវិទ្យាសាស្ត្រ**

តាមរយៈអ្នកវិទ្យាសាស្ត្រ អាចក្លាយទៅជាសច្ចៈបានលុះត្រាតែមានការពិសោធធ្វើការបកស្រាយបញ្ជាក់ប្រកបដោយអំណះអំណាងត្រឹមត្រូវ។ ក្រោយពីធ្វើការពិសោធគេទទួលបានលទ្ធផលបែបណាលទ្ធផលនោះហើយ គឺជាសច្ចៈ។

**៣.៣-រូបភាពនៃការប្រកាន់យកសច្ចធម៌**

មនុស្សដែលប្រកាន់សច្ចធម៌ គឺ ប្រព្រឹត្តតែអំពើល្អ និយាយស្តីតែងតែប្រើពាក្យពិតមិនកុតកុហក មិននិយាយពាក្យណាដែលនាំឱ្យគេខូចប្រយោជន៍។ មនុស្សទាំងនោះមានចិត្តទៀងត្រង់ គោរពពាក្យសច្ចៈនោះគ្រប់ករណីនៃទំនាក់ទំនងជាមួយអ្នកដទៃគ្រួសារ ដូចជា ការគោរពកិច្ចសន្យា ដែលខ្លួនបានព្រមព្រៀង រួចហើយជាដើម។

ប្រសិនបើខ្លួនបានជួបហេតុការណ៍អ្វីមួយខ្លួនត្រូវបកស្រាយតាមសភាពជាក់ស្តែងមិននិយាយសបំផ្លើសហេតុការណ៍ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនឬបំផ្លាញផលប្រយោជន៍ អ្នកដទៃនោះទេ។ ដំបូន្មានរបស់ព្រះពុទ្ធមានច្រើនណាស់ ប៉ុន្តែគោលសំខាន់គឺសង្កត់ធ្ងន់ទៅលើបីប៉ុណ្ណោះ គឺ " មិនប្រព្រឹត្តអំពើបាប សាបព្រោះបណ្តុះបណ្តាលតែអំពើបុណ្យ និងធ្វើចិត្តឱ្យស្អាតបរិសុទ្ធ "។

**៣.៤.លទ្ធផលនៃការប្រកាន់ខ្ជាប់នូវសច្ចធម៌**

ការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវសច្ចធម៌ គឺជាការជួយខ្លួនឯងរបស់មនុស្សនិងសង្គម។ ផលនៃការប្រកាន់យកនូវសច្ចធម៌នោះមាន៖

-មិនធ្លាក់ខ្លួនទៅក្នុងផ្លូវខុស

-មិនមានសេចក្តីភ័យខ្លាចឬក្តីអន្តរាយ

-មិនមានអ្នកដទៃត្មះតិះដៀល

-មានកិត្តិយសនិងកេរ្តិ៍ឈ្មោះល្អ

-មានស្មារតីនឹងនរ

-មានសេចក្តីសុខទាំងពេលបច្ចុប្បន្ននិងអនាគត

-កំចាត់បង់អស់នូវកង្វល់ ព្រោះមនុស្សប្រកាន់យកនូវសច្ចធម៌ តែងតែមានមនុស្សល្អនៅជុំវិញខ្លួន

-សម្អាតគំនិតឱ្យស្អាតបរិសុទ្ធ

-ធ្វើឱ្យសង្គមគ្មានការកេងបន្លំ ជាសង្គមល្អបរិសុទ្ធ។

---

[២] Plato –The story of Philosophy, by will Durant, Page 11,12,13

ដូច្នេះសច្ចធម៌ គឺជាមូលបទមួយដែលមនុស្សត្រូវតែគិតពិចារណា ត្រូវតែគោរព ត្រូវតែអនុវត្តដោយវាមានសារៈសំខាន់ណាស់សម្រាប់ជីវិតនៃការរស់នៅរបស់មនុស្សវាធ្វើឱ្យសង្គមមានស្ថេរភាពមានសេចក្ដីសុខមានភាពស្មោះត្រង់។

## ៤. អហិង្សាធម៌

### ៤.១.និយមន័យអហិង្សាធម៌

*អហិង្សាធម៌ ជាសភាវៈទ្រទ្រង់មនុស្សមិនឱ្យបៀតបៀនអ្នកដទៃឬ ធ្វើទុក្ខបុកម្នេញអ្នកដទៃឱ្យមានការឈឺចាប់ ឱ្យមានការលំបាក។*

*ធម៌អហិង្សា គឺជាធម៌ទាំងឡាយជាគោលការណ៍ ជាមាគ៌ានៃជីវិតសម្រាប់ផ្លាស់ប្ដូរមនុស្សឱ្យមានតម្លៃខ្ពង់ខ្ពស់បំផុត ដោយមិនត្រូវរំលោភរំពាន ឬបំផ្លិចបំផ្លាញចំពោះរាងកាយនិងជីវិតអ្នកដទៃនោះឡើយ។*

### ៤.២.ទស្សនៈផ្សេងៗស្ដីពីអហិង្សាធម៌

#### *ក-ទស្សនៈព្រះពុទ្ធសមណគោតម*

*ព្រះពុទ្ធមិនមែនគ្រាន់តែជាអ្នកប្រឆាំងនឹងសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ធ្វើអន្តរាគមន៍គ្រប់បែបយ៉ាងដើម្បីបញ្ចៀសកុំឱ្យមានសង្គ្រាមទៀតផង ដោយទ្រង់បានប្រើប្រាស់នូវធម៌អហិង្សានេះ។ ព្រះពុទ្ធអង្គជាបុគ្គលដែលពោរពេញទៅដោយព្រហ្មវិហារធម៌ហើយធម៌ទាំង៤នេះបានធ្វើឱ្យពិភពលោកទាំងមូល ពុំមានសង្គ្រាមហើយទទួលបានតែសេចក្ដីសុខក្សេមក្សាន្តគ្រប់ពេលវេលា។ ព្រះពុទ្ធអង្គទ្រង់បានសម្ដែងថា "មេត្តាជាបន្សារសម្រាប់ផ្សារភ្ជាប់ពិភពលោក" មានន័យថា គ្រួសារ ប្រទេសជាតិ និងពិភពលោកទាំងមូល ផ្សារភ្ជាប់គ្នាជាសាច់ឈាមតែមួយដោយគ្មានការប្រកាន់វណ្ណៈ ពូជសាសន៍ នោះពិតជាគ្មានសង្គ្រាម និងមានតែការស្រឡាញ់គ្នា។*

#### *ខ-ទស្សនៈរបស់ខុងជឺ*

*ខុងជឺជាទស្សនវិទូដ៏ល្បីល្បាញរបស់ប្រជាជនចិន ក៏ដូចជាប្រជាជនលើពិភពលោក។ គុណសម្បត្តិនៃទស្សនៈរបស់លោកគឺការឱ្យតម្លៃទៅលើសប្បុរសធម៌ មនុស្សធម៌ និងយុត្តិធម៌។ ខុងជឺ បានហាមប្រាមមនុស្សមិនឱ្យធ្វើសង្គ្រាមជាដាច់ខាត់។ លោកមើលឃើញថា សង្គ្រាមជាប្រភពនៃអមនុស្សធម៌ ព្រោះសង្គ្រាមនាំឱ្យមានការប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃលើមនុស្ស*[៣]*។*

*គុណធម៌របស់ខុងជឺ សំដៅទៅលើទឹកចិត្តមេត្តា ករុណា និងភាពត្រឹមត្រូវ។ លោកបានកំណត់ថាមនុស្សម្នាក់ៗរស់នៅក្នុងសង្គម សុទ្ធតែមានភារកិច្ចដែលគេគួរធ្វើដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ*

---

[៣] *សាកលវិទ្យាល័យបៀលប្រាយ ៖ សិល្បៈនៃការរស់នៅ ជ.៦.ម.ទំព័រ៦*

*ប្រកបដោយសីលធម៌ និងភាពត្រឹមត្រូវ។ ត្រង់ចំណុចនេះហើយដែលយើងអាចចាត់ទុកថាជាគុណធម៌របស់ខុងជឺ។*

*លោកបានផ្ដល់ទស្សនៈបន្ថែមទៀតថា"កុំធ្វើទៅលើអ្នកដទៃនូវអំពើអ្វីដែលអ្នកមិនចង់ឱ្យអ្នកដទៃធ្វើមកលើខ្លួនវិញ"។ ថ្វីដ្បិតតែខុងជឺមិនបានចែងពីធម៌អហិង្សាក៏ដោយ តែខ្លឹមសារនៃទស្សនៈរបស់លោកពិតជាបានផ្សព្វផ្សាយនូវឥទ្ធិពលនៃគំនិតអហិង្សានេះបានយ៉ាងខ្លាំងក្លាបំផុត។*

***គ-ទស្សនៈមហាត្មៈគន្ធី***

*មហាត្មៈគន្ធី ជាមហាវីរបុរសដ៏ឆ្នើមនៃប្រជាជនប្រមាណជាង១០០០លាននាក់ និងមានកេរ្តិ៍ឈ្មោះល្បីល្បាញពេញសកលលោកក្នុងការតស៊ូទាមទារឯករាជ្យពីអាណានិគមអង់គ្លេសតាមរយៈមធ្យោបាយអហិង្សា។ សកម្មភាអហិង្សារបស់លោកបានទទួលជោគជ័យយ៉ាងត្រចះត្រចង់លើពួកអាណានិគមទទួលជោគជ័យក្នុងការរំលាយចោលនូវការប្រកាន់វណ្ណៈទាំង៤របស់ឥណ្ឌា និងរំដោះអាហ្វ្រិកខាងត្បូង។*

*លោកបានណែនាំឱ្យគេប្រើមធ្យោបាយត្រជាក់ដើម្បីដោះស្រាយវិបត្តិផ្សេងៗទោះជាមានការចាប់ចង ឬវាយដំបែបណាក៏ដោយ។ បើអ្នកធ្វើអំពើអហិង្សា សូមកុំប្រកាន់ខ្លួន កុំខ្ជិល ហើយត្រូវប្រយ័ត្នជានិច្ចចំពោះសេចក្ដីក្រោធ ដែលកើតមាននៅក្នុងសន្ដានចិត្តរបស់អ្នក។ លោកមិនឱ្យមនុស្សប្រើកម្លាំងកាយទេព្រោះវាជាអំពើបាប ប៉ុន្តែគេត្រូវប្រើបញ្ញាដើម្បីដោះស្រាយវិបត្តិ[៤]។*

**៤.៣.រូបភាពនៃការប្រតិបត្តិអហិង្សាធម៌**

*-ការប្រកាន់ខ្ជាប់នូវសេចក្ដីស្ងប់តាមផ្លូវកាយនិងផ្លូវចិត្តគឺរួមរស់ជាមួយគ្នាដោយសេចក្ដីសុខដុមរមនាមិនបៀតបៀនមិនព្យាបាទមិនឈ្នានីសគ្នា ពោលគឺរស់នៅប្រកបដោយចិត្តមេត្តា ករុណា មុទិតា ឧបេក្ខា មិនលោភលន់ កេងប្រវញ្ច ។*

*-ខន្តីឬសេចក្ដីអត់ធន់ គឺជាឱសថទប់ទល់នឹងពាក្យតិះដៀលនិងការឈ្លោះប្រកែកគ្នា។ បុគ្គលដែលប្រកបដោយសេចក្ដីអត់ធន់នឹងទទួលបានមិត្តល្អ មានកិត្តិយសនិងសុភមង្គល។ ជនដែលមានការអត់ឱនតែងតែមានការរាប់អានពីអ្នកដទៃជានិច្ច។*

*-ការប្រព្រឹត្តតែអំពើល្អ លះបង់គំនុំគុំគួនដែលមាននៅក្នុងចិត្តហើយមានតែសេចក្ដីស្រឡាញ់ទេដែលជួយឱ្យមនុស្សរួចផុតពីសេចក្ដីស្អប់និងកំហឹងបាន។ការរស់នៅប្រកបដោយចិត្តមេត្តាករុណា និងនាំមកនូវសុភមង្គលជានិច្ចនិរន្តរ៍។*

---

[៤] *សាកលវិទ្យាល័យបៀលប្រាយ ៖ សិល្បៈនៃការរស់នៅ ដ.ឯ.ម.ទំព័រ៧*

## ៤.៤.ផលប្រយោជន៍នៃការប្រតិបត្តិអហិង្សាធម៌

*-មនុស្សអាចទទួលបានភាពជោគជ័យលើចិត្តខ្លួនឯងបាន ប្រសិនបើពួកគេបានយកធម៌អហិង្សាយកមកដាក់ក្នុងខ្លួនគេម្នាក់ៗ។*

*-ការជ្រើសរើសឬប្រកាន់យកនូវធម៌អហិង្សាមកដាក់ក្នុងខ្លួនធ្វើឱ្យគ្រួសារសហគមន៍ប្រទេសជាតិ និងពិភពលោកទាំងមូល មិនមានជម្លោះ មិនមានសង្គ្រាម ជួបប្រទះតែសន្តិភាព ការគោរពទៅវិញទៅមក មានការយោគយល់គ្នារវាងជនជាតិនិងជនជាតិ និងការយោគយល់គ្នាជាអន្តរជាតិ។*

*-និយាយជារួម បើបុគ្គលគ្រប់រូបប្រកាន់ខ្ជាប់ខ្លួននូវធម៌អហិង្សានោះវាពិតជាធ្វើឱ្យសង្គមគ្រួសារប្រទេសជាតិមានការអភិវឌ្ឍគ្រប់ផ្នែក មានសន្តិភាពទាំងផ្លូវកាយផ្លូវចិត្ត មានសុភមង្គលដល់ជីវិតគ្រប់រូប។*

## ៥. ខន្តីធម៌

### ៥.១.និយមន័យខន្តីធម៌

*ខន្តីធម៌ គឺជាគុណធម៌ដ៏ឧត្តុង្គឧត្តម ដែលមនុស្សគ្រប់រូបត្រូវតែប្រកាន់យកទុកជាមាគ៌ាមួយដ៏ល្អប្រសើរ ឆ្ពោះទៅរកសេចក្ដីសុខក្នុងជីវិតរស់នៅ។ខន្តីគឺជាការគោរពគ្នា ការយោគយល់ ការអត់ឱនគ្នាតាមរយៈការយល់ចិត្តគ្នាទៅវិញទៅមក ទាំងកាយ ទាំងវាចា ទាំងចិត្ត។*

*ខន្តី គឺជាចំណង់ចំណូលចិត្តឬជាសមត្ថភាពម៉្យាងរបស់មនុស្ស ដើម្បីប្រឈមនឹងស្ថានការលំបាកនានា។ មនុស្សមានគំនិតខន្តី គឺជាមនុស្សមិនមានភាពមានៈ មានតែគំនិតរបស់ខ្លួនទេដែលត្រឹមត្រូវ តែគំនិតរបស់អ្នកដទៃក៏អាចត្រឹមត្រូវដែរ ជាគំនិតដែលខ្លួនព្រមទទួលយកមកពិចារណា។*

*ការសន្តោសប្រណី គឺជាសេចក្ដីត្រេកអរពេញចិត្តចំពោះវត្ថុដែលជារបស់ខ្លួន របស់ដែលខ្លួនរកបានដោយវិធីត្រឹមត្រូវតាមសមត្ថភាពគឺរកបានប៉ុន្មានក៏ល្មមចិត្តត្រឹមប៉ុណ្ណោះ មិនសង្វាតលោភលន់ និងមិនវាតទីហួសហេតុ ហួសបំណងរបស់ខ្លួនឡើយ។ ការសន្តោសគឺជាការត្រេកអរពេញចិត្តនឹងរបស់ដែលខ្លួនទទួលបានពីអាជីវកម្មសុចរិតត្រឹមត្រូវ។*

*ខន្តីធម៌គឺជាការបន្ទន់ចិត្តមិនប្រកាន់ទោសអូសដំណើចំពោះជនដទៃ ដែលប្រព្រឹត្តខុស អនុគ្រោះលើកលែងទោសកំហុសឱ្យរហូតទៅដល់ការចែករំលែកទ្រព្យសម្បត្តិ ឬសេចក្ដីសុខដល់មនុស្សដែលស្ថិតនៅក្នុងស្ថានភាពយ៉ាប់យ៉ឺន។*

### ៥.២.រូបភាពនៃខន្តីធម៌

*មនុស្សដែលមានខន្តីធម៌ តែងតែមានចិត្តទូលាយមិនឆេវឆាវ មិនអន្ទះអន្ទែងចំពោះទង្វើដែលមិនសមរម្យមកលើខ្លួន។ ហេតុការណ៍អ្វីក៏ដោយ អ្នកដែលមានគំនិតអធ្យាស្រ័យតែងតែយកហេតុការណ៍ឬទង្វើ*

នោះមកពិចារណាគ្រប់ជ្រុងជ្រោយ ទើបធ្វើសេចក្តីសម្រេចចិត្ត ព្រោះថាមនុស្សគ្រប់រូបតែងតែមានកំហុសពុំអាចជៀសបានឡើយ។

នៅក្នុងសង្គមទង្វើខុសឆ្គងរបស់មនុស្សមានច្រើនណាស់តែមានអ្នកខ្លះពុំព្រមទទួលសារភាពកំហុសរបស់ខ្លួនទេ។ គេមិនត្រឹមតែមិនទទួលកំហុសនោះទេ តែគេថែមទាំងបញ្ចេញសំដី ឬកពាមិនសមរម្យទៅលើមនុស្សដែលត្រឹមត្រូវ ឬជនរងគ្រោះនោះថែមទៀត។ អាកប្បកិរិយាបែបនេះពុំមែនជាមនុស្សដែលមានធម៌អធ្យាស្រ័យសន្តោសប្រណីនោះទេ។ មានតែការអត់ឱនការលើកលែង មិនប្រកែប្រកាន់លើកំហុសអ្នកដទៃនោះទេ ទើបអាចចាត់ថាជាបុគ្គលមានអធ្យាស្រ័យនិងការសន្តោសប្រណីបាន។

ខន្តីធម៌គឺជាធម៌ដែលមនុស្សគ្រប់រូបគ្រប់ស្រទាប់គួរតែអនុវត្តឱ្យបានដើម្បីឈានទៅរកសន្តិភាពនិងការអភិវឌ្ឍដល់មនុស្សគ្រប់រូប។ អំពើចោរកម្ម ការលួចឆក់ប្លន់ ការកាប់សម្លាប់ការគំរាមកំហែងតែងតែកើតឡើងពីជនមួយចំនួនដែលមានចិត្តអន្តិរ្ថិយ គ្មានធម៌អធ្យាស្រ័យ គ្មានធម៌សន្តោសប្រណីក្នុងខ្លួន។

## ៥.៣.ទស្សនៈផ្សេងៗទាក់ទងនឹងខន្តីធម៌

### ក-ទស្សនៈរបស់ព្រះពុទ្ធសមណគោតម

ទស្សនៈរបស់ព្រះពុទ្ធលើបញ្ហានេះ ទ្រង់បានឱ្យដំបូន្មានមនុស្សថា ឱ្យត្រេកអរចំពោះវត្ថុដែលខ្លួនរកបាន ពោល គឺធ្វើជាមនុស្សមិនត្រូវចង់បាន ចង់មានហួសហេតុនោះទេ ត្រូវធ្វើឱ្យសមល្មមនឹងសមត្ថភាព លទ្ធភាពដែលខ្លួនមាន។ លក្ខណៈនៃការសន្តោសរបស់ព្រះពុទ្ធមាន៣យ៉ាងគឺៈ

-សេចក្តីត្រេកអរពេញចិត្តនឹងរបស់ដែលមាន ដូចជាត្រេកអរនឹងទ្រព្យសម្បត្តិរបស់ខ្លួន កូនប្រពន្ធប្តី និងរបស់ដែលខ្លួនមាន។

-សេចក្តីត្រេកអរនឹងរបស់ដែលរកបាន។ ទ្រព្យសម្បត្តិបានមកពីព្រោះតែយើងចេះស្វែងរកដោយភាពសុចរិតត្រឹមត្រូវ មិនលោភលន់។

-សេចក្តីត្រេកអររបស់ដែលគួរ។ ទ្រព្យសម្បត្តិដែលរកបានមកនោះអាចបានមកដោយវិធីអាក្រក់ក៏មាន ដូច្នេះយើងគប្បីពិចារណាមើលថា តើទ្រព្យដែលរកបានមកនោះ ប្រកបដោយភាពត្រឹមត្រូវដែរឬទេ? បើមើលទៅឃើញថាពុំត្រឹមត្រូវនោះទេ គួរតែលះបង់វាចោលចេញ ទើបជាការប្រសើរ។

### ខ-ទស្សនៈរបស់ខុងជឺ

លោកខុងជឺ ដែលជាទស្សនវិទូចិនដ៏ល្បីល្បាញនោះបានផ្តល់ជាមតិមួយថា "កុំ

ធ្វើទៅលើអ្នកដទៃ នូវអំពើអ្វីដែលអ្នកមិនចង់ឱ្យអ្នកដទៃធ្វើមកលើខ្លួនវិញ”។ គាត់គិតថា មនុស្សដែលមានគុណធម៌ពិតជាមានបំណងបង្កើតខ្លួនឯង ដោយស្វែងរកភាពជោគជ័យដោយខ្លួនឯងផង និងជួយជំរុញឱ្យអ្នកដទៃទទួលជោគជ័យដូចខ្លួនផងដែរ។ ទស្សនៈរបស់លោកសុទ្ធតែនាំមនុស្សគ្រប់រូបឱ្យមានការអត់ធ្មត់ឱ្យចេះអត់ឱនអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក មិនឈ្លោះទាស់ទែងគ្នាពោលគឺយកធម៌អហិង្សាតបទៅនឹងអំពើហិង្សាដើម្បីសង្គមទទួលបានសេចក្ដីសុខនិងមានការរីកចម្រើន។

**គ-ទស្សនៈមហាត្មៈគន្ធី**

លោកបានផ្ដល់យោបល់ថា“ចិត្តក្ដៅពុំអាចរំលត់ដោយចិត្តក្ដៅបានទេតែគេត្រូវតែយកចិត្តទឹកទៅរំលត់ក្ដៅទើបបាន”។ ចំណុចនេះមានន័យថាបើមានទំនាស់នឹងគ្នា យើងត្រូវតែមានការអធ្យាស្រ័យ យោគយល់គ្នាទើបអាចបង្ក្រាបកំហឹង ឬទោសៈរបស់មនុស្សបាន“ កុំយកកំហឹងទល់នឹងកំហល់”។

**ឃ-ទស្សនៈរបស់ឡាហ្វុងតែន**

លោកឡាហ្វុងតែន បានផ្ដល់ជាទស្សនៈថា“ មនុស្សយើងអធ្យាស្រ័យឱ្យខ្លួនយើងគ្រប់កំហុសទាំងឡាយក៏ប៉ុន្តែមិនចូលចិត្តអធ្យាស្រ័យកំហុសឱ្យអ្នកដទៃឡើយ ”។ ទស្សនៈនេះវាស៊ីនឹងផ្នត់គំនិតរបស់ខ្មែរដែលបានសរសេរជាកំណាព្យមួយឃ្លាថា“ទោសគេតូចសោតសល់រមិលយល់ប៉ុនទាំងភ្នំ” ។ នេះគឺជាការរិះគន់ពេញទំហឹង ទៅលើទស្សនៈនៃការមិនចេះយោគយល់ មិនចេះអត់ឱននិងអធ្យាស្រ័យឱ្យមនុស្សដទៃ។ បើយើងអធ្យាស្រ័យឱ្យខ្លួនឯងបានក៏គួរតែអធ្យាស្រ័យសន្ដោសប្រណីដល់អ្នកដទៃផងដែរនោះទើបសង្គមជួបប្រទះតែសេចក្ដីសុខ។

**ង-ទស្សនៈពីសាណូនីកូឡា**

ទស្សនៈរបស់ជាងចម្លាក់រូបនេះក៏មិនខុសពីទស្សនៈរបស់អ្នកប្រាជ្ញខាងលើនោះដែរ។លោកបានកំណត់ថា“ការសងសឹកជាមួយនឹងមនុស្សដែលបំពានមកលើរូបយើង គឺយើងដាក់ខ្លួនឱ្យស្មើនឹងសត្រូវ”។ បើយើងអធ្យាស្រ័យឱ្យគេគឺយើងលើកស្ទួយខ្លួនយើងឱ្យខ្ពស់ជាងគេ។ ការអធ្យាស្រ័យចំពោះខ្លួនឯង ហើយតឹងតែងចំពោះអ្នកដទៃគឺជាកំហុសតែមួយដូចគ្នា។ ទស្សនៈនេះចង់បញ្ជាក់ថា រវាងការសងសឹកនិងការអធ្យាស្រ័យ គេគួរជ្រើសរើសយកការអធ្យាស្រ័យប្រសើរជាង។

**៥.៤.លទ្ធផលនៃការប្រកាន់ខន្តីធម៌**

ការប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវធម៌អហិង្សា ធម៌សន្ដោសប្រណីដោយចេះលើកលែង អត់ឱនទោសឱ្យអ្នកដទៃ កុំយកការតបតការសងសឹកមកធ្វើជាត្រីមុខនោះវានឹងផ្ដល់ផលយ៉ាងច្រើន៖

-ធ្វើឱ្យយើងត្រេកអរពេញចិត្តនឹងសម្បត្តិដែលខ្លួនមាន។សម្បត្តិដែលខ្លួនរកបានប្រកបដោយភាពសុចរិតយុត្តិធម៌។

-ធ្វើឱ្យយើងចេះគិតមើលថាសម្បត្តិណាដែលគួរត្រេកអរនិងសម្បត្តិណាដែលមិនគួរស្រវាស្រទេញ មិនគួរត្រេកអរ។

-ធ្វើឱ្យយើងមានចិត្តស្ងប់ ដោយគ្មានការនឹកស្ដាយក្រោយ។

-ធ្វើឱ្យយើងអាចកាត់បន្ថយសត្រូវបង្កើនមិត្ត។

-មានកិត្តិយសល្អនិងមានឈ្មោះថាជាអ្នកធ្វើប្រយោជន៍ដល់ខ្លួនឯងនិងសង្គម។

-ធ្វើឱ្យសង្គមមានស្ថេរភាពមានសន្តិភាពដោយការចេះយោគយល់អត់ឱនឱ្យគ្នាទៅវិញទៅមក។

-ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈបែបណាក៏ដោយក៏ធម៌អធ្យាស្រ័យ និងការសន្តោសប្រោសប្រណីនៅតែជាមាគ៌ាមួយដ៏ល្អត្រចះត្រចង់សម្រាប់មនុស្សគ្រប់រូប ស្វែងរកសេចក្តីស្ងប់និងសន្តិភាពនៅក្នុងគ្រួសារក៏ដូចជានៅក្នុងសង្គមជាតិ និងពិភពលោកទាំងមូលដែរ។

## ៦. សុចរិតធម៌

### ៦.១-និយមន័យសុចរិតធម៌

សុចរិតធម៌មានន័យថាការប្រព្រឹត្តល្អ ការប្រព្រឹត្តដោយភាពស្មោះត្រង់ ការប្រព្រឹត្តប្រកបដោយភាពបរិសុទ្ធនិងត្រឹមត្រូវ។

សុចរិតធម៌ សំដៅទៅលើការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការប្រព្រឹត្តត្រឹមត្រូវ និងការប្រកបមុខរបរចិញ្ចឹមជីវិតដោយភាពបរិសុទ្ធតាមគន្លងធម៌ស្របតាមច្បាប់សង្គមហើយមិនធ្វើឱ្យអ្នកដទៃរងការឈឺចាប់ការខូចខាតផលប្រយោជន៍ ពេលវេលាឬទទួលគ្រោះថ្នាក់ដោយសារទង្វើនិងមុខរបររបស់ខ្លួន។

ដើម្បីពង្រឹងមាគ៌ាសន្តិភាព និងសុភមង្គលជាសកលឱ្យកាន់តែបានល្អប្រសើរ ព្រះពុទ្ធអង្គទ្រង់បានអប់រំទូន្មានឱ្យមនុស្សទាំងអស់ប្រកាន់ខ្ជាប់នូវកុសលកម្មគឺការប្រព្រឹត្តល្អ១០យ៉ាងដោយកាយ វាចា និងចិត្តគឺមានកាយសុចរិត៣ វចីសុចរិត៤ និងមនោសុចរិត៣។

### ៦.២.រូបភាពនៃការប្រកាន់យកសុចរិតធម៌

មនុស្សដែលចូលចិត្តប្រព្រឹត្តភាពត្រឹមត្រូវ មិនវៀចវេរ មិនលម្អៀងនិងដោយភាពស្មោះត្រង់នោះត្រូវបានគេចាត់ទុកវាជាមនុស្សប្រកាន់ខ្ជាប់នូវសុចរិតធម៌។ ភាពស្មោះត្រង់ត្រឹមត្រូវនេះវាជាតម្រូវការចាំបាច់បំផុតសម្រាប់មនុស្សរាល់រូបព្រោះថាបើអ្នកប្រកាប់ខ្ជាប់នូវភាពសុចរិតនេះនោះអ្នកនឹងក្លាយទៅជាមនុស្សដែលទទួលបាននូវជំនឿទុកចិត្តពីមនុស្សដទៃ។

បើយើងគិតពីសកម្មភាពប្រចាំថ្ងៃក្នុងការប្រកបរបររកស៊ីចិញ្ចឹមជីវិតទៅតាមចំណង់ចំណូលចិត្ត សមត្ថភាពនិងជំនាញ

របស់ខ្លួននោះ មានរបរខ្លះត្រឹមត្រូវសុចរិត តែក៏មានមនុស្សមួយចំនួនយកជំនាញ យកសមត្ថភាពនោះទៅប្រព្រឹត្តអំពើមិនត្រឹមត្រូវ មិនស្របច្បាប់ដែរ។ គេអាចសង្កេតឃើញថា អ្នកប្រកាន់ភាពសុចរិត រស់នៅបានសុខសាន្តពុំសូវមានសត្រូវនោះទេ។ ចំពោះអ្នកប្រព្រឹត្តមិនសុចរិតដូចជាការកេងប្រវ័ញ្ចគេ គៃបន្លំ ឆបោកអ្នកដទៃ ធ្វើឱ្យគេក្តៅក្រហាយ បង្កទៅជាជម្លោះ ទៅជាភាពស្អប់គ្រោះ ធ្វើឱ្យបុគ្គលនោះរស់នៅក្នុងភាពមិនសុខសប្បាយនោះទេ។

### ៦.៣.ទស្សនៈព្រះពុទ្ធទាក់ទងនឹងសុចរិតធម៌

ទស្សនៈរបស់ព្រះពុទ្ធដូចដែលបានបង្ហាញពីខាងដើមរួចមកហើយគឺការប្រកាន់ខ្ជាប់នូវកុសលកម្មបទ១០ប្រការ គឺៈ

ក-កាយសុចរិតធម៌

មិនបំបាត់ជីវិតអ្នកដទៃ (បាណាតិបាតា វេរមណី)មិនលួចទ្រព្យសម្បត្តិអ្នកដទៃ (អទិន្នាទានា វេរមណី)

មិនសហាយស្មន់ជាមួយប្តីប្រពន្ធកូនអ្នកដទៃ (កាមេសុមិច្ឆាចារា វេរមណី)

ខ-វចីសុចរិតធម៌

-មិនភូតកុហកឆបោកអ្នកដទៃ(មុសាវាទានា វេរមណី)

-មិនញុះញង់បំបែកបំបាក់អ្នកដទៃ (បិសុណាយវាចាយ វេរមណី)

-មិនពោលពាក្យ ទ្រគោះបោះបោក ឬជេរប្រទេចផ្តាសាអ្នកដទៃ(ផរុសាយវាចាយ វេរមណី)

-មិនពោលពាក្យពាយមាយឥតប្រយោជន៍ ( សម្ផប្បលាប វេរមណី)

គ-មនោសុចរិតធម៌

-មិនមានចិត្តសម្លឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ(អនភិជ្ឈា)

-មិនមានចិត្តគំនុំ ឬមានគំនិតព្យាបាទអ្នកដទៃ (អព្យាបាទោ)

-មានគំនិតយល់ឃើញត្រូវពិតតាមច្បាប់សង្គម សីលធម៌ (សម្មាទិដ្ឋិ)វត្ថុដែលមានតម្លៃខ្ពស់បំផុត និងគួរឱ្យគោរពនោះគឺកិត្តិយសកេរ្តិ៍ឈ្មោះដែលបានមកពីសេចក្តីសុចរិតត្រឹមត្រូវទៀងត្រង់។ មនុស្សគ្រប់រូបមិនត្រូវបញ្ឈប់នូវការតាំងចិត្តប្រព្រឹត្តនូវអំពើសុចរិតនោះទេ ត្រូវចងចាំថារាល់ពាក្យសំដីរបស់អ្នក គឺជាកិច្ចសន្យានិងប្តូរដោយកិត្តិយសរបស់អ្នក។

### ៦.៤.ផលនៃការប្រតិបត្តិសុចរិតធម៌

មនុស្សគ្រប់រូបគប្បីប្រព្រឹត្តតែអំពើល្អត្រឹមត្រូវចៀសវាងអំពើអាក្រក់ទាំងឡាយ ប្រកបមុខរបរសុចរិតស្មោះត្រង់និងធ្វើចិត្តឱ្យបរិសុទ្ធជានិច្ច ព្រោះគុណសម្បត្តិទាំងនោះនាំមកឱ្យយើងនូវសុវត្ថិភាពក្នុងជីវិតរស់នៅ។

***ផលនៃអ្នកប្រកាន់ខ្ជាប់សុចរិតធម៌ៈ***

រស់នៅមានសុវត្ថិភាព សុភមង្គល រីកចម្រើន ថ្លៃថ្នូរ គ្មានការត្មះតិះដៀលពីជន

ដទៃ មានកេរ្តិ៍ឈ្មោះល្អ ជាមនុស្សសុចរិត មានមិត្តភក្តិ និងមានមនុស្សនៅជុំវិញវិញខ្លួនគោរព ស្រឡាញ់រាប់អាន គ្មានការសងសឹក ព្យាបាទពីអ្នកដទៃ មានសុភមង្គលក្នុងគ្រួសារ សហគមន៍ និងសង្គមមានសន្តិភាព តែងតែបានទទួលត្រឡប់មកវិញនូវភាពប្រកបដោយសុចរិតធម៌។

## ៧. សាមគ្គីធម៌

### ៧.១.និយមន័យសាមគ្គីធម៌

-សាមគ្គី គឺជាការព្រមព្រៀងគ្នាឬស្រុះស្រួលគ្នា

-សាមគ្គីធម៌គឺជាច្បាប់ឬលក្ខខណ្ឌសម្រាប់ប្រតិបត្តិឱ្យមានការព្រមព្រៀងគ្នាឬសាមគ្គីគ្នា

-សាមគ្គីភាព គឺជាបែបបទ ឬរបៀបនៃការព្រមព្រៀងគ្នា

-សាមគ្គីរស គឺជារសនៃសាមគ្គី មានន័យថាជាការព្រមព្រៀងដោយការពេញចិត្តនិងដោយការស្រឡាញ់រាប់អានគ្នាទៅវិញទៅមក

-សាមគ្គីធម៌គឺជាការព្រមព្រៀងចុះសម្រុងគ្នាទាំងកាយទាំងវាចាទាំងចិត្តៈ

ការព្រមព្រៀងដោយកាយ នៅក្នុងក្រុមនីមួយៗ ប្រសិនបើពួកគេមានកិច្ចការអ្វីដែលត្រូវធ្វើរួមគ្នាគឺត្រូវទៅរួបរួមនៅជាមួយគ្នា ជួយបំពេញកិច្ចការនោះតាមពេលវេលាដែលបានកំណត់ទុកដោយគ្មានអ្នកណាម្នាក់ហ៊ានសំងំលាក់ខ្លួនឡើយ។

ការព្រមព្រៀងដោយវាចា ក្នុងពេលដែលមានការប្រជុំ ដើម្បីផ្លាស់ប្តូរយោបល់គ្នាក្នុងការរួបរួមគ្នាធ្វើកិច្ចការអ្វីមួយគឺត្រូវមានការយោគយល់ស្តាប់គ្នា មិនប្រកែកយកឈ្នះតែរៀងៗខ្លួន ហ៊ានទទួលយកគំនិតប្រឆាំងដែលសមហេតុផល។

ការព្រមព្រៀងដោយចិត្ត ត្រូវប្រកាន់ចិត្តស្មើគ្នា អធ្យាស្រ័យគ្នាទប់ចិត្ត សម្របសម្រួលចិត្តរបស់ខ្លួនឱ្យស្របជាមួយគ្នា មិនដណ្តើមយកឈ្នះគ្នាដោយភាពអស្មិមានៈ។

### ៧.២-រូបភាពនៃការមានសាមគ្គីធម៌

សាមគ្គីខ្លះបង្កើតឡើងក្នុងគោលបំណងលើកស្ទួយជីវភាពរស់នៅឱ្យមានភាពរីកចម្រើននិងភាពសុខសាន្តហើយសាមគ្គីខ្លះទៀតបង្កើតឡើងដើម្បីចង់សម្រេចគោលបំណងអ្វីមួយ ឬ ដើម្បីរំដោះប្រទេសជាតិពីការត្រួតត្រារបស់បរទេសដើម្បីឯករាជ្យជាតិ។

ដូនតាខ្មែរយើង ពិសេសនៅសម័យមហានគរមានឈ្មោះល្បីល្បាញមានឥទ្ធិពលពេញភូមិភាគអាស៊ីអាគ្នេយ៍ទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកវប្បធម៌និងនយោបាយ មិនមែនកើតឡើងដោយសារការប្រទានរបស់អាទិទេពនោះទេ តែបានដោយសារកម្លាំងសាមគ្គីជាតិរវាងប្រជាជននិងអ្នកដឹក

នាំ រវាងអ្នកដឹកនាំ និងអ្នកដឹកនាំរវាងប្រជាជននិងប្រជាជននេះឯង។

តាមឯកសាររបស់វិទ្យាស្ថានខ្មែរវប្បធម៌បានធ្វើការអះអាងលើទំហំនៃសាមគ្គីភាពរបស់ខ្មែរសម័យមហានគរដែលមានប្រាសាទបាយ័នជាកស្តុតាង។ ប្រាសាទនេះមានកំពូលចំនួន៥៤ខ្លោងទ្វារចំនួន៥ ហើយកំពូលនីមួយៗមានមុខបួន ជានិមិត្តរូបនៃព្រហ្មវិហារធម៌។ ប្រាសាទបាយ័នជារូបមន្តនៃសាមគ្គីភាព ឯកភាពរវាងអំណាចកណ្តាលនិងអំណាចតំបន់ អំណាចភូមិភាគនិងអំណាចមូលដ្ឋាន។ មានន័យថារូបភាពនេះបានបញ្ជាក់ពីភាពត្រូវគ្នា ពីភាពរួបរួមគ្នារវាងអ្នកដឹកនាំជាមួយថ្នាក់ដឹកនាំរវាងថ្នាក់ដឹកនាំជាមួយរាស្ត្ររវាងរាស្ត្រនិងរាស្ត្រ។ ហេតុផលនេះហើយទើបធ្វើឱ្យខ្មែរមានតម្លៃមានកិត្តិយសល្បីរន្ទឺពេញពិភពលោក ប្រទេសរីកចម្រើន រាស្ត្ររស់នៅក្នុងភាពសុខសប្បាយ។

## ៧.៣.បច្ច័យនាំឱ្យមានសាមគ្គីធម៌

### ក-ការតស៊ូនិងការអត់ធ្មត់

ប្រសិនបើមនុស្សម្នាក់ៗចាប់ផ្តើមធ្វើការងារអ្វីមួយដែលមានប្រយោជន៍ហើយមានឧបសគ្គ ឬមានគ្រោះថ្នាក់ដល់រូបរាងកាយ ទ្រព្យសម្បត្តិ ចិត្ត គ្រួសារ សង្គមជាតិ គេមិនត្រូវចុះចាញ់ឧបសគ្គទាំងនោះឡើយ គឺគេត្រូវតែតស៊ូយកជ័យជម្នះលើឧបសគ្គនោះឱ្យបានដោយការតាំងចិត្តលះបង់ខ្ពស់។

### ខ-ការសន្តោសនិងការស្មោះត្រង់

កិច្ចការដែលយើងបានធ្វើ ហើយទោះបីមានផលតិចក្តីច្រើនក្តីមិនបានផលសោះ ឬបានផលមិនសមតាមបំណងក្តី ឱ្យតែជាផលនោះបានដោយភាពត្រឹមត្រូវ យើងត្រូវតែទទួលដោយភាពរីករាយ។ យើងមិនត្រូវមានចិត្តរើសអើងទោះបីមនុស្សនោះមានបំណងបែបណាក៏ដោយ គឺត្រូវយកគុណធម៌នៃមនុស្សជាតិមកដាក់ក្នុងចិត្ត។

### គ-ការមិនប្រកាន់និងមិនរើសអើង

ទោះបីអ្នកមានកិត្តិយសខ្ពង់ខ្ពស់ មានទ្រព្យសម្បត្តិច្រើន មានចំណេះវិជ្ជាជ្រៅជ្រះ អ្នកមិនត្រូវបញ្ចេញអាកប្បកិរិយារើសអើង ក្រអឺតក្រទមដែលនាំឱ្យមានការអាក់អន់ក្នុងចិត្តអ្នកដទៃឡើយ ព្រោះសាមគ្គីនឹងកើតមានលុះត្រាតែមនុស្សម្នាក់ៗមិនប្រកាន់មិនរើសអើង។

### ឃ-មិនច្រណែននិន្ទាឈ្នានីស

អ្នកមិនត្រូវមានចិត្តចង្អៀតចង្អល់ បន្ទុះបង្អាប់ ត្មះតិះដៀល ឬព្យាយាមរកឧបាយកលបំផ្លិចបំផ្លាញធ្វើឱ្យអ្នកដទៃវិនាសអន្តរាយដោយសារខ្លួន ព្រោះតែការច្រណែនឃើញគេមានទ្រព្យជាងខ្លួន គេមានចំណេះខ្ពស់ជាងខ្លួន នោះពិតជាមិនអាចនាំមកនូវសាមគ្គីភាពបាននោះទេ ដោយហេតុថាគ្មានភាពចុះសម្រុងជាមួយគ្នា។

### ង-ការស្មោះត្រង់ទៅវិញទៅមក

អ្នកមិនត្រូវយករួចតែខ្លួនដោយប្រាសចាកការរួមសុខទុក្ខជាមួយក្រុមក្នុងការស្វែងរកប្រយោជន៍ និងសេចក្ដីសុខដោយបិទបាំងសេចក្ដីវិនាសដែលបម្រុងនឹងកើតឡើង ឬកំពុងកើតឡើងដល់ក្រុមនោះឡើយ។ ទង្វើនេះនាំឱ្យលែងមានការទុកចិត្តគ្នាទៅវិញទៅមក ហើយទីបញ្ចប់គឺឈានទៅរកការបែកបាក់សាមគ្គីជាមិនខាន។

### ច-ការពិចារណារកហេតុផលតាមផ្លូវល្អ

កាលបើមានហេតុការណ៍ណាមួយកើតឡើង ទោះបីជាហេតុការណ៍នោះនាំផលចម្រើនក្ដី មិនចម្រើនក្ដី អ្នកត្រូវតែត្រិះរិះពិនិត្យពិច័យពិចារណាឱ្យបានល្អិតល្អន់រិះរកវិធីកែប្រែឱ្យបានសមស្របទៅតាមគំនិតដែលយើងបានដៅទុកជាមុនរួចហើយកុំឱ្យខុសពីគោលបំណងនោះឡើយ។ ការថ្លឹងថ្លែងពិគ្រោះពិចារណានៅលើផ្លូវល្អនេះអាចបង្កើតបាននូវការទុកចិត្តការរួបរួមគ្នាដោះស្រាយបញ្ហាបានពោល គឺឈានទៅរកសាមគ្គីភាពនេះឯង។

ជារួមមកយើងឃើញថា ការបង្កើតឱ្យមានភាពសាមគ្គីបិតបេរត្រឹមត្រូវ គឺអាស្រ័យលើចិត្តបុគ្គលដែលមានលក្ខណៈរួបរួមគ្នា" ចិត្តមួយថ្លើមមួយ" ក្នុងការបំពេញកិច្ចការអ្វីមួយ ជាប្រយោជន៍ដល់គ្នានឹងគ្នាដោយមិនលំអៀង។

## ៧.៤.លទ្ធផលនៃការសម្រេចបានសាមគ្គីធម៌

ផលដែលកើតឡើងដោយភាពសាមគ្គីមាន៖

-ការរីកចម្រើនឆាប់រហ័សទទួលបានជោគជ័យនិងមិនចំណាយពេលវេលាច្រើន

-ការពារផលប្រយោជន៍បានបិតបេរគង់វង្ស

-ការបង្កើតបានសមិទ្ធផល កាន់តែច្រើនថែមទៀត

-គ្រួសារសហគមន៍ និងសង្គមមានកម្លាំងកាន់តែរឹងមាំមានកិត្តិយស កេរ្តិ៍ឈ្មោះនិងគ្មានសត្រូវណាហ៊ានបៀតបៀននោះទេ

-ការឯកភាពគ្នាជាធ្លុងមួយ គ្មានការប្រឆាំងដែលនាំឱ្យសង្គមគ្មានការបែកបាក់គ្នា

-ចុងក្រោយ គឺគ្រួសាររីកចម្រើន ជាតិរីកចម្រើន។

# ៨. សុជីវធម៌

## ៨.១.និយមន័យសុជីវធម៌

ពាក្យថា « សុជីវធម៌ » ជាចំណេះដឹងសណ្ដាប់ធ្នាប់ ការដឹងប្រមាណ ការគួរសមច្បាប់ជីវិតល្អ ឬរបៀបរស់នៅសមរម្យបានដល់លំនាំរស់នៅសភាពជាមនុស្សដែលប្លែកពីការរស់នៅរបស់សត្វតិរច្ឆាន [៥]។

---

[៥] កុក រស់ និង ហែម ឡាច ៖ ទស្សនៈនៃការរស់នៅប្រកបដោយគុណធម៌និងក្រមសីលធម៌មន្ត្រីសាធារណៈ គ.ស. ២០១៦ ទំព័រ១៥។

សុជីវធម៌ < សុ+ជីវ+ធម៌

សុ =ងាយស្រួល ល្អ ប្រពៃ។

ជីវ = ជីវិត អាយុ ការរស់នៅ។

ធម៌ = សភាវទ្រទ្រង់នូវសត្វលោក។

សុជីវធម៌ = ការរស់នៅសុខស្រួល ប្រកបដោយក្រមសីលធម៌។

### ៨.២.ប្រភេទសុជីវធម៌

សុជីវធម៌បែងចែកជា ៦ប្រភេទ ៖

-ការស្គាល់ហេតុផលគួរឬមិនគួរ

-ការស្គាល់ឋានៈរបស់ខ្លួននិងអ្នកដទៃ

-ការស្គាល់ប្រមាណជីវភាព

-ការស្គាល់កាលសម័យ

-ការស្គាល់ប្រជុំជននិងទីប្រជុំ

-ការស្គាល់មិត្រសម្លាញ់។

#### ក-ការស្គាល់ហេតុផល

បទប្បញ្ញត្តិនិងទំនៀមទម្លាប់ ឬពាក្យទូន្មានប្រៀនប្រដៅទាំងឡាយដែលប្រកបដោយគតិបណ្ឌិតបានទុកជាហេតុគួរមួយដែលជនពល់រូបត្រូវគោរពនិងប្រតិបត្តិតាម។ បើជនណាមិនដឹងមិនយល់ថាជាហេតុគួរហើយចេះតែប្រព្រឹត្តធ្វើផ្តេសផ្តាសតាមអំពើចិត្ត ជននោះប្រាកដជាទទួលផលអាក្រក់។ អ្នកដែលស្គាល់ពីបទប្បញ្ញត្តិនិងទំនៀមទម្លាប់ប្រកបដោយហេតុផលល្អគួរតាមកាលៈទេសៈតែងបានផលល្អសុខចម្រើនរស់នៅសមរម្យក្នុងចំណោមមនុស្ស។

ការស្គាល់ហេតុផលគួរមិនគួរច្បាស់ប្រាកដពីចិត្តគំនិតខ្លួនទើបអាចធ្វើខ្លួនឱ្យទៅជាមនុស្ស មានសុជីវធម៌ គឺស្គាល់ថាហេតុផលនេះល្អត្រូវតែប្រតិបត្តិតាមហេតុផលនេះអាក្រក់ត្រូវតែលះបង់។

#### ខ-ការស្គាល់ឋានៈរបស់ខ្លួននិងអ្នកដទៃ

ដើម្បីរស់នៅឱ្យបានសុខស្រួលក្នុងពិភពលោកដែលកម្មនិងធម្មជាតិបានបង្កើតមនុស្សមកឱ្យមានឋានៈមិនស្មើគ្នានោះ មនុស្សម្នាក់ៗត្រូវតែស្គាល់ឋានៈខ្លួននិងឋានៈអ្នកដទៃឱ្យបានច្បាស់ ហើយញ៉ាំងដំណើរជីវិតឱ្យប្រព្រឹត្តទៅតាមទំហំឋានៈរៀងៗខ្លួនទើបមានសម្ពន្ធភាពអាចទាក់ទង រួមគ្នាបានមិនប៉ះទង្គិចថ្នាំងថ្នាក់បែកបាក់គ្នា។ ពាក្យថាស្គាល់ឋានៈ គឺស្គាល់យសសក្តិជាតិ ត្រកូល វ័យ សេចក្តីចេះដឹងរបស់ខ្លួននិងអ្នកដទៃ។

#### គ-ការស្គាល់ប្រមាណជីវភាព

ការស្គាល់ប្រមាណជីវភាព បានន័យថា « ចេះបានចេះបង់, ចេះចាយចេះរក » បើចេះតែ ចង់បាន ចេះតែខំរកមិនគិតពីការខុសត្រូវអាក្រក់ល្អ គួរមិនគួរសោះនោះ នឹងធ្លាក់ទៅក្នុងផ្លូវអាក្រក់ ទុច្ចរិត មានការស៊ីសំណូក លួចប្លន់ជាដើម នាំឱ្យថោកទាបខូចកិត្តិយស ឬក៏ចេះតែខំរកមក មិនហ៊ានស៊ីចាយ ឱ្យសមឋានៈនោះ ក៏នាំឱ្យខូចកិត្តិយសដែរ ឈ្មោះថាជាអ្នកមិនស្គាល់ប្រមាណជីវភាពទៅវិញ។

### ឃ-ការស្គាល់កាលសម័យ

ដើម្បីរស់នៅក្នុងពិភពលោកនេះឱ្យបានសមរម្យទាន់សម័យនឹងគេ និងធ្វើឱ្យដំណើរ ជីវិតប្រព្រឹត្តទៅទាន់ព្រឹត្តិការណ៍ដែលជាហេតុនាំឱ្យបានលាភបានជ័យ សុខចម្រើន ត្រូវជាអ្នកស្គាល់ពេលវេលាដែលត្រូវដេក ដើរ ឈរ អង្គុយ និយាយ ស្តាប់ គិតធ្វើការងារឱ្យបានច្បាស់លាស់។

ម្យ៉ាងទៀត ត្រូវបំពេញករណីកិច្ចរបស់ខ្លួនឱ្យទាន់ល្បឿននៃដំណើរជីវិត ព្រោះជីវិតចេះ តែទៅមុខគ្រប់នាទីមិនត្រឡប់ថយក្រោយ ឬឈប់បង្អង់ចាំឱ្យយើងបំពេញករណីកិច្ចនេះសិននោះទេ។

ដូច្នេះបុគ្គលម្នាក់ៗ មិនត្រូវស្ទាប់ចិត្តគំនិតជាប់ជំពាក់ ចំពោះអារម្មណ៍ណាមួយយូរពេកទេ ត្រូវឱ្យមានចលនាប្រព្រឹត្តទៅឱ្យទាន់កាលសម័យនិងទាន់ដំណើរជីវិត។ ពេលសិក្សារៀនសូត្រ ត្រូវស្រូតប្រឹងប្រែងឱ្យទាន់ចំណេះដែលត្រូវចេះដឹង តាមទំហំជំនាន់វ័យរបស់ខ្លួន កុំគិតពីជជែកគ្នាលេងក្នុងម៉ោងដែលត្រូវសិក្សា។ បើយើងមិនស្រូតតាមឱ្យទាន់កាលៈទេសៈទេ អនាគតយើងត្រូវពេលវេលាទំពាស៊ីអស់ ពេលគេត្រូវមានប្រពន្ធកូនខ្លួនគ្មាន ពេលគេត្រូវមានចៅខ្លួនទើបនឹងមានប្រពន្ធ ចេះតែខុសដើរមិនទាន់សម័យ មិនទាន់ព្រឹត្តិការណ៍សោះ មកពីគ្មានសុជីវធម៌មិនស្គាល់កាលសម័យនៅក្រាញផ្សងព្រេងជាមួយកន្ទែងៗយូរពេក ដូចជាពេលប្រឡងរកការងារធ្វើ បើប្រឡង៣ដងមិនបានជាប់ហើយ កុំក្រាញនៅដាក់ដីម៉ង់ប្រឡងរាប់ឆ្នាំឱ្យទាល់តែគ្រប់ក្រសួងគ្មានសល់នោះឡើយ។

យើងត្រូវខិតខំស្វែងយល់ឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីរៀបចំការរស់នៅរបស់ខ្លួនឱ្យមានលក្ខណៈសមរម្យក្នុងសង្គមស៊ីវិល័យសម័យបច្ចេកវិទ្យានាយុគបច្ចុប្បន្ន។

### ង-ការស្គាល់ប្រជុំជននិងទីជំនុំ

ដើម្បីជាមនុស្សចុះជំនុំជុំចំណោមនឹងគេ ត្រូវចេះរបៀបរៀបចំពាក្យសំដីនិយាយ សើច ដេក ដើរ ឈរ អង្គុយ ស៊ី ផឹក ស្លៀកពាក់ សួរ ឆ្លើយ គោរព ក្រាបសំពះថ្វាយបង្គំ ចាប់ដៃ ងក់ក្បាល និងក្អកកណ្តាស់ជាដើម ឱ្យមានបែបបទសណ្តាប់ធ្នាប់ល្អ។

បើយើងមិនបានដឹង មិនចេះរបៀបរៀបចំទាំងនេះឱ្យមានបែបបទល្អទេ គេថាមនុស្សឥតសណ្តាប់ធ្នាប់ គ្មានសុជីវធម៌ ឬថាជាមនុស្សមិនចុះជំនុំទៅចូលចំណោមជំនុំនឹងគេក្នុងទីណានាំឱ្យអ្នកផងគេធុញទ្រាន់អាក់អន់រំខានចិត្ត អៀនខ្មាសដោយសារខ្លួនក្នុងទីនោះ។

### ច-ការស្គាល់មិត្រសម្លាញ់

បុគ្គលដទៃក្រៅពីមាតាបិតា ស្វាមីភរិយា បុត្រធីតា និងញាតិសន្តានរបស់ខ្លួនចេញ គ្មានបុគ្គលណាជាទីស្រលាញ់ស្និទ្ធស្នាលទុកចិត្តជួយផ្តល់ប្រយោជន៍ទៅវិញទៅមកជាងមិត្រសម្លាញ់ខ្លួនទេ មានតែមិត្រនេះហើយដែលអាចជួយគាំទ្រដំណើរជីវិត

អ្នកឱ្យប្រព្រឹត្តទៅស្រួល ប្រកបដោយជោគជ័យក្នុងលោកនេះ។

### ៨.៣.សុជីវធម៌ក្នុងក្របខណ្ឌការងារ

*ក-សុជីវធម៌រវាងអ្នកធំទៅអ្នកតូច*

*ប្រការគួរធ្វើ :*

*-និយាយដោយបោរីភាពជានិច្ច*

*-ចេះស្តាប់យោបល់អ្នកក្រោមបង្គាប់*

*-និយាយតែសាច់ការ*

*-លើកទឹកចិត្តដោយការសរសើរនិងជូនរង្វាន់។*

*ប្រការមិនគួរធ្វើ :*

*-ស្និទ្ធស្នាលហួសប្រមាណ*

*-ប្រើប្រាស់ភាសាមិនសមរម្យ*

*-ជជែកខ្វែងយោបល់ជាមួយអ្នកតូចជាង*

*-រំខានដល់ការងារអ្នកក្រោមបង្គាប់។*

*ខ-សុជីវធម៌រវាងអ្នកតូចទៅអ្នកធំ*

*ប្រការគួរធ្វើ :*

*-ប្រកាន់សេចក្តីគោរពជានិច្ច*

*-គោរពការសម្រេចចុងក្រោយរបស់ចៅហ្វាយនាយ*

*-និយាយតែការណាមានប្រយោជន៍ច្បាស់លាស់ ខ្លី ខ្លឹម។*

*ប្រការមិនគួរធ្វើ :*

*-តវ៉ា ប្រឆាំងជំទាស់ដោយឥតហេតុ-ផល*

*-សួរដេញដោលអ្នកធំច្រើនពេក*

*-រំខានពេលវេលារបស់ចៅហ្វាយនាយ។*

*គ-សុជីវធម៌សម្រាប់អ្នកមានឋានៈស្មើគ្នា*

*- សហប្រតិបត្តិការ ( ជួយរួមដៃ )*

*- សោមនស្សភាព ភាតរភាព*

*- មិនរំលោភបំពានការងារគ្នា*

*- បុរសត្រូវសន្តោសនារី។*

## ៩. សង្គហធម៌

### ៩.១.និយមន័យសង្គហធម៌

*សង្គហធម៌ គឺជាធម៌សម្រាប់សង្គ្រោះគ្នាទៅវិញទៅមក។ គ្រប់មនុស្សទាំងអស់នៅក្នុងលោក គួរតែមានសង្គហធម៌សង្គ្រោះដល់គ្នានឹងគ្នាទៅវិញទៅមកតាមជាន់ថ្នាក់ ទើបចក្រទាំងគូគឺ ពុទ្ធចក្រ និង អាណាចក្រ វិលទៅរកធម៌និងសុខសន្តិភាពជានិច្ចនិរន្តរ៍[៦]។*

### ៩.២.ប្រភេទសង្គហធម៌

*ក-សង្គហធម៌របស់ស្វាមីនិងភរិយា*

*សង្គហធម៌របស់ស្វាមីចំពោះភរិយា៖*

*-គប្បីលើកតម្កើងភរិយាឱ្យពេញទី*

*-មិនត្រូវមើលងាយភរិយា*

*-មិនត្រូវក្បត់ចិត្តភរិយា*

*-ត្រូវប្រគល់សិទ្ធិឱ្យភរិយាជាធំនៅក្នុងផ្ទះ*

*-ត្រូវឧស្សាហ៍ធ្វើអំណោយដល់ភរិយា។*

*សង្គហធម៌របស់ភរិយាចំពោះស្វាមី៖*

---

*[៦] កុក រស់ និង ហែម ឡាចះ ទស្សនៈនៃការរស់នៅប្រកបដោយគុណធម៌និងក្រមសីលធម៌មន្រ្តីសាធារណៈ ដ.ឯ.ម .ទំព័រ១៨*

-ត្រូវចាត់ចែងការងារផ្ទះដោយផ្ចិតផ្ចង់

-ត្រូវសង្គ្រោះញាតិទាំងសងខាងដោយល្អ មិនប្រកាន់ ឬធ្វើងព្រងើយ

-មិនត្រូវប្រព្រឹត្តក្បត់ចិត្តស្វាមី

-ត្រូវថែទាំទ្រព្យដែលស្វាមីរកបាន

-ឈ្លាសវៃ មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង។

**ខ-សង្គហធម៌របស់មាតាបិតានិងបុត្រ**

សង្គហធម៌របស់មាតាបិតាចំពោះបុត្រៈ

-ហាមកូនកុំឱ្យប្រព្រឹត្តខុស ឬធ្វើកម្មអាក្រក់ផ្សេងៗ

-អប់រំកូនចៅឱ្យធ្វើតែអំពើល្អ

-ទំនុកបម្រុងឱ្យសិក្សារៀនសូត្រ

-រៀបចំផ្សំផ្គុំបុត្រឱ្យមានគូស្រករ

-បែងចែកទ្រព្យធនដែលជាកេរមរតកតាមកាលសម័យសមគួរ។

សង្គហធម៌របស់បុត្រចំពោះមាតាបិតាៈ

-លោកបានចិញ្ចឹមកូន កូនគប្បីចិញ្ចឹមលោកវិញ

-បម្រើលោកដោយធ្វើកិច្ចការជំនួស

-រក្សាវង្សត្រកូលលោកឱ្យបានល្អ

-ថែរក្សាកេរមរតកនិងប្រព្រឹត្តខ្លួនជាមនុស្សល្អគួរទទួលមរតក

-កាលណាលោកអនិច្ចកម្មទៅត្រូវធ្វើបុណ្យឧទ្ទិសកុសលជូន។

**គ-សង្គហធម៌របស់គ្រូនិងសិស្ស**

សង្គហធម៌របស់គ្រូចំពោះសិស្សៈ

-អប់រំសិស្សឱ្យបានល្អ

-បង្រៀនសិស្សឱ្យបានចេះដឹង

-បង្រៀនសិស្សឱ្យអស់ដើងមិនលាក់វិជ្ជា

-លើកតម្កើងសិស្សក្នុងទីប្រជុំមិត្តភក្តិ

-ការពារកេរ្តិ៍ឈ្មោះសិស្សនិងធ្វើឱ្យសិស្សស្រឡាញ់រាប់អានគ្នា។

សង្គហធម៌របស់សិស្សចំពោះគ្រូៈ

-ត្រូវក្រោកឡើងទទួលដំណើរចូលនិងជូនដំណើរចេញ

-ត្រូវចូលទៅជិតដើម្បីបម្រើ

-យកចិត្តទុកដាក់ស្តាប់ឱវាទ

-ទំនុកបម្រុងផ្គងផ្គើមគ្រប់មធ្យោបាយ

-គោរពយ៉ាងស្មោះអស់ពីចិត្ត។

**ឃ-សង្គហធម៌របស់ចៅហ្វាយនិងកម្មករ ( ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ )**

សង្គហធម៌របស់ចៅហ្វាយចំពោះកម្មករៈ

-ចាត់ចែងនិងដាក់ការងារឱ្យធ្វើទៅតាមសមត្ថភាពនិងកម្លាំង

-ផ្តល់អាហារនិងកម្រៃប្រាក់ឈ្នួលឬបំណាច់រង្វាន់ទៅតាមសមត្ថភាពនៃការងារ

-ថែរក្សានិងព្យាបាលនៅពេលដែលមានជំងឺ ឬគ្រោះថ្នាក់ការងារ

-ចែករំលែកនូវអាហារដែលមានរសជាតិឆ្ងាញ់ក្នុងកាលម្តងៗ

-អនុញ្ញាតឱ្យឈប់សម្រាកពីការងារនៅពេលមានជំងឺ ឬនៅថ្ងៃបុណ្យទាន។

សង្គហធម៌របស់មន្ត្រីក្រោមឱវាទចំពោះថ្នាក់ដឹកនាំ

-ចូលធ្វើការមុនម៉ោង ឬមុនចៅហ្វាយនាយ

-ចេញពីធ្វើការក្រោយម៉ោងឬក្រោយចៅហ្វាយនាយ

-មិនលួចទ្រព្យសម្បត្តិចៅហ្វាយនាយ( ទទួលយកតែរបស់ណាដែលគាត់ឱ្យ )

-ធ្វើការងារដោយផ្ចិតផ្ចង់អស់ពីចិត្ត

-ពោលសរសើរការងារឬគុណសម្បត្តិរបស់គាត់។

## ១០. ទសពិរាជធម៌

### ១០.១-និយមន័យទសពិធរាជធម៌

ទសពិធរាជធម៌ ជាធម៌សម្រាប់ថ្នាក់ដឹកនាំមានជាអាទិ៍ ព្រះរាជា ប្រធានាធិបតី នាយករដ្ឋមន្ត្រី និងមន្ត្រីសាធារណៈទាំងអស់យកមកប្រតិបត្តិស្របតាមរបបគ្រប់គ្រងរដ្ឋ ទោះជាតាមទំនៀម ទម្លាប់ក្តី ឬតាមរដ្ឋធម្មនុញ្ញក្តី[៧]។

ទសពិធរាជធម៌១០យ៉ាង គឺធម៌១០ប្រការ សម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតី មន្ត្រីតូចធំ និងពួកប្រជានុរាស្ត្រឱ្យប្រព្រឹត្តផង។ ទសពិធរាជធម៌ជាក្រឹត្យក្រមច្បាប់ វិន័យដែលព្រះមហាក្សត្រ ឬ អ្នកដឹកនាំប្រទេសជាតិត្រូវតែប្រកាន់គោរព និងអនុវត្តតាមដោយហ្មត់ចត់ខ្ជាប់ខ្ជួននិងត្រឹមត្រូវជាទីបំផុត។ បើពុំនោះទេប្រទេសជាតិ ប្រជានុរាស្ត្រនឹងជួបប្រទះនូវវិបត្តិអន្តរាយ ក្តៅក្រហាយ រំជើបរំជួល ចលាចល អសន្តិសុខ សង្គ្រាម ទុក្ខសោក សង្រេងក័យព្រួយព្រាត់ប្រាស ក្រុមគ្រួសារញាតិសន្តាន ជាក់ជាមិនខាន។

### ១០.២.សមាសធាតុនៃទសពិធរាជធម៌

ទសពិធរាជធម៌ទាំង១០មានដូចជាៈ

-ទានៈ : ការឱ្យ

-សីលៈ : ការប្រព្រឹត្តល្អ

-បរិច្ចាគៈ : ការបរិច្ចាគ

-អាជ្ជវៈ : ការស្មោះត្រង់

-មទ្ទវៈ : ការទន់ភ្លន់

-តបៈ : ការដុតកិលេស

-អក្កោធៈ : ការមិនក្រោធ

-អវិហិង្សាៈ ការមិនបៀតបៀន

-ខន្តី : ការអត់ធន់

-អវិរោធនៈ : ការមិនធ្វើខុស

នៅក្នុងសង្គមមនុស្ស មនុស្សត្រូវការខ្ពស់បំផុតបន្ទាប់ពីជីវិតរស់នៅនោះគឺតម្លៃមនុស្ស។ មនុស្សដែលមានតម្លៃ គឺជាបុគ្គលទាំងឡាយណាដែលត្រូវបានសង្គមវាយតម្លៃផ្តល់តម្លៃជាមនុស្សល្អ មនុស្សត្រឹមត្រូវមិនគិតតែខ្លួនឯង ថាតែខ្លួនឯង ថាខ្លួនជា

[៧] កុក រស់ និង ហែម ឡាច ៖ ទស្សនៈនៃការរស់នៅប្រកបដោយគុណធម៌និងក្រមសីលធម៌មន្ត្រីសាធារណៈ ជ.ឯ.ម.ទំព័រ២២។

មនុស្សល្អ មនុស្សពូកែជាងគេគ្មាននរណាប្រៀបប្រដូចខ្លួនបាននោះទេ។ បុគ្គលដែលត្រូវសង្គមវាយតម្លៃថាល្អប្រសើរទៅជាឧត្តមបុគ្គល ជាកំពូលមនុស្សនោះលុះត្រាតែបុគ្គលទាំងនោះបានប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវធម៌ទាំង១០នោះ  ដូចជា ត្រូវមានចិត្តមេត្តាករុណាអាណិតឱ្យតម្លៃមនុស្សដូចគ្នា ប្រព្រឹត្តតែអំពើសុចរិតត្រឹមត្រូវ មិនកេងប្រវញ្ចកុហកបោកបញ្ឆោតអ្នកដទៃ ពេលជួបបញ្ហាត្រូវប្រើខួរក្បាលសម្រាប់ដោះស្រាយបញ្ហា មិនមែនប្រើកម្លាំងបាយស្រាយបញ្ហានោះទេ។ បន្ថែមពីលើនេះ បុគ្គលនោះត្រូវតែមានឆន្ទៈប្រកបដោយសច្ចធម៌ មានគំនិតចេះយល់យោគ ចេះអត់ឱនអធ្យាស្រ័យឱ្យមនុស្សដូចគ្នា ហើយគោលការណ៍មួយទៀតដែលគួរប្រកាន់ខ្ជាប់នោះគឺភាពស្មោះត្រង់ មិនប្រណែនឈ្នានីសមិនប្រកាន់ឫកពា ឬរើសអើង ដែលជាធាតុនៃសាមគ្គីធម៌។

ការនិយាយបែបនេះមិនមែនមានន័យថា បុគ្គលដែលមានតម្លៃជាមនុស្សល្អថ្លៃថ្នូរ មានតែការប្រកាន់ខ្ជាប់នូវគោលការណ៍តែ១០ដូចបានលើកមកធ្វើការសិក្សានោះទេ តែចំណុចទាំង១០នេះ គឺជាចំណុចសំខាន់ក្នុងការកំណត់តម្លៃមនុស្ស ជំរុញឱ្យមនុស្សរស់នៅប្រកបដោយ "  គុណធម៌ "។

## គន្ថនិទ្ទេស


១- កុក រស់ និង ហែម ឡាច ៖ ទស្សនៈនៃការរស់នៅប្រកបដោយគុណធម៌និងក្រមសីលធម៌មន្ត្រីសាធារណៈ គ. ស. ២០១៦

២- ខ្លូត ធីតា ៖ អរិយទ្រព្យដ៏ប្រសើររបស់មនុស្ស គ. ស. ២០១៣

៣- ប៉ិត សារង្ស ៖ សិក្ខាបទមនុស្សល្អ គ. ស. ២០០២

៤- ពុទ្ធសាសនបណ្ឌិត្យ ៖ វចនានុក្រមខ្មែរ គ. ស. ១៩៦៧

៥- សាកលវិទ្យាល័យបៀលប្រាយ ៖ សិល្បៈនៃការរស់នៅ គ. ស. ២០១២

៦- ហេង មណីចិន្តា ៖ ព្រះបាទធម្មិក គ. ស. ១៩៩៨

៧- Plato –The story of Philosophy, by will Durant, Page 11,12,13

# ការអនុវត្តការងាររដ្ឋបាលអប់រំនៃ
# វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីកក្នុងខេត្តត្បូងឃ្មុំ

The Implementation of the Educational Administration in Bun Rany Hun Sen Amporvorn Chhumnik High School in Tbong Khmum Province

*ដោយៈ លោក* **ប៉ាន់ សំណាង**

*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ,វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្ដីផ្ដើម

*ជាធម្មតា ក្នុងរដ្ឋនីមួយៗរមែងតែងតែមានអ្នកនយោបាយ និងមានអ្នកឯកទេសគិតគូរពីការរៀបចំ ការគ្រប់គ្រងរដ្ឋបាលនៃប្រទេសរបស់គេ[១]។ ប្រទេសកម្ពុជាបាននិងកំពុងធ្វើសកលភាវូបនីយកម្ម ជាមួយពិភពលោកនិងប្រទេសនានានៅក្នុងតំបន់ស្ទើរតែគ្រប់វិស័យ ដោយក្នុងនោះមាន សេដ្ឋកិច្ច សង្គមកិច្ច នយោបាយ សន្តិសុខ និងសិក្សាធិការជាដើមៗ ការធ្វើសកលភាវូបនីយកម្មនេះ គឺវិស័យព័ត៌មានវិទ្យាបានដើរតួនាទី យ៉ាងសំខាន់ក្នុងការជំរុញដំណើរការទាំងនោះ។ លើសពីនេះទៅទៀត ការអប់រំក៏មានតួនាទីសំខាន់ ដើម្បីតម្រង់ទិសដៅរបស់សិស្សានុសិស្សឱ្យចំគោលដៅសុខដុមរមនារបស់មនុស្សលោក។ នៅក្នុងន័យនេះ មេដឹកនាំអប់រំ ថ្នាក់ដឹកនាំសាលារៀន និងអ្នកវិភាគគោលនយោបាយអប់រំ ត្រូវពិចារណាទៅលើការផ្ដត់ផ្គង់ការអប់រំនិងតម្រូវការអប់រំរបស់ពលរដ្ឋក្នុងសង្គមៗ នៅក្នុងការផ្ដត់ផ្គង់ការអប់រំ អ្នកវិភាគត្រូវពិចារណាទៅបញ្ហា មិនគ្រប់គ្រាន់នៃការចុះឈ្មោះសិស្សគ្រប់អាយុចូលរៀន ការផ្ដត់ផ្គង់សាលារៀនមិនបានគ្រប់គ្រាន់ឱ្យសមស្របទៅនឹងកំណើនប្រជាពលរដ្ឋ និងកង្វះខាតធនធាននានា ដូចជាធនធានមនុស្ស ធនធានសម្ភារៈនិងធនធានហិរញ្ញវត្ថុជាដើម ។*

[១] *បណ្ឌិត សាយ បូរី នីតិរដ្ឋបាលទូទៅ ទំព័រ២៨ ២០០៦។*

ដោយឡែក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានខិតខំយ៉ាងសស្រាក់សស្រាំជាពិសេស ក្នុងកំឡុងពេលទសវត្សចុងក្រោយនេះ។ រាជរដ្ឋាភិបាល បានធ្វើការជំរុញ និងលើកកំពស់វិស័យអប់រំ យុវជន និងកីឡា ដែលជាវិស័យអាទិភាពមួយក្នុងចំណោម វិស័យទាំង៤មាន វិស័យអប់រំ សុខាភិបាល វិស័យអភិវឌ្ឍជនបទ និងវិស័យកសិកម្ម ដើម្បីអភិវឌ្ឍន៍ វិស័យសេដ្ឋកិច្ចដែលជាកត្តាចម្បង ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ជាពិសេសនៅទីជនបទដាច់ស្រយាលនៅប្រទេសកម្ពុជា។

ដើម្បីសម្រេចទិសដៅជាយុទ្ធសាស្ត្រ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្សយ៉ាងខ្លាំងពីព្រោះ ធនធានមនុស្ស គឺសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសជាតិរយៈពេលយូរអង្វែង។ទន្ទឹមនឹងនេះដែរ ការស្រាវជ្រាវនេះមានបំណងរកឱ្យឃើញជាក់ស្តែងនៃដំណើរការងាររដ្ឋបាលនៅវិទ្យាល័យមួយ ក៏ជាការសង្កេតនិងទាញយកនូវសូចនាករមកវិភាគនិងបកស្រាយឱ្យបានច្បាស់លាស់ ដើម្បីជាពន្លឺក្នុងការអនុវត្តបន្តទៀតរបស់អ្នកសិក្សាក្រោយៗ ជាពិសេសអ្នកគ្រប់គ្រងអប់រំ អ្នកគ្រប់គ្រងរដ្ឋបាលនាសម័យថ្មីនេះ ។



វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក ស្ថិតក្នុងខេត្តត្បូងឃ្មុំ (រូបភាពឆ្នាំ២០២២)



*រូបភាពបង្ហាញពីអគារធនធាននិងកន្លែងលេងកីឡាបាល់បោះ*

## ១. ស្ថានភាពទូទៅនៃវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក

### ១. ១. ប្រវត្តិសាលា

*វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក បានលេចជារូបរាងឡើងនៅពេលនេះ គឺដោយសារតែអំណោយដ៏ខ្ពង់ខ្ពស់ចេញពីទឹកចិត្តដ៏ថ្លៃថ្លារបស់* ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែនប្រមុខរាជរដ្ឋាភិបាល និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានីហ៊ុនសែន។***

*ការបង្កើតវិទ្យាល័យនេះឡើង ក្នុងគោលបំណងស្រូបយកសិស្សានុសិស្ស ពីឃុំបីនៃខេត្តពីរ គឺឃុំខ្សាច់អណ្តែត ស្រុកឆ្លូង ខេត្តក្រចេះ ឃុំជំនីកនិងឃុំរការខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ពីព្រោះពេលសិស្សបញ្ចប់ពីអនុវិទ្យាល័យទៅត្រូវទៅសិក្សានៅឆ្ងាយពេក។ ចំពោះសិស្សនៅឃុំខ្សាច់អណ្តែតត្រូវទៅសិក្សានៅ វិទ្យាល័យ*

សិលាវេទីគាតឈន់ឯទីរួមស្រុកឆ្លូង ហើយសិស្សានុសិស្សឃុំជំនីកនិងរការខ្នុរត្រូវទៅសិក្សាបន្តនៅវិទ្យាល័យក្រូចឆ្មារឯទីរួមស្រុកក្រូចឆ្មារឯណោះដែរ។ ដូច្នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានីហ៊ុនសែន** បានធ្វើការសម្រេចចិត្តបង្កើតវិទ្យាល័យនេះឡើងដើម្បីបំពេញសេចក្តីត្រូវការនិងការចង់ចេះចង់ដឹងរបស់ប្អូនៗ សិស្សានុសិស្សនៅតំបន់ជនបទនេះ។

សូមបញ្ជាក់ថា នៅឆ្នាំ២០០២ សាលានេះ ជាឧបសម្ព័ន្ធរបស់អនុវិទ្យាល័យសម្តេចហ៊ុនសែនរការខ្នុរ ដោយមានតែពីរថ្នាក់ទេ ពោលគឺមានតែកម្រិតថ្នាក់ទី៧ប៉ុណ្ណោះ។ នៅឆ្នាំ២០០៣ សាលា ក៏បានផ្តាច់ខ្លួនចេញ ពីអនុវិទ្យាល័យសម្តេចហ៊ុនសែនរការខ្នុរដែលមានឈ្មោះផ្លាល់ថា អនុវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែនជំនីកដោយមាន៤ថ្នាក់ ពោលគឺទី៧ពីរនិងទី៨ពីរថ្នាក់។ លុះមកដល់ឆ្នាំ២០០៥ អនុវិទ្យាល័យនេះ ក៏បានពង្រីកខ្លួនទៅជាវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែនជំនីក។

ក្រសួងអប់រំ យុវជននិងកីឡា បានទទួលស្គាល់ពីការពង្រីកអនុវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែន ជំនីកទៅជាវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែនជំនីក តាមរយៈប្រកាសលេខ ១៤២៣អយក.ប្រក ចុះថ្ងៃទី១០ខែតុលា ឆ្នាំ២០០៥។

### ១. ២. ឈ្មោះនិងទីតាំងសាលា

#### ១. ២. ១-ឈ្មោះ

តើហេតុអ្វីបានជាសាលានេះមានឈ្មោះថា **វិទ្យាល័យ**ប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែន **ជំនីក** ដូច្នេះ?

ហេតុផលគឺ៖

-ប៊ុនរ៉ានីហ៊ុនសែន ៖ វិទ្យាល័យនេះជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានីហ៊ុនសែន និង សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន ហើយទីតាំងសាលាជាអតីតសាលាបឋមសិក្សាដែលសម្តេចកិត្តិព្រឹទ្ធបណ្ឌិតធ្លាប់បានសិក្សាពីកុមារភាព[២]។

**-អម្ពវ៉ែនជំនីក** ៖ទីតាំងសាលាស្ថិតក្នុងបរិវេណវត្ត **អម្ពវ៉ែន** ហៅវត្ត ស្វាយដំណាក់ ដែលស្ថិតនៅក្នុងភូមិស្វាយដំណាក់ ឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ (អតីតខេត្តកំពង់ចាម)។

---

[២] *ពៅ សុខ ទឹកចិត្តអ្នកជួយសង្គ្រោះ បោះពុម្ពគ្រាទី១ ថ្ងៃទី១៥ ខែធ្នូ គ.ស.២០២០បានសរសេរះពីកុមារភាព រ៉ានីបានចូលសិក្សានៅសាលាបឋមសិក្សាអម្ពវ៉ែនក្នុងវត្តអម្ពវ៉ែន...។*

## ១. ២. ២. ទីតាំងសាលា

វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីកបានសាងសង់ឡើងក្នុងទីតាំងភូមិសាស្ត្រនៃទឹកដី ភូមិស្វាយដំណាក់ ឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ មានចម្ងាយប្រមាណ ៨១គីឡូម៉ែត្រពីទីរួមខេត្តកំពង់ចាម។ បើយើងធ្វើដំណើរពីទីរួមខេត្តកំពង់ចាមមក កាត់តាមផ្លូវជាតិលេខ៧ រួចបត់ចូលទីរួមស្រុកតំបែរមកកាន់ស្រុកឆ្លូង រួចបត់ឆ្វេងតាមបណ្ដោយផ្លូវក្រាលកៅស៊ូថ្មីៗ ឆ្ពោះទៅកាន់ស្រុកក្រូចឆ្មារវិញ តាមដងទន្លេមេគង្គលើ យើងនឹងមកដល់ឃុំជំនីក ឃើញវត្តជំនីក រួចវត្តអម្ពវ័ន។ នៅក្នុងបរិវេណវត្តអម្ពវ័ននេះហើយ អ្នកនឹងឃើញសំណង់អគារជាច្រើនសម្រាប់បម្រើសេវាកម្មអប់រំក្នុងនោះមានបឋមផងនិងវិទ្យាល័យផង។ វិទ្យាល័យនេះគឺ វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក។ ម្យ៉ាងទៀត យើងក៏អាចធ្វើដំណើរតាមស្ពានគីសូណាពីទីរួមខេត្តកំពង់ចាម រួចចុះតាមស្ពានបត់ឆ្វេងតាមមាត់ទន្លេដែលមានផ្លូវបេតុង ជិះត្រង់មកស្រុកក្រូចឆ្មារ ហើយមកដល់ឃុំជំនីកក្នុងបរិវេណវត្តអម្ពវ័ន យើងនឹងឃើញវិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក ដែលមានអគារដ៏ស្កឹមស្កៃ។



*ផែននទីបង្ហាញពីទីតាំងវិទ្យាល័យ **ប៊ុនរ៉ានីហ៊ុនសែន** អម្ពវ័នជំនីក ស្ថិតនៅភូមិស្វាយដំណាក់ ឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ*




*ផែនទីបង្ហាញពីទីតាំងវិទ្យាល័យ**ប៊ុនរ៉ានីហ៊ុនសែន**អម្ពវ័នជំនីក* (*ប្រភព៖* GoogleEarth)

## ១. ៣. រចនាសម្ព័ន្ធវិទ្យាល័យ

### ១.៣.១. តារាងបែងចែកមុខងារ

***វិទ្យាល័យ**ប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំ**នីក*** មាននាយករងមួយរូប[៣] និងបុគ្គលិកសិក្សា ៣៨រូប ដែលបែងចែកតួនាទីខាងក្រោម៖

[៣] *ដោយនាយករងមួយរូបត្រូវចូលនិវត្តន៍(ជាប់ឆ្នោតជាជំទប់ឃុំរការខ្នុរឆ្នាំ២០២២)*




### ១. ៣. ២. សកម្មភាពតាមតួនាទី

*ក- នាយកសាលា*[៤]

*នាយកសាលា មានតួនាទីទទួលខុសត្រូវរួម លើការងាររដ្ឋបាល ការងារបច្ចេកទេសគរុកោសល្យនិងអត្តបទការងារទំនាក់ទំនងនានា។*

*១- ការងាររដ្ឋបាល*

*- ជានាដំណើរការល្អរបស់សាលារៀន*

*- បែងចែកសិស្សានុសិស្សតាមថ្នាក់នីមួយៗ*

*- ចាត់ចែងបែងចែកការកិច្ចដល់បុគ្គលិកក្រោមឱវាទតាមសំណើរបស់ក្រុមប្រឹក្សាគ្រូបង្រៀន*

*- ជានានិយ័តភាពការបង្រៀននិងរៀនរបស់លោក-អ្នកគ្រូ*

*- ត្រៀមការការពារបរិស្ថាន សោភ័ណភាព និងអនាម័យក្នុងទីធ្លាសាលា ថ្នាក់រៀន ទីចាត់ការ អគារកាត់ដេរ តូបលក់ចំណីអាហារ ដើមឈើម្លប់ សួនផ្កា បង្គន់...*

*- ជានាឱ្យវិទ្យាល័យបំពេញនូវសេវាសាធារណៈ ដោយទទួលនិងការពារកុមារឱ្យបានល្អ*

---

*[៤] នៅប្រទេសជឿនលឿន សមាគមមាតាបិតាសិស្សជាអ្នកជ្រើសរើសនាយកសាលាបឋមសិក្សានិងមធ្យមសិក្សា។*

-ជានាសណ្តាប់ធ្នាប់និងវិន័យក្នុងសាលា ប្រកបដោយចីរភាព

- ចូលរួមបង្កើតក្រុមប្រឹក្សានានា ដូចជា ក្រុមប្រឹក្សាវិន័យ ក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សាអប់រំ ជាដើម

-ចាត់ចែងឱ្យមានការចូលរួមផ្សេងៗ របស់សាលារៀនក្នុងសកម្មភាពសង្គម

-រៀបចំទីចាត់ការសាលារៀន

-ធ្វើរបាយការណ៍ជូនថ្នាក់លើអំពីសកម្មភាពនានារបស់សាលារៀន

-ធ្វើអាជ្ញាកណ្តាលក្នុងការផ្សះផ្សាទំនាស់ផ្សេងៗ ដែលកើតមានក្នុងសាលារៀន

**២- ការងារបច្ចេកទេសគរុកោសល្យ**

នៅក្នុង**វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក** មាននាយក១រូប ទទួលបន្ទុករួម និងនាយករង១រូបដែរ ទទួលបន្ទុកបច្ចេកទេសគរុកោសល្យ វិន័យ និងយុវជន។ ចំពោះការងារបច្ចេកទេសគរុកោសល្យនេះ នាយកសាលាត្រូវ៖

-គ្រប់គ្រងការរៀន និងបង្រៀនជាភារកិច្ចស្នូលរបស់នាយកសាលា

-នាយកសាលាមិនត្រូវឃុំខ្លួនឯងតែនៅទីចាត់ការនោះទេ ដោយមិនព្រមទៅតាមដានពិនិត្យ ការបង្រៀន និងរៀនរបស់លោកគ្រូអ្នកគ្រូ និងប្អូនសិក្សានុសិស្សឱ្យបានញឹកញាប់

-នាយកសាលាត្រូវគោរពនិយ័តភាពការងារជាគំរូ ពិព្រោះនាយកល្អគឺជាអ្នកឈានមុខគេជានិច្ចដោយធ្វើជាគ្រូបង្រៀនដ៏ល្អផង និងជារដ្ឋបាលដ៏ល្អផង។

**៣. ការងារទំនាក់ទំនង**

ដើម្បីឱ្យមានប្រសិទ្ធភាពនៃការងារអប់រំ ការងាររដ្ឋបាល និងការងារបច្ចេកទេសគរុកោសល្យនោះទោះបីជាដំណើរល្អយ៉ាងណាដ៏ដោយ ក៏នាយកសាលាមិនអាចធ្វើការងារអប់រំរបស់ខ្លួនមានភាពរលូនទៅមុខណាស់ដែរ បើខ្វះទំនាក់ទំនងល្អនោះ។

ការងារទំនាក់ទំនងមានដូចខាងក្រោម ៖

**-ទំនាក់ទំនងផ្ទៃក្នុង**

ជាដំបូងនាយកសាលាត្រូវមានទំនាក់ទំនងល្អជាមួយសហការីរួមការងារ និងអ្នកដែលនៅក្រោមឱវាទ ដូចជា នាយករង គ្រូបង្រៀន បុគ្គលិកផ្សេងៗ ពិសេសប្អូនៗសិក្សានុសិស្ស។

**-នាយករង៖** នាយកសាលាត្រូវប្រគល់ភារកិច្ចឱ្យទៅនាយករងដែលជាជំនួយការឱ្យបានសមស្រប និងតាមសមត្ថភាព និងតាមតួនាទីដែលបានកំណត់។

ជាការពិតណាស់ នាយកមានតួនាទីសំខាន់បំផុតក្នុងការដឹកនាំការងារអប់រំ តែដាច់ខាតត្រូវអនុវត្តការគ្រប់គ្រង ដោយមានការចូលរួម គឺចូលរួមពីគ្រប់បុគ្គលិកទាំងអស់របស់សាលារៀន ពីសិស្សានុសិស្ស និងពីមាតាបិតា អាណាព្យាបាលសិស្សដែលក្នុងនោះរាប់ទាំងអាជ្ញាធរដែនដី ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ...។ល។

**ខ-នាយករង**

នៅក្នុង**វិទ្យាល័យ**ប៊ុនរ៉ានីហ៊ុនសែនអម្លាំងជំនីក មាននាយករងតែ១រូបទេដែលទទួលបន្ទុកបច្ចេកទេសគរុកោសល្យ វិន័យនិងយុវជន។ ភារកិច្ចដែលនាយករងទទួលខុសត្រូវមានដូចខាងក្រោម៖

-ជាជំនួយការរបស់នាយក។

-រក្សាទុកលិខិតស្នាមនានាដែលនាយកផ្ដល់ជូន និងធ្វើរបាយការណ៍ផ្សេងៗបញ្ជាក់ពីសកម្មភាពសាលារៀន។

-រក្សារបៀបរៀបរយ សណ្ដាប់ធ្នាប់និងវិន័យក្នុងអង្គភាព។

- ចូលរួមសកម្មភាពនានាតាមការចាំបាច់របស់សាលា, ចូលរួមបង្កើតក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាវិន័យ

- កសាងផែនការបច្ចេកទេស។

-គ្រូបង្រៀន និងបុគ្គលិកផ្សេងៗ៖ នាយកត្រូវបែងចែកភារកិច្ចសមនឹងសមត្ថភាព ព្រមទាំងចេះជួយណែនាំ លើកទឹកចិត្ត ផ្ដល់កិត្តិយស និងជួយសម្រួលការងារដើម្បីឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាព។

-**សិក្សានុសិស្ស៖** នាយកត្រូវបង្ហាញឱ្យសិស្សទាំងអស់ឃើញថា រាល់ការប្រឹងប្រែងរបស់នាយក គ្រូបង្រៀន សហគមន៍ និងវិធានការវិន័យចំពោះសិស្ស គឺដើម្បីជួយសិស្សទាំងអស់ឱ្យបានសម្រេចនៅលទ្ធផលល្អនៃការសិក្សាដែលបង្កឱ្យពួកគេមានអនាគតល្អពេលបញ្ចប់ពីការបណ្ដុះបណ្ដាលទៅ។

-**ទំនាក់ទំនងខាងក្រៅ**

តួនាទី និងភារកិច្ចទទួលខុសត្រូវអង្គភាពសាលារៀន នាយកសាលាត្រូវចំណាយពេលវេលាមួយចំនួនដើម្បីប្រាស្រ័យទាក់ទងជាមួយ៖

-មាតាបិតាឬអាណាព្យាបាលសិស្ស។

-សហគមន៍ សប្បុរសជន ជាតិនិងអន្តរជាតិ។

-អាជ្ញាធរ ដែនដី និង ភ្នាក់ងារស្ថាប័ននានាក្នុងភូមិឃុំ ដូចជា មណ្ឌលសុខភាព សមាគម អង្គការដែលផ្សារភ្ជាប់នឹងការងារអប់រំ រដ្ឋបាល បច្ចេកទេស។

- អភិវឌ្ឍបណ្ណាល័យ និងកសាងសម្ភារឧបទេស។

-ចូលរួមប្រជុំបច្ចេកទេស គរុកោសល្យ

- រៀបចំកាលវិភាគប្រចាំសប្តាហ៍តាមថ្នាក់នីមួយៗ។

-ត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សាដែលក្រសួងដាក់ជូន។

-បូកសរុបវាយតម្លៃលទ្ធផលការសិក្សា។

-មានទំនាក់ទំនងល្អនឹងនាយកបុគ្គលិក សិក្សា និងសិស្សានុសិស្ស។

**គ- គ្រូបង្រៀន**

គ្រូបង្រៀនមានឋានៈជាសិក្ខាបទធារី ជាកម្លាំងចម្បងក្នុងការអប់រំបណ្តុះបណ្តាលដល់សិស្សានុសិស្សដោយផ្ទាល់ដើម្បីឱ្យពួកគេសម្រេចបាននូវភារកិច្ចស្នូលរបស់ពួកគេក្នុងការសិក្សារៀនសូត្រ ។

-គ្រូបង្រៀនជាអ្នកជួយណែនាំ អប់រំ និងបង្ហាត់បង្រៀនដល់សិស្សានុសិស្ស

-គ្រូបង្រៀនជាអ្នកបច្ចេកទេសដែលបង្រៀនតាមឯកទេសរបស់ខ្លួន ដោយអនុវត្តស្របតាមវិធីសាស្ត្រដែលក្រសួងអប់រំ និងកីឡាបានដាក់ចេញ

-គ្រូបង្រៀនមិនអាចអភិវឌ្ឍសម្បទាចិត្តគោរុកោសល្យខ្លួនបានទេ បើគាត់មិនបង្រៀនតាមវិធីសាស្ត្រ

-គ្រូបង្រៀនត្រូវទទួលខុសត្រូវក្នុងការបង្រៀនស្របតាមកម្មវិធីសិក្សាប្រកបដោយគុណភាព ពីព្រោះគ្រូបង្រៀនជាជនគំរូ និងជាអ្នកកសាងធនធានមនុស្សជូនជាតិ សមស្របនឹងគោលនយោបាយរដ្ឋាភិបាល។

**ឃ.គ្រូបន្ទុកថ្នាក់**

ថ្នាក់រៀននីមួយៗ ត្រូវមានគ្រូទទួលបន្ទុកថ្នាក់មួយរូបតាមការចាត់តាំងរបស់នាយកសាលា។តួនាទីរបស់គ្រូទទួលបន្ទុកថ្នាក់ គឺជាគ្រូបង្រៀនមុខវិជ្ជាឯកទេស និងជាអ្នកគ្រប់គ្រងសិស្សផ្ទាល់ក្នុងមួយថ្នាក់។ គ្រូទទួលបន្ទុកថ្នាក់ មានសិទ្ធិអំណាចអាចអនុញ្ញាតឱ្យសិស្សឈប់យ៉ាងច្រើន២ថ្ងៃ។ បើមានច្បាប់ពីអាណាព្យាបាល ឬមាតាបិតាសិស្សនឹងចុះហត្ថលេខាព្រមទាំងមូលវិចារសៀវភៅសិក្ខាគារិក ព្រឹត្តបត្រពិន្ទុ និងសៀវភៅតាមដានសិក្សា។ គ្រូទទួលបន្ទុកថ្នាក់ មានភារកិច្ចដូចទៅះ

-បង្រៀនសិស្សតាមមុខវិជ្ជាឯកទេសដែលមានម៉ោងកំណត់១៣ម៉ោង សម្រាប់គ្រូ

មធ្យមសិក្សាទុតិយភូមិ និង១៥ម៉ោងសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ។

-សហការយ៉ាងជិតស្និទជាមួយគ្រូបង្រៀនមុខវិជ្ជាផ្សេងទៀតរបស់ថ្នាក់ដែលគ្រូទទួលបន្ទុក ដើម្បីឱ្យការសិក្សារបស់សិស្សប្រព្រឹត្តទៅសមស្រប។

-គ្រប់គ្រងថ្នាក់រៀនមួយក្នុងនោះមានគ្រប់គ្រងសិស្សក្នុងថ្នាក់រៀន ដោយជ្រើសរើសប្រធាន និងអនុប្រធានសិស្សប្រចាំថ្នាក់ចាត់តាំងវេនសម្អាតថ្នាក់ជាប្រចាំ។

-ណែនាំសិស្សឱ្យតុបតែងលម្អថ្នាក់រៀន។

-គ្រប់គ្រងវត្តមានសិស្សដោយទទួលពាក្យសុំច្បាប់របស់សិស្ស រួចបញ្ជូនទៅសុំការអនុញ្ញាតពីនាយកសាលា, តាមដានសៀវភៅវត្តមានសិស្ស, ស្រង់វត្តមានសិស្សរៀងរាល់ថ្ងៃរួចបញ្ចូលក្នុងបញ្ជីហៅឈ្មោះ និងបូកសរុបវត្តមានសិស្សប្រចាំខែ។

-គ្រប់គ្រងការសិក្សាដោយបូកសរុបក្នុងបញ្ជីពិន្ទុប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ

-តាមដានការសិក្សារបស់សិស្សគ្រប់មុខវិជ្ជា។

-ផ្សព្វផ្សាយលទ្ធផលសិក្សារបស់សិស្សរៀងរាល់ខែ ឆមាស និងតំណាច់ឆ្នាំ។

-ផ្តល់ព្រឹត្តបត្រពិន្ទុ ឬសៀវភៅតាមដានការសិក្សាដល់មាតាបិតាឬអាណាព្យាបាលសិស្ស ទំនាក់ទំនងជាមួយមាតាបិតាអាណាព្យាបាលសិស្ស ដើម្បីងាយស្រួលគ្រប់គ្រងវិន័យសិស្ស និងការសិក្សារបស់សិស្ស ចម្លងពិន្ទុដាក់ក្នុងសៀវភៅសិក្ខាគារិក និងព្រឹត្តបត្រពិន្ទុ រួចឱ្យគ្រូបង្រៀនគ្រប់មុខវិជ្ជាចុះហត្ថលេខា និងមូលវិចារ ហើយប្រគល់ជូននាយកសាលាចុះហត្ថលេខា និងបោះត្រា។

-អប់រំសីលធម៌ដល់សិស្សម្នាក់ៗផ្ទាល់ឬក្រុមសិស្សរួមថ្នាក់ កោះហៅសិស្សណាដែលប្រព្រឹត្តខុសនឹងបទបញ្ជាផ្ទៃក្នុងមកណែនាំឬព្រមាន កោះអញ្ជើញមាតាបិតាឬអាណាព្យាបាលសិស្សណាដែលឈប់អត់ច្បាប់ច្រើនដង ដើម្បីចូលរួមអប់រំណែនាំ បញ្ជូនសិស្សឲ្យទៅជួបក្រុមប្រឹក្សាវិន័យ ក្នុងករណីចាំបាច់[៥]

-ធ្វើរបាយការណ៍ពីវត្តមានសិស្សប្រចាំខែជូននាយកសាលា។

-គ្រប់គ្រងឯកសារផ្សេងៗ ដូចជាឯកសារបង្រៀន ឯកសារគ្រប់គ្រងថ្នាក់។

---

[៥] ចៅលិន ឯកសារបង្រៀនរដ្ឋបាលសិក្សានៅវិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០០៥។

-ចូលរួមសកម្មភាពសង្គមដោយដឹកនាំ បដិសណ្ឋារកិច្ចនិងសកម្មភាពសង្គមផ្សេងៗទៀត។ សិស្សធ្វើពលកម្មក្នុងនិងក្រៅសាលាដឹកនាំធ្វើ



រូបភាពសកម្មភាពសិក្សាក្នុងថ្នាក់និងស្វ័យសិក្សាក្នុងបណ្ណាល័យ



រូបភាពសកម្មភាពសិក្សាក្នុងថ្នាក់និងស្វ័យសិក្សាក្នុងបណ្ណាល័យ



រូបភាពសិស្សានុសិស្សខ្មែរអ៊ីស្លាមសិក្សាជាក្រុមក្នុងបណ្ណាល័យ

**ខ.លេខាធិការ**

***វិទ្យាល័យ***ប៊ុនរ៉ានីហ៊ុនសែនអម្ពវ័ន ***ជំនីក***នេះ មានលេខាធិការម្នាក់ដែលមានជំនាញរដ្ឋបាល កំព្យូទ័រសម្រាប់ធ្វើជាជំនួយការនាយកសាលា។ ភារកិច្ចរបស់លេខាធិការរួមមាន៖

-រៀបចំទុកដាក់បញ្ជីឯកសារផ្សេងៗ

-ទទួលខុសត្រូវលើការងារលិខិតស្នាម

-ការងារទំនាក់ទំនងជាមួយមន្ត្រីអប់រំនិងគ្រូបង្រៀនក្នុងសាលា

-ជួយសម្រួលការងារចរន្តរបស់ទីចាត់ការ

-ជួយការងាររដ្ឋបាលរបស់នាយកសាលា។

**ច.បណ្ណារក្ស**

ចំពោះបណ្ណារក្ស មានភារកិច្ចដូចខាងក្រោម៖

-រៀបចំនិងគ្រប់គ្រងបណ្ណាល័យ និងទុកដាក់សៀវភៅរបស់សាលារៀន

-បង្កលក្ខខណ្ឌឱ្យសិស្សខ្ចីសៀវភៅអាននៅផ្ទះ ដោយមានការណែនាំឱ្យគេជួយថែឱ្យបានល្អផង

-ថែរក្សាសៀវភៅ សម្ភារឧបទេសនិងធ្វើសៀវភៅសារពើភណ្ឌ

-ធ្វើគម្រោងចំណាយលើការទិញសៀវភៅថ្មី ជួសជុលសៀវភៅខូចហែកនិងសម្ភារៈបរិក្ខាសម្រាប់ទុកដាក់សៀវភៅ។

**ឆ.គណនេយ្យករ**

គណនេយ្យករមានភារកិច្ចជារួមមានៈ

-រៀបចំលិខិតស្នាមដែលពាក់ពន្ធនិងចំណូលចំណាយរបស់សាលា

-ធ្វើតុល្យភាពចំណូលចំណាយ

-ធ្វើរបាយការណ៍តុល្យភាពចំណូលចំណាយជូននាយកវិទ្យាល័យតាមកាលកំណត់

-រៀបចំធ្វើផែនការPBរបស់សាលា

-រៀបចំលិខិតស្នាមដែលទាក់ទង និង PB (Program Budget)។

**១. ៤.ការងារទូទៅនៃវិទ្យាល័យ**

**១. ៤. ១. ការរៀបចំផែនការ**

រយៈកាលកន្លងមក ***វិទ្យាល័យ***ប៊ុនរ៉ានីហ៊ុនសែនអម្ពវន័***ជំនីក*** បានរៀបចំការប្រជុំពីផែនការអភិវឌ្ឍន៍សាលារៀនទុកជាមុន ដោយមានការចូលរួមពីសំណាក់លោកនាយក នាយករង តំណាងសហគមន៍ និងលោកគ្រូ អ្នកគ្រូទាំងអស់នៃវិទ្យាល័យ។ ប្រធានបទនៃអង្គប្រជុំរួមមាន:

-បែងចែកគ្រូ តាមមុខវិជ្ជា

-ចែកសិស្សតាមថ្នាក់

-ធ្វើអត្រាឡើងថ្នាក់ និងត្រួតថ្នាក់របស់សិស្ស

-សម្អាតបរិស្ថាន

-ព្រាងគ្រូតាមមុខវិជ្ជាទប់ស្កាត់ការខ្វះគ្រូ

-ចែកគ្រូតាមកម្រិតថ្នាក់

-ថែរក្សាសណ្តាប់ធ្នាប់ក្នុងវិទ្យាល័យ

-បែងចែកកម្មវិធីសិក្សាក្នុងឆ្នាំនីមួយៗ

-ពង្រឹងគុណភាពគ្រូតាមរយៈការប្រជុំក្រុមបច្ចេកទេស

-ត្រួតពិនិត្យវាយតម្លៃការសិក្សារបស់សិស្ស

-ត្រៀមលក្ខណៈឱ្យអគារកាត់ដេរមានដំណើរការ

-ត្រៀមផែនការឱ្យគ្រូដែលមិនទាន់ចេះកុំព្យូទ័រ ចេះកុំព្យូទ័រ

-ត្រៀមរៀបចំឱ្យមានភ្លើងប្រើប្រាស់គ្រប់គ្រាន់

-ពង្រឹងគុណភាពសិស្ស ពិសេសសិស្សថ្នាក់ទី១២ ឱ្យប្រឡងជាប់សញ្ញាបត្រទុតិយភូមិបានអត្រាខ្ពស់។

**១. ៤. ២.កិច្ចការរដ្ឋបាល**

ផ្នែករដ្ឋបាល ជាឆ្អឹងខ្នងនៃវិទ្យាល័យនេះ។ បុគ្គលិកជំនាញរដ្ឋបាល មានភារកិច្ចរៀបចំឱ្យមានសៀវភៅនិង បញ្ជីផ្សេងៗដែល

នាយកសាលាបានប្រគល់ឱ្យ ដោយក្នុងនោះមាន៖

*-**បញ្ជីអត្តលេខ៖** បុគ្គលិករដ្ឋបាលបានរៀបចំសិស្សដែលចូលរៀនឆ្នាំនីមួយៗឱ្យមានអត្តលេខគ្រប់ៗគ្នា ដើម្បីងាយស្រួលក្នុងការចុះនៅលើសៀវភៅសិក្ខាគារិកនិងកាតសំគាល់ខ្លួនរបស់សិស្សតាមឆ្នាំសិក្សា។*

*-**សៀវភៅសិក្ខាគារិក៖** បុគ្គលិករដ្ឋបាល បានរៀបចំលិខិតសុំសៀវភៅសិក្ខាគារិក ពីគ្រប់អនុវិទ្យាល័យទាំងអស់ដែលមានសិស្សមកបន្តការសិក្សានៅវិទ្យាល័យនេះ ដើម្បីត្រៀមរៀបចំបែងចែកតាមឈ្មោះសិស្សានុសិស្សទាំងនោះ។*

*-**សៀវភៅស្រង់អវត្តមាន៖** ពេលបើកបវេសនកាលក្នុងឆ្នាំសិក្សានីមួយៗ រដ្ឋបាលបានបែងចែកសៀវភៅចុះអវត្តមានសិស្សតាមថ្នាក់នីមួយៗនិងមានសៀវភៅសម្រាប់ចុះអវត្តមានគ្រូ។*

*-**សៀវភៅកំណត់ចាត់ការ៖** ពេលវិទ្យាល័យចាប់ផ្ដើមបើកបវេសនកាលនៅឆ្នាំសិក្សានីមួយៗ បុគ្គលិករដ្ឋបាលបានរៀបចំសៀវភៅកំណត់ចាត់ការផ្សេងៗក្នុងពេលដំណើរការសកម្មភាពនានាក្នុងសាលា។*

*-**សៀវភៅផែនការប្រចាំវិទ្យាល័យ៖** នៅក្នុងវិទ្យាល័យមួយ អាចដំណើរការបានល្អលុះត្រាតែសាលាមានការ រៀបចំផែនការឱ្យបានច្បាស់លាស់ប្រកបដោយភាពត្រឹមត្រូវ ដូចជា រៀបចំផែនការប្រឡងឆមាស ប្រឡងសិស្សពូកែ ប្រឡងថ្នាក់ជាតិជាដើម។*

*-**បញ្ជីសារពើភ័ណ្ឌ៖** បុគ្គលិករដ្ឋបាលត្រូវរៀបចំសង្ហារិមនិងសម្ភារៈក្នុងបន្ទប់នីមួយៗដោយបំពាក់សម្ភារៈឧបទេស ជាច្រើនដើម្បីឱ្យលោកគ្រូអ្នកគ្រូងាយស្រួលបង្រៀនពិសេសបន្ទប់សិស្សថ្នាក់ទី១២*

*-**សៀវភៅចំណូលចំណាយ៖** បុគ្គលិករដ្ឋបាល រៀបចំសៀវភៅចំណូលចំណាយឱ្យបានច្បាស់លាស់ដាច់ពីគ្នា ដើម្បីងាយស្រួលក្នុងការទូទាត់ PB ឬ PAP។*

*-**លិខិតបញ្ជាក់ការសិក្សា៖** នៅដើមឆ្នាំសិក្សានីមួយៗ សិស្សដែលជាកូនមន្ត្រីរាជការនានាតែងមកធ្វើលិខិតបញ្ជាក់ការសិក្សា ដើម្បីទូទាត់បៀវត្សប្រចាំខែរបស់ពួកគាត់។*

### ១. ៤. ៣. ផ្នែកហិរញ្ញវត្ថុ

*នាយកសាលា បានបែងចែកអ្នកគ្រប់គ្រងហិរញ្ញវត្ថុរួមមាន "នាយករងមួយនាក់ គណនេយ្យករមួយនាក់"។*

-នាយករង មានតួនាទីទទួលបន្ទុកការងារលិខិតស្នាមដែលពាក់ព័ន្ធនឹងថវិការបស់សាលា។

-គណនេយ្យករ មានតួនាទីធ្វើលិខិតស្នាមផ្សេងៗដែលទាក់ទងនឹងចំណូលចំណាយផ្សេងៗរបស់សាលា។

**១.៤.៤.ការបែងចែកគ្រូតាមមុខវិជ្ជា**

នៅវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីកក្នុងពេលត្រៀមបើកបវេសនកាលនីមួយៗ នាយកសាលា បានប្រគល់ការងារឱ្យនាយករងធ្វើការបែងចែកគ្រូតាមមុខវិជ្ជានៃក្រុមនីមួយៗឱ្យបានគ្រប់ម៉ោងនឹងគ្រប់កម្រិតថ្នាក់ស្របនឹងចំនួនសិស្សក្នុងឆ្នាំសិក្សានីមួយៗ។ តាមក្រុមបច្ចេកទេសមានពីរក្រុមគឺក្រុមវិទ្យាសាស្ត្រធម្មជាតិ ឬ វិទ្យាសាស្ត្រពិត និងក្រុមវិទ្យាសាស្ត្រសង្គម។

-ក្រុមវិទ្យាសាស្ត្រសង្គមមាន: ភាសាខ្មែរ ប្រវត្តិវិទ្យា ភូមិវិទ្យា ពលរដ្ឋវិជ្ជា គេហកិច្ច ភាសាអង់គ្លេស

-ក្រុមវិទ្យាសាស្ត្រពិតមាន: គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា។

**១.៤.៥.ការបែងចែកសិស្សតាមថ្នាក់**

បុគ្គលិកដែលទទួលបន្ទុកការងាររដ្ឋបាល បានយកចិត្តទុកដាក់ខ្ពស់ក្នុងការបែងចែកសិស្សតាមថ្នាក់ដោយឱ្យមានរបាយសិស្សប្រុសស្រីស្មើៗគ្នាតាមបន្ទប់នីមួយៗ។ នេះជាចំណុចមួយដែលត្រូវយកចិត្តទុកដាក់លើសមភាពយេនឌ័រវាងសិស្សប្រុសនិងសិស្សស្រី។នាយក ត្រូវពិនិត្យលើចំណាត់ការនេះឱ្យបានល្អនិងច្បាស់លាស់ ព្រោះការរៀបចំរបាយសិស្សនេះ ក៏ជាផ្នែកមួយសំខាន់ដែលជះឥទ្ធិពលដល់ការបង្រៀននិងរៀនរបស់គ្រូនិងសិស្សដែរ។



រូបភាពបង្ហាញសកម្មភាពសិស្សានុសិស្សជួយរៀបចំអគារកាត់ដេរ

## ២. ការអនុវត្តរដ្ឋបាល

### ២. ១. អ្នករដ្ឋបាលជាអ្វី?

មុននឹងឆ្លើយថា អ្នករដ្ឋបាលជាអ្វី យើងត្រូវដឹងថារដ្ឋបាលជាអ្វីសិន។ តាមលោកបណ្ឌិត សាយ បូរី បានសរសេរអំពីរដ្ឋបាលៈ «ដំបូង តាមន័យទូលំទូលាយ ពាក្យថា រដ្ឋបាល (administration) ជូនកាលសម្ដៅលើ « សកម្មភាពគ្រប់គ្រង» ជូនកាលលើ «អង្គការ» ដែលគ្រប់គ្រង។ ន័យទាំងពីរនេះ អាចប្រើបានទាំងខាងវិស័យឯកជន ទាំងខាងវិស័យសាធារណៈ។[៦] តាមឯកសារមួយទៀតបានលើកឡើងថា រដ្ឋបាល មានន័យថា ការត្រួត

[៦] បណ្ឌិត សាយ បូរី នីតិរដ្ឋបាលទូទៅ ២០០៦ ទំព័រ១០។

ពិនិត្យ ឬ គ្រប់គ្រងចាត់ចែងនូវជំនួញ ការិយាល័យ ឬការត្រួតពិនិត្យទៅលើមនុស្ស (Administration is controlling or managing a business, office, etc....; people in control)។[៧]

អ្នករដ្ឋបាល គឺជា សេនាធិការមួយឱ្យថ្នាក់ដឹកនាំ ស្ថាប័នក៏ដូចជាការិយាល័យ មន្ទីរក្រោមឱវាទទាំងអស់។ អ្នករដ្ឋបាល ត្រូវចេះពីការងាររដ្ឋបាលឱ្យបានច្បាស់លាស់ ដូចជាការប្រើប្រាស់ឬធ្វើលិខិតស្នាមនានា ពិនិត្យលិខិតចេញចូល រៀបចំផែនការ និងការងារផ្សេងៗក្នុងអង្គភាពខ្លួនដោយលៃយ៉ាងណាឱ្យមានដំណើរការល្អ ផ្សារភ្ជាប់នឹងការរៀបចំរចនាសម្ព័ន្ធក្នុងសាលារៀន ក្នុងទីចាត់ការបន្ទប់ប្រជុំថ្នាក់រៀនជាដើម។

## ២. ២. ការងាររដ្ឋបាលទូទៅ

ជាទូទៅ ការងាររដ្ឋបាលផ្សារភ្ជាប់នឹងការគ្រប់គ្រង ដោយទាក់ទិននឹងដំណើរប្រព្រឹត្តទៅនៃស្ថាប័នឬអង្គភាពណាមួយ ។ ជាពិសេស និយាយដល់រដ្ឋបាល គឺ និយាយដល់ការអនុវត្តការងារទាំងសកម្មភាពនិងទាំងលិខិតស្នាម។

### ២. ២. ១. ការងារគ្រប់គ្រង

#### ក.អ្នកគ្រប់គ្រង

អ្នកគ្រប់គ្រង ជាអ្នកដែលមានចំណេះដឹងខ្ពស់អំពីវិធានការការងាររបស់ខ្លួន។ ម្យ៉ាងទៀត ត្រូវចេះផ្លាស់ប្តូរ កែលម្អឱ្យមានការរីកចំរើននៅថ្ងៃអនាគត ទើបទាក់ទាញមនុស្សគ្រប់រូបឱ្យចេះធ្វើការ ចេះគោរពពេលវេលានិងចេះអប់រំកូនចៅជំនាន់ក្រោយឱ្យក្លាយជាពលរដ្ឋល្អមានប្រយោជន៍សម្រាប់សង្គមជាតិ ។

អ្នកគ្រប់គ្រង គួរយកចិត្តទុកដាក់នូវចំណុចខាងក្រោម៖

-កន្លែងអង្គុយមិនចង្អៀត

-ការងារមានលក្ខណៈជាប្រព័ន្ធ

-ចំណាយសមស្រប

-តម្រូវការជានា

-ភាពមាំទាំប្រើបានយូរ

-បម្រុងទុកមុន

-ការប្រើប្រាស់ពណ៌

-គ្មានភាពស្មុគស្មាញ

-ការថែទាំ

-មានប្រដាប់ប្រដាណែនាំឱ្យមានផាសុកភាព សុវត្ថិភាព

អ្នកគ្រប់គ្រង ត្រូវអនុវត្តគោលនយោបាយ ជាតិដែលពាក់ព័ន្ធនឹងការគ្រប់

[៧] ដកស្រង់ចេញពីវចនានុក្រម Oxford Basic English Dictionary 1993 ទំព័រ៣។

គ្រងនៅតាមមូលដ្ឋាន ពិសេសតាមមហាវិទ្យាល័យ ។

អ្នកគ្រប់គ្រង មានអ្នកគ្រប់គ្រងថ្នាក់ទាបនិងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ ។

**-អ្នកគ្រប់គ្រងថ្នាក់ទាប**

សិទ្ធិអំណាច ទទួលបានដោយផ្អែកលើគោលការណ៍ច្បាប់ជាធំ ដើម្បីអនុវត្តន៍នូវរាល់ការងារ។ ការធ្វើការសម្រេចចិត្តរបស់អ្នកគ្រប់គ្រងថ្នាក់ទាបមាននិន្នាការធ្វើឱ្យងាយស្រួល ដល់បន្ទុកការងារប្រតិបត្តិដ៏ធ្ងន់ធ្ងរ និងធ្វើឱ្យថ្នាក់លើមានពេលវេលាពិនិត្យលើការងារសំខាន់ៗ។ អ្នកគ្រប់គ្រងថ្នាក់ទាបអាចស្គាល់បញ្ហាបានល្អ ហើយអាចធ្វើ សេចក្តីសម្រេចបានល្អដែរ ។ ទោះបីជាយ៉ាងនេះក្តី ក៏អ្នកគ្រប់គ្រងថ្នាក់ទាប អាចជួបបញ្ហាខ្លះៗដូចជាៈ

-ភាពស្ទាក់ស្ទើរក្នុងការប្រគល់សិទ្ធិអំណាច

-ខ្ញុំអាចធ្វើការងារនេះដោយខ្លួនខ្ញុំបាន

-អ្នកថ្នាក់ទាបរបស់ខ្ញុំគ្មានសមត្ថភាពទេ

-ខ្ញុំប្រើពេលច្រើនដើម្បីពន្យល់កិច្ចការនឹង

-អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ខ្លាចបាត់បង់អំណាច

-ខ្វះជំនឿ អ្នកគ្រប់គ្រងថ្នាក់ទាបអាងលើជំនាញនិងបទពិសោធន៍ខ្លួន

-ភាពស្ទាក់ស្ទើរក្នុងការទទួលអំណាច[៨]។

**-អ្នកគ្រប់គ្រងថ្នាក់ខ្ពស់**

ការសម្រេចចិត្តសំខាន់ៗទាំងអស់ ត្រូវបានធ្វើឡើងដោយអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ ដើម្បីរក្សាលំនឹងសកម្មភាពរបស់ស្ថាប័ន។ ក្នុងនោះដែរអ្នកគ្រប់គ្រង អាចមានបទពិសោធន៍ច្រើន និងអាចធ្វើសេចក្តីសម្រេចបានល្អជាងអ្នកគ្រប់គ្រងថ្នាក់ទាប។ អ្នកគ្រប់គ្រងថ្នាក់ខ្ពស់មានការយល់ទូលំទូលាយ និងអាចថ្លឹងថ្លែងពីតម្រូវការនៃផ្នែកផ្សេងៗរបស់ការិយាល័យក្នុងការសម្រេចចិត្ត។ ការដឹកនាំក្នុងការិយាល័យឬក្នុងស្ថាប័នមួយត្រូវប្រគល់អំណាចទាំងឡាយទៅឱ្យថ្នាក់ដឹកនាំថ្នាក់ខ្ពស់។ អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ មានភាពលំបាកស្មុគស្មាញដោយបន្ទុកការងារធ្ងន់ពេក ពោលគឺថ្នាក់លើត្រូវធ្វើការសម្រេចចិត្តតាំងពីកិច្ចការតូចតាចរហូតដល់ការងារធំ ហើយអាចធ្វើឱ្យការងារនោះយឺតយ៉ាវទៀតផង។

---

[៨] ក្រសួងអប់រំ ការងាររដ្ឋបាល ឆ្នាំ២០០២ ទំព័រ២៥។

### ខ.ច្បាប់នៃការគ្រប់គ្រង

បុគ្គលិកម្នាក់១ ត្រូវមានគុណភាព លទ្ធភាព និង មានស្មារតីភ្ញាក់រលឹក ដើម្បីតួនាទីរបស់ខ្លួន។ មន្ត្រីជាម្ចាស់ការិយាល័យ ស្ថាប័ន ធ្វើយ៉ាងណាឱ្យការិយាល័យ និង ស្ថាប័នរីកចម្រើនលូតលាស់ជានិរន្តរ៍។ កត្តាដែលជាគ្រឹះដ៏រឹងមាំជានាឱ្យសម្រេចតួនាទីជាអ្នកគ្រប់គ្រងល្អត្រឹមត្រូវកម្រិតខ្ពស់បានត្រូវមានសីលធម៌ល្អ៥ប្រការ គឺ៖

-ស្មោះត្រង់ជានិច្ចចំពោះមាតុភូមិ

-បម្រើប្រយោជន៍អ្នកក្រោមឱវាទរបស់ខ្លួន

-មានវិន័យសាមគ្គីល្អជាគម

-ខិតខំរៀនសូត្រ លើកកម្ពស់សមត្ថភាពលើមុខជំនាញគ្រប់បច្ចេកទេស

-រស់នៅស្អាតស្អំ[៩]

-សមត្ថភាព លើមុខជំនាញគ្រប់បច្ចេកទេស

ជាទូទៅ ការិយាល័យឬស្ថាប័នមួយមានភាពរីកចម្រើន ក៏វាអាស្រ័យនឹងវិន័យព្រមទាំងបទបញ្ជាផ្ទៃក្នុងផងដែរ។ បទបញ្ជាផ្ទៃក្នុង មានជាអាទិ៍ ដូចខាងក្រោម៖

-មាននិយ័តភាពក្នុងការងារ

-សំលៀកបំពាក់សមរម្យ

-ចុះវត្តមានរាល់ថ្ងៃ

-ត្រូវមានដំណឹងពេលមានធុរៈ

-ខិតខំបំពេញការងារ

-មិនត្រូវរំខានដល់អ្នកដទៃ

-ជួយទំនុកបម្រុង និងការពារសម្បត្តិរបស់ការិយាល័យឬស្ថាប័ន

-ចូលរួមការពារសុវត្ថិភាពការងារ

-រក្សាសណ្តាប់ធ្នាប់

-គោរពការចាត់តាំង

-រក្សាការសម្ងាត់នៃការងារ

-មានចរិយាស្លូតបូត សមរម្យ

-មិនត្រូវយកឯកសារទៅផ្ទះ

-មិនត្រូវធ្វើការងារឯកជនក្នុងម៉ោងធ្វើការងារ

-មិនត្រូវលេងល្បែងស៊ីសងគ្រប់ប្រភេទ។

### ២. ២. ២.ការងាររដ្ឋបាល

អ្នកជំនាញរដ្ឋបាល គឺជាអាជ្ញាកណ្តាលសម្រាប់ផ្សះផ្សាទំនាស់ផ្សេងៗក្នុងអង្គភាពជំនួសថ្នាក់ដឹកនាំមួយចំនួនដែលអវត្តមានឬមានបេសកកម្មចុះទីកន្លែងឆ្ងាយ។ អ្នកជំនាញរដ្ឋបាល បំពេញការងារតាមភារកិច្ចរបស់ខ្លួនច្បាស់លាស់ ហើយទើប ពិនិត្យតាម

[៩] ជ សោ រដ្ឋបាលអប់រំ ២០០៦ ទំព័រ៩៦។

ផ្នែក (លិខិតចូល លិខិតចេញ របាយការណ៍ សរុបរបាយការណ៍) រួចហើយទើបអ្នកជំនាញទាំងនោះ ត្រូវធ្វើការវាយតម្លៃការងាររបស់ខ្លួនដែលបានបំពេញ។

នៅក្នុងអង្គភាពមួយ មានការរីកចម្រើនបាន លុះត្រាតែអ្នកគ្រប់គ្រងនៅទីនោះ មានការបែងចែកភារកិច្ច និង តួនាទីរបស់បុគ្គលិកឱ្យបានច្បាស់លាស់។ រីឯការងារលិខិតស្នាម ត្រូវមានការគ្រប់គ្រងឱ្យបានល្អ ពោលគឺមានបច្ចេក ទេសត្រឹមត្រូវលើការងារនោះ ។

បច្ចេកទេសទុកដាក់ឯកសារ គឺគោរពតាមលំនាំខាងក្រោម៖

-លក្ខណៈរឿងតាមកាល

-លក្ខណៈរឿងតាមប្រភេទ

-លក្ខណៈរឿងតាមនិទ្ទេស

-លក្ខណៈរឿងតាមការវិភាគ

-លក្ខណៈរឿងតាមអក្សរ

ការគ្រប់គ្រងឯកសារបានល្អ មានសារប្រយោជន៍ណាស់ ពោលគឺ៖

-ដំណើរការងារងាយស្រួល ពិសេសពេលយកមកប្រើវិញ

-ធ្វើឱ្យមានការប្រែប្រួលទៅអនាគត

-ធ្វើឱ្យមានការចំណាយទាប

-ធ្វើឲ្យមានសុវត្ថិភាព

-ធ្វើឲ្យមានភាពសមរម្យនិងត្រឹមត្រូវ

-ធ្វើឲ្យមានស្តង់ដារនៅក្នុងអង្គភាពឬការិយាល័យនានា ខ្លឹមសារទម្រង់លិខិតសំណោរផ្លូវការ ចែកចេញជា៖

.រដ្ឋបាលមានៈរូបភាព សណ្ឋាន ប្រភេទ អត្ថន័យ លក្ខណៈ លក្ខណៈពិសេស

-រូបភាព៖ កិច្ចការរដ្ឋបាលត្រឹមត្រូវដែលអាចយកជាការបាន លុះត្រាតែមានរូបភាពជាក្រដាសស្នាមជាលាយលក្ខណ៍អក្សរ ដើម្បីទុកជាភស្តុតាងក្នុងការអនុវត្តការងារផ្សេងៗ មានន័យថា ទោះកិច្ចការតូចតាចក៏ដោយមិនត្រូវជឿលើសម្តីគេឡើយ។

-សណ្ឋាន៖ មានការសរសេរដោយដៃ វាយកុំព្យូទ័រ ខ្លះទៀតច្បាប់ថតចម្លង...។

-ប្រភេទ៖ សំណោរជាផ្លូវការ មានច្រើនប្រភេទសម្រាប់អនុវត្តន៍ និងប្រើទៅតាមប្រភេទនៃការងារដូចជា លិខិត ដីការអមសារាចរ លិខិតឧទ្ទេសនាម អនុក្រឹត្យ ព្រះរាជក្រឹត្យ...។

-អត្ថន័យ៖ មានប្លែកគ្នាតាមប្រភេទលិខិតដូចខាងក្រោមៈ

-ដីការអម គឺសម្រាប់បញ្ជូនសំនុំរឿង ផ្សេងៗ សម្ភារនានាទៅកាន់អង្គភាពផ្សេងៗ មួយទៀត។

-កំណត់ចាត់ការ ជាបំណែងចែកការ កិច្ចឲ្យទទួលខុសត្រូវរបស់មន្ត្រីក្រោមឱវាទ។

-របាយហេតុ ទម្រង់របាយការណ៍ បន្ទាន់ ពុំមានព័ត៌មានគ្រប់គ្រាន់។

-របាយការណ៍ សេចក្តីរាយការណ៍ ដែលមានខ្លឹមសារពេញលេញ។

-លក្ខណៈ គឺរបៀបបែបដែលមានលក្ខណៈកត់សម្គាល់ ក្នុងនោះមានឈ្មោះស្ថាប័ន ឈ្មះប្រទេស ទីកន្លែង លេខអក្សរសម្ងាត់ឬ អក្សរកាត់ ឋានៈមុខតំណែងអ្នកទទួល និង ហត្ថលេខា។

-លក្ខណៈពិសេសមានបន្ថែមលើលក្ខណៈធម្មតានូវពាក្យ"ប្រញាប់ ប្រញាប់ណាស់ ប្រញាប់បំផុត សម្ងាត់ សម្ងាត់បំផុត"ដោយសរសេរជាពណ៌ក្រហមឬខៀវនៅខាងឆ្វេងពីក្រោមលេខ។ការប្រើពាក្យពេចន៍នេះ ត្រូវប្រកាន់យកពាក្យសមរម្យ ច្បាស់លាស់ និង សាមញ្ញ។

-ភាពចាំបាច់នៃលិខិត រាល់លិខិតទាំងអស់ មានទម្រង់និងសណ្ឋានប្លែកៗគ្នាតាមស្ថាប័ននីមួយៗ។ ឧទាហរណ៍ លិខិតចេញដោយព្រះមហាក្សត្រ លិខិតចេញដោយរដ្ឋសភា ព្រឹទ្ធសភា លិខិតចេញដោយ រដ្ឋាភិបាល លិខិតប្រើជាផ្លូវការ ធម្មតា លិខិតឯកជន លិខិតចេញដោយ តុលាការ...។

-ទម្រង់លិខិត ចែកជា៤ផ្នែក

១-ឈ្មោះប្រទេសឬបាវចនា អាចសរសេរជាអក្សរធំៗចំកណ្តាលឬខាងស្តាំទំព័រផ្នែកខាងលើ ឯលិខិតឯកជន គេមិនចាំបាច់ប្រើទេ (ពីឯកជនទៅឯកជន)។

២-ប្រភពនិងលេខលិខិតៈប្រភពគឺ បង្ហាញពីក្រសួង មន្ទីរ ស្ថាប័ន ណាមួយដែល ចុះនៅខាងលើ ចុងខាងឆ្វេងឯលេខដាក់ដើម្បីកំណត់រយៈពេលហើយត្រូវសរសេរក្រោម ប្រភព។អក្សរសម្ងាត់ អក្សរកាត់មិនឲ្យតិចជាងពីរតួនិងមិនឲ្យលើសពីបីតួ បើអាចធ្វើបាន។

៣-កាលបរិច្ឆេទលិខិត ក្រោយពីចុះហត្ថលេខានិងប្រថាប់ត្រា ត្រូវដាក់ថ្ងៃ ខែ ឆ្នាំលិខិត មិនត្រូវចុះមុនទេ។ចំពោះលិខិតទូទៅ កាលបរិច្ឆេទត្រូវដាក់ខាងលើប៉ែកខាងស្តាំ។

៤-អ្នកចុះហត្ថលេខាៈ រាល់លិខិតដែលអាចយកជាការបាន លុះត្រាតែមានហត្ថលេខារបស់អ្នកទទួលខុសត្រូវ។

-ឈ្មោះត្រូវដាក់២/៣ផ្នែកខាងស្តាំហត្ថលេខា

-ត្រាត្រូវបោះ១/៣នៃហត្ថលេខាផ្នែកខាងឆ្វេង។

## ២.៣.ការអនុវត្តការងាររដ្ឋបាល

នៅក្នុងអង្គភាពមួយ មានដំណើរការរីកចម្រើនល្អបាន លុត្រាតែអ្នកគ្រប់គ្រងមានការបែងចែកការងារ ភារកិច្ចនិងតួនាទីច្បាស់លាស់សិន។ ជាដំណើរការនៃការធ្វើផែនការ ចាត់តាំង ដឹកនាំ ត្រួតពិនិត្យ លើការប្រើប្រាស់ធនធានមនុស្សនិងធនធានដទៃទៀតដើម្បីសម្រេចគោលដៅអង្គភាពឬស្ថាប័នណាមួយឲ្យមានប្រសិទ្ធិភាព។

នៅក្នុងវិទ្យាល័យមួយ មានការិ យាល័យច្រើន មនុស្សម្នាក់ៗក្នុងការិយាល័យនោះមានទំនួលខុសត្រូវតាមផ្នែកនីមួយៗរបស់ខ្លួន។ ចំពោះវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនអម្ពវ័នដំនីក បុគ្គលិកទាំងអស់ធ្វើការដោយយកចិត្តទុកដាក់ណាស់ព្រោះម្នាក់ៗមានស្មារតីខ្ពស់ មានការលះបង់ ពោលគឺ មានការងារនិងមានទំនួលខុសត្រូវលើកិច្ចការនោះ ដោយមាននាយកសាលាជាអ្នកចំណាត់ការ។ ពេលបញ្ចប់ខែ ឆមាស ឆ្នាំសិក្សា បុគ្គលិកម្នាក់ៗ ក៏ដូចជាប្រធានក្រុមបច្ចេកទេសឬនាយកសុទ្ធតែមានរបាយការណ៍នៃការងាររបស់ខ្លួនដែលបានបំពេញកន្លងមក ដូចជាធ្វើរបាយការណ៍បវេសនកាល របាយការណ៍ឆមាសទី១ របាយការណ៍ឆមាសទី២ របាយការណ៍ខែនីមួយៗ(តុលា វិច្ឆិកា មករា...)និងរបាយការណ៍ដំណាច់ឆ្នាំ។ល។

ការគ្រប់គ្រងរដ្ឋបាលនៅវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នដំនីក មានវិធីសាស្ត្រគ្រប់គ្រងច្បាស់លាស់មិនថាបុគ្គលិកឬសិស្សទេត្រូវគោរពតាមវិធីសាស្ត្រត្រឹមត្រូវ។ ការគ្រប់គ្រងរដ្ឋបាលនៅអង្គភាពមួយ ប្រធានត្រូវទទួលខុសត្រូវលើ៖

. ក្តាប់រួម

. លិខិតចូលពីក្រសួងឬស្ថាប័នផ្សេងៗនិងរាយការណ៍ជូនថ្នាក់ដឹកនាំ

. គ្រប់គ្រងលើត្រាអង្គភាព

. ការងារបុគ្គលិកការិយាល័យ

. ធានាដំណើរការល្អរបស់ស្ថាប័ន និងចាត់ចែងភារកិច្ចដល់បុគ្គលិកក្រោមឱវាទតាមសំណើររបស់ក្រុមប្រឹក្សា

. ធានានិយ័តភាពក្នុងអង្គភាព

. ត្រៀមការពារបរិស្ថាន សោភណភាពនិងអនាម័យសាលារៀន

. រក្សាសណ្តាប់ធ្នាប់និងវិន័យក្នុងស្ថាប័ននិងចូលរួមបង្កើតក្រុមប្រឹក្សានានា

. រៀបចំដំណើរការចុះឈ្មោះចូលរៀន ដោយមានការប្រជុំរវាង ថ្នាក់គ្រប់គ្រងជាមួយនឹងគណៈកម្មាធិការទ្រទ្រង់សាលាសហគមន៍ មាតាបិតាសិស្ស ដើម្បីធ្វើការផ្សព្វផ្សាយនិងរៀបចំចាត់តាំងមន្ត្រីមួយចំនួននៅដើមខែកញ្ញាឱ្យទទួលការកិច្ចចុះឈ្មោះសិស្សនេះ

. ធ្វើផែនការគ្រប់គ្រងធនធានមនុស្ស

. មានការលើកទឹកចិត្តចំពោះបុគ្គលិកដែលយកចិត្តទុកដាក់លើការងារ និងណែនាំដោយទន់ភ្លន់តែម៉ឺងម៉ាត់ចំពោះបុគ្គលិកមិនសកម្ម។




*រូបភាពប៉ាណូ «ចតុស្តម្ភការអប់រំ» តាំងក្នុងបរិវេណវិទ្យាល័យ*

## ៣.ចំណុចខ្លាំងនិងចំណុចខ្សោះខាត

### ៣.១. ចំណុចខ្លាំង

-វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នដំនីក មានការរីកចម្រើនដូចសព្វថ្ងៃដោយសារមានការយកចិត្តទុកដាក់ខ្ពស់ពីថ្នាក់ដឹកនាំ ដូចជា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា**រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្មនិង

សំណាង់ ពិសេសបំផុតពីសំណាក់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិតនិងសម្តេចតេជោ នាយករដ្ឋមន្ត្រី។**

-ជាអង្គភាពមានសាមគ្គីភាពផ្ទៃក្នុងរឹងមាំ ដោយបុគ្គលិកសិក្សាលោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រង និងសមាគមមាតាបិតាសិស្សមានទំនាក់ទំនងល្អ សហការបំពេញការងារក្នុងស្មារតីភាតរភាពនិងមានទំនួលខុសត្រូវខ្ពស់។

-មានអគារកាត់ដេរ មានម៉ាស៊ីនកាត់ដេរ ដែលអាចជួយបណ្តុះបណ្តាលនូវជំនាញវិជ្ជាជីវៈដល់យុវជន យុវតី ទោះបីសិស្សស្រីៗខ្វះលទ្ធភាពបន្តការសិក្សាទៅឧត្តមសិក្សាក៏គាត់មានជំនាញកាត់ដេរដើម្បីប្រកបការងារទ្រទ្រង់ជីវភាពដែរ។

-ផ្សារភ្ជាប់ជនបទនិងទីក្រុងដោយមានការបណ្តុះបណ្តាលព័ត៌មានវិទ្យាដែលជាបច្ចេកវិទ្យាទំនើប ដោយសាលាភាគច្រើនទទួលបានការសិក្សាតែនៅទីក្រុង។

-ជួយបានច្រើនក្នុងការកសាងធនធានមនុស្សនៅជនបទ ពិសេសជួយបណ្តុះបណ្តាលបងប្អូនខ្មែរអ៊ីស្លាម ដូចជានៅឃុំជំនីក ឃុំប៉ើសជាដើម។

-សិស្សមានគុណភាពមិនឃ្លាតឆ្ងាយពីសិស្សទីក្រុង ទោះបីវិទ្យាល័យស្ថិតនៅជនបទក៏ដោយ ព្រោះវិទ្យាល័យតែងតែប្រសូត្រចេញនូវសិស្សពូកែ សិស្សឆ្នើមជានិច្ច ដូចជានៅឆ្នាំសិក្សា២០១៣ សិស្សឈ្មោះ **កោ រតន** :បានប្រឡងជាប់សិស្សពូកែគណិតវិទ្យាប្រចាំខេត្ត និងបន្តជាប់អាហារូបករណ៍ទៅសិក្សាក្រៅប្រទេសថែមទៀតនិងឆ្នាំផ្សេងៗទៀត ក៏មានជាហូរហែរ។

-ជួយកសាងធនធានមនុស្សបន្តវេន ព្រោះសិស្សដែលបញ្ចប់ថ្នាក់ទី១២ បានប្រឡងជាប់គ្រូ ហើយក៏បញ្ចប់ពីការបណ្តុះបណ្តាល ក៏មកបម្រើការងារជួយបង្ហាត់បង្រៀនដល់ប្អូនៗជំនាន់ក្រោយរបស់ពួកគេ។

### ៣.២. ចំណុចខ្វះខាត

សាលាមិនទាន់មានសួនបន្លែច្រើនដែលបណ្តុះបំណិនកសិកម្មដល់សិស្សានុសិស្ស ហើយក៏ខ្វះគ្រូកសិកម្មដែរ។

-ពិបាករកគ្រូបង្រៀនវិជ្ជាជីវៈកាត់ដេរ បើយកគ្រូពីក្រៅត្រូវមានប្រាក់ឧបត្ថម្ភ។

-សេវាអ៊ីនធើណេតខ្សោយ ពិបាកក្នុងការផ្តល់សេវាអនឡាញ ទាំងការបង្រៀន ទាំងការរៀន ឬប្រជុំពេលករណីចាំបាច់ ដូចករណីអនុវត្តកិច្ចការផ្សេងៗ ឬប្រជុំអនឡាញ ក្នុងដំណាក់កាលរាតត្បាតជម្ងឺកូវីដ-១៩ ជាដើម។

## សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ថា ការអភិវឌ្ឍប្រទេសមួយបាន គឺអាស្រ័យទៅលើធនធានមនុស្សដែលប្រកបទៅដោយសមត្ថភាពនិងជំនាញច្បាស់លាស់ពិតប្រាកដ។ ដើម្បីឲ្យប្រទេសជាតិស្ថិតនៅក្នុងសន្តិភាពសំបូរសប្បាយមានសុខដុមរមនា ចំពោះប្រជាពលរដ្ឋទូទៅក៏ដូចជាមន្ត្រីរាជការ អ្នកមុខ អ្នកការ ព្រះសង្ឃ និង អ្នកកាន់សាសនាដទៃទៀតនោះ យើងត្រូវប្រើប្រាស់នូវវិធីនិងប្រាជ្ញាឆ្លាតវៃ ស្មុគស្មាញ ដើម្បីរកច្រកចេញសម្រេចទៅដល់គោលដៅរួមទាំងអស់គ្នា។ ការអប់រំបានបាញ់តម្រង់ទៅរកចំណុចគោលដៅរួមរបស់យើងទាំងអស់គ្នាទូទាំងប្រទេស ពោល គឺការអប់រំដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ (EFA)[១០] ដោយតម្រង់ទៅរកការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច សេវាកម្ម សន្តិសុខ និងពង្រីកឥទ្ធិពលរបស់ខ្លួន។

តាមសេចក្តីណែនាំ ការចាត់តាំង តាមអនុសាសន៍ថ្នាក់ដឹកនាំក្នុងក្របខណ្ឌសីលធម៌វិជ្ជាជីវៈ និង ឆ្លងតាមការចុះស្រាវជ្រាវនិងវិភាគរកធាតុចូលសំខាន់ពីដំណើរការប្រព្រឹត្តទៅនៃរដ្ឋបាលអប់រំប្រចាំវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នដំនីក យើងឃើញថា សាលារៀននេះ អាចដំណើរការបានទៅមុខជានិច្ចព្រោះ បុគ្គលិកសិក្សា គ្រូបង្រៀនតាមមុខវិជ្ជាក៏ដូចជាគណៈគ្រប់គ្រង មានការប្រឹងប្រែងទាំងអស់គ្នា ទោះបីមានកង្វះសម្ភារៈបរិក្ខារខ្លះក៏ពិតមែន ហើយមាតាបិតាអាណាព្យាបាលសិស្សនិងសិស្សានុសិស្សខ្លួនឯង មានការសហការព្យាយាមទាំងអស់គ្នាដែលជាកត្តាជំរុញឲ្យសាលារៀនមានដំណើរការទៅមុខជានិច្ច។ ដូច្នេះ លទ្ធផលនៃការងាររដ្ឋបាលអប់រំមានលទ្ធផលឬលទ្ធភាព សម្រេចបានល្អ ជាផ្ទៃផ្កាដោយមានសាមគ្គីភាពផ្ទៃក្នុងរឹងមាំក្រោមការដឹកនាំប្រកបដោយតម្លាភាពនិងសមត្ថភាព។

[១០] EFA: Education For All

# ឯកសារពិគ្រោះ

## ឯកសារភាសាខ្មែរ


១. ជួន ណាត *វចនានុក្រមខ្មែរ* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧

២. ប៉ាន់ សំណាង *របាយការណ៍ស្រាវជ្រាវស្តីពីដំណើរការរដ្ឋបាលនៃវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក* សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ឆ្នាំ២០០៩

៣. ពៅ សុខ *ទឹកចិត្តអ្នកជួយសង្គ្រោះ* ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ ២០២០

៤. សាយ បូរី *នីតិរដ្ឋបាលទូទៅ* ឆ្នាំ២០០៦

៥. ធ សោ *រដ្ឋបាលអប់រំ* ឆ្នាំ២០០៦

៦. ក្រសួងអប់រំយុវជននិងកីឡា ប្រកាសលេខ១៤២៣អយក.ប្រក ចុះថ្ងៃទី១០ខែតុលា ឆ្នាំ២០០៥

៧. ឯកសារវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក


## ឯកសារភាសាអង់គ្លេស


១.Oxford University Press, Oxford Basic English Dictionary 1993


## ឯកសារដកស្រង់ពីប្រព័ន្ធអ៊ីនធឺណេត


១ -http//:www.school.for.champions.com/education/process.htm

២ -http//:www.school-works.org

# នានាភាពនៃអក្សរសិល្ប៍សម័យអាណានិគមនិយមបារាំង

ដោយៈ បណ្ឌិត **ឃិន យ៉ង់**
ប្រធាននាយកដ្ឋានកិច្ចការទូទៅ,វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា

អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងសង្គម សង្គមបែបណាអក្សរសិល្ប៍បែបនោះៗ ឆ្លងតាមរយៈការសិក្សាស្នាដៃអក្សរសិល្ប៍ អ្នកសិក្សាអាចក្រេបជញ្ជក់ពុទ្ធិល្អៗ មានតម្លៃបានយ៉ាងច្រើនដែលអ្នកនិពន្ធជួបប្រទះ សន្សំទុកនិងផ្តល់ឱ្យតាមរយៈវណ្ណកម្មនានាក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្សទៅតាមឧត្តមគតិរបស់ខ្លួនៗ ការសិក្សា អត្ថបទស្នាដៃអក្សរសិល្ប៍នានាបានផ្តល់ឱ្យអ្នកសិក្សាអាចមើលឃើញពីព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងអតីតកាលយកមកធ្វើជាបទពិសោធន៍ជំនួយដល់ការរៀបចំបច្ចុប្បន្នកាល និង បន្តរៀបចំផែនការកសាងអនាគត កាលមួយ ប្រកបដោយភាពសុខសាន្ត និងមាននិរន្តរភាព។ ដើម្បីសម្រេចតាមគោលដៅនេះ ដើម្បីចូលរួមចំណែកក្នុងការស្វែងយល់ពីវិធីសាស្ត្រតែងនិពន្ធ គំនិត ជំបូន្មាន នានាដែលអ្នកនិពន្ធបានបន្សល់ ទុកការ សិក្សាប្រៀបធៀបស្នាដៃក្នុងសម័យកាលនីមួយៗ គឺជាបេសកកម្មដ៏សំខាន់របស់អ្នកសិក្សាដើម្បីចូលរួមចំណែកក្នុងការបកស្រាយ គំនិតជំបូន្មានក៏ដូចជាបទពិសោធន៍ជីវិតនានាដែលអ្នកនិពន្ធគ្រប់រូប បានបន្សល់ទុកតាមរយៈស្នាដៃរបស់ខ្លួនសម្រេចបំណងនេះៗ

អ្នកនិពន្ធខ្មែរជាច្រើនរូបនៅដើមសម័យអាណានិគមនិយមបារាំង ជាអាទ៏លោក ញ៉ុក ថែម លោក រីម គីន លោក នូ ហាច ជាអ្នកនិពន្ធខ្មែរដែលមានទេពកោសល្យខ្ពស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការស្ថាបនាប្រវត្តិប្រលោមលោកពាក្យរាយខ្មែរ (អក្សរសិល្ប៍ខ្មែរទំនើប) នាដើមសតវត្សទីម្ភៃនេះ ដោយបានបន្សល់ទុកស្នាដៃមួយចំនួនមកដល់បច្ចុប្បន្នប្រកបដោយទេពកោសល្យក្នុងការតែងនិពន្ធ និងមានឧត្តមគតិស្នេហាជាតិដ៏ជ្រាលជ្រៅ។

អាស្រ័យដោយសេចក្តីកម្រនិង យល់ឃើញថាការសិក្សាលើអក្សរសិល្ប៍ខ្មែរនាសម័យអាណានិគមនិយមបារាំង មានរបត់វិវឌ្ឍន៍ជាដំណាក់កាលយ៉ាងសំខាន់ក្នុងប្រវត្តិអក្សរសាស្ត្រខ្មែរអាចផ្តល់ជាសារប្រយោជន៍ បានមួយចំណែកដល់ការសិក្សាអក្សរសិល្ប៍ខ្មែរផងនោះ ការធ្វើបទបង្ហាញលើប្រធានបទនេះធ្វើឡើងដោយចង់បង្ហាញឱ្យឃើញថា តើ៖

-អក្សរសិល្ប៍ខ្មែរនាសម័យអាណាព្យាបាលបារាំងមានស្ថានភាពដូចម្តេច?

-តើអក្សរសិល្ប៍សម័យអាណានិគមនិយមបារាំងមានការប្រែប្រួលដូចម្តេចខ្លះ?

-តើអក្សរសិល្ប៍សម័យអាណានិគមនិយមបារាំងត្រូវបានបែងចែកជាប្រភេទអ្វីខ្លះ?

នាដើមសម័យឧដុង្គ វិស័យអក្សរសាស្ត្រខ្មែរមានការរីកចម្រើនគួរជាទីមោទនៈ ដែលក្នុងនោះយើងសង្កេត ឃើញមានព្រះមហាក្សត្រខ្មែរខ្លះ ទ្រង់ជាព្រះរាជកវីនិពន្ធដ៏វិសេសៗផងដែរ ជាអាទិ៍ ព្រះរាជសម្ភារចៅពញាតូ ដែលទ្រង់បានព្រះរាជនិពន្ធ ច្បាប់ត្រីរាជនីតិ ច្បាប់ព្រះរាជសម្ភារ ដែលជាក្បួនច្បាប់ដ៏សំខាន់ក្នុងការដឹកនាំប្រទេសនាសម័យក្រោយអង្គរ និងព្រះរាជនិពន្ធជាកំណាព្យរីណាគីត សម្តែងចេញនូវមនោសញ្ចេតនាផ្ទាល់ព្រះអង្គក្នុងផ្លូវស្នេហា និងការទូន្មានប្រៀនប្រដៅមនុស្សអំពីទោសក្នុងការប្រព្រឹត្តខុសក្នុងកាមេផងដែរ។ ក្រៅពីនេះ ក៏មានព្រះមហាសង្ឃរាជ ព្រះសង្ឃរាជាគណៈ ព្រះសង្ឃអង្គខ្លះក៏ជាអ្នកប្រាជ្ញបណ្ឌិតក្នុងវិស័យអក្សរសាស្ត្រផងដែរ ដូចជា ព្រះសុគន្ធ ព្រះសង្ឃនាយកជាព្រះរាជគ្រូនៃព្រះរាជសម្ភារជាដើម។

នៅក្នុងដំណាក់កាលដំបូងនៃការដាក់អាណាព្យាបាលលើប្រទេសកម្ពុជានាឆ្នាំ ១៨៦៣ បារាំងបានប្រើប្រាស់មធ្យោបាយក្តៅក្នុងការដាក់សម្ពាធ ដើម្បីគ្រប់គ្រងលើព្រះមហាក្សត្រខ្មែរ ដោយពុំបានស្វែងយល់ឱ្យច្បាស់អំពីឥទ្ធិពលនៃរាជបល្ល័ង្កខ្មែរចំពោះប្រជារាស្ត្រខ្មែរ និងការបាត់បង់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មន្ត្រីខ្មែរគ្រប់ជាន់ថ្នាក់ដែលជាមូលហេតុធ្វើឱ្យមានការបះបោរប្រឆាំងបារាំងនៅគ្រប់ទីកន្លែង។

ការបះបោរនៅទូទាំងប្រទេសបានធ្វើឱ្យបារាំង បន្ធូរយគំនាបសង្កត់លើព្រះមហាក្សត្រខ្មែរវិញ។ ប៉ុន្តែ ជាបន្តបន្ទាប់អាណាព្យាបាលបារាំង បានដកហូតយកអំណាចព្រះរាជាខ្មែរបន្តិចម្តងៗ រហូតព្រះអង្គពុំមានសិទ្ធិធ្វើអ្វីសោះ ក្រៅពីដើរតួជានិមិត្តរូបនៃប្រជាជាតិខ្មែរ ក្រោមការគាំពារ ថែរក្សា និងទំនុបបម្រុងទាំងស្រុងពីរបបអាណាព្យាបាលបារាំង។

## ១. ស្ថានភាពសង្គមខ្មែរក្រោមអាណាព្យាបាលបារាំង

ដំណាក់កាលនេះ ជាសម័យកាលជាប់ទាក់ទងផ្ទាល់ជាមួយអ្នកនិពន្ធ បានបង្ហាញពីរបត់ប្រវត្តិសាស្ត្រមួយដែលបន្តជះឥទ្ធិពលលើផ្នត់គំនិតអ្នកដឹកនាំ អ្នកចេះដឹងខ្មែរឱ្យបង្កើតសមិទ្ធផលអ្វីដែលថ្មីៗ ទាំងក្នុងវិស័យនយោបាយដឹកនាំប្រទេស ទាំងលើវិស័យអក្សរសាស្ត្រជាតិ។ ក្រៅពីនេះ មានការភ្ជាប់ព្រឹត្តិការណ៍ប្រវត្តិមួយចំនួន ដែលកើតឡើងនៅប្រទេសសៀម ដែលក្រោយមកប្តូរជាថៃវិញ ហើយព្រឹត្តិការណ៍ទាំង នេះបានផ្តល់ផលប៉ះពាល់មួយចំនួនដែលមានកម្រិតខ្ពស់មកលើប្រទេសខ្មែរ។

នៅពេលដែលព្រះបាទហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គដួង សោយទិវង្គតទៅពួកមន្ត្រីនិងព្រាហ្មណ៍បុរោហិត បានលើក

ព្រះរាជបុត្រច្បងនាមអង្គច្រឡឹង ឬអង្គវតី (ព្រះបាទនរោត្តម) ឱ្យឡើងសោយរាជ្យស្នងព្រះបិតា នៅរាជធានីឧដុង្គនាគ.ស. ១៨៥៩។ ក្នុងរាជ្យរបស់ព្រះអង្គ ខ្មែរនៅកម្ពុជាក្រោមបានបន្តការតស៊ូប្រឆាំងនឹងការឈ្លានពានរបស់យួនពីរលើកធំៗគឺ លើកទី១ នៅគ.ស.១៨៥៩ និងលើកទីពីរនៅគ.ស. ១៨៦០។ ព្រះអនុជព្រះអង្គព្រះនាម ស៊ីវត្ថា ដែលមានគំនិតប្រណែនចង់បានរាជ្យសម្បត្តិបានរួមដៃជាមួយបក្សពួកមួយចំនួនបង្កចម្បាំងរាំងរាំងជល់ក្នុងស្រុកឡើងពីគ.ស.១៨៦១ ដល់ គ.ស.១៨៦២។

មានព្រឹត្តិការណ៍សំខាន់ៗ ជាច្រើនដែលជះឥទ្ធិពលដល់ការវិវឌ្ឍន៍នៃអក្សរសិល្ប៍ខ្មែរ ជាអាទិ៍៖

ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ការចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពការ ការពារ និងពាណិជ្ជកម្ម រវាងព្រះបាទ នរោត្តម និងលោកឧត្តមនាវី ដឺ ឡា ហ្គ្រង់ឌីយែរ ទេសាភិបាលបារាំងប្រចាំដែនកូសាំងស៊ីន។

ព្រះបាទ នរោត្តម ទ្រង់បានចេញព្រះរាជបញ្ញត្តិកែទម្រង់ ដើម្បីឱ្យប្រទេសជាតិមានការរីកចម្រើន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧។

អនុសញ្ញាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ បានដាក់អាណាព្យាបាលភាព ពិតប្រាកដលើប្រទេសខ្មែរដោយលោក ធាលថមសុន ទេសាភិបាលដែនកូសាំងស៊ីន។

ពីខែវិច្ឆិកា ឆ្នាំ១៨៨៤ ដល់ខែ មករា ឆ្នាំ១៨៨៧ មានការងើបឡើងតស៊ូរបស់អ្នកស្នេហាជាតិខ្មែរប្រឆាំងសន្ធិសញ្ញា ឆ្នាំ១៨៨៤ នៅទូទាំងប្រទេស។

ឆ្នាំ១៨៦៧ ទឹកដីកម្ពុជាក្រោមបានក្លាយជាដែនដីអាណានិគមរបស់បារាំង។

បន្ទាប់ពីការសោយទីវង្គតរបស់ព្រះបាទនរោត្តម ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩០៤ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កដែលមានទេសាភិបាលបារាំងនៅអមបានជ្រើសរើសព្រះមហាឧបរាជ ស៊ីសុវត្ថិជាព្រះអនុជឱ្យឡើងសោយរាជ្យ។ ក្នុងឆ្នាំដដែលនេះមានការបង្វិលឱ្យវិញនូវខេត្តត្រាច កោះកុង មូព្រៃ ទន្លេពៅ ពីសំណាក់ប្រទេសសៀម និងខេត្តស្ទឹងត្រែង ស្រុកសៀមប៉ាងពីប្រទេស ឡាវដែលដកហូតដោយបារាំងដល់កម្ពុជា។

ឆ្នាំ១៩០៤ របបអាណានិគមនិយមបារាំង បានបង្កើត អនុវិទ្យាល័យស៊ីសុវត្ថិ ជាការលើទឹក ព្រះទ័យដល់ព្រះបាទស៊ីសុវត្ថិ ក្នុងឆ្នាំដំបូងដែលទ្រង់ឡើងសោយរាជ្យ។

ឆ្នាំ១៩០៧ បង្កើតគណៈកម្មការពីរ សម្រាប់ចងក្រងប្រវត្តិសាស្ត្រខ្មែរ។ សៀមប្រគល់ខេត្តកំពង់ធំ (និងព្រះវិហារ) សៀមរាប-ឧត្តរមានជ័យ បាត់ដំបង សេរីសោភ័ណ ផ្នែកមួយនៃខេត្តពោធិ៍សាត់ មកខ្មែរវិញ។

ព្រះរាជបញ្ញត្តិចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩១២ ឱ្យឪពុកម្ដាយត្រូវតែបញ្ជូនកូនប្រុសស្រី ឱ្យទៅកាន់សាលារៀន បើពុំដូច្នោះទេនឹងត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់។

ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩១៥ រាជបញ្ញត្តិរបស់ព្រះបាទស៊ីសុវត្ថិ

បង្កើតគណៈកម្មការរៀបចំវចនានុក្រមខ្មែរជាលើកដំបូង។

ឆ្នាំ១៩១៨ លោក ហ្សក ហ្គ្រូសលីយេរ បង្កើតសារមន្ទីរមួយនៅក្រុងភ្នំពេញ។

ឆ្នាំ១៩២១ ព្រះបាទស៊ីសុវត្ថិ ទ្រង់កសាងសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ។

ថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩២៧ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក បានជ្រើសរើសព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ជាព្រះរាជបុត្រច្បងឱ្យឡើងគ្រងរាជ្យស្នងព្រះបាទ ស៊ីសុវត្ថិ ជាព្រះរាជបិតាដែលបានសោយទីវង្គត (សោយរាជ្យពីឆ្នាំ១៩២៧ ដល់ឆ្នាំ១៩៤១)។

ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩២៩ បង្កើតក្រុមជំនុំប្រែព្រះត្រៃបិដក។

-ឆ្នាំ១៩៣០ បង្កើតវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ។

-ឆ្នាំ១៩៣៦ សារពត៌មានជាភាសាខ្មែរទី១" នគរវត្តឬអង្គរវត្ត" បានបង្កើតឡើងដោយលោកស៊ឺង ង៉ុកថាញ់ លោកស៊ឹម វ៉ា និង លោក ប៉ាច ឈឿន។

-ថ្ងៃទី២៤ មិថុនា ឆ្នាំ១៩៣៩ ប្រទេសសៀម ដូរឈ្មោះជា ប្រទេសថៃ វិញ។

-ឆ្នាំ១៩៣៩ សង្គ្រាមលោកលើកទី២ ផ្ទុះឡើង។ សៀមដោយមានការគាំទ្រពីជប៉ុនបានធ្វើការកៀបសង្កត់ប្រទេសបារាំងដណ្ដើមយកខេត្តបាត់ដំបង ទឹកដីស្ថិតនៅចន្លោះជួរភ្នំដងរែក និងខ្សែស្របក្រាដទី១៥។

ថ្ងៃទី១៧ កញ្ញា ឆ្នាំ១៩៤០ ថៃទាមទារឱ្យបារាំងប្រគល់ដីកម្ពុជា និងឡាវមួយភាគធំ។

ថ្ងៃទី២៦ កញ្ញា ឆ្នាំ១៩៤០ កងទ័ពជប៉ុន ចាប់ផ្ដើមកាន់កាប់ឥណ្ឌូចិន។

ថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៤០ ថៃវាយប្រហារលើបារាំងនៅកម្ពុជា ទ័ពបារាំងទទួលបរាជ័យ។

ថ្ងៃទី០១ មករា ឆ្នាំ១៩៤១ ទ័ពជើងទឹកបារាំង មានជ័យជំនះលើទ័ពជើងទឹកថៃនៅកោះឆាង។

ឆ្លៀតឱកាសដែលបារាំងបរាជ័យក្នុងសង្គ្រាមនៅអឺរ៉ុប ថៃបានវាយប្រហារលើទីតាំងរបស់បារាំងនៅប្រទេស ឡាវ និងកម្ពុជាកាន់កាប់ទឹកដីមួយភាគធំនៅប៉ែកពាយ័ព្យនៃប្រទេសកម្ពុជា ។

ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៤១ បារាំងនិងថៃ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលចុះហត្ថលេខា ជាសន្ធិសញ្ញាសម្រេចនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៤១ ដែលថៃទាមទារបានទឹកដីខេត្តប៉ែកខាងលិចទន្លេមេគង្គនៃប្រទេសឡាវ ទឹកដីបីភាគបួននៃខេត្តកំពង់ធំ និង ទឹកដីប៉ែកខាងជើងនៃប្រទេសកម្ពុជា (សរុប៧០ ០០០ គីឡូម៉ែត្រត្រីគុណ)។

រាត្រីថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៤១ ព្រះបាទស៊ីសុវត្ថិ មុនីវង្ស សោយទីវង្គតនៅបូកគោក្នុងព្រះជន្ម៦៥ វស្សា។ ព្រះរាជនត្តាព្រះអង្គម្ចាស់នរោត្តម សីហនុ ត្រូវបានជ្រើសរើសជាក្សត្រអង្គថ្មី។ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៤១ ព្រះអង្គម្ចាស់សីហនុ ទទួលរាជា

កិសេកជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា [១]។

## ២. អ្នកនិពន្ធល្បីៗនាសម័យអាណានិគមនិយមបារាំង

នៅឆ្នាំ១៨៦១ លោក ហង់ រីម៉ូហូត រុក្ខវិទូជាតិបារាំងបានឃើញប្រាង្គប្រាសាទសិលាខ្មែរ នៅតំបន់អង្គរ ពិសេសប្រាសាទអង្គរវត្ត។ ដោយសេចក្តីស្ញើចសរសើរចំពោះភាពមហស្ចារ្យរបស់មត៌កស្នាដៃដ៏សម្បើមនេះ នៅឆ្នាំ១៨៦៣ អត្ថបទរបស់លោកដែលនិយាយពីអង្គរ ក៏បានផ្សព្វផ្សាយពាសពេញពិភពលោក ចុះផ្សាយដោយទស្សនាវដ្តីទូតឡឺម៉ុង(Tout le Monde)។ នៅឆ្នាំ១៨៦៣នេះ បារាំងបានដាក់អាណាព្យាបាលជាលើកដំបូងនៅលើទឹកដីអង្គរ។ ថ្វីត្បិតតែវិស័យមួយចំនួនបានទទួលឥទ្ធិពលពីបស្ចឹមប្រទេស ពិសេសប្រទេសបារាំង ក៏ដោយ ប៉ុន្តែវិស័យសិក្សាធិការអប់រំនៅតែប្រព្រឹត្តទៅតាមបែបបុរាណនៅឡើយ។ ដោយបន្តមរតកពីសម័យឧដុង្គ ដែលអ្នកសិក្សាចាត់ទុកជាយុគមាសនៃអក្សរសិល្ប៍ខ្មែរ ការតែងនិពន្ធស្នាដៃអក្សរសិល្ប៍ផ្សេងៗ នៅតែប្រព្រឹត្តទៅជាពាក្យកាព្យតាមបែបសាសនានៅឡើយ។ ប្រហែលកន្លះសតវត្សក្រោយពេលបារាំងដាក់ នឹមអាណាព្យាបាលលើប្រទេសកម្ពុជា ទើបគេឃើញមានការវិវឌ្ឍន៍លើកម្មវិធីសិក្សា ដោយមានការកែទម្រង់លើវិស័យនេះ ឱ្យមានលក្ខណៈទំនើបជាបណ្តើរៗ សម្រាប់បំពេញតម្រូវការរដ្ឋការអាណាព្យាបាលដែលទាមទារអ្នកចេះដឹងផ្នែកភាសាបារាំងផ្នែករដ្ឋបាលបារាំងជាដើម។ ការសិក្សានៅសាលាវត្តបែបថ្មី និងនៅសាលាមធ្យម សិក្សាទំនើប ជះឥទ្ធិពលជាខ្លាំងលើផ្នត់គំនិត ការគិតគូរពិចារណារបស់យុវសិស្សខ្មែរនាសម័យនោះ។ មិនត្រឹម តែប៉ុណ្ណោះ ការសិក្សានេះបានជំរុញឱ្យមានការវិវឌ្ឍន៍មួយយ៉ាងធំក្នុងវិស័យអក្សរសាស្ត្រខ្មែរ។ នៅចុល្លសករាជ ១២៦៩ ឆ្នាំមមែ នព្វស័ក ត្រូវនឹងគ្រិស្តសករាជ១៩០៧ តាមាសអាយុជាង៨០ឆ្នាំថ្វាយ បានតែងអត្ថបទពាក្យរាយមួយឡើងឈ្មោះថា “ រឿងបន្ទាំតាមាស” ។ ច្បាប់បន្ទាំតាមាសនេះ មានលក្ខណៈប្លែកពីសាស្ត្រាក្បួនច្បាប់ផ្សេងៗ ដោយលោកតាមាស បានសរសេរតែពីអ្វីដែលគាត់មើលឃើញ ជួបប្រទះក្នុងពេលគាត់រស់នៅ ពីជីវប្រវត្តិគ្រួសារគាត់ ដែលជីតា និងឪពុកបាត់ខ្លួនក្នុងសង្គ្រាមជាមួយយួន កាលរាជហ្លួងអង្គមី ពីព្រះទ័យព្រះអង្គឌួង ចំពោះប្រទេសជាតិ ដែលរងគ្រោះដោយសារសង្គ្រាម គំនាបពីប្រទេសជិតខាងនៅមុន និងក្នុងរជ្ជកាលព្រះអង្គ។ ពីព្រឹត្តិការ-ណ៍ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ព្រះបាទនរោត្តម ដែលមានទំនាក់ទំនងចងស្ពានមេត្រីឱ្យបារាំងសែសជួយរក្សាស្រុក ដោយបាននាំយកបច្ចេកវិជ្ជា ទំនើបចូលស្រុកខ្មែរ ដូចជាកប៉ាល់ភ្លើងកង់រទេះលើផ្លូវដែកដើរដោយកុំឡាំងទឹកពុះ ដោយមិនចាំបាច់ពឹងកុំឡាំងសេះ សត្វពាហណៈ ឬប្រើក្តោងថែវក្រជីង

[១] *See* WWW.Qecicity *chronology of Cambodian History year 1940-1941.*

ឡើយ។ ពីការនាំប្រេងកាតមកលក់ក្នុងស្រុកខ្មែរពីចន្លោះឆ្នាំ១៨០០ ដែលបំភ្លឺហ៍ក្រុងភ្នំពេញ ដោយភ្លើងអគ្គិសនីរត់តាមខ្សែលួសខ្សែលួសវៃទៅមករកគ្នា ហើយស្តាប់គ្នាបានពីចំម្ងាយ។ ការនាំមយកម៉ាស៊ីនហិបច្រៀង កុនស្រម៉ោលឆ្លុះរូប គ្រឿងថតរូបពីព្រឹត្តិការណ៍ប្រវត្តិប្រទេសយួនក្នុងពេលជាមួយគ្នានេះផងដែរ[២]។

នៅរវាងពាក់កណ្តាលទសវត្សទី២ នៃសតវត្សទី២០ ឆ្នាំ១៩១៥ គេឃើញមានការវិវឌ្ឍន៍លើផ្នែកអត្ថន័យក្នុងស្នាដៃអក្សរ សិល្ប៍សំណេរខ្មែរ ដោយចាប់ផ្តើមងាកចេញពីសាសនាមកបកស្រាយបញ្ហាជីវភាពរស់នៅជាក់ស្តែងក្នុងសង្គមមនុស្ស និងផ្នែកអត្ថរសពីអច្ឆរិយរសមកតថរសតាមរយៈរឿងទុំទាវ (ស្នាដៃព្រះ ភិក្ខុបទុមត្ថេរសោម) (គេឃើញមានការវិវឌ្ឍន៍ពីអច្ឆរិយ ភាពមកលក្ខណៈវិទ្យាសាស្ត្រក្នុង រឿងហង្សយន្ត របស់កវីចៅកត្តីឧក បង្ហាញពីគំនិតជឿនលឿនក្នុងបច្ចេកវិទ្យា គឺការធ្វើហង្សយន្តដោយជាងប្រើបច្ចេកទេសគ្រឿងចក្រ អាចហោះហើរបានមិនមែនហោះហើរដោយសិល្ប៍សាស្ត្រមន្តអាគម)។

លោកសាស្ត្រាចារ្យ ពៅ សាមី យល់ថា អក្សរសិល្ប៍ខ្មែរចាប់ដល់មនុស្សនិយម (Humanisme) តាំងពីមានរឿងរាមកេរ្តិ៍មកម្ល៉េះ ហើយនៅក្នុងអក្សរសិល្ប៍ពុទ្ធនិយមយើងអាចរកលក្ខណៈនេះឃើញក្នុងអត្ថបទវេស្សន្តរសម្រាយ។

បន្ទាប់ពីនោះបន្តិច អក្សរសិល្ប៍ឧបទេស ដែលមានវត្តមានជាយូរយារណាស់មកហើយនោះ ក៏មានការប្រែប្រួលតាមរយៈអ្នកចម្រៀងសាដៀវមួយរូបដ៏ល្បីល្បាញដែរ គឺអ្នកព្រះភិរម្យភាសាក្រមង៉ុយ។ តាមរយៈសម្លេងចម្រៀងរបស់គាត់ បានដាស់តឿនកូនខ្មែរឱ្យភ្ញាក់រលឹកពីការលង់លក់ក្នុងអបិយជំនឿ " កូនអើយអ្នកចាំ កុំជឿ ខែឆ្នាំ កុំជឿតម្រា ពាក្យក្បួនតម្រាយ កើតពីមនុស្សចារពីដូនពីតាចារតាមសម្គាល់[៣]" ចេះប្រណិប័តន៍ចំពោះការងារគ្រូបាធ្យាយ នាយ ចៅហ្វាយ ឪពុកម្តាយ ចេះរៀនអក្សរលេខនព្វន្តដើម្បីកុំឱ្យឈ្មួញ នាយទុនបោកប្រាស់បាន និងបញ្ហាផ្សេងៗទៀតជាច្រើន។ ប្រហែលចិតសិបឆ្នាំ ក្រោយពេលបារាំងដាក់អាណាព្យាបាល គឺនៅចុងក្នុងរវាងពាក់កណ្តាលទីពីរនាទសវត្សទី៤ នៃសតវត្សទី២០ មានការប្រែប្រួលធំមួយក្នុងការតែងនិពន្ធស្នាដៃអក្សរសិល្ប៍ខ្មែរ។ ឥទ្ធិពលប្រលោម លោកបស្ចិមប្រទេសនាពេលនោះ បានជំរុញឱ្យមានការ វិវឌ្ឍផ្នែកអត្ថរូបពីទម្រង់កាព្យ តាមបែបសាសនា មកជាពាក្យរាយតាមបែបប្រលោម លោកបស្ចិមប្រទេសវិញម្តង។ នៅពេលនោះហើយ ដែលវិធីនិម្មិតកម្មស្នាដៃក្នុងការតែងនិពន្ធអក្សរសិល្ប៍ខ្មែរ បានវិវឌ្ឍទាំងស្រុងលើផ្នែកអត្ថរូប ពីទម្រង់ពាក្យកាព្យ (សាស្ត្រា) មកជាទម្រង់ពាក្យរាយ (ប្រលោមលោក) ផ្នែកអត្ថន័យពីជំនឿក្នុងសាសនាមកជាលក្ខណៈមនុស្សនិយម និង ផ្នែក

[២] សូមមើល តាមាស ច្បាប់បន្ទាំតាមាស ១៩០៤?។

[៣] ក្រមង៉ុយ ច្បាប់ល្បើកថ្មី ក្នុងច្បាប់ក្រមង៉ុយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ទំព័រ២០។

អត្ថសេពីអច្ឆរិយសេមកជាតថសេនាទសវត្សទី ៤ នៃសតវត្សទី២០នេះ។

យោងតាមរយៈការវិវឌ្ឍន៍នេះ គេអាចចែកអ្នកនិពន្ធសម័យអាណាព្យាបាលបារាំងជាពីរប្រភេទគឺ ៖

### ២-១. អ្នកនិពន្ធបែបប្រពៃណីមុនទទួលឥទ្ធិពលប្រលោមលោកបស្ចិមប្រទេស

អ្នកនិពន្ធបែបប្រពៃណីមុនទទួលឥទ្ធិពលប្រលោមលោកបស្ចិមប្រទេស គឺជាផ្នែកដំបូងនៃអ្នកនិពន្ធសម័យអាណាព្យាបាលបារាំង ដែលបានទទួលការសិក្សា បែបប្រពៃណី ពីសំណាក់គ្រូបាអាចារ្យជាព្រះសង្ឃតាមវត្តអារាមនានា ដែលជាឃ្លាំងផ្ទុកចំណេះដឹងសព្វយ៉ាងទាំងអក្សរសាស្ត្រ វប្បធម៌អរិយធម៌ ទស្សនវិជ្ជា លេខនព្វន្ត បច្ចេកទេស ហត្ថកម្មផ្សេងៗជាច្រើនរបស់ជាតិ។ ពេលខ្លះ អ្នកនិពន្ធមួយចំនួនមានភេទជាព្រះសង្ឃផងក៏មានដែរ។ ជាទូទៅ អ្នកនិពន្ធទាំងនោះពុំបានទទួលការសិក្សាតាមបែបទំនើប ឬទទួលឥទ្ធិពលប្រលោមលោកផ្សេងៗនៃអក្សរសិល្ប៍បស្ចិមប្រទេស។ អ្នកនិពន្ធទាំងនោះបន្តអត្ថិភាពរបស់ខ្លួនក្នុងការនិពន្ធអត្ថបទកាព្យ ជាសាស្ត្រាល្បែងតាមបែបសាសនា តាំងពីសម័យមុន រហូតដល់ពាក់កណ្ដាល ទីមួយនៃសតវត្សទី២០ នៅពេលអ្នកនិពន្ធតាមបែបប្រលោមលោកទំនើបចូលមកជំនួសទើបអស់អត្ថិភាព។ អ្នកនិពន្ធទាំងអស់នោះ ជាអ្នករក្សាទម្រង់វិធីនិម្មិតកម្មស្នាដៃតាមបែបសាសនា បានយ៉ាងខ្ជាប់ខ្ជួន ហើយជាអ្នកដែលទទួលឥទ្ធិពលពីសាសនាយ៉ាងមុតមាំ។ វិធីនិម្មិតកម្មនោះចែកជា៖

ផ្នែកអត្ថន័យ៖ និយាយពីការអន្ទោលកើតស្លាប់ក្នុងជាតិផ្សេងៗ ដើម្បីកសាងបារមីរបស់តួអង្គ ព្រះពោធិសត្វ មានការកសាងបារមីទាំងដប់ក្នុងរឿងទសជាតក ការកសាងបារមីផ្សេងៗក្នុងរឿងពុទ្ធនិយមក្លាយ (ក្នុងរឿងបញ្ញាសជាតក) និងក្នុងរឿងពុទ្ធនិយមក្លាយ ហួសហេតុ (ផ្ទុម) ក្នុងបំណងត្រាស់ជាព្រះពុទ្ធនាអនាគតជាតិ នៅក្នុងគោលពុទ្ធនិយម។ ការបង្ក្រាបសភាវៈអាក្រក់របស់អវតារព្រះអាទិទេព ដែលជាតំណាងសភាវៈល្អ នៅក្នុងគោលព្រាហ្មណ៍និយម។

**ផ្នែកអត្ថរូប ៖** ស្នាដៃនិពន្ធឡើងជាពាក្យកាព្យ ពោរពេញទៅដោយពាក្យច្នូរណ្ដំផ្ទួនណែងណង បន្តគ្នាប្រកបដោយរូបារម្មណ៍នៃសាសនា ដើម្បីបន្ទន់ចិត្តអ្នកអាន អ្នកស្ដាប់ឱ្យលង់លក់ទៅក្នុងគំនិត វើរវាយអារម្មណ៍ អណ្ដែតអណ្ដូងទៅក្នុងអច្ឆរិយភាពឥតព្រំដែនរបស់សាសនា ដោយប្រើពាក្យពេចន៍ជាភាសាបាលី(មគធភាសា) សំស្ក្រឹតដែលគេយល់ថាជាភាសាល្អប្រសើរខ្ពង់ខ្ពស់ មានក្បួនខ្នាតត្រឹមត្រូវ ប្រសើរថ្លៃថ្លាជាភាសារបស់អាទិទេពលាយឡំជាមួយភាសាខ្មែរបុរាណ។ អ្នកប្រាជ្ញបុរាណខ្មែរបានចារឹកអត្ថបទទាំងនោះលើផ្ទាំងសិលាចារឹកលើស្បែកសត្វ លើសាស្ត្រាស្លឹករឹត លើក្រាំងគម្ពីរនានាទៅតាមសម័យកាល និងចលនានីមួយៗ។ ផ្ទៃរឿងចែកចេញជាបីដំណាក់កាល គឺផ្ដើមរឿងនិយាយពីការនមស្ការ

ព្រះរតនត្រ័យព្រះពុទ្ធអង្គសម្តែងព្រះធម្មទេសនានៅអារាមណាមួយជាការនិទានពីការកសាងបារមីណាមួយក្នុងអតីតជាតិប្រោសសាវ័ក និងពុទ្ធបរិស័ទទាំងឡាយ ដំណើររឿងនិទានពីការចេញចាកព្រះរាជបល្ល័ង្កទៅកសាងបារមីផ្សេងៗរបស់តួអង្គពោធិសត្វឬមហាសត្វ បញ្ចប់រឿងនិយាយពីការជួបជុំមូលត្រកូលគ្រួសារ ការវិលត្រឡប់មកគ្រងរាជសម្បត្តិវិញរបស់តួអង្គព្រះពោធិសត្វ ការសជាតិមកបច្ចុប្បន្នជាតិរបស់ព្រះពុទ្ធអង្គនិងអង្គសាវ័កទាំងឡាយ ជាដើមក្នុងគោលពុទ្ធនិយមៗ ការផ្តើមរឿងនិយាយពីការធ្វើហោមពិធីរបស់មហាឫសីអង្គណាមួយ ដើម្បីជប្បវត្តស័ក្តិសិទ្ធិក្នុងគោលព្រាហ្មណ៍និយម ដំណើររឿងនិទាន ពីការធ្វើសង្គ្រាមបង្ក្រាបពួកយក្ស អសុរ ជាសភាវៈអាក្រក់ ដែលដើរបំផ្លិចបំផ្លាញសេចក្តីសុខ ភាពរុងរឿងរបស់ប្រជាជន របស់តួអង្គអវតាព្រះអាទិទេព ពិសេសព្រះវិស្ណុ និងបញ្ចប់រឿងនិទាន ពីការទទួលជោគជ័យលើពួកសភាវៈអាក្រក់ ការវិលត្រឡប់ទៅសោយរាជ្យវិញរបស់តួអង្គអវតា (រឿងរាមកេរ្តិ៍) ការសោយសុខនៅស្ថានសួគ៌(រឿងមហាភារតយុទ្ធ)ជាដើមក្នុងគោលព្រាហ្មណ៍និយមៗ

ទោះបីអត្ថបទខ្លះ ពុំបានគោរពទៅតាមគោលការណ៍ខាងលើឱ្យបានត្រឹមត្រូវក៏ដោយ ប៉ុន្តែការនិពន្ធជាអត្ថបទកាព្យអាចចាត់ទុកជាគ្រឿងសម្គាល់មួយដ៏សំខាន់សម្រាប់កំណត់ប្រភេទអ្នកនិពន្ធមុនពេលទទួលឥទ្ធិពលបស្ចឹមប្រទេសវៀរលែងតែស្នាដៃសម័យក្រោយៗមួយចំនួនដែលអ្នកនិពន្ធព្យាយាមសរសេរ ជាអត្ថបទកំណាព្យឡើងវិញៗ

អ្នកនិពន្ធ និងស្នាដៃលេចធ្លោមួយចំនួន ក្នុងសម័យនោះមានជាអាទិ៍៖

-ព្រះធម្មបញ្ញា អ៊ុក និពន្ធរឿងមរណមាតា ឆ្នាំ១៨៧៧

-ព្រហ្មបវរកត្តី និពន្ធរឿង ពោធិវង្ស ឆ្នាំ១៨៨១

-ឧកញ៉ាវង្សាធិបតី អ៊ុក និពន្ធរឿងសង្ខសិល្បជ័យ ឆ្នាំ១៨៨២

-ឃុនសន្ធរពិនិត្យ និពន្ធរឿងចៅមាស ឆ្នាំ១៨៨៧

-ព្រះចៅអធិការវត្តព្រែកប្រណាក និពន្ធរឿង ព្រះលក្ខិណាវង្ស ឆ្នាំ១៨៩០

-ហ្លួនកក្តីអក្សរ តន់ និពន្ធរឿង សព្វសិទ្ធិ ( ពាក្យប្រាំពីរ) ឆ្នាំ១៨៩៩

-ឧកញ៉ាសុត្តន្តប្រីជាឥន្ទ្រ (អ៊ិន) និពន្ធរឿង អំបែងបែក ឆ្នាំ១៨៨៩ រឿង គតិលោក ឆ្នាំ១៩២០ រឿងកាព្យនិរាសអង្គរ ឆ្នាំ១៩២៦ និពន្ធ ច្បាប់កូនចៅ បោះពុម្ពឆ្នាំ១៩០០ នៅទីក្រុងប៉ារីស

-តាមាស និពន្ធ ច្បាប់បណ្តាំតាមាស ឆ្នាំ១៩០៤ បោះពុម្ពឆ្នាំ១៩០៨

-? និពន្ធសាស្ត្រាទាវឯក ឆ្នាំ១៩០៥

-ព្រះកិត្តុបទុមត្ថេរសោម និពន្ធរឿង ទុំ ទាវ ឆ្នាំ១៩១៥

-លោកយោធានរិន្ទ វ៉ាន់ និពន្ធរឿង សេកសារិកា ឆ្នាំ១៩២០

-អ្នកស្រីសិទ្ធ និពន្ធរឿង ពិម្ពាពិលាប ឆ្នាំ១៩២០

-ឧកញ៉ាវិបុលរាជសេនា នូ កន និពន្ធរឿងពិម្ពានិព្វាន ឆ្នាំ១៩២០ រឿងទាវឯក ឆ្នាំ ១៩៤២

-អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ (ក្រមង៉ុយ) និពន្ធច្បាប់ក្រមង៉ុយ

-បំរើឧទ័យ យស ងិន និពន្ធរឿងទេវវង្សកុមារ (ចៅស្រទបចេក) (រជ្ជកាលព្រះបាទស៊ីសុវត្ថិ)

-អ្នកនិពន្ធ ហ្វូងអគ្គវិសេស ដួង និពន្ធរឿង ល្បើកអក ? ល្បើកជុច និងត្រីល្បើកផ្ការផ្តាំក្តាមខ្យងល្បើកសារិកា ?

## ២-២ .អ្នកនិពន្ធប្រលោមលោកទំនើប

អ្នកនិពន្ធប្រលោមលោកទំនើប គឺបណ្តាអ្នកនិពន្ធដែលបានទទួលការសិក្សាពីសាលាទំនើប ទទួលឥទ្ធិពលពីការអានសិក្សាប្រលោមលោកបស្ចឹមប្រទេស ដែលហូរចូលមកប្រទេសខ្មែរ តាមរយៈអាណាព្យាបាលបារាំង ឬពីសំណាក់ប្រទេសជិតខាង ដែលបានទទួលឥទ្ធិពលនេះពី ប្រទេសលោកខាងលិច ជាអាទិ៍បារាំង អង់គ្លេស។ អ្នកនិពន្ធប្រភេទនេះក៏បានទទួលការសិក្សាពីសាលាវត្តផងដែរ ក្នុងកម្រិតដំបូង ទើបបន្តការសិក្សាថ្នាក់មធ្យមសិក្សាជាដើមនៅតាមសាលាទំនើបដែលជាសាលាកម្រនៅប្រទេសខ្មែរនាសម័យនោះ។ ក្នុងសម័យប្រទេសយើងត្រូវពួកអាណានិគមនិយមវាជិះជាន់វប្បធម៌សេរីភាពនិយមរបស់ពួកវាមានសន្ទុះខ្លាំង ក៏នាំឱ្យអក្សរសាស្ត្ររបស់ខ្មែរយើងមួយផ្នែក មាននិន្នាការទៅតាម ពួកវា ទៅដែលយើងឱ្យឈ្មោះថា ៖ អក្សរសាស្ត្រផ្នែកបរទេសនិយម។ ពាក្យថាបរទេសនិយមនេះ គឺមានន័យថា បរទេសប៉ែកខាងលិចច្រើនជាង ពីព្រោះថា បរទេសដែលនៅជិតខាងយើង ដូចជា សៀម យួន ចិន លាវ..។ល។ ក៏ត្រូវទទួលឥទ្ធិពលនៃវប្បធម៌បរទេសបស្ចឹមនិយមដូចយើងដែរ[៤]។ នាសម័យកាលនេះ អក្សរសិល្ប៍ខ្មែរមានលក្ខណៈមនុស្សនិយមដោយអ្នកនិពន្ធលើកយកបញ្ហាមនុស្សមកចោទ ដោះស្រាយទៅតាមតថភាពសង្គម និងខិតខំបង្ហាញពីមធ្យោបាយការយល់ឃើញផ្សេងៗរបស់ខ្លួនក្នុងបំណងលុបបំបាត់ភាពអសកម្មក្នុងជីវភាពសង្គម ផ្ទុះផ្សាទំនាស់សង្គមជាដើម។ ប្រធានបទសំខាន់នាសម័យកាលនោះគឺ«ស្នេហា» ដែលស្នេហានេះត្រូវប្រឈមជាមួយបញ្ហាទ្រព្យសម្បត្តិកិត្តិយសអំណាចផ្តាច់ការរបស់មាតាបិតា អាណាព្យាបាលជា ដើម។

អ្នកនិពន្ធប្រលោមលោកពាក្យរាយដំបូងក្នុងសម័យនោះ មានជាអាទិ៍:

- អ្នកនិពន្ធ ញ៉ុក ថែម និពន្ធរឿង កូលាបប៉ៃលិន

ឆ្នាំ១៩៣៦

- អ្នកនិពន្ធ រីម គីន និពន្ធរឿង សូផាត ឆ្នាំ១៩៣៨

[៤] ហ៊ុន គឹមសៀ *មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ* បណ្ណាគារភ្នំពេញ ឆ្នាំ១៩៦៣ ទំព័រ៣៨។

- អ្នកនិពន្ធ គីម ហាក់ និពន្ធរឿង ទឹកទន្លេសាប ឆ្នាំ១៩៣៩

- អ្នកនិពន្ធ សិទ្ធិនិពន្ធរឿងគូសាង មិត្តមិនទ្រូស្តមិត្តរឿងចិត្តសត្យាឆ្នាំ១៩៤០

- អ្នកនិពន្ធ នូ ហាច និពន្ធរឿង ផ្កាស្រពោន ឆ្នាំ១៩៤០

- អ្នកនិពន្ធ ញ៉ុក ថែម និពន្ធរឿង បិសាចស្នេហា ឆ្នាំ១៩៤០

- អ្នកនិពន្ធ នង ឈុំ និពន្ធរឿង ចៅកើតកុសល ឆ្នាំ១៩៤១

- អ្នកនិពន្ធ តូច សឹងហន និពន្ធរឿង កែបមាត់សមុទ្រ ឆ្នាំ១៩៤២

-អ្នកនិពន្ធ ហេង យ៉ាន់ និពន្ធរឿង កំពូលកំសត់ ឆ្នាំ១៩៤៤

-អ្នកនិពន្ធ ហេង យ៉ាន់ និពន្ធរឿង កំពូលស្នេហា ឆ្នាំ១៩៤៦

- អ្នកនិពន្ធ អ៊ុំម ហ៊ី និពន្ធរឿង មហាអភ័ព្វ ឆ្នាំ១៩៤៦

-អ្នកនិពន្ធ នូ កន និពន្ធរឿងតុង ឈិន ឆ្នាំ១៩៤៧

- អ្នកនិពន្ធ ឈុប និពន្ធរឿងព្រាត់ ដួងចិត្ត ឆ្នាំ១៩៤៧

- អ្នកនិពន្ធ អ៊ុំម ហ៊ី និពន្ធរឿងទឹកភ្នែកស្រីស្រុកស្រែ ឆ្នាំ១៩៤៧

-កញ្ញា ស៊ឹម វណ្ណស៊ី និពន្ធរឿង សង្ឃឹមជានិច្ច ឆ្នាំ១៩៤៨

- អ្នកនិពន្ធ នូ ហាច និពន្ធរឿង មាលាដួងចិត្ត ឆ្នាំ១៩៥២

- អ្នកនិពន្ធ រឹម គីន និពន្ធរឿង នាង សមាភារី ឆ្នាំ១៩៥២

-អ្នកនិពន្ធ និពន្ធរឿង ម៉ាក់កយុងកែវ ឆ្នាំ១៩៥២

## ៣. នានាភាពនៃអក្សរសិល្ប៍ខ្មែរ សម័យអាណានិគមនិយមបារាំង

### ៣-១ អក្សរសិល្ប៍បែបប្រពៃណី

អក្សរសិល្ប៍បែបប្រពៃណី គឺជាបណ្តាស្នាដៃទទួលឥទ្ធិពលពីសាសនាមុន ពេលអក្សរសិល្ប៍ខ្មែរទទួលឥទ្ធិពលពីអក្សរ សិល្ប៍ទំនើបបែបបស្ចឹមប្រទេស តាមរយៈប្រទេសបារាំង ដែលដាក់អាណាព្យាបាលលើប្រទេសកម្ពុជាពីឆ្នាំ១៨៦៣ មក។

អក្សរសិល្ប៍បែបប្រពៃណីមានពីរដំណាក់កាលធំៗគឺ អក្សរសិល្ប៍-អក្សរសាស្ត្រសិលាចារឹក និងអក្សរសិល្ប៍-អក្សរសាស្ត្រសាស្ត្រាស្លឹករឹត។ ស្នាដៃភាគច្រើនលើសលុបនៃអក្សរសិល្ប៍បែបប្រពៃណី គឺជាអត្ថបទពាក្យកាព្យ មានច្រើនទម្រង់ ច្រើនប្រភេទដ៏សម្បូរបែបជាមត៌កវណ្ណកម្មអក្សរសាស្ត្រខ្មែរគ្រប់ជំនាន់។

អត្ថបទពាក្យកាព្យ ឬកំណាព្យ គឺជាស្នាដៃអក្សរសិល្ប៍សំណេរមួយប្រភេទរបស់ខ្មែរដែលខុសប្លែកពីអត្ថបទពាក្យរាយ ព្រោះទាមទារឱ្យកវីខិតខំបញ្ចេញនូវទេពកោសល្យរបស់ខ្លួនដើម្បីទាបអន្ទងអូសទាញវិញ្ញាណអ្នកអាន អ្នកស្តាប់ឱ្យជក់ចិត្តជិតអារម្មណ៍ រំភើបលន្លង់លន្លោចឱ្យស្រងេះស្រងោចទៅតាមដំណើររឿងរបស់ខ្លួន។ ការតាក់តែងកំណាព្យទាមទារឱ្យកវីគោរពតាមក្បួនចំណាប់ជួនទី២ត្រូវឱ្យមានអត្ថន័យល្អ។ លើ

ផ្នែកអត្ថន័យកំណាព្យ ត្រូវឱ្យមានន័យឃ្លោង (មិនត្រង់ពេក) ពោលបើចង់ថ្លែងពីរឿងអ្វីមួយ គេមិនបាច់ចង់និយាយបូរបាច់ច្រើនពេកទេ គឺគេថ្លែងហាក់មិនដឹងហាក់មិនយល់ន័យដែលគេចង់ថ្លែង។ ម្យ៉ាងទៀតពីឃ្លាមួយទៅឃ្លាមួយពីវគ្គមួយទៅវគ្គមួយត្រូវឱ្យកាន់តែប្លែកឡើងៗកាន់តែធ្វើឱ្យបរិយាកាស និងសម្ពាធ ន័យកាន់តែឡើងកាន់តែរំភើបឡើងរហូត។

កវីខ្មែរបុរាណបានបន្សល់នូវស្នាដៃកំណាព្យដ៏ល្អៗជាច្រើន ទុកជាមរតកដ៏ថ្លៃថ្លា សម្រាប់កូនខ្មែរជំនាន់ក្រោយសិក្សារៀនសូត្រ។ កំណាព្យខ្មែរ មានអាយុកាលស្មើនឹងមនុស្សខ្មែរ ហើយមានតួនាទីយ៉ាងសកម្មក្នុងការប្រលោមលួងលោមអារម្មណ៍របស់ខ្មែរ ប្រកបដោយអត្ថន័យអប់រំ។ កំណាព្យទាំងនោះមានលក្ខណៈពីរោះណែងណងល្គងល្គាយ មានរូបារម្មណ៍យ៉ាងអាថ៌កំបាំង ហើយ មានអត្ថន័យជ្រាលជ្រៅ ព្រមទាំងបង្កប់នូវតម្លៃអប់រំ សីលធម៌ សុជីវធម៌ របៀបរបបរស់នៅ និងការរកទទួលទាន។

### ៣-១-១ អក្សរសិល្ប៍សាស្ត្រាល្បែង

សាស្ត្រាល្បែងជាប្រភេទអក្សរសិល្ប៍ខ្មែរ សម័យកណ្ដាល ដែលមានកំណើតឡើងនៅប្រមាណសតវត្ស ទី១៦ ហើយបានបន្សល់នូវភាពសម្បូរបែបនៃមត៌កនេះច្រើនជាស្នាដៃនាសតវត្សទី១៨-១៩ នាចុងសម័យឧដុង្គ និងដើមសម័យអាណាព្យាបាលបារាំង។ ស្នាដៃសំខាន់ៗនៃសាស្ត្រាល្បែង ច្រើនជាអត្ថបទកំណាព្យរឿងបែបពុទ្ធសាសនាទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនាខ្លះៗ នៅក្នុងដំណើររឿង ដែលត្រូវបានប្រើប្រាស់ដើម្បីជារឿងអប់រំ ចិត្តគំនិត កែកម្សាន្ត កែអផ្សុក នៅក្នុងពេលស្រុកជួប ប្រទះសង្គ្រាមជាញឹកញាប់ស្ទើរគ្រប់ពេលវេលា។

មានការឱ្យនិយមន័យសាស្ត្រាល្បែងជាច្រើនបែបទៅតាមការយល់ឃើញរបស់អ្នកសិក្សាស្រាវជ្រាវអក្សរសាស្ត្រខ្មែរមួយចំនួនដូចជាសម្ដេចព្រះសង្ឃរាជជួន ណាត ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ុំឈុំ ប៊ុន ឯកឧត្តមបណ្ឌិតសភាចារ្យ សោម សុមុនី លោកបណ្ឌិតសភាចារ្យឃីង ហុកឌី ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ធ សោ លោក អ៊ូ ឈៀង ជាដើមដែលនិយមន័យទាំងនោះមានលក្ខណៈប្រហាក់ប្រហែលគ្នា។

### ៣-១-២. អក្សរសិល្ប៍ឧបទេសសាស្ត្រាច្បាប់

អក្សរសិល្ប៍ឧបទេស គឺជាប្រភេទស្នាដៃអក្សរសិល្ប៍ ដែលបានតាក់តែងឡើងដើម្បីធ្វើការអប់រំ ណែនាំផ្ដល់ដំបូន្មានល្អៗដល់មហាជនខ្មែរគ្រប់វ័យឱ្យចេះគិតគូរពិចារណា មុននឹងធ្វើកិច្ចការអ្វីមួយរបៀបរបបរស់នៅ ក្នុងជីវភាពប្រចាំថ្ងៃ ក្នុងសង្គមទៅតាមចំណេះដឹង និងចំណង់ចំណូលចិត្តរបស់អ្នកតែង។

សាស្ត្រាច្បាប់ គឺជាកម្រងឯកសារច្បាប់ សម័យកណ្ដាល ដែលបន្សល់ទុកតៗពីជំនាន់មួយទៅជំនាន់មួយ សម្រាប់អនុវត្តក្នុងកិច្ចដឹកនាំ គ្រប់គ្រងប្រទេសប្រជាជនឱ្យប្រព្រឹត្តទៅបានល្អ។ ច្បាប់ក្នុងសាស្ត្រាច្បាប់មានលក្ខណៈជាច្បាប់ប្រពៃណី សាសនា

ចង់ក្រងទៅតាមចំណោះដឹងរបស់អ្នកតែង ដែលអាចជាព្រះរាជា ដូចជា ច្បាប់ព្រះរាជសម្ភារច្បាប់ត្រីនេត្រ ឬជាមន្ត្រីជាន់ខ្ពស់ ឬអាចជាបុព្វជិតជាពស្ត្រសាមញ្ញ ដែលមានចំណោះដឹងធ្លាប់បានបួសរៀនចេះគម្ពីរវិន័យធម៌អាថ៌ព្រះពុទ្ធសាសនា គាត់តែងឡើងដើម្បី អប់រំចិត្តគំនិតមហាជនឱ្យវៀរចាកអ បាយមុខទាំងឡាយ។

### ៣-២ អក្សរសិល្ប៍ទំនើប ប្រលោមលោក ពាក្យរាយ

ប្រលោមលោមលោកទំនើបខ្មែរ បានចាប់ផ្ដើមចេញដំណើរនៅដើមសតវត្សទី២០ ដោយត្រូវបានសន្មត់យកឆ្នាំ១៩០០ ជាគោល។ ប្រលោមលោកទំនើបបានវិវត្តអត្ថន័យពីលក្ខណៈសាសនា មកជីវភាពមនុស្សសាមញ្ញ តាមរយៈអត្ថបទជាស្នាដៃកំណាព្យមួយ ចំនួននាដើមសតវត្សទី២០ ជាអាទិ៍ឧកញ៉ា សុត្តន្តប្រីយ៍ជាឥន្ទ្រ (អ៊ិន) និពន្ធរឿង អំបែងបែកឆ្នាំ ១៨៨៩ រឿងគតិលោក ឆ្នាំ ១៩២០ អ្នកនិពន្ធច្បាប់កូនចៅ បោះពុម្ពឆ្នាំ១៩០០ នៅទីក្រុងប៉ារីស តាមាស និពន្ធ ច្បាប់បណ្ដាំតាមាស ឆ្នាំ១៩០៤ ព្រះភិក្ខុបទុមត្ថេរសោម និពន្ធ រឿងទុំទាវ ឆ្នាំ១៩១៥ លោកយោធានរិន្ទ រ៉ាន់ និពន្ធរឿងសេក សារិកា ឆ្នាំ១៩២០ ក្រមង៉ុយ តាមរយៈច្បាប់ ក្រមង៉ុយ ជាដើម។ ចំណែកអត្ថរូបបានវិវត្តពីលក្ខណៈប្រពៃណីជាកំណាព្យ មកជាពាក្យរាយនាទសវត្សទី ៤ នៃសតវត្សទី ២០ តាមរយៈស្នាដៃដំបូងៗ ដូចជា អ្នកនិពន្ធ ញ៉ុក ថែម និពន្ធរឿងកុលាបប៉ៃលិន ឆ្នាំ១៩៣៦ អ្នកនិពន្ធ រីម គីន និពន្ធរឿង សូផាត ឆ្នាំ១៩៣៨ អ្នកនិពន្ធ គីម ហាក់ និពន្ធរឿង ទឹកទន្លេសាប ឆ្នាំ ១៩៣៩ អ្នកនិពន្ធ សិទ្ធិ និពន្ធរឿងគូសាងមិត្ត មិនទ្រូស្តមិត្ត រឿងចិត្ត សត្យា ឆ្នាំ១៩៤០ អ្នកនិពន្ធ នូ ហាច និពន្ធ រឿងផ្កាស្រពោន ឆ្នាំ ១៩៤០ អ្នកនិពន្ធ ញ៉ុក ថែម និពន្ធរឿងបិសាចស្នេហា ឆ្នាំ១៩៤០ ជាដើម។ នៅក្នុង ផ្នែក អត្ថរសបានវិវត្ត ពី លក្ខណៈអច្ឆរិយរសមកជាលក្ខណៈតថរសសង្គមរសដែលស្ដែងចេញ តាមរយៈការ បង្ហាញ ពីតថ ភាពសង្គម ជីវភាពរស់នៅ បញ្ហារបស់មនុស្សសាមញ្ញ ទូទៅជំនួសឱ្យបញ្ហាសាសនា។

# ឯកសារពិគ្រោះ

**ស្នាដៃបោះពុម្ពផ្សាយ និងនិក្ខេបបទ**

**ល.រ អ្នកនិពន្ធ ឈ្មោះសៀវភៅ រោងពុម្ព ឆ្នាំ**


*១. ក្រុមអ្នកចងក្រង ៖ សំរាវជ្រាវជីវប្រវត្តិអ្នកនិពន្ធខ្មែរ ? ១៩៨៦*

*៣. គីន ណាន ៖ ក្រមុំចូលម្លប់និងពិធីរើសគូស្រករ ?១៩៨២*

*៤. គឹមសែត ៖ ប្រវត្តិអក្សរសាស្ត្រ ? ?*

*៥. ឃីង ហុកឌី ៖ ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ ដាសតៀនស ល់គារមាតតាន១៩៩៧*

*៦. ឃីង ហុក ឌី, មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី១៩, បណ្ណាគារអង្គរ,២០០៧*

*៧. ឃីង ហុក ឌី, មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី២០, បណ្ណាគារអង្គរ,២០០៧*

*៨. ឃឹម សាគុណា ៖ សិទ្ធិមនុស្សតាមរយៈអក្សរសិល្ប៍ខ្មែរ ?១៩៨២*

*៩. ឃឹម សំឌិ ៖ប្រវត្តិអក្សរសាស្ត្រខ្មែរ ?១៩៦១*

*១០. ឃួន សុខម្ភៈ ប្រវត្តិអ្នកនិពន្ធខ្មែរ ? ?*

*១១. ង៉ុយ ៖ ច្បាប់ក្រមង៉ុយ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧២,២៥១៦*

*១២. ជួន ណាត ៖ វចនានុក្រមខ្មែរភាគ១-២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៧*

*១៣. អង្គឌួង ៖ ច្បាប់ស្រី ពុទ្ធសាសនបណ្ឌិត្យ ១៩៦២,២៥០៥*

*១៥. ត្រឹង ង៉ា,ប្រវត្តិសាស្ត្រខ្មែរ, ភាគ១ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ, ១៩៧៤*

*១៦. ត្រឹង ង៉ា ៖ ប្រវត្តិសាស្ត្រខ្មែរ ភាគ២ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ, ១៩៧៤,២៥១៨*

*១៩. ធ សោ ៖ លក្ខណៈទីពីកក្នុងអក្សរសិល្ប៍ និងសិល្បៈខ្មែរ មេរៀនសរសេរដៃ ២០០២*

*២០. ហ៊ិន គឹមសៀ ៖ មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ ? ?*

*២១. ពៅ សាមី ៖ លក្ខណៈទំនេរនៃអក្សរសិល្ប៍និងសិល្បៈ*

*២២. ពៅ សាមី ៖លក្ខណៈទំនេរនៃអក្សរសិល្ប៍និងសិល្បៈ*

*២៣. ពៅ សាមី ៖ តថនិយមក្នុងអក្សរសិល្ប៍ខ្មែរសតវត្សទី២០*

*២៤. ពៅ សាមី ៖ មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ ប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់ ១៩៨៧*

*២៥. រស់ ចន្ត្រាបុត្រ ៖ អំពីស្នេហា សារពត៌មានមហាជន ១៩៧១*

*២៦. លាង ហ័បអាន ៖ សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ ភាគ១ ?១៩៦៧*

*២៧. លាង ហ័បអាន ៖ សិក្សាអត្ថបទ ភាគ១ ?១៩៦៦*

*២៨. លាង ហ័បអាន ៖ សិក្សាអត្ថបទ ភាគ២ ?១៩៦៦*

*២៩. លាង ហាប់អាន ៖ ប្រជុំវិញ្ញាសាតែងសេចក្តីគំរូសំរាប់ថ្នាក់ទី៥.៤.៣ ទំនើប ?*

៣០. លាង ហាប់អាន ៖ សិក្សាសង្ខេបរឿងកុលាបប៉ៃលិន ??
៣១. លី ធាមតេង ៖ អ្នកនិពន្ធខ្មែរដែលមានឈ្មោះល្បី បណ្ណាល័យអប្សរា សមាគមអ្នកនិពន្ធខ្មែរ ១៩៧២
៣២.លី សុមុនី, កំណាព្យខ្មែរ, ក្រសួងអប់រំយុវជន និង កីឡា, ២០០២
៣៣. វ៉ាន់ឌី កាអុន ៖ វិភាគទាននៃក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ ??
៣៤. វ៉ាន់ឌី កាអុន ៖ក្បួនចិត្តសាស្ត្រ ?១៩៧៣
៣៥. វ៉ាន់ឌី កាអុន ៖វិភាគទានក្នុងការសិក្សាប្រាកដនិយមនិងអណ្តែតអណ្តូងនិយម ?១៩៧៣
៣៦. វ៉ាន់ឌី កាអុន ៖សង្គមសាស្ត្រ ?១៩៧៣
៣៧. ស៊ន សំណាង (E.d.) ៖ ខេមរវិទ្យា ចំណេះដឹងអំពីអតីតកាល និង ការរួមវិភាគទានក្នុងការស្តារ និង ស្ថាបនាប្រទេសកម្ពុជាឡើងវិញ ភាគ២ រោងពុម្ពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៩
៣៨. សម្ព័ន្ធអ្នកសារពត៌មាន រដ្ឋាភិបាលកម្ពុជា ពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៩៣ ??
៣៩. សមាគមអ្នកនិពន្ធខ្មែរ ៖ ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធសមាជិកនៃសមាគម ១៩៧០
៤០. សមាគមអ្នកនិពន្ធបទភ្លេង នឹងទំនុកច្រៀង ៖លក្ខន្តិកៈ ? ១៩៦២
៤១. សោម សុមុនី ៖ អក្សរសិល្ប៍ពាក្យរាយខ្មែរ និក្ខេបបទថ្នាក់បណ្ឌិត, សំណេរដៃ, ?
៤២. សែម សូរ ៖ វិជ្ជានិពន្ធន៍ខ្មែរចម្រុះ បណ្ណាគារភ្នំពេញ, ១៩៦៣
៤៣. ស៊ុំ ឈុំប៊ុន ៖ តួអង្គក្នុងអក្សរសិល្ប៍ទំនើបខ្មែរ ពីទសវត្សទី៤០ ដល់ទី៦០ និក្ខេបបទថ្នាក់បណ្ឌិត, ?
៤៤. ស៊ុំ ឈុំប៊ុន ៖ អក្សរសិល្ប៍ខ្មែរ សម័យទំនើប មេរៀនសរសេរដៃ, ២០០២
៤៥. ស៊ុំ ឈុំប៊ុន ៖ គោលសង្ខេបនៃការសិក្សាប្រវត្តិអក្សរសិល្ប៍ខ្មែរ មេរៀនសរសេរដៃ, ២០០២
៤៦. អ៊ុក ចួន ៖ ចំណោទ និងសំរាយបញ្ហាក្នុងអក្សរសិល្ប៍ខ្មែរ សកព, ១៩៨៨
៤៧. អ៊ុក សាម៉ន ៖ សិក្សាកថារឿងទុំ-ទាវ បណ្ណាគារភ្នំពេញ, ១៩៦៦,២៥០៨
៥៤. Klairung Amratisha: ***The Cambodian Novel,A study of its Emergence and Development*** ?1998
៧៩. អក្សរសាស្ត្រ-មនុស្សសាស្ត្រ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ លេខ១៩ ត្រីមាសទី៣ ឆ្នាំ២០០២
៨០. ឯកសារ ៖ សន្និសីទជាតិស្តីពី ការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា ៖ តុល្យការ និង ចក្ខុវិស័យ រាជបណ្ឌិតសភាកម្ពុជា ២០០០

**អត្ថបទរឿង**

**ល.រ ឈ្មោះអ្នកនិពន្ធ ឈ្មោះអត្ថបទ ផ្សាយពី ពេទពុម្ភ កាលបរិច្ឆេទ**

*៨២. គឹម ហាក់ ទឹកទន្លេសាប ? ១៩៣៦*

*៨៣. ឃីង ហុក ឌី, ទាវឯក, បណ្ណាគារអង្គរ,២០០៥។*

*៨៤. ញ៉ុក ថែម កុលាបប៉ៃលិន គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ក្រ.អ.យ.ក. ២០០១,២៥៤៥*

*៨៥. នូ ហាច ផ្កាស្រពោន ក្រសួងសិក្សាធិការជាតិ ពេងពុម្ពរស្មី១៩៦០.២៥០៣*

*៩០. នូ ហាច មាលាដួងចិត្ត មជ្ឈមណ្ឌលស្រាវជ្រាវអារ្យធម៌ខ្មែរ១៩៨១*

*៩២. នូ ហាច មាលាដួងចិត្ត ឯកសារប្រើប្រាស់ផ្ទៃក្នុង សាលាគរុវិជ្ជាជាន់ខ្ពស់ ១៩៨៩*

*៩៣. រីម គីន សូផាត បណ្ណាគារ សេង ង៉ួនហួត ភ្នំពេញ ១៩៦៥,២៥០៧*

*៩៤. រីម គីន នាងសមាគារី បណ្ណាល័យជាតិ ភ្នំពេញ ២០១៣*

*៩៥. សោម ទុំទាវ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧១,២៥១៤*

*៩៦. ចៅកក្តីឱក ហង្សយន្ត ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៩៨,២៥៤២*

# ការអប់រំ និងឧក្រិដ្ឋកម្ម
## (Education and Crime)

*ដោយៈ បណ្ឌិត* **សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ,វិទ្យាស្ថាន*
*មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា*

*ឧក្រិដ្ឋកម្ម ឬបទល្មើសព្រហ្មទណ្ឌជាអំពើដែលបង្កគ្រោះថ្នាក់មិនត្រឹមតែចំពោះបុគ្គលមួយចំនួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់សហគមន៍ សង្គម ឬប្រទេសផងដែរ។*

*គំនិតដែលធ្វើសកម្មភាពដូចជាឃាតកម្មការចាប់រំលោភ និងចោរកម្មត្រូវបានហាមឃាត់នៅទូទាំងពិភពលោក។ អ្វីដែលជាបទល្មើសព្រហ្មទណ្ឌត្រូវបានកំណត់ដោយច្បាប់ព្រហ្មទណ្ឌនៃយុត្តាធិការពាក់ព័ន្ធនីមួយៗ។ ខណៈពេលដែលមនុស្សជាច្រើនមានកាតាឡុក ឬបញ្ជីរាយឈ្មោះ*(Catalogue)*នៃឧក្រិដ្ឋកម្មដែលហៅថា ក្រមព្រហ្មទណ្ឌ នៅក្នុងប្រទេសច្បាប់ទូទៅមួយចំនួនមិនមានលក្ខន្តិកៈទូលំទូលាយបែបនេះទេ។*

*ប្រទេស ដែលមានការអប់រំកម្រិតខ្ពស់តែងទទួលអត្រាឧក្រិដ្ឋកម្មទាបជាងមធ្យមភាគកម្រិតជាតិផងដែរ។ ប្រទេសដែលមានអត្រាចុះឈ្មោះចូលរៀន នៅមហាវិទ្យាល័យខ្ពស់មានអត្រាឧក្រិដ្ឋកម្មហិង្សាទាបជាងប្រទេស ដែលមានអត្រាចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យទាបជាង។*

### ១. សេដ្ឋកិច្ចវិទ្យានៃការអប់រំ និងឧក្រិដ្ឋកម្ម (The economics of education and crime)

*ហេតុអ្វីបានជាការអប់រំកាត់បន្ថយឧក្រិដ្ឋកម្ម និងប្រភេទនៃឧក្រិដ្ឋកម្មណាទំនងជាមានភាពទាក់ទាញបំផុតចំពោះគោលនយោបាយអប់រំ? ទស្សនវិស័យសេដ្ឋកិច្ចផ្តល់នូវការយល់ដឹងដ៏មានប្រយោជន៍ជាច្រើនលើបញ្ហាទាំងនេះ។*

Lochner (២០០៤) *បានសង្កត់ធ្ងន់លើតួនាទីនៃការអប់រំ ជាការវិនិយោគមូលធនមនុស្សដែលបង្កើនឱកាសការងារស្របច្បាប់ នាពេលអនាគតដែលរារាំងដល់ការចូលរួមក្នុងឧក្រិដ្ឋកម្ម។ រឿងនេះ កើតមានស្របគ្នានឹងការសិក្សាជាច្រើនដែលចងក្រងជាឯកសារនោះ និងថាប្រាក់ឈ្នួលខ្ពស់ កាត់បន្ថយឧក្រិដ្ឋកម្ម ហើយការស្រាវជ្រាវជាច្រើនទសវត្សនៅក្នុងការងារសេដ្ឋកិច្ចបានបង្ហាញថា ការអប់រំបង្កើន*

អត្រាប្រាក់ឈ្នួល។ ប្រសិនបើទុនមនុស្សបង្កើនចំណោញតែបន្តិចបន្តួចពីការងារច្រើនជាងឧក្រិដ្ឋកម្ម អញ្ចឹងការវិនិយោគមូលធនមនុស្ស និងការសិក្សាអប់រំ គួរកាត់បន្ថយឧក្រិដ្ឋកម្ម។ ដូច្នេះគោលនយោបាយដែលបង្កើនការសិក្សាអប់រំ (ឬប្រសិទ្ធភាពនៃសាលារៀន) គួរកាត់បន្ថយប្រភេទឧក្រិដ្ឋកម្មតាមដងវិថីក្នុងចំណោមមនុស្សពេញវ័យ។ ទោះយ៉ាងណាក៏ដោយ ប្រភេទឧក្រិដ្ឋកម្មខាងបញ្ញាមួយចំនួន (ឧ. ការកិបកេងបន្លំ) អាចកើនឡើងជាមួយនឹងការអប់រំដែលបានរៀននៅសាលា។

ការអប់រំ ក៏អាចបង្រៀនបុគ្គលឱ្យមានការអត់ធ្មត់ច្រើនជាងនេះដែរ (Becker & Mulligan, ១៩៩៧)។ រឿងនេះនឹងបន្ទាចឧក្រិដ្ឋកម្ម ដោយហេតុថា បុគ្គលម្នាក់ៗតែងគិតដល់ការដាក់ទម្ងន់លើការផ្តន្ទាទោសណាមួយយ៉ាងខ្លាំង ពាក់ព័ន្ធនឹងសកម្មភាពឧក្រិដ្ឋរបស់ពួកគេ នាពេលអនាគត។ ឧក្រិដ្ឋកម្ម ពាក់ព័ន្ធនឹងការកាត់ទោសជាប់ពន្ធនាគាររយៈពេលវែង (ឬផលវិបាករយៈពេលវែងផ្សេងទៀត) គួរតែត្រូវបានប៉ះពាល់ខ្លាំងបំផុត។

តាមការកសាងគ្រួសារ (Becker, ១៩៩១) បុរសដែលមានការអប់រំច្រើន មានទំនោរទៅរៀបការជាមួយស្ត្រី ដែលមានការអប់រំច្រើន។ រឿងនេះ អាចជះឥទ្ធិពលដល់ធនធានគ្រួសារ អាកប្បកិរិយានៃការមានកូន និងស្ថិរភាពគ្រួសារដែលអាចជះឥទ្ធិពលដល់ការសម្រេចចិត្តក្នុងការចូលរួមក្នុងឧក្រិដ្ឋកម្ម។

ជាទូទៅ ប្រសិនបើមនុស្ស ដែលមានការអប់រំ កាន់តែច្រើនធ្វើអន្តរកម្មកាន់តែច្រើនជាមួយមនុស្ស ដែលមានការអប់រំផ្សេងទៀត ដែលមិនសូវមានទំនោរចង់ចូលរួមក្នុងឧក្រិដ្ឋកម្មនេះ ទំនងជារួមបញ្ចូលការកាត់បន្ថយនូវឧក្រិដ្ឋកម្មដែលទាក់ទងនឹងការសិក្សា។ ក្នុងករណីភាគច្រើនយន្តការទាក់ទង នឹងការផ្លាស់ប្តូរចំណូលចិត្ត ឬអន្តរកម្មសង្គមបានបង្ហាញថា ការទទួលបានការអប់រំទំនងជាអាចកាត់បន្ថយប្រភេទឧក្រិដ្ឋកម្មភាគច្រើនក្នុងចំណោមមនុស្សពេញវ័យ។

## ២. ភស្តុតាង ស្តីពីការអប់រំ គុណភាពសាលារៀន និងឧក្រិដ្ឋកម្ម

(Evidence on Education, School Quality, and Crime)

មានភស្តុតាងកាន់តែច្រើនឡើងពីជុំវិញពិភពលោក ស្តីពីឥទ្ធិពលនៃការទទួលបានការអប់រំលើផលនៃឧក្រិដ្ឋកម្មជាបន្តបន្ទាប់។ ការអប់រំកាន់តែច្រើននាំឱ្យមានឧក្រិដ្ឋកម្មគេចផុសចេញពីការសិក្សាភាគច្រើន។

ការសិក្សាមួយចំនួន ក៏ពិនិត្យមើលផលប៉ះពាល់នៃជម្រើសសាលារៀននិងគុណភាពលើអាកប្បកិរិយាឧក្រិដ្ឋកម្ម។ អ្នកស្រាវជ្រាវថ្មីៗជាច្រើនបានវិភាគអំពីទំនាក់ទំនងសហសម័យរវាងការចូលរៀន និងឧក្រិដ្ឋកម្ម។ ការសិក្សាទាំងនេះ បង្ហាញពីទំនាក់ទំនងស្មុគ្រស្មាញដែលបង្ហាញពីសារៈសំខាន់លើបរិបទ។

## ៣. ឥទ្ធិពលនៃការអប់រំលើឧក្រិដ្ឋកម្ម

( Effects of Educational Attainment on Crime)

ការសិក្សាដំបូងអំពីទំនាក់ទំនងរវាងការអប់រំ និងឧក្រិដ្ឋកម្ម ផ្ដោតលើការជាប់ទាក់ទងគ្នារបស់ពួកគេតាមលក្ខខណ្ឌលើលក្ខណៈបុគ្គល និងគ្រួសារដែលបានវាស់វែងដោយប្រើវិធីតម្រែតម្រង់ស្ដង់ដា។ ការសិក្សាទាំងនេះ ត្រូវបានបកស្រាយដោយប្រយ័ត្នប្រយែង ចាប់តាំងពីការជាប់ទាក់ទងផ្នែកអវិជ្ជមានរវាងការអប់រំ និងឧក្រិដ្ឋកម្ម សូម្បីតែសម្រាប់ប្រវត្តិគ្រួសារ និងលក្ខណៈអ្នកជិតខាង។

- ទី១៖ លក្ខណៈពិសេសបុគ្គលដូចជាការអត់ធ្មត់ ឬការស្អប់ខ្ពើមហានិភ័យទំនងជាជះឥទ្ធិពលផ្ទាល់ទាំងការចូលរៀន និងការសម្រេចចិត្តផ្នែកព្រហ្មទណ្ឌ។ បុគ្គលដែលជ្រើសរើសការសិក្សាបន្ថែមទៀត ក៏អាចជ្រើសរើសឧក្រិដ្ឋកម្មតិចជាងមុនដោយមិនគិតពីកម្រិតនៃការអប់រំរបស់ពួកគេ។

- ទី២៖ ការប្រែប្រួលនៃឧក្រិដ្ឋកម្ម និងការអប់រំ នៅទូទាំងសហគមន៍មូលដ្ឋាន ក៏អាចបង្កើតការប៉ាន់ស្មានដោយលំអៀងផងដែរ។ រដ្ឋាភិបាល អាចប្រឈមមុខនឹងជម្រើសរវាងការផ្ដល់មូលនិធិដល់ប៉ូលីស ឬសាលារដ្ឋល្អ ដែលបង្កើតទំនាក់ទំនងវិជ្ជមានដ៏គួរឱ្យភ្ញាក់ផ្អើលរវាងការអប់រំ និងឧក្រិដ្ឋកម្ម។ ម្យ៉ាងវិញទៀត លក្ខណៈដែលមិនបានសង្កេតអំពីសហគមន៍ អាចប៉ះពាល់ដោយផ្ទាល់ទៅលើការចំណាយ ឬអត្ថប្រយោជន៍ទាំងការអប់រំ និងឧក្រិដ្ឋកម្ម។

-ទី៣៖ មូលហេតុបញ្ច្រាស គឺកង្វល់សំខាន់មួយទៀត។ បុគ្គលដែលមានគម្រោងចូលរួមក្នុងឧក្រិដ្ឋកម្មកម្រិតធ្ងន់ទំនងជានឹងជ្រើសរើសការឈប់រៀនតាំងពីក្មេង (Lochner, ២០០៤)។ ការចាប់ខ្លួន ឬការឃុំឃាំងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអនីតិជនក៏អាចបណ្ដាលឱ្យយុវជនមួយចំនួនបោះបង់ការសិក្សាឱ្យបានឆាប់ផងដែរ។

ការសិក្សាជាក់ស្ដែង នាពេលថ្មីៗនេះ ជាទូទៅប៉ាន់ប្រមាណពីផលប៉ះពាល់នៃការទទួលបានការអប់រំទៅលើការចាប់ខ្លួន ការផ្ដន្ទាទោស ឬអត្រាជាប់ពន្ធនាគារ។ ដើម្បីបញ្ជាក់គុណសម្បត្តិ និងភាពផ្សេងៗ ដែលមិនបានសង្កេត អ្នកស្រាវជ្រាវបានទាញយកប្រយោជន៍ពីការផ្លាស់ប្ដូរខាងក្រៅ នៅក្នុងច្បាប់រដ្ឋ ឬជាតិដែលប៉ះពាល់ដល់ការសម្រេចចិត្តរបស់សាលា ការពិនិត្យមើលផលប៉ះពាល់នៃគោលនយោបាយទាំងនេះ លើឧក្រិដ្ឋកម្មជាបន្តបន្ទាប់។ នេះធានាថា ការប៉ាន់ប្រមាណ ឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃការអប់រំលើឧក្រិដ្ឋកម្ម និងមិនមែនគ្រាន់តែជាការជាប់ទាក់ទងគ្នាដ៏ចម្លែកនោះទេ។

Hjalmarsson,Holmlund,and Lindquist (២០១៥) ប្រើប្រាស់ទិន្នន័យខ្នាតតូចផ្នែករដ្ឋបាល និងកំណែទម្រង់សាលារៀននៅប្រទេសស៊ុយអែត ដើម្បីកំណត់ពីឥទ្ធិពលនៃការអប់រំទៅលើឧក្រិដ្ឋកម្ម។ កំណែទម្រង់ស៊ុយអែតជា

ចម្បង បានពង្រីកការចូលរៀនជាកំហិតពីប្រាំពីរឆ្នាំទៅប្រាំបួនឆ្នាំ ហើយត្រូវបានអនុវត្តនៅពេលផ្សេងគ្នា នៅទូទាំងក្រុងក្នុងអំឡុងទសវត្សឆ្នាំ១៩៥០ និងឆ្នាំ១៩៦០។ ដូចនេះ Hjalmarsson និងអ្នកដទៃទៀត ប្រៀបធៀបបុគ្គលដែលត្រូវបានប៉ះពាល់នឹងប្រព័ន្ធសាលារៀនពីរផ្សេងគ្នា ប៉ុន្តែ អ្នកដែលមកពីក្រុមកំណើតដូចគ្នា និងធ្វើការនៅក្នុងទីផ្សារការងារដូចគ្នា។ ការលោតត្រដាងទៅនឹងកំណែទម្រង់បានបង្កើនការទទួលបានការអប់រំជាមធ្យម ០,៣៣ ឆ្នាំសម្រាប់បុរស និង០,២0 ឆ្នាំសម្រាប់ស្ត្រី។ ឥទ្ធិពលប៉ាន់ស្មានលើឧក្រិដ្ឋកម្មស្ត្រីមិនច្បាស់លាស់ ទោះយ៉ាងណាក៏ដោយ ការប៉ាន់ប្រមាណសម្រាប់បុរសបានបង្ហាញថា ការសិក្សាបន្ថែមមួយឆ្នាំអាចកាត់បន្ថយលទ្ធភាពនៃការផ្តន្ទាទោសព្រហ្មទណ្ឌឡើងវិញ៧% និងលទ្ធភាពនៃការជាប់គុក១៦%។ ក្រឡេកទៅមើលប្រភេទបទល្មើស ការចូលរៀនឆ្នាំបន្ថែមកាត់បន្ថយលទ្ធភាពនៃការផ្តន្ទាទោសឧក្រិដ្ឋកម្មលើអចលនទ្រព្យ១៤% ការផ្តន្ទាទោសឧក្រិដ្ឋកម្មហិង្សា១០% និងការផ្តន្ទាទោសប្រភេទឧក្រិដ្ឋកម្មផ្សេងទៀត៦% ប្រហាក់ប្រ ហែលនឹងការប៉ាន់ស្មាន សម្រាប់សហរដ្ឋអាម៉េរិក។

Meghir, Palme, and Schnabel (២០១៤) បង្ហាញថា កំណែទម្រង់សាលារៀនស៊ុយអែត ក៏ប៉ះពាល់ដល់សកម្មភាពឧក្រិដ្ឋកម្មរបស់មនុស្សជំនាន់ក្រោយផងដែរ។ ការប៉ាន់ស្មានរបស់ពួកគេបានបង្ហាញថា កំណែទម្រង់បាននាំឱ្យមានការថយចុះ០,៨% នៃអត្រាការផ្តន្ទាទោសព្រហ្មទណ្ឌ (ប្រហែលមួយភាគបីនៃអត្រាមូលដ្ឋាន) ក្នុងចំណោមកូនប្រុសរបស់ឪពុកដែលប្រឈមនឹងកំណែទម្រង់សាលារៀន។ ផលប៉ះពាល់ត្រូវបានប្រមូលផ្តុំភាគច្រើនក្នុងចំណោមឧក្រិដ្ឋកម្មហិង្សា ឧក្រិដ្ឋកម្មចរាចរណ៍ធ្ងន់ធ្ងរ និងការក្លែងបន្លំ (រួមទាំងការគេចពន្ធ)។ ផ្ទុយទៅវិញ ពួកគេមិនបានរកឃើញឥទ្ធិពលនៃកំណែទម្រង់លើអត្រាការផ្តន្ទាទោសក្នុងចំ ណោមនោះទេ។ កូនប្រុសរបស់ស្ត្រីម្នាក់ បានលោតត្រដាងទៅនឹងកំណែទម្រង់នេះ បើទោះបី ជាមានផលប៉ះពាល់ស្រដៀងគ្នាលើការសិក្សារបស់ពួកគេក៏ដោយ។

Buonanno and Leonida (២០០៩) ប៉ាន់ប្រមាណពីផលប៉ះពាល់នៃការទទួលបានការអប់រំលើអត្រាឧក្រិដ្ឋកម្ម ដោយប្រើក្រុមអ្នកស្រាវជ្រាវ២០តំបន់ នៅអ៊ីតាលីពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩៥។ ពួកគេបង្ហាញថា ការកើនឡើង១០ភាគរយនៃអត្រាបញ្ចប់ការសិក្សានៅវិទ្យាល័យ នឹងកាត់បន្ថយអត្រាឧក្រិដ្ឋកម្មអចលនទ្រព្យ (Property crime rates)ចំនួន៤% និងអត្រាឧក្រិដ្ឋកម្មសរុប (total crime rates) ត្រឹម៣%។ ពួកគេបានរកឃើញភស្តុតាងមួយដែលបង្ហាញថា ការបញ្ចប់សាកលវិទ្យាល័យកាត់បន្ថយឧក្រិដ្ឋកម្ម (They find evidence to suggest that university completion reduces crime.)។

ការសិក្សាចុងក្រោយពិនិត្យផលប៉ះពាល់នៃការឧបត្ថម្ភធនផ្នែកអប់រំច្បាស់លាស់លើអត្រាចោរកម្មរបស់យុវជននៅក្នុងប្រទេសអង់គ្លេស។ ចន្លោះឆ្នាំ១៩៩៩ និង២០០២ ប្រទេសអង់គ្លេស បានសាកល្បងប្រាក់ឧបត្ថម្ភថៃទាំអប់រំ (EMAs, Educational Maintenance Allowances) ដែលផ្តល់ប្រាក់ឧបត្ថម្ភរហូតដល់ £៤០ ក្នុងមួយសប្តាហ៍ (បូកនឹងប្រាក់រង្វាន់សម្រាប់ការបញ្ចប់ការសិក្សា សម្រាប់យុវជនអាយុ១៦-១៨ឆ្នាំដែលមានចំណូលទាប ដើម្បីចូលរៀន។ កម្មវិធីនេះ ត្រូវបានអនុវត្តក្នុងតំបន់មូលដ្ឋានចំនួន១៥ ដែលមានអត្រារួមចូលរៀនទាប។ ក្នុងអំឡុងពេលដូចគ្នានេះ គំនិតផ្តួចផ្តើមកាត់បន្ថយការលួចបន្លំ (RBI, the Reducing Burglary Initiative) បានផ្តល់មូលនិធិដល់៦៣ គម្រោងកាត់បន្ថយការលួចចូលក្នុងតំបន់ផ្សេងៗគ្នា ជាគម្រោងសាកល្បងដាច់ដោយឡែកមួយ។ ប្រហែលពាក់កណ្តាលនៃតំបន់សាកល្បងEMAទាំងអស់ ក៏ត្រូវបានជ្រើសរើសសម្រាប់RBIផងដែរ។ Sabates និងFeinstein (២០០៨) ប្រើយុទ្ធសាស្ត្រភាពខុសគ្នា ដើម្បីកំណត់ពីផលប៉ះពាល់នៃកម្មវិធីសាកល្បងនីមួយៗ ក៏ដូចជាការរួមបញ្ចូលគ្នានៃទាំងពីរលើការលួច។ ការរកឃើញរបស់ពួកគេបានបង្ហាញថា ការរួមបញ្ចូលគ្នានៃEMA និងRBI បានកាត់បន្ថយយ៉ាងខ្លាំងនូវអត្រាចោរកម្មប្រហែល ៥.៥% ទាក់ទងទៅនឹងតំបន់ប្រៀបធៀប"ដែលត្រូវគ្នា"។ ឥទ្ធិពលនៃEMA តែម្នាក់ឯង គឺទាបជាងបន្តិច ប៉ុន្តែនៅតែមានសារៈសំខាន់។

## ៤. ផលនៃការអប់រំលើឧក្រិដ្ឋកម្មស្ត្រី

**(Effects of Education on Female Crime)**

ឯកសារភាគច្រើន បានផ្តោតអារម្មណ៍លើបុរស ដែលមានអត្រាឧក្រិដ្ឋកម្មខ្ពស់ជាងគេ។ Cano-Urbina and Lochner (២០១៩) ផ្តល់នូវភស្តុតាងដំបូងមួយចំនួនដែលថា ការទទួលបានការអប់រំ អាចកាត់បន្ថយឧក្រិដ្ឋកម្មរបស់ស្ត្រី។ លោក Lochner (២០០៤) ពួកគេបង្ហាញថា ការសិក្សាបន្ថែមកាត់បន្ថយ ប្រូបាប៊ីលីតេនៃការជាប់ឃុំឃាំងត្រឹម០,០៥-០,០៩ ភាគរយនៅក្នុងចំណោម ស្ត្រីជនជាតិអាម៉េរិកស្បែកស (ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៨០) ខណៈដែលការកើនឡើងមួយឆ្នាំនៃកម្រិតសិក្សាជាមធ្យម កាត់បន្ថយអត្រាការចាប់ខ្លួនស្ត្រីសម្រាប់ទាំងឧក្រិដ្ឋកម្មហិង្សា និងទ្រព្យសម្បត្តិច្រើនជាង៥០% (ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩០)។ មានផលប៉ះពាល់តិចតួចនៃការសិក្សាបន្ថែមលើឧក្រិដ្ឋកម្មគន្លាស់អាវពណ៌ស (បញ្ញាជន)។

ការប៉ាន់ប្រមាណ នៃផលប៉ះពាល់នៃឆ្នាំសិក្សាបន្ថែម លើប្រូបាប៊ីលីតេនៃការជាប់ឃុំឃាំងគឺប្រហែល៤ដងសម្រាប់បុរសជាងស្ត្រី ខណៈដែលអត្រាជាប់ឃុំជាមូលដ្ឋានគឺខ្ពស់ជាងប្រហែល២០ដងសម្រាប់បុរសដែលមានការអប់រំទាបធៀបនឹងស្ត្រី។ ដូច្នេះ ផលប៉ះពាល់នៃ

ការអប់រំលើការជាប់ពន្ធនាគារគឺខ្លាំងជាង សម្រាប់ស្ត្រីគិតជាភាគរយ។ នេះក៏ជាការពិត សម្រាប់ការចាប់ខ្លួន។

ដូចដែលបានពិភាក្សាខាងលើ ឥទ្ធិពលភាគច្រើននៃការអប់រំលើឧក្រិដ្ឋកម្ម នៅក្នុងចំណោមបុរស អាចត្រូវបានពន្យល់ដោយការកើនឡើងនៃប្រាក់ឈ្នួល និងការចូលរួមទីផ្សារការងារកាន់តែច្រើន។ Cano-Urbina and Lochner (២០១៩) បង្ហាញថា នេះ មិនទំនងជាករណីសម្រាប់ស្ត្រីទេ (យ៉ាងហោចណាស់សម្រាប់ឆ្នាំ១៩៦០-៨០) ចាប់តាំងពីពួកគេបានប៉ាន់ប្រមាណឥទ្ធិពលតិចតួចនៃការសិក្សាលើឥរិយាបថផ្គត់ផ្គង់ពលកម្មស្ត្រី។ ផ្ទុយទៅវិញ ការអប់រំហាក់ដូចជាធ្វើឱ្យអនាគតអាពាហ៍ពិពាហ៍របស់ស្ត្រី កាន់តែប្រសើរឡើង។ ការកើនឡើងនៃអាពាហ៍ពិពាហ៍ទំនងជាកាត់បន្ថយឧក្រិដ្ឋកម្មដោយការពង្រឹងចំណងគ្រួសារ ខណៈដែលការកើនឡើងនៃការអប់រំប្តីប្រពន្ធ និងធនធានគ្រួសារ អាចកំណត់ការលើកទឹកចិត្តសម្រាប់ស្ត្រីឱ្យងាកទៅរកឧក្រិដ្ឋកម្ម ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។ ទោះជាយ៉ាងនេះក្តី ការអប់រំកាត់បន្ថយការជាប់ឃុំឃាំងជាស្ត្រី បើទោះបីជាលក្ខខណ្ឌនៃស្ថានភាពអាពាហ៍ពិពាហ៍ក៏ដោយ ដូច្នេះបណ្តាញផ្សេងទៀតក៏សំខាន់ផងដែរ។

Cano-Urbina and Lochner (២០១៩) ប៉ាន់ប្រមាណថា ការកើនឡើងនៃការសិក្សាក៏បណ្តាលឱ្យស្ត្រី មានកូនកាន់តែច្រើនផងដែរ ដែលអាចបង្អាក់ឧក្រិដ្ឋកម្មដោយការបង្កើនចំណាយផ្ទាល់ខ្លួននៃពេលវេលានៅក្នុងពន្ធនាគារ និងការពង្រឹងចំណងគ្រួសារ/សង្គម។ ជាការពិតណាស់ បណ្តាញអប់រំដែលជះ ឥទ្ធិពលដល់ឧក្រិដ្ឋកម្មរបស់ស្ត្រី ប្រហែលជាបានផ្លាស់ប្តូរក្នុងប៉ុន្មានទសវត្សថ្មីៗនេះ ដោយសារស្ត្រីបានចូលទីផ្សារការងារកាន់តែច្រើន កាត់បន្ថយពេលវេលានៅផ្ទះ និងចិញ្ចឹមកូនតិចជាងមុន។

## ៥. ឥទ្ធិពលនៃជម្រើសសាលារៀន និងគុណភាព លើឧក្រិដ្ឋកម្ម (Effects of School Choice and Quality on Crime)

ការសិក្សាមួយចំនួនបានបង្ហាញថា ការកែលម្អគុណភាពសាលារៀន អាចនាំឱ្យមានការថយចុះនៃសកម្មភាពឧក្រិដ្ឋ នៅក្នុងអំឡុងពេលពេញវ័យដំបូង។ ការប្រើប្រាស់ឆ្នោតចូលសាលារៀនដោយចៃដន្យ Cullen, Jacob,and Levitt(២00៦)និងDeming (២០១១) បានរកឃើញថាសិស្សដែល'ឈ្នះ'ឱកាសដើម្បីចូលរួមសាលារដ្ឋដែលដំណើរការល្អជាងមុន មិនត្រូវការអនុវត្តការសិក្សាបានប្រសើរជាងមុន ប៉ុន្តែ ពួកគេប្រព្រឹត្តបទឧក្រិដ្ឋតិចជាងគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលសិក្សា និងប៉ុន្មានឆ្នាំដំបូង បន្ទាប់ពីចាកចេញពីសាលា។ Weiner,Lutz, and Ludwig (២00៩)បង្ហាញថា គំនិតផ្តួចផ្តើមបំបែកបំបាក់នៅក្នុងរដ្ឋមួយចំនួនរបស់សហរដ្ឋអាម៉េរិកបាននាំឱ្យមានការកែលម្អយ៉ាងខ្លាំងនៅក្នុងគុណភាពសាលារៀនសម្រាប់ជនស្បែកខ្មៅ។ ក្នុងចំណោមជនជាតិស្បែកខ្មៅដែលជួប

ប្រទះការបែកខ្ញែកអត្រាបញ្ចប់ការសិក្សានៅវិទ្យាល័យបានកើនឡើងពីរឬបីភាគរយ ហើយអត្រាចាប់ខ្លួនមនុស្សឃាតបានធ្លាក់ចុះមួយភាគបីនៅអាយុ១៥-១៩ឆ្នាំ។

ផ្ទុយទៅវិញ ការវិភាគរបស់Cano Urbina និងLochner (២០១៩) ផ្តល់នូវភស្តុតាងចម្រុះ ទាក់ទងនឹងផលប៉ះពាល់នៃគុណភាពសាលារៀន (ដូចដែលបានវាស់វែងដោយសមាមាត្រសិស្ស-គ្រូ រយៈពេល និងអត្រាប្រាក់ឈ្នួលគ្រូ) លើឧក្រិដ្ឋកម្មស្ត្រី។ ជាពិសេស ការប៉ាន់ប្រមាណផលប៉ះពាល់ដោយផ្ទាល់នៃការកែលម្អគុណភាពសាលារៀន (ការរក្សាការទទួលបានការអប់រំត្រូវបានជួសជុល) មានភាពមិនស៊ីសង្វាក់គ្នាលើវិធានការនៃគុណភាពទាំងពីរនិងឧក្រិដ្ឋកម្ម។ ដោយសារការកែលម្អគុណភាពសាលារៀន នាំឱ្យមានការកើនឡើងនៃការទទួលបានការអប់រំ និងផលប៉ះពាល់ប៉ាន់ស្មាននៃការទទួលបានសាលារៀនលើឧក្រិដ្ឋកម្មគឺខ្លាំងផលប៉ះពាល់ដោយប្រយោលនៃការកែលម្អគុណភាព (ទាំងការចាប់ខ្លួន និងការឃុំឃាំង)តាមរយៈការកើនឡើងនៃការសិក្សាមានភាពវិជ្ជមាន ទោះបីជាតិចតួចក៏ដោយសម្រាប់គុណភាព ដែលបានសង្កេតទាំងអស់នឹងដែលបានវាស់វែង។

## ៦. សាលាសហសម័យ និងឧក្រិដ្ឋកម្ម

(Contemporaneous Schooling and Crime)

មានវិធីសំខាន់ៗចំនួនបី ដែលការផ្លាស់ប្តូរការចូលរៀនរបស់យុវជនទំនងជាប៉ះពាល់ដល់ការចូលរួមក្នុងឧក្រិដ្ឋកម្មក្នុងពេលបច្ចុប្បន្នរបស់ពួកគេ។

- ទី១៖ សាលារៀន អាចមានឥទ្ធិពលដល់ផលអសមត្ថភាពយុវជន មិនអាចស្ថិតនៅកន្លែងពីរក្នុងពេលតែមួយបានទេ។ ឱកាសឧក្រិដ្ឋកម្មជាច្រើនមានកម្រិតនៅក្នុងសាលារៀនជាងនៅតាមដងផ្លូវ។ ឥទ្ធិពលនេះ មួយផ្នែកអាស្រ័យលើភាពងាយស្រួលដែលយុវជនអាចចូលរួម នៅក្នុងឧក្រិដ្ឋកម្មក្នុងអំឡុងពេលមិនចូលរៀន។

-ទី២៖ រយៈពេលនៃការចូលរៀន នៅសាលាយូរជាងនេះ គួរតែបង្កើនជំនាញទីផ្សារការងារ និងកែលម្អលទ្ធភាពការងារនាពេលអនាគត ដូចដែលបានសង្កត់ធ្ងន់ខាងលើ។ នេះគួរតែធ្វើឱ្យការចាប់ខ្លួនអនីតិជន និងការឃុំខ្លួនរយៈពេលវែងមានតម្លៃថ្លៃជាងមុនដោយកាត់បន្ថយការលើកទឹកចិត្តឱ្យចូលរួមក្នុងឧក្រិដ្ឋកម្មនៅពេលចុះឈ្មោះចូលរៀន។

-ទី៣៖ សាលារៀន នាំក្មេងជំទង់រាប់រយនាក់ មកជួបជុំគ្នា នាពេលបច្ចុប្បន្ន។ អន្តរកម្មសង្គមពីរនេះអាចនាំឱ្យមានការឈ្លោះប្រកែកគ្នានិងការប្រព្រឹត្តខុសលើក្រុមទូទៅបន្ថែមទៀត។ ឥទ្ធិពលអសមត្ថភាពនិងមូលធនមនុស្សទំនងជាបង្ហាញពីផលប៉ះពាល់អវិជ្ជមាននៃការ

ចូលរៀននៅសាលាលើឧក្រិដ្ឋកម្មខណៈពេលដែលឥទ្ធិពលអន្តរកម្មសង្គមអាចជាវិជ្ជមាន ឬអវិជ្ជមាន។

ការសិក្សាមួយចំនួន បានបង្ហាញពន្លឺលើផលប៉ះពាល់ទាំងនេះ ដោយការប៉ាន់ប្រមាណពីផលប៉ះពាល់នៃ«អន្តរាគមន៍» ផ្សេងៗគ្នា ដែលជះឥទ្ធិពលដោយផ្ទាល់ដល់ការចូលរៀននៅសាលារបស់យុវជន។ Anderson (២០១៤) និង Brilli និងTonello (២០១៨) ពិនិត្យមើលឥទ្ធិពលនៃការបង្កើនអាយុចូលរៀនជាកាតព្វកិច្ច (ពោលគឺការបង្ខំយុវជនមួយចំនួនឱ្យស្នាក់នៅក្នុងសាលារៀន) ខណៈពេលដែល Jacob និងLefgren (២០០៣)និង Luallen (២០០៦) សិក្សាពីឥទ្ធិពលនៃថ្ងៃបន្ថែមនៃការឈប់សម្រាកពីសាលាដោយសារតែគ្រូបង្រៀននៅក្នុងថ្ងៃបម្រើសេវា ឬការធ្វើកូដកម្មរបស់គ្រូបង្រៀន (ពោលគឺការរក្សាយុវជនទាំងអស់ចេញពីសាលា)។ អន្តរាគមន៍ទាំងនេះខុសគ្នាក្នុងការគោរពសំខាន់ពីរ៖

- ទី១៖ ការកើនឡើងនៃអាយុកាតព្វកិច្ចសិក្សា តម្រូវជាធម្មតា ដែលសិស្សស្នាក់នៅក្នុងសាលាយ៉ាងហោចណាស់មួយឆ្នាំ បន្ថែមច្រើនជាងនេះ ហើយពេលខ្លះទៀតនោះ ខណៈពេលដែលគ្រូបង្រៀននៅក្នុងសេវាកម្ម និងកូដកម្មមានរយៈពេលខ្លីណាស់។

-ទី២៖ ខណៈពេលដែលគ្រូធ្វើកូដកម្ម និងថ្ងៃធ្វើការ ដោះលែងសិស្សទាំងអស់ចេញពីសាលារៀន ការផ្លាស់ប្តូរច្បាប់ស្តីពីការចូលរៀនជាកាតព្វកិច្ចជាធម្មតា ប៉ះពាល់ដល់សិស្សមួយចំនួនតូចៗ ផលប៉ះពាល់សក្តានុពលទាំងបីនៃការចូលរៀន នៅសាលាលើឧក្រិដ្ឋកម្មទំនងជាពាក់ព័ន្ធនឹងការផ្លាស់ប្តូរនៅក្នុងសាលាជាកាតព្វកិច្ច ខណៈពេលដែលផលប៉ះពាល់នៃថ្ងៃធ្វើការ និងកូដកម្មរបស់គ្រូបង្រៀន ទំនងជាត្រូវបានកំណត់ ចំពោះភាពអសមត្ថភាព និងអន្តរកម្មសង្គម។ ផលអន្តរកម្មសង្គមទំនងជាត្រូវបានពង្រីកនៅក្នុងករណីចុងក្រោយ ដោយសារតែលក្ខណៈសកលនៃគោលនយោបាយ។

Anderson (2014) ប៉ាន់ប្រមាណថាកំណើនអាយុនៅសាលាកាតព្វកិច្ចរដ្ឋរបស់សហរដ្ឋអាម៉េរិកមានអាយុចាប់ពី១៦ដល់១៨ កាត់បន្ថយការចាប់ខ្លួនយ៉ាងសំខាន់នៅអាយុដែលរងផលប៉ះពាល់ប្រហែល១៧% ជាមួយនឹងផលប៉ះពាល់ស្រដៀងគ្នា ទាំងលើឧក្រិដ្ឋកម្មហិង្សានិងទ្រព្យសម្បត្តិ។ ផលប៉ះពាល់គឺស្រដៀងគ្នា ទោះបីជាស្ថិតិមិនសំខាន់ក៏ដោយសម្រាប់ឧក្រិដ្ឋកម្មគ្រឿងញៀន។

ការប្រើប្រាស់ទិន្នន័យរដ្ឋបាលរបស់ប្រទេសអ៊ីតាលី អំពីអត្រាបំពានតាមអាយុ ឆ្នាំ និងខេត្ត Brilli និងTonello (2018) សិក្សាពីផលប៉ះពាល់នៃការបង្កើនអាយុសិក្សាអប្បបរមាពី ១៤ទៅ១៥ឆ្នាំក្នុងឆ្នាំ១៩៩៩។ ខណៈពេលដែលការចុះឈ្មោះចូលរៀននៅសាលាបានកើនឡើងប្រ ហែល៤% នៅអាយុ១៤-១៧ឆ្នាំ អត្រាបំពានបានធ្លាក់ចុះ ដោយឧប្បត្តិហេតុប្រហែល ២ ក្នុង១០០០យុវជន នៅអាយុ១៤ឆ្នាំប៉ុណ្ណោះ។

ពួកគេបានប៉ាន់ប្រមាណថា មិនមានភស្តុតាងនៃការផ្លាស់ទីលំនៅ ទៅពេលវេលាផ្សេងទៀតនៃថ្ងៃ/ឆ្នាំដែលសាលាមិនចូលរៀន។ ទោះយ៉ាងណាក៏ដោយ វាហាក់ដូចជាមានការកើនឡើងនៃប្រូបាប៊ីលីតេនៃការក្លាយជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដោយហិង្សាខណៈពេលដែលនៅសាលារៀន។ លទ្ធផលទាំងនេះ បង្ហាញពីការរួមបញ្ចូលគ្នានៃឥទ្ធិពលអសមត្ថភាពទូទៅ (កាត់បន្ថយឧក្រិដ្ឋកម្មនៅខាងក្រៅសាលា) និងឥទ្ធិពលអន្តរកម្មសង្គមដែលនាំឱ្យមានឧក្រិដ្ឋកម្មហិង្សាបន្ថែម ក្នុងអំឡុងពេលសាលារៀន។

ជំនួយបន្ថែមសម្រាប់ភាពអសមត្ថភាព និងផលប៉ះពាល់អន្តរកម្មនៃការចូលរៀននៅសាលាត្រូវបានផ្តល់ដោយ Jacob និង Lefgren(២០០៣)និងLuallen(២០០៦)ដែលប៉ាន់ប្រមាណពីផលប៉ះពាល់ចម្រុះនៃថ្ងៃឈប់សម្រាកពីសាលាលើឧក្រិដ្ឋកម្មដោយសារថ្ងៃធ្វើការឬកូដកម្មរបស់គ្រូ។ ការប៉ាន់ប្រមាណរបស់ពួកគេបានបង្ហាញថា នៅក្នុងតំបន់ទីក្រុងមួយថ្ងៃនៃសាលារៀនបន្ថែម កាត់បន្ថយឧក្រិដ្ឋកម្មលើអនីតិជនដោយ១៥-៣០%។ ទោះយ៉ាងណាក៏ដោយ វាបង្កើនឧក្រិដ្ឋកម្មហិង្សាប្រហែល ៣០%។

ជាងនេះទៅទៀត Luallen (២០០៦) រកឃើញថា ផលប៉ះពាល់នៃថ្ងៃសិក្សាបន្ថែមគឺមិនសូវសំខាន់នៅក្នុងតំបន់ជនបទ និងជាយក្រុង ដោយផ្តល់យោបល់ថា អសមត្ថភាព និងឥទ្ធិពលអន្តរកម្មសង្គមនៃការចូលរៀននៅសាលាគឺខ្លាំងជាពិសេស នៅក្នុងតំបន់ទីក្រុង និងមានការធ្វេសប្រហែស នៅកន្លែងផ្សេងទៀត។

## ៧. សេចក្តីអធិប្បាយខ្លីៗ ស្តីពីវិធានការព្រហ្មទណ្ឌ (Brief Comment on Measures of Criminality)

កង្វល់ដ៏មានសក្តានុពលមួយ ចំពោះការសិក្សាទាំងនេះ ភាគច្រើនគឺការពឹងផ្អែកលើការចាប់ខ្លួន ការផ្តន្ទាទោស និងការឃុំខ្លួន ជាវិធានការនៃឧក្រិដ្ឋកម្ម។ វាអាចទៅរួចដែលថាការអប់រំធ្វើឱ្យប្រសើរឡើងនូវឱកាសដែលនរណាម្នាក់ គេចពីការចាប់ខ្លួន ឬការកាត់ទោស ឬថាចៅក្រម មានទំនោរក្នុងការផ្តល់ឱ្យជនជាប់ចោទ ដែលមានការអប់រំកាន់តែច្រើនទោសដាក់ពន្ធនាគារស្រាលជាងមុន។ ខណៈពេលដែលមានភស្តុតាងផ្ទាល់តិចតួច លើបញ្ហាទាំងនេះ Mustard (២០០១) រកឃើញផលប៉ះពាល់តិចតួចនៃកម្រិតការអប់រំចុងចោទលើប្រវែងទោសដែលពួកគេទទួល។ ជាងនេះទៅទៀតលទ្ធផលដោយប្រើវិធានការណ៍ដែលរាយការណ៍ដោយខ្លួនឯងនៃសកម្មភាពឧក្រិដ្ឋកម្មនៅក្នុងការស្ទង់មតិបណ្តោយជាតិនៃយុវជនគាំទ្រដល់ករណីដែលការអប់រំកាត់បន្ថយអំពើហិង្សា និងឧក្រិដ្ឋកម្មលើទ្រព្យសម្បត្តិ មិនត្រឹមតែប្រូបាប៊ីលីតេនៃការចាប់ខ្លួន ឬការឃុំឃាំងដែលមានលក្ខខណ្ឌលើឧក្រិដ្ឋកម្មទេ (Lochner, ២00៤; Lochner & Moretti, ២០០៤)។

## ៨. ឥទ្ធិពលនៃការចាប់ខ្លួន និងការឃុំឃាំងលើការអប់រំ (The Effects of Arrest and Incarceration on Education)

ការសិក្សាចំនួនពីរឈានដល់ការសន្និដ្ឋានស្រដៀងគ្នា អំពីឥទ្ធិពលនៃការចាប់ខ្លួនយុវជន និងការជាប់ពន្ធនាគារលើលទ្ធផលអប់រំ។

ការសិក្សានៅសហរដ្ឋអាម៉េរិក Hjalmarsson (២០០៨) ប៉ាន់ប្រមាណពីផលប៉ះពាល់នៃការជាប់ឃុំឃាំងរបស់អនីតិជន លើការគ្រប់គ្រងនៃបញ្ចប់ការសិក្សានៅវិទ្យាល័យ សម្រាប់សមិទ្ធផលនៃការយល់ដឹងរបស់យុវជន កំណត់ត្រាឧក្រិដ្ឋកម្ម និងការចាប់ខ្លួន និងប្រវត្តិគ្រួសារ។ គាត់ក៏ពិចារណាផងដែរនូវលក្ខណៈជាក់លាក់ដែលគិតគូរពីផលប៉ះពាល់ ដែលបានកំណត់ដោយរដ្ឋ ឬ គ្រួសារដើម្បីគិតគូរពីភាពខុសគ្នានៃការអនុវត្ត និងការអប់រំអនីតិជនកម្រិតរដ្ឋ។

គោលនយោបាយ ក៏ដូចជាភាពខុសគ្នានៅក្នុងបរិយាកាសគ្រួសារ(និងសង្កាត់)។ ការប៉ាន់ប្រមាណដោយផ្អែកលើការតម្រែតម្រង់របស់នាង បានបង្ហាញថា យុវជន ដែលជាប់ឃុំឃាំងជាប់ទាក់ទងនឹងសកម្មភាពឧក្រិដ្ឋកម្មអនីតិជន និងអត្រាការចាប់ឃុំខ្លួនថេរ ទំនងជាតិចជាងក្នុងការបញ្ចប់វិទ្យាល័យ។ ការជាប់ឃុំឃាំង មានឥទ្ធិពលខ្លាំងបំផុតទៅលើការបញ្ចប់ការសិក្សានៅវិទ្យាល័យ នៅពេលដែលការកាត់ទោសត្រួតលើគ្នាជាមួយនឹងឆ្នាំសិក្សា។ ទោះយ៉ាងណាក៏ដោយប្រវែងនៃប្រយោគមិនប៉ះពាល់ដល់ប្រូបាប៊ីលីតេនៃការបញ្ចប់ការសិក្សា។ ទីបំផុត គេយល់ឃើញថា ការជាប់ឃុំឃាំងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការបញ្ចប់វិទ្យាល័យ នៅក្នុងរដ្ឋដែលតម្រូវឱ្យប្រព័ន្ធយុត្តិធម៌ ជូនដំណឹងដល់សាលារៀនអំពីការចាប់ខ្លួន ដោយណែនាំថា គ្រូបង្រៀន និងឬអ្នកគ្រប់គ្រងអាចប្រព្រឹត្តចំពោះសិស្សខុសៗគ្នា ប្រសិនបើពួកគេត្រូវបានគេដឹងថាត្រូវបានជាប់គុក។ ការជាប់ឃុំឃាំងអនីតិជនអាចនាំមកនូវការមាក់ងាយអវិជ្ជមាន នៅក្នុងសាលារៀន ដូចជាវាកើតឡើងនៅក្នុងទីផ្សារការងារ។

Aizer និងDoyle(២០១៥) ដោះស្រាយកង្វល់អំពីកត្តា ដែលមិនបានសង្កេតដែលអាចប៉ះពាល់ដល់ទាំងការសិក្សា និងឧក្រិដ្ឋកម្ម/ការចាប់ខ្លួន/ការឃុំខ្លួន ដោយប្រើការពិសោធន៍ធម្មជាតិថ្មី៖ ការចាត់តាំងដោយចៃដន្យនៃសំណុំរឿង ដែលបានវិនិច្ឆ័យនៅក្នុងប្រព័ន្ធតុលាការអនីតិជននៅទីក្រុងឈីកាហ្គោ។ ការកេងប្រវ័ញ្ចលើភាពខុសប្លែកគ្នារវាងចៅក្រមក្នុងលទ្ធភាពដែលពួកគេបានចាត់តាំងយុវជនឱ្យឃុំខ្លួន។ ទោះបីជាការពិតដែលថា យុវជនភាគច្រើនចំណាយពេលត្រឹមតែពីរបីខែក្នុងការឃុំឃាំងក៏ដោយមានមនុស្សតិចណាស់ដែលត្រឡប់ទៅសាលារៀនវិញបន្ទាប់ពីនោះ។

## សេចក្តីសន្និដ្ឋាន និងមេរៀនគោលនយោបាយ

ករណីតាងបច្ចុប្បន្ន ផ្តល់នូវមេរៀនគោលនយោបាយសំខាន់ៗមួយចំនួន ទាក់ទងនឹងការអប់រំ និងឧក្រិដ្ឋកម្ម។

-ទី១៖ គោលនយោបាយ ដែលមានមូលដ្ឋានលើសាលារៀន ផ្តល់អត្ថប្រយោជន៍សង្គមយ៉ាងច្រើន ពីការកាត់បន្ថយឧក្រិដ្ឋកម្ម។ Lochner and Moretti (២00៤) គណនាថា ការសន្សំសង្គមនៃការកើនឡើងមួយភាគរយនៃអត្រាបញ្ចប់ការសិក្សានៅវិទ្យាល័យរបស់បុរសនៅសហរដ្ឋអាម៉េរិក (ពីការកាត់បន្ថយឧក្រិដ្ឋកម្មតែម្នាក់ឯង) ក្នុងឆ្នាំ១៩៩0 នឹងមានចំនួនច្រើនជាង២ពាន់លានដុល្លារ។ នេះ តំណាងឱ្យច្រើនជាងប្រាក់សន្សំប្រចាំឆ្នាំចំនួន៣០០០ ដុល្លារ សម្រាប់និស្សិតបញ្ចប់ការសិក្សាបន្ថែម។ នៅចក្រភពអង់គ្លេស Machin et al. ២០១១) ប៉ាន់ប្រមាណការសន្សំសង្គមជាង១០,០០០ផោន ក្នុងមួយគុណវុឌ្ឍិរបស់សិស្សបន្ថែម (ស្រដៀងនឹងការបញ្ចប់វិទ្យាល័យនៅសហរដ្ឋអាម៉េរិក) ពីការកាត់បន្ថយនៅក្នុងឧក្រិដ្ឋកម្មទ្រព្យសម្បត្តិតែម្នាក់ឯង។

-ទី២៖ គោលនយោបាយដែលជំរុញឱ្យការបញ្ចប់មធ្យមសិក្សាទុតិយភូមិ ហាក់ដូចជាមានជោគជ័យបំផុតទាក់ទងនឹងឥទ្ធិពលរបស់ពួកគេលើឧក្រិដ្ឋកម្ម។ អត្រាឧក្រិដ្ឋកម្មមានកម្រិតទាបរួចទៅ ហើយក្នុងចំណោមនិស្សិត បញ្ចប់ការសិក្សានៅវិទ្យាល័យ ដូច្នេះគោលនយោបាយដែលជំរុញឱ្យមានការចូលរួមក្រោយមធ្យមសិក្សា ឬការបញ្ចប់ការសិក្សាទំនងជានឹងផ្តល់ផលប្រយោជន៍សង្គមតិចតួចពីការកាត់បន្ថយឧក្រិដ្ឋកម្ម។

-ទី៣៖ គោលនយោបាយដែលរៀបចំឡើង ដើម្បីលើកទឹកចិត្តដល់ការសិក្សានៅក្នុងចំណោមក្រុម ដែលងាយនឹងឧក្រិដ្ឋកម្មកាន់តែច្រើន ទំនងជានឹងបង្កើតផលចំណេញច្រើនបំផុតពីការកាត់បន្ថយឧក្រិដ្ឋកម្ម។ Deming (២០១១) ប៉ាន់ប្រមាណថា ជម្រើសសាលារៀនប្រសើរឡើងសម្រាប់សិស្សមធ្យមសិក្សា និងវិទ្យាល័យនាំឱ្យមានការថយចុះគួរឱ្យកត់សម្គាល់ក្នុងការចាប់ខ្លួនយុវជនដែលមានហានិភ័យខ្ពស់ ប៉ុន្តែមិនមែនសម្រាប់អ្នកដទៃទេ។ ស្របនឹងបញ្ហានេះ កម្មវិធីពន្លឿន (Fast Track) ក្នុងវ័យសិក្សាហាក់ដូចជាបានកាត់បន្ថយឧក្រិដ្ឋកម្មអនីតិជន មានតែក្នុងចំណោមកុមារ ដែលមានហានិភ័យខ្ពស់ប៉ុណ្ណោះ ដែលបង្ហាញពីផលប៉ះពាល់តិចតួចលើកុមារដែលមានហានិភ័យខ្ពស់កម្រិតមធ្យម (CPPRG ២០០៧, ២០១០)។

-ទី៤៖ គោលនយោបាយអប់រំអាចកាត់បន្ថយទាំងទ្រព្យសម្បត្តិ និងឧក្រិដ្ឋកម្មហិង្សា។ ទាំងនៅអាម៉េរិក និងប្រទេសស៊ុយអែត ផលប៉ះពាល់ដែលបានប៉ាន់ប្រមាណនៃការទទួលបានការអប់រំ ឬការចុះឈ្មោះចូលរៀននៅសាលាលើទ្រព្យសម្បត្តិ និងការរំលោភបំពានដោយហិង្សាគឺស្រដៀងគ្នាក្នុងលក្ខខណ្ឌ

*ភាគរយ។ សូម្បីតែឃាតកម្ម ក៏ហាក់ដូចជាមានប្រតិកម្មខ្លាំងដែរ។*

*-ទី៥៖ ផលប៉ះពាល់នៃការអប់រំលើឧក្រិដ្ឋកម្ម សម្រាប់បុរស អាចត្រូវបានពន្យល់យ៉ាងទូលំទូលាយដោយការកែលម្អប្រាក់ឈ្នួល និងឱកាសទីផ្សារការងារ។ ទោះយ៉ាងណាក៏ដោយ នេះមិនមែនជាករណីសម្រាប់ស្ត្រីនោះទេ។*

# ឯកសារយោង


1. Aizer, A., & Doyle, J., Jr. (2015). Juvenile incarceration, human capital, and future crime: Evidence from randomly assigned judges. *The Quarterly Journal of Economics,130*.
2. -Anderson, D. M. (2014). In school and out of trouble? The minimum dropout age and juvenile crime. *Review of Economics and Statistics, 96*(2).
3. Becker, G. S. (1991). *A treatise on the family* (enlarged ed.). Harvard University Press.
4. Becker, G., & Mulligan, C. (1997). The endogenous determination of time preference. *Quarterly Journal of Economics, 112*.
5. Brilli, Y., & Tonello, M. (2018). Does increasing compulsory education decrease or displace adolescent crime? New ev idence from administrative and victimization data. *CESifo Economic Studies, 64*.
6. Buonanno, P., & Leonida, L. (2009). Non-market effects of education on crime: evidence from Italian regions. Economics of Education Review, *28*.
7. Cano-Urbina, J., & Lochner, L. (2019). The effect of education and school quality on female crime. *Journal of Human Capital, 13*.
8. Conduct Problems Prevention Research Group. (2007). Fast Track randomized controlled trial to prevent externalizing psychiatric disorders: Findings from grades 3 to 9. *Journal of the American Academy of Child and Adolescent Psychiatry, 46*.
9. Conduct Problems Prevention Research Group. (2010). Fast Track intervention effects on youth arrests and delinquency. *Journal of Experimental Criminology, 6*.
10. Cullen, J., Jacob, B., & Levitt, S. (2006). The effect of school choice on participants: Evidence from randomized lotteries. *Econometrica, 74*.
11. Deming, D. (2011). Better schools, less crime? *Quarterly Journal of Economics, 126*.
12. Ehrlich, I. (1975). On the relation between education and crime. In F. T. Juster (Ed.), *Education, income, and human behavior*. New York: McGraw-Hill Book Co.
13. Gould, E., Mustard, D., & Weinberg, B. (2002). Crime rates and local labor market opportunities in the United States: 1977e1997. *Review of Economics and Statistics, 84,*
14. Grogger, J. (1998). Market wages and youth crime. *Journal of Labor Economics, 16*.
15. Harlow, C. (2003). Education and Correctional Populations.
16. U.S. Department of Justice, Bureau of Justice Statistics Special Report, NCJ 195670, Washington DC.
17. Heckman, J. J., Lochner, L., & Todd, P. (2006). Earnings functions, rates of return and treatment effects: The Mincer equation and beyond. In E. Hanushek, & F. Welch (Eds.), *Handbook of the economics of education* (Vol. 1, pp. 307e458). Amsterdam: Elsevier.

18. Hjalmarsson, R. (2008). Criminal justice involvement and high school completion. *Journal of Urban Economics, 63*.
19. Hjalmarsson, R., Holmlund, H., & Lindquist, M. J. (2015). The effect of education on criminal convictions and incarceration: Causal evidence from micro-data. *Economic Journal, 125*.
20. Hjalmarsson, R., & Lochner, L. (2012). The impact of educa tion on crime: International evidence. *CESifo DICE Report, 10*(2), 49.
21. Jacob, B., & Lefgren, L. (2003). Are idle hands the devil's workshop? Incapacitation, concentration, and juvenilecrime. *American Economic Review, 93*.
22. Lochner, L. (2004). Education, work, and crime: A human capital approach. *International Economic Review, 45*(3).
23. Lochner, L. (2010). Education policy and crime. In P. Cook,
24. J. Ludwig, & J. McCrary (Eds.), *Controlling crime: Strategies and tradeoffs*. Chicago: University of Chicago Press.
25. Lochner, L. (2011). Nonproduction benefits of education: Crime, health, and good citizenship. In E. Hanushek,
26. S. Machin, & L. Woessmann (Eds.), *Handbook of the eco- nomics of education* (Vol. 4, pp. 183-282). Elsevier.
27. Lochner, L., & Moretti, E. (2004). The effect of education on crime: Evidence from prison inmates, arrests, and self-reports. *American Economic Review, 94*(1).
28. Luallen, J. (2006). School's out forever: A study of juvenile crime, at-risk youths and teacher strikes. *Journal of Urban Economics, 59*.
29. Machin, S., Marie, O., & Vujić, S. (2011). The crime reducing effect of education. *Economic Journal, 121*(552)
30. Machin, S., & Meghir, C. (2004). Crime and economic incentives. *Journal of Human Resources, 39*.
31. Meghir, C., Palme, M., & Schnabel, M. (2014). *The effect of education policy on crime: An intergenerational perspective*. Working Paper.
32. Mustard, D. (2001). Racial, ethnic and gender disparities in sentencing: Evidence from the US federal courts. *Journal of Law and Economics, 44*(1).
33. Sabates, R., & Feinstein, L. (2008). Effects of government initiatives on youth crime. *Oxford Economic Papers, 60*.
34. Weiner, D., Lutz, B., & Ludwig, J. (2009). *The effects of school deseg regation on crime*. NBER Working Paper Paper No. 15380.
35. Witte, A. D. (1997). Crime. In J. Behrman, & N. Stacey (Eds.), *The social benefits of education*. Ann Arbor: University of Michigan Press

# បច្ចុប្បន្នភាពនៃយេនឌ័រ និង តួនាទីយេនឌ័រនៅកម្ពុជា

ដោយៈ លោកស្រីបណ្ឌិត **ជា ចណ្ណី**
ប្រធានផ្នែកធម្មសាស្ត្រ ចរិយាសាស្ត្រនិងយេនឌ័រ,វិទ្យាស្ថាន
មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា

នាពេលបច្ចុប្បន្ននេះ កម្ពុជាគឺជាប្រទេសមួយដែលកំពុងវិវត្តន៍ខ្លួនពីប្រទេសកំពុងអភិវឌ្ឍន៍ឆ្ពោះទៅជាប្រទេសអភិវឌ្ឍមួយដូចបណ្តាប្រទេសនានានៅលើពិភពលោកដែរ ហើយនៅក្នុងការប្រតិបត្តិលើគ្រប់វិស័យនោះកម្ពុជាបាននឹងកំពុងតែធ្វើការលើកកម្ពស់ការយល់ដឹងសង្គមដល់ប្រជាពលរដ្ឋទាំងពីរភេទក្នុងការផ្តល់នូវភាពក្លាហានដល់យេនឌ័រក្នុងការបំពេញភារកិច្ចរបស់ខ្លួន គឺមានការរីកចម្រើនគួរឱ្យកត់ សម្គាល់ និងជាទីមោទនៈផងដែរ។ យ៉ាងណាមិញ ការផ្តល់ភាពក្លាហានចំពោះស្ត្រីនៅក្នុងប្រទេសកម្ពុជាយើង ក៏មានការយកចិត្តទុកដាក់ជាពិសេសផងដែរ គឺស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសង្គមស្ទើរគ្រប់វិស័យ ពោលគឺស្ត្រីពិតជាមានភារកិច្ចយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការជួយបង្កើនសេដ្ឋកិច្ចគ្រួសារ ហើយស្ត្រីក៏ជាឆ្អឹងខ្នងដ៏សំខាន់ក្នុងការជួយបង្កើនសេដ្ឋកិច្ចសង្គមកម្ពុជាដែលមិនអាចខ្វះបាន។

ប៉ុន្តែ បើយើងធ្វើការសង្កេតជាទូទៅ ឃើញថា ទាំងអង្គការសង្គមស៊ីវិល ក៏ដូចជាក្រសួង មន្ទីរ និងស្ថាប័នមួយចំនួនដែលមានទាំងក្រសួងកិច្ចការនារីផងដែរ បានកត់សម្គាល់ឃើញថា បើទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវគោលនយោបាយលើកកម្ពស់ភាពអង់អាចក្លាហានរបស់ស្ត្រីក្នុងសង្គមយ៉ាងណាក៏ដោយ ក៏គេនៅតែសង្កេតឃើញថា បញ្ហាយេនឌ័រ ជាពិសេសស្ត្រីនៅតែជួបបញ្ហាប្រឈមមួយចំនួនក្នុងការរួមចំណែកអភិវឌ្ឍន៍គ្រួសារក៏ដូចជាសង្គមជាតិខ្លួន ដែលបញ្ហាទាំងនេះ រាជរដ្ឋាភិបាលបាននឹងកំពុងពង្រឹង និងពង្រីកការយកចិត្តទុកដាក់បន្ថែមទៀតចំពោះស្ត្រី។

ទន្ទឹមនឹងការយកចិត្តទុកដាក់ពីសង្គមនេះ ស្ត្រីខ្លួនឯងក៏គួរតែត្រូវខិតខំពង្រីកចំណេះដឹងពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីជម្នះរាល់ឧបសគ្គឈានទៅរកភាពជោគជ័យក្នុងតួនាទីនិងភារកិច្ចរបស់ខ្លួនជាស្ត្រី។ បើយោងតាមអង្កេតជាទូទៅ ស្ត្រីជាផ្នែកមួយនៃដំណើរ

ការរបស់យុទ្ធនាការសិទ្ធិស្ត្រី ក្នុងការទទួលបានសេវាសង្គមជាមូលដ្ឋានប្រកបដោយគុណភាពនិងសមធម៌។ ស្ត្រីគឺជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ សង្គម និងគ្រួសារ ប៉ុន្តែជាញឹកញយស្ត្រីត្រូវបានសង្គម និងគ្រួសារបំភ្លេចចោលហើយយកការចូលរួមនៅក្នុងសង្គមរបស់ស្ត្រីគឺជារឿងធម្មតាទៅវិញ។ បច្ចុប្បន្នមានបុរសស្វាមី ឬក្រុមគ្រួសារមួយចំនួនបានលើកឡើងនូវពំនោលថា ***ភរិយា ម្ដាយ ឬបងប្អូនស្រីរបស់*** *ខ្លួន មិនមានធ្វើអ្វីទេ គឺនៅតែផ្ទះៗ* តែទន្ទឹមនឹងពំនោល ស្ត្រីនៅតែផ្ទះនេះ គឺការងារ១០០ជំពូកស្ថិតក្នុងកណ្ដាប់ដៃស្ត្រីដែលជាអ្នកនៅផ្ទះនោះ គឺស្ត្រីជាកម្មករក្នុងគ្រួសារ ស្ត្រីជាអ្នកបោសជូតបោកគក់ ស្ត្រីជាចុងភៅ ស្ត្រីជាអ្នកមើលថែកុមារនិងមនុស្សចាស់ជរា ក៏ដូចជាការមើលការខុសត្រូវនូវរាល់ការងាររាក់ជ្រៅសព្វយ៉ាង ដែលស្ត្រីមិនដែលបានទទួលកម្រៃថ្លៃឈ្នួលពីការងារទាំងនោះទេ។ ដូច្នេះ «ក្នុងនាមយើងជាស្ត្រី និងក្នុងនាមយើងជាមនុស្សនៅក្នុងសង្គម យើងត្រូវដឹងឱ្យបានច្បាស់ថាស្ត្រីជាកម្លាំងចលករ ស្ត្រីជាឆ្អឹងខ្នងដ៏សំខាន់នៃសេដ្ឋកិច្ច ស្ត្រីជាផ្នែកមួយដ៏សំខាន់ដែលធ្វើឱ្យសង្គមជាតិ សង្គមគ្រួសាររឹងមាំ ស្ត្រីមិនមែនជាជនរងគ្រោះ ឬជាជនទន់ខ្សោយនោះឡើយ»។

ពាក់ព័ន្ធនឹងការផ្ដល់ភាពអង់អាចក្លាហាន ក៏ដូចជាការលើកកម្ពស់ចំពោះស្ត្រី ការផ្ដល់ភាពអង់អាចក្លាហានផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅលើពិភពលោកនាពេលបច្ចុប្បន្ននេះ ត្រូវបានគេចាត់ទុកថាវាជាយុទ្ធសាស្ត្រចាំបាច់ក្នុងការផ្លាស់ប្ដូរផ្នត់គំនិតនៃការគិតគូអំពីគម្ចាតយេនឌ័រនៃសេដ្ឋកិច្ច។ យ៉ាងណាមិញប្រទេសកម្ពុជា គឺជាសង្គមសមូហភាពមួយដែលអាចបង្កើនសក្ដានុពលភាពនៃធនធានស្ត្រីឱ្យក្លាយទៅជាធនធានដែលមានតម្លៃនៅក្នុងសេដ្ឋកិច្ចនិងសង្គមផងដែរ គឺតាមរយៈការលើកកម្ពស់សិទ្ធិស្ត្រី។ តែទោះជាយ៉ាងណាក៏ដោយ ក៏ស្ត្រីនៅតែជួបបញ្ហាប្រឈមមួយចំនួនផងដែរក្នុងការលើកស្ទួយ ជួយពង្រឹងសេដ្ឋកិច្ចក្នុងគ្រួសាររបស់ខ្លួន។ បញ្ហាប្រឈមទាំងនោះមានដូចជា ស្ត្រីនៅតែប្រឈមនូវបញ្ហាក្នុងការចាប់ផ្ដើមដំណើរការពង្រីកនិងពង្រឹងអាជីវកម្មរបស់ខ្លួន ស្ត្រីជាទូទៅនៅតែទទួលបានឱកាសនិងការគ្រប់គ្រងចំណូលសេដ្ឋកិច្ចតិចតួចជាងបុរស ដែលមិនតែប៉ុណ្ណោះ ស្ត្រីថែមទាំងទទួលបន្ទុកគ្រួសារ ជាពិសេសសមាជិកចាស់ជរាក្នុងគ្រួសារ និងការងារគ្មានប្រាក់កម្រៃក៏ដូចជា ការងារដែលងាយរងគ្រោះជាច្រើន។

យើងទាំងអស់គ្នាបានដឹងហើយថាការបង្កើនភាពអង់អាចដល់ស្ត្រី គឺជាកត្តាចាំបាច់ក្នុងការផ្លាស់ប្ដូរផ្នត់គំនិតនៃការគិតគូសម្រាប់ការអភិវឌ្ឍន៍និងកសាងប្រទេស។ មានស្ត្រីមួយចំនួនដែលជាអ្នកធ្វើការតាមរោងចក្រ និងសហគ្រាសនានាបានយកកម្រៃថវិកាដែលនាងទទួលបានពីការធ្វើការតាមរោងចក្រ និងសហគ្រាសទាំងនោះ ទៅជួយផ្គត់ផ្គង់

ដល់សាច់ញាតិរបស់ខ្លួន ជាពិសេសគឺជួយដល់មាតាបិតាដែលចាស់ជរា និងផ្គត់ផ្គង់ដល់បងប្អូនកូនក្មួយៗដែលកំពុងបន្តការសិក្សានៅតាមភូមិសិក្សានានាផងដែរ។ ដូច្នេះការងារតាមរោងចក្រនិងសហគ្រាសក៏បានរួមចំណែកយ៉ាងសំខាន់ជាមួយរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមកម្ពុជា ហើយរដ្ឋាភិបាលក៏បាននិងកំពុងតែបង្កើនពង្រឹងនិងពង្រីកការយកចិត្តទុកដាក់លើកកម្ពស់សិទ្ធិស្ត្រីឱ្យបានច្រើនថែមទៀត ដើម្បីផ្តល់នូវតម្លៃដល់ស្ត្រីដែលបម្រើការងារតាមរោងចក្រទាំងនោះបន្ថែមទៀតផងដែរ ដ្បិតសព្វថ្ងៃការឱ្យតម្លៃរបស់សង្គមទៅលើស្ត្រីនៅមានកម្រិតនៅឡើយ។ នាពេលកន្លងមក ស្ត្រីដែលបម្រើការនៅតាមរោងចក្រសហគ្រាសទាំងនោះ តែងតែបានស្នើឱ្យរាជរដ្ឋាភិបាលលើកស្ទួយស្ត្រីឱ្យបានច្រើន ហើយត្រូវផ្តល់តម្លៃស្ត្រីឱ្យបានកាន់តែច្រើន ដ្បិតស្ត្រីអាចធ្វើអ្វីៗបានគ្រប់យ៉ាងទាំងអស់ដែលមានការងារខ្លះបុរសមិនអាចធ្វើបានទៀតផង ប៉ុន្តែស្ត្រីអាចធ្វើបាន ដូចជា ការពពោះ ការបង្កើតកូន ការចិញ្ចឹមកូនដោយទឹកដោះម្តាយផ្ទាល់ ក៏ដូចជាការមើលថែបីបាច់សមាជិកក្នុងគ្រួសារ និងការចិញ្ចឹមបីបាច់ថែរក្សាកូនដោយមានទំនួលខុសត្រូវ»។ សព្វថ្ងៃក្រៅពីវិស័យសេដ្ឋកិច្ច ស្ត្រីខ្មែរក៏បានចូលប្រឡូកស្មើរគ្រប់វិស័យ ទាំងវិស័យសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយផងដែរ ដែលបានបង្ហាញ តាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់កន្លងមក គឺគណបក្សនយោបាយនីមួយៗបានចាប់អារម្មណ៍ និងផ្តល់ឱកាសឱ្យស្ត្រីក្លាយជាបេក្ខជន ហើយរាជរដ្ឋាភិបាលសព្វថ្ងៃក៏បានលើកបង្ហាញពីតម្លៃពីប្រកព និងការចូលរួមចំណែករបស់ស្ត្រី ជាក់ស្តែងដូចជាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២នេះ ប្រមុខរាជរដ្ឋាភិបាល គឺសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** លោកបានលើកឡើងពីបច្ចុប្បន្នភាព ស្ត្រីបានចូលរួមចំណែកក្នុងកិច្ចការងារជាច្រើនវិស័យ[១] រួមទាំងបញ្ហាដែលស្ត្រីជួបប្រទះក្នុងវិស័យសេដ្ឋកិច្ច ទាំងក្នុងគ្រួសារ និងសង្គម និងលើកឡើងពីតម្រូវការរបស់ស្ត្រីក្នុងការទទួលបានសេវាសង្គមជាមូលដ្ឋានប្រកបដោយគុណភាព សមធម៌ ក៏ដូចជាការពង្រឹងនិងពង្រីកនូវសាមគ្គីភាពនៃចលនាស្ត្រីនៅកម្ពុជា ប៉ុន្តែវាហាក់បីដូចជានៅមានកម្រិតនៅឡើយ។

តើនាពេលបច្ចុប្បន្ននេះ យេនឌ័របានចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិយ៉ាងដូចម្តេចខ្លះ?

ដូច្នេះមុននឹងយើងធ្វើការសិក្សា និងវិភាគឱ្យបានស៊ីជម្រៅចំពោះបញ្ហានេះ យើងគួរស្វែងយល់ពីពាក្យយេនឌ័រជាមុនសិន។

## ១. ន័យនៃពាក្យយេនឌ័រ

នាពេលបច្ចុប្បន្ន ពាក្យ ***យេនឌ័រ*** តែងតែត្រូវគេប្រើជំនួសឱ្យពាក្យ ***ភេទ*** របស់មនុស្ស

[១] https://www.srpostnews.com/article/42981.

ម្នាក់ (ប្រុស ឬ ស្រី) និងមានការឱ្យនិយមន័យផ្សេងៗគ្នានូវពាក្យ **យេនឌ័រ** និង **ភេទ** នៅក្នុងវិទ្យាសាស្ត្រសង្គមមានលក្ខណៈខុសគ្នា ដូចជា៖

- ពាក្យ «**ភេទ**» សំដៅទៅលើខ្លួនប្រាណរបស់នរណាម្នាក់។ វាបង្ហាញពីភាពស្រី ឬប្រុសរបស់ខ្លួនប្រាណខាងក្រៅរបស់នរណាម្នាក់។

-ពាក្យ យេនឌ័រ (Gender) គឺជាភាពស្មើគ្នារវាងបុរស និងស្ត្រី ស្តីអំពី សិទ្ធិ តួនាទី ការទទួលខុសត្រូវ ការសម្រេចចិត្ត ឧបសគ្គ ឱកាស នឹងតម្រូវការរបស់បុរស និងស្ត្រីនៅគ្រប់បរិបទ គ្រប់វិស័យ និងគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលកំណត់ដោយសង្គមវប្បធម៌ ហើយអាចផ្លាស់ប្តូរបានទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង ឬ អាចនិយាយថា ជាគោលគំនិតផ្នែកសេដ្ឋកិច្ចសង្គមក្នុងការវិភាគលើតួនាទី និងទំនួលខុសត្រូវ។ យេនឌ័រក៏ជាការកំណត់របស់គ្រួសារ សហគមន៍ និងសង្គមពាក់ព័ន្ធនឹងការបែងចែកការងារការអប់រំ សិទ្ធិអំណាច ឋានៈ និងតួនាទី ដល់កូនស្រី កូនប្រុស និងស្ត្រី បុរស។ យេនឌ័រអាចផ្លាស់ប្តូរកែប្រែបាន ព្រោះវាជាលក្ខខណ្ឌសង្គមមិនមែនមានពីកំណើតនោះទេ។

-ពាក្យ «**យេនឌ័រ**» គឺសំដៅទៅលើបុគ្គលិកលក្ខណៈ និងអត្តចរិតរបស់នរណាម្នាក់ដែលបង្ហាញអំពីអារម្មណ៍ ឬកាយវិការរបស់មនុស្សម្នាក់ ថាតើគេដូចមនុស្សស្រី ឬដូចមនុស្សប្រុស។

- **យេនឌ័រ** គឺជាគោលគំនិតផ្នែកសេដ្ឋកិច្ចសង្គមក្នុងការវិភាគលើតួនាទី ទំនួលខុសត្រូវ ឧបសគ្គឱកាស និងតម្រូវការរបស់បុរសនិងស្ត្រីនៅគ្រប់បរិបទ គ្រប់វិស័យ គ្រប់មជ្ឈដ្ឋាន។ ឧទាហរណ៍៖ ស្ត្រី និងបុរសអាចធ្វើជាគ្រូបង្រៀន វិស្វករ កម្មករ... ហើយស្ត្រី និងបុរសអាចមើលថែកូន និងមនុស្សចាស់ជាដើម។

- **យេនឌ័រ** សំដៅលើភាពខុសគ្នារវាងបុរសនិងស្ត្រីដែលកំណត់ដោយសង្គម ហើយដែលគេបានរៀនសូត្រ និងមានការប្រែប្រួលពីពេលមួយទៅពេលមួយ។ យេនឌ័រមានការផ្លាស់ប្តូរយ៉ាងទូលំទូលាយរវាងតួនាទីបុរសនិងស្ត្រីទៅតាមវប្បធម៌មួយទៅវប្បធម៌មួយ។

. **យេនឌ័រ** គឺជាគោលគំនិតផ្នែកសេដ្ឋកិច្ច និងសង្គម ក្នុងការធ្វើការវិភាគនៃតួនាទីទទួលខុសត្រូវ ឧបសគ្គ និងតម្រូវការរបស់បុរស និងស្ត្រីនៅគ្រប់បរិបទទាំងអស់។ ដោយសារយេនឌ័រត្រូវបានបង្កើតឡើងដោយសង្គម ទើបការកំណត់អំពីតួនាទីតម្រូវការអាទិភាពនិងសកម្មភាពរបស់ស្ត្រីមានទំនាក់ទំនងទៅនឹង បរិបទជាក់ស្តែងនៃវប្បធម៌ សាសនានិងសេដ្ឋកិច្ចសង្គម។

-**យេនឌ័រ** ជាភាពស្មើគ្នារវាង បុរស និងស្ត្រីអំពីសិទ្ធិ តួនាទី ការទទួលខុសត្រូវ និងការសម្រេចចិត្តដែលកំណត់ដោយសង្គមវប្បធម៌

ហើយអាចផ្លាស់ប្តូរបានតាមពេលវេលា និង ស្ថានភាព ជាក់ស្តែង[២]។

នៅពេលទារកម្នាក់កើតមក គេដឹងថា ជាស្រី ឬប្រុស គឺគេសម្គាល់លើប្រដាប់ភេទ របស់ទារកនោះ ដែលជាផ្នែកមួយនៃជីវ សាស្ត្រ។ ប៉ុន្តែយេនឌ័រ គឺខុសគ្នា។ វប្បធម៌ ទំនៀម ទម្លាប់ និងច្បាប់របស់យើង បានកំណត់នូវតួ នាទីយេនឌ័រសម្រាប់បុរសនិងស្ត្រី។ តួនាទីនេះ ចែងថា ស្ត្រីត្រូវធ្វើការងារផ្ទះ ហើយបុរសជា អ្នកសម្រេចចិត្តសំខាន់ៗនៅក្នុងសហគមន៍។ យើងច្រើនតែយល់ច្រឡំរវាងតួនាទីយេនឌ័រ ជាមួយនិងតួនាទីភេទ ហើយគិតថា វាជារឿង ធម្មជាតិ ឬមិនអាចផ្លាស់ប្តូរបាន។

តើយេនឌ័រមានន័យដូចម្តេច? យេន ឌ័របានចាប់កំណើតពីពេលណាមក?

យេនឌ័រ តាមវចនានុក្រម Learner’s Dictionary ជាភាសាអង់គ្លេសខ្មែរ បានពន្យល់ ថាជាលិង្គ។ លិង្គនេះមិនមែនសំដៅលើប្រដាប់ ភេទបុរសទេ តែវាសំដៅលើភេទ(នបុំសក លិង្គ និងឥត្ថីលិង្គ)[៣]។ យេនឌ័រ ឬជេនឌ័រ គឺ សំដៅលើរូបសាស្ត្រ ជីវសាស្ត្រ ចិត្ត ឥរិយាបទ ទាក់ទងនឹងភាពប្លែកគ្នារវាងនបុំលិង្គ និងបុំ លិង្គ។ យោងតាមបរិបទវាក្យសព្ទសំដៅដល់ ជីវសាស្ត្រភេទ (ឧ. ថ្លែងដល់ភេទ ប្រុស និង ស្រីឬក៏អន្តរភេទ) ភេទដែលផ្អែកទៅលើរចនា សម្ព័ន្ធសង្គម (រួមបញ្ចូលទាំងតួនាទីភេទ និង តួនាទីសង្គមដទៃទៀត)ឬអត្តសញ្ញាណភេទ។

អ្នកភេទវិទ្យាលោក John Money បាន បែងចែកវាក្យសព្ទរវាងជីវសាស្ត្រភេទ និង យេនឌ័រ ជាច្បាប់មួយនៅឆ្នាំ១៩៥៥។ មុន ពេលចាប់ផ្តើមការងាររបស់គាត់ វាជារឿងមិន ធម្មតាមួយដើម្បីប្រើប្រាស់ពាក្យយេនឌ័រ សំដៅលើអ្វីមួយ ដូចការបែងចែកក្នុងវេយ្យា ករណ៍នោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយ អត្ថន័យរបស់លោក Money ទៅលើពាក្យនេះ មិនមានលក្ខណៈសកលទូទៅទេរហូតដល់ ទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលអ្នកទ្រឹស្តី ស្ត្រីបានក្រសោបទស្សនៈទៅលើការបែងចែក រវាងជីវសាស្ត្រភេទ និងរចនាសម្ព័ន្ធសង្គមនៃ យេនឌ័រ។ សព្វថ្ងៃនេះ ការបែងចែកបានដើរ តាមយ៉ាងជាក់ច្បាស់នៅក្នុងបរិបទសង្គម ជា ពិសេសក្នុងវិទ្យាសាស្ត្រសង្គម និងឯកសារ ដែលបានសរសេរឡើងដោយអង្គការសុខភាព ពិភពលោក(WHO)។ ទោះបីជានៅក្នុងបរិបទ ដទៃទៀត នៅក្នុងផ្នែកវិទ្យាសាស្ត្រសង្គមអត្ថ ន័យនៃពាក្យថាយេនឌ័រ បានទទួលនូវរបៀប ប្រើប្រាស់ផ្លាស់គ្នា រួមទាំងភេទ (Sex) ទោះបី ជាដាក់ជំនួសនៅពីក្រោយពាក្យផ្សេង។ ទោះ បីជាការបញ្ចប់នូវការផ្លាស់ប្តូរនេះនៅក្នុងអត្ថ ន័យនៃពាក្យយេនឌ័រដែលអាចធ្វើឱ្យអូស បន្លាយមកទល់នឹងទសវត្សរ៍១៩៨០។ ការព ន្លឿនដ៏តូចនៃដំណើរការក្នុងវិទ្យាសាស្ត្រអក្សរ

[២] https://rhac.org.kh/km

[៣] សេរីវុធ Learner’s Dictionary បោះពុម្ពលើកទី១ ព.ស។ .២៥៤១ គ.ស១៩៩៧ ទំព័រ១៩៥។

សាស្ត្រត្រូវបានសង្កេតនៅពេលមួយក្នុងឆ្នាំ ១៩៩៣ ដោយរដ្ឋបាលអាហារ និងឱសថ បានចាប់ផ្តើមប្រើប្រាស់ពាក្យ យេនឌ័រ ជំនួសឱ្យពាក្យភេទ។ យេនឌ័រ គឺឥឡូវត្រូវបានគេប្រើប្រាស់ជាធម្មតាដែលថែមទាំងមិនមែនជាមនុស្ស និងសត្វ ដោយមិនឱ្យជាប់ទាក់ទិនទៅនឹងតួនាទីយេនឌ័រក្នុងសង្គម។

ចំណែកឯនៅក្នុងអក្សរសាស្ត្រអង់គ្លេសវិញ ការបែងចែកជាបីរវាង ជីវសាស្ត្រភេទ ចិត្តសាស្ត្រភេទ និងតួនាទីសង្គមភេទ ដែលដំបូងបានលេចចេញក្នុងកាសែតស្ត្រីមួយ ចំពោះការនិយមប្តូរភេទនៅឆ្នាំ១៩៧៨។ វប្បធម៌មួយចំនួនកំណត់តួនាទីជាយថាភេទ (ច្បាស់) ពាក់ពន្ធ័នឹងតួនាទីសង្គម ដូចជាពួកហ៊ីជ្រ:(Hijra) នៃប្រទេសឥណ្ឌា និងប៉ាគីស្ថានជាដើម។

## ២. ន័យនៃតួនាទីយេនឌ័រ

តួនាទីយេនឌ័រ គឺជាការរៀបរាប់ពីអ្វីដែលបុរសនិងស្ត្រី រំពឹងថានឹងធ្វើអ្វីមួយបាន។ ឧទាហរណ៍៖ បុរសត្រូវបានគេរំពឹងទុកថា ជាអ្នកទទួលបន្ទុកចេញទៅធ្វើការងារខាងក្រៅ ដូចជា ធ្វើជារាជការ ធ្វើជាអ្នកជំនួញ ធ្វើស្រែចម្ការ កាប់អុស រកត្រី រីឯស្ត្រីវិញគឺជាអ្នកចម្អិនអាហារ មើលថែកូន។ ចាប់តាំងពីបានបង្កើតតួនាទីយេនឌ័រ ធ្វើឱ្យមានការផ្លាស់ប្តូរការទទួលខុសត្រូវការងាររបស់បុរស និងស្ត្រីក្នុងជីវិតរស់នៅ និងការយល់ដឹងពីឥទ្ធិពលនៃយេនឌ័រទៅលើការអនុវត្តឱ្យបានល្អសម្រាប់បុរសនិងស្ត្រី។ ស្ត្រីមានការជឿជាក់ថា ពួកគេមិនអាចចចេសរឹងរូស និងមានតែបុរសប៉ុណ្ណោះជាអ្នកគ្រប់គ្រងគ្រួសារ។ ដូច្នេះ បើយោងទៅលើការគិតនេះ វាអាចមានភាពលម្អៀងនៃយេនឌ័រដែលមានដែនកំណត់សម្រាប់អ្វីដែលបុរសនិងស្ត្រីក្នុងការធ្វើសកម្មភាពនានាទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ។

តួនាទីយេនឌ័រ មានសារៈសំខាន់ណាស់ក្នុងការចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពទាំងឡាយរបស់គ្រួសារ និងសហគមន៍ ដើម្បីអភិវឌ្ឍន៍គ្រួសារ និងសហគមន៍គប្បីបង្កើតឱ្យមានការពិភាក្សាអំពីវិធីផ្សេងៗក្នុងការចែករំលែកការទទួលខុសត្រូវផ្អែកលើសមភាពយេនឌ័រ[៤]។

ក្នុងពេលបច្ចុប្បន្ននៅលើពិភពលោកយើងនេះ ទំនៀមទម្លាប់យេនឌ័រ គឺកំពុងតែមានការផ្លាស់ប្តូរផងដែរ ដ្បិតមានមនុស្សវ័យក្មេងជាច្រើនដែលធ្វើការ ដើម្បីសមភាព និងយុត្តិធម៌កំពុងតែជួយឱ្យមានការផ្លាស់ប្តូរនេះ។ យេនឌ័រខ្លះអាចជះឥទ្ធិពលដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ហើយចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរ។ ឧទាហរណ៍៖ ស្ត្រីបង្វិលចង្ក្រានមិនជុំ គឺជាពាំនោលមួយដែលធ្វើឱ្យស្ត្រីបាត់បង់សេរីភាពនិងឱកាសនៃការចូលរួមក្នុងសកម្មភាពនានាក្នុងសង្គមដែលទាក់ទងនឹងការអប់រំ

[៤] https://rhac.org.kh/km

ការទទួលបានពត៌មាន និងការបញ្ចេញមតិយោបល់ជាដើម។

ជាទូទៅនៅក្នុងសង្គមខ្មែរ បុរសគឺជាមេគ្រួសារក្នុងគ្រួសារ បុរសមានអំណាច បុរសមានសិទ្ធិ បុរសជាអ្នកសម្រេចកិច្ចការក្នុងគ្រួសារ ដូច្នេះស្ត្រីត្រូវតែស្តាប់បង្គាប់បុរស ត្រូវតែគោរពបុរស ទោះបីជាគំនិតរបស់បុរសទាំងនោះអាចបង្កជាបញ្ហាក៏ដោយ ហើយតួនាទីយេឌ័រដែលគេរំពឹងទុកនោះ គឺត្រូវបានគេមើលឃើញជាក់ច្បាស់នៅក្នុងទិដ្ឋភាពជាច្រើននៃគ្រួសារ។ គ្រួសារខ្លះបានប្រព្រឹត្តចំពោះក្មេងស្រី និងក្មេងប្រុសស្មើភាពគ្នា តែក៏មានគ្រួសារជាច្រើនទៀត ដែលមិនបានប្រព្រឹត្តចំពោះក្មេងប្រុសនិងក្មេងស្រីឱ្យបានស្មើភាពគ្នានោះទេ។ ដូច្នេះគ្រួសារ និងសហគមន៍ គួរគប្បីបង្កើតឱ្យមានការពិភាក្សាអំពីវិធីផ្សេងៗក្នុងការចែករំលែក ការទទួលខុសត្រូវដោយផ្អែកលើសមភាពយេនឌ័រ។ ការធ្វើដូច្នេះ ពួកគេអាចមានលទ្ធភាពក្នុងការស្វែងរកវិធីដ៏ល្អប្រសើរសម្រាប់ពួកគេ ចែករំលែកនូវតួនាទីដែលអាចធ្វើឱ្យយុវវ័យមានការសប្បាយរីករាយ ដើម្បីភាពសុខដុមរមនានៅក្នុងគ្រួសារ។

តួនាទីយេនឌ័រ បានបង្កើតឱ្យមានការរំពឹងទុកផ្សេងៗនូវអ្វីដែលគេហៅថា "បុរសពេញលក្ខណៈ" និង "ស្ត្រីពេញលក្ខណៈ"។ នៅពេលដែលការរំពឹងទុករបស់យេនឌ័របានរួមបញ្ចូលនូវការគោរពនិងការសរសើរចំពោះតួនាទីរបស់គេទផ្សេងៗគ្នា នោះស្ត្រីនិងបុរសអាចមានដំណើរជីវិតមួយដែលប្រកបទៅដោយភាពពេញចិត្ត ការរួមផ្សំគ្នា និងសមិទ្ធិផលផ្សេងៗ ប៉ុន្តែជារឿយៗ តួនាទីរបស់ស្ត្រីមានឋានៈទាបជាងយ៉ាងខ្លាំង បើធៀបនឹងតួនាទីរបស់បុរស។ ឋានៈមិនស្មើគ្នានៅក្នុងយេនឌ័រនេះ រឹតតែបណ្តាលឱ្យមានគ្រោះថ្នាក់ថែមទៀត នៅពេលដែលមានការរំពឹងទុកពីសង្គមថា បុរសមានការគ្រប់គ្រងលើស្ត្រី ឬនរណាម្នាក់ដែលមានរូបរាង ឬគំនិតដូចស្ត្រី។ វិធីមួយដើម្បីមើលឃើញពីភាពខុសគ្នារវាងឋានៈបុរសនិងស្ត្រី គឺតាមរយៈការឆ្លុះបញ្ចាំងពីបុគ្គលិកលក្ខណៈនៃភាពជាបុរសនិងភាពជាស្ត្រីដែលមនុស្សទូទៅកោតសរសើរ។ ធ្វើបែបនេះអាចជួយឱ្យមនុស្សគិតថា តើបុគ្គលិកលក្ខណៈណាខ្លះដែលសហគមន៍ទទួលស្គាល់។ ការឆ្លុះបញ្ចាំងបែបនេះក៏ជួយឱ្យក្រុមស្វែងយល់ថា តើបុរសនិងស្ត្រីទូទៅប្រព្រឹត្តបែបណា ដើម្បីលើកកម្ពស់ការរំពឹងទុកក្នុងយេនឌ័រ ហើយតើនឹងមានអ្វីកើតឡើងបើមនុស្សម្នាក់ប្រព្រឹត្តខុសគេ។ ស្ត្រីៗច្រើនតែជជែកគ្នា ស្វាត់ៗអំពីបទពិសោធន៍និងអារម្មណ៍របស់ពួកគេ ហើយការរៀបរាប់ពីភាពលំបាកផ្សេងៗក្នុងជីវិត ជាពិសេសអំពីការប្រាស្រ័យទាក់ទងដ៏លំបាកជាមួយបុរស ជួយឱ្យស្ត្រីមានអារម្មណ៍ថា មិនសូវឯកា។ ប៉ុន្តែការជជែកគ្នារបស់ពួកគេ ជាទូទៅមិនសូវលើកយកសំណួរដែលស្វែងរកមូលហេតុនៃភាព

លំបាករបស់ពួកគេ ឬអំពីដំណោះស្រាយនៃបញ្ហានោះទេ។ សកម្មភាពធ្វុះបញ្ចាំងនិងចែករំលែកអាចផ្តល់នូវទឹកន្ទៃងមួយដែលមានសុវត្ថិភាព និងភាពងាយស្រួលដល់ស្ត្រី ដើម្បីឱ្យពួកគាត់ពិភាក្សាអំពីបទពិសោធន៍របស់ខ្លួន ព្រមទាំងប្រៀបធៀបតួនាទីរបស់ពួកគាត់ជាមួយនឹងតួនាទីរបស់បុរស។ នៅគ្រប់សហគមន៍ទាំងអស់ មានការងារខ្លះត្រូវបានចាត់ទុកថាជា "ការងារបុរស" ហើយការងារខ្លះទៀតជា "ការងារស្ត្រី។ ភាពខុសគ្នានៃការរំពឹងទុកទាំងនេះ គឺជាផ្នែកមួយនៃតួនាទីយេនឌ័រ។ ការងារដែលស្ត្រីជាច្រើនធ្វើ ដូចជាមើលថែកូន និងតម្រូវការប្រចាំថ្ងៃរបស់គ្រួសារច្រើនតែមិនទទួលបានតម្លៃខ្ពស់ទេ ឬថែមទាំងមិនត្រូវបានគិតថាជាការ ងារទៀតផង។ នេះគឺជាមូលហេតុមួយដែលធ្វើឱ្យស្ត្រីមានឋានៈទាប និងមានការងារច្រើនដែលមិនស្មើភាព។ ការពិភាក្សាអំពីតួនាទីយេនឌ័រនិងការងារអាចជួយឱ្យមនុស្សគិតអំពីការផ្លាស់ប្តូរផ្សេងៗដែលអាចនាំឱ្យសុខភាពរបស់ស្ត្រីបានប្រសើរឡើង។ ការរៀបរាប់អំពីសកម្មភាពទាំងឡាយដែលបុរសនិងស្ត្រីធ្វើរៀងរាល់ថ្ងៃ អាចផ្តល់ជាមូលដ្ឋានសម្រាប់ការពិភាក្សាអំពីការងារ និងយេនឌ័រ។ ជួនកាលបុរស ឬស្ត្រី មិនបានដឹងទេថា តើស្ត្រី ឬបុរសធ្វើអ្វីខ្លះក្នុងមួយថ្ងៃៗ។

ពេលខ្លះស្ត្រីមិនដែលគិតថា អ្វីដែលស្ត្រីធ្វើនៅផ្ទះ ជាការងារទេ ទោះបីជាស្ត្រីមានការងារពេញមួយថ្ងៃក៏ដោយ ក៏ស្ត្រីនៅតែត្រូវធ្វើការងារផ្ទះដែរ ហើយមិនដែលបានសម្រាកអ្វីឡើយ។ ស្ត្រីតែងតែគិតថា បុរសត្រូវការអាហារនិងការសម្រាកច្រើនជាង ព្រោះពួកគេធ្វើការងារនឿយហត់ជាង តែជាក់ស្តែងស្ត្រីធ្វើការនឿយហត់ដែរ តែហូបនិងសម្រាកបានតិចទៅវិញ។ ស្ត្រីហាក់ដូចជាធ្វើការងារច្រើនម៉ោងជាង តែសម្រាកបានតិចជាង។

តួនាទីយេនឌ័រ តែងតែប្រែប្រួលទៅតាមពេលវេលា។ ជាញឹកញាប់ តួនាទីយេនឌ័រតែងតែកំណត់ ឋានៈស្ត្រីឱ្យនៅទាប ដែលមានន័យថា មិនសូវទទួលបានការថែទាំសុខភាពមិនអាចគ្រប់គ្រងរាងកាយខ្លួនឯងយ៉ាងពេញលេញ ធ្វើការងារច្រើនម៉ោង និងមិនសូវមានអំណាចក្នុងការសម្រេចចិត្តនោះទេ។ ដើម្បីឱ្យសហគមន៍អាចកែលម្អសុខភាពរបស់ស្ត្រីបាន ពួកគេចាំបាច់ត្រូវកែប្រែតួនាទីយេនឌ័រជាពិសេស ចំណុចដែលធ្វើឱ្យស្ត្រីងាយរងគ្រោះពីបុរស។ ត្រង់នេះហាក់ដូចជាពិបាកកែប្រែខ្លាំងណាស់ ប៉ុន្តែវាមិនសូវជាពិបាកទេ នៅពេលដែលយើងយល់ដឹងថា យេនឌ័រមិនមែនជាបញ្ហាជីវសាស្ត្រនោះ មានន័យថា អ្វីៗដែលយើងគិតថា ស័ក្តិសមជាបុរស និងស័ក្តិសមជាស្ត្រី គឺជាការយល់ឃើញរបស់យើងតែប៉ុណ្ណោះ វាមិនមែនកើតចេញពីធម្មជាតិនោះទេ។ ម្យ៉ាងទៀតគួរចាំថា នៅគ្រប់តំបន់នៅទូទាំងសកលលោក តួនាទីយេនឌ័រ តែងតែប្រែប្រួលទៅតាមពេលវេលា។ ការពិភាក្សាអំពីខ្សែជីវិតរបស់ស្ត្រីក្នុងអតីតកាលធៀបនឹងបច្ចុប្បន្ន

*កាលអាចជួយឱ្យមនុស្សមើលឃើញថា តួនាទីយេនឌ័រពិតជាផ្លាស់ប្តូរមែន និងឃើញថាការផ្លាស់ប្តូរទាំងនេះបានធ្វើឱ្យសុខភាពរបស់ស្ត្រីកាន់តែប្រសើរ។*

## ឯកសារយោង


1. សេរីវ៉ុធ Learner's Dictionary បោះពុម្ពលើកទី១ ព.ស.២៥៤១ គ.ស.១៩៩៧ ទំព័រ១៩៥។
2. https://www.srpostnews.com/article/42981.
3. https://rhac.org.kh/km

# ប្រជាសាស្ត្រតំបន់ឆ្នេរសមុទ្រកម្ពុជា

Demography of Cambodia Coastal Zone

*ដោយៈ លោក* **ហៃ សុគន្ធា**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានភូមិវិទ្យានិងនគរូបនីយកម្ម,វិទ្យាស្ថាន*

*មនុស្សសាស្ត្រនិង វិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា*

Email: haysokunthea@yahoo.com

## ១. សេចក្តីផ្តើម

*ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយនៃអាស៊ីអាគ្នេយ៍ នៅចន្លោះខ្សែស្របទី១០និងទី១៥ នៃរយៈទទឹងខាងជើង និងនៅចន្លោះខ្សែបណ្តោយទី១០២ និងទី១០៨ នៃរយៈបណ្តោយខាងកើត ដែលមានផ្ទៃក្រឡាប្រមាណ១៨១ ០៣៥ គម²។ សណ្ឋានដីប្រទេសកម្ពុជាមានរាងជាពហុកោណស្ទើរស្មើជ្រុង ដែលមានចំណុចកណ្តាល ស្ថិតនៅក្បែរទីរួមខេត្តកំពង់ធំ ប្រវែងពីជើងទៅត្បូងប្រមាណជា៤៤០គ.ម. និងពីកើតទៅលិចប្រមាណជា៥៦០គ.ម.។ ប្រទេសកម្ពុជាមានព្រំប្រទល់ខាងជើងជាប់នឹងប្រទេសថៃនិងប្រទេសឡាវ ខាងកើតជាប់នឹងប្រទេស វៀតណាម ខាងត្បូងជាប់នឹងប្រទេសវៀតណាមនិងឈូងសមុទ្រថៃ និងខាងលិចជាប់នឹងប្រទេសថៃ ហើយមានប្រវែងសរុបប្រមាណ២.៦០០គ.ម. ដែលក្នុងនោះមាន ៥/៦ ជាដីគោក និង ១/៦ ជាមាត់សមុទ្រ។*

*តាមលក្ខណៈភូមិសាស្ត្រទូទៅ ប្រទេសណាដែលមានផ្ទៃដីកាន់តែធំមានន័យថាប្រទេសនោះមានលក្ខណៈនិងរូបរាងនៃសណ្ឋានដីកាន់តែខុសគ្នា។ សណ្ឋានដី គឺជាធាតុផ្គុំសំខាន់នៃអង្គផែនដីចម្រុះដោយធម្មជាតិ ប្រកបដោយធាតុសមាសផ្សេងៗក្នុងបរិស្ថានធម្មជាតិ រួមមាន សិលា ដី ទឹក រុក្ខជាតិ សត្វ កម្តៅព្រះអាទិត្យ អាកាសធាតុ កម្លាំងតិចតូចនិចៗល។ ក្រោយពីបានទទួលអន្តរកម្មដ៏ខ្លាំងក្លា និងយ៉ាងស្មុគស្មាញមក ធាតុបង្កនៃបរិស្ថានធម្មជាតិក៏បានឯកភាពរួមជាសណ្ឋានដីមួយ ដែលមានទម្រង់ដូចសព្វថ្ងៃនេះ។ សណ្ឋានដីមួយផ្នែកទទួលឥទ្ធិពលពីសកម្មភាពធម្មជាតិ រីឯមួយផ្នែកទៀតទទួលសកម្មភាពពីមនុស្ស ពោលគឺមានសារៈសំខាន់ដល់ដែនដីផលិតកម្ម ពិសេសដល់របាយកម្លាំង*

ផលិតកម្មសម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់សង្គមនិងពិភពលោកទាំងមូលតែម្តង។ មានន័យថា នៅលើផ្ទៃសណ្ឋានដីជាច្រើន គឺអាចជាកន្លែងសម្រាប់ប្រកបការងារផលិតកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃសង្គមមនុស្ស និងជីវិតទូទៅនៃភពផែនដី។

ចំពោះលក្ខណៈទូទៅ នៃសណ្ឋានដីប្រទេសកម្ពុជា គឺមានរាងផតចំកណ្តាលដែលព័ទ្ធស្ទើរជុំវិញទៅដោយភ្នំនិងខ្ពង់រាប។ បើសិនជាធ្វើពុំនូសកាត់ទទឹង សណ្ឋានដីប្រទេសកម្ពុជាពីប៉ែកនិរតីទៅឦសាន គេឃើញសណ្ឋានដីប្រទេសកម្ពុជាមានលក្ខណៈងាយ មិនសាំញ៉ាំ ព្រោះតំបន់ខ្ពស់ៗ ស្ថិតនៅតែតាមព្រំប្រទល់ប្រទេស ហើយព័ទ្ធស្ទើរជុំវិញកំហូងមួយដ៏ធំមួយ ដែលគ្របដណ្តប់ទៅដោយដីល្បាប់ គឺតំបន់ទំនាបកណ្តាល ដែលជាតំបន់ដ៏ប្រសើរសម្រាប់ដំណាំកសិកម្ម និងជាតំបន់ដែលបង្កលក្ខណៈងាយស្រួលដល់ការតាំងទីលំនៅផងដែរ។

គំនូសកាត់សណ្ឋានដីប្រទេសកម្ពុជាពីនិរតីទៅឦសាន



តំបន់ទំនាបឆ្នេរនៃប្រទេសកម្ពុជា គឺស្ថិតនៅចន្លោះឆ្នេរសមុទ្រនិងតំបន់ជួរភ្នំក្រវាញ មានប្រវែងប្រមាណពី២០ទៅ៣០គ.ម. លាតសន្ធឹងនៅតាមបណ្តោយឈូងសមុទ្រថៃ គ្របដណ្តប់ខេត្តចំនួន៤នៃប្រទេសកម្ពុជា គឺខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប ដែលសណ្ឋានដីភាគច្រើនមានទម្រង់ជាដីខ្សាច់ ដែលអាចបង្កលទ្ធភាពប្រសើរសម្រាប់ដំណាំកសិកម្មពិសេសដំណាំដូង និងដំណាំចម្ការធំៗ ដូចជាចម្ការម្រេច ធុរេន កៅស៊ូ និងដំណាំស្រូវជាដើម។ ម៉្យាងទៀត តំបន់នេះ ក៏មានប្រព័ន្ធផ្លូវទឹកជាច្រើនដែលមានប្រភពមកពីតំបន់ជួរភ្នំក្រវាញ ហើយអាចផ្តល់លទ្ធភាពសម្រាប់ផលិតថាមពលវារីអគ្គិសនីបានផងដែរ។ សម្រាប់ទំនាបឆ្នេរវិញ ក៏ជាតំបន់ដែលអាចផ្តល់ផលប្រយោជន៍ជាច្រើនសម្រាប់ជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈធនធានធម្មជាតិ និងការអភិវឌ្ឍវិស័យទេសចរណ៍ រួមជាមួយនឹងឆ្នេរសមុទ្រកម្ពុជាប្រវែង ៤៤០ គ.ម. ប្រកបទៅដោយទេសភាពល្អប្រសើរ ពោលគឺមានរុក្ខជាតិស្រស់បំព្រងនៅគ្រប់រដូវកាល ជាពិសេសគឺព្រៃកោងកាងនៅតាមឆ្នេរសមុទ្រ។ ក្រៅពីជាមជ្ឈមណ្ឌលទេសចរណ៍ តំបន់ទំនាបឆ្នេរសមុទ្រកម្ពុជាដែលមានឆកកំពង់សោម និងឆករាម ក៏ជាទីជម្រកដ៏ប្រសើរសម្រាប់កំពង់ផែ ដូចជាកំពង់ផែក្រុងព្រះសីហនុ ដែលសព្វថ្ងៃកំពុងមានសកម្មភាពយ៉ាងខ្លាំងក្លាសម្រាប់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិ។ ដូចគ្នានេះដែរ តំបន់ឈូងសមុទ្រកម្ពុជា ដែលមានលក្ខណៈជាសមុទ្រត្រូពិក គឺជាទីប្រសើរដល់ការធ្វើអាជីវកម្មនេសាទសមុទ្រ នាវាទេសចរណ៍តាមឆ្នេរ និងសកម្មភាពកំពង់ផែជាដើម។ ធនធានសមុទ្រជាច្រើនទៀតក៏ជាផ្នែកមួយដ៏សំខាន់សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាដែរ

ដូចជា ធនធានរ៉ែនៅតំបន់ជាយទ្វីបនិងតំបន់ឈូងសមុទ្រកម្ពុជា និងលទ្ធភាពនៃឧស្សាហកម្មផ្សេងទៀត(អំបិលក្លរ៉ូ សូដ្យូម ប៉ូតាស្យូម....)។

បើប្រៀបធៀបជាមួយបណ្ដាប្រទេសជិតខាង តំបន់ឆ្នេរសមុទ្រកម្ពុជាដែលពោរពេញទៅដោយភាពទាក់ទាញ គឺជាអចលទ្រព្យដែលមិនទាន់មានការអភិវឌ្ឍខ្លាំងក្លានៅឡើយទេ។ តំបន់ឆ្នេរសមុទ្រកម្ពុជា កំពុងត្រូវបានចាប់អារម្មណ៍ពីវិនិយោគបរទេសក្នុងការធ្វើនគរូបនីយកម្ម ប៉ុន្តែតំបន់ទំនាបឆ្នេរ ដែលមានវិលាសភាពដ៏ធំធេងហាក់មិនទាន់មានការវិនិយោគច្បាស់លាស់នៅឡើយទេ ពោលគឺតំបន់ទាំងនេះនៅតែជាទីកន្លែងសម្រាប់ប្រជាជននៅក្នុងតំបន់ ប្រកបរបរចិញ្ចឹមជីវិត ដោយអាស្រ័យធនធាននានានៅតាមតំបន់ឆ្នេរនិងឈូងសមុទ្រ។

## ២. លក្ខណៈភូមិសាស្ត្រតំបន់ឆ្នេរនិងឈូងសមុទ្រកម្ពុជា

សិទ្ធិស្ដីពីការបង្កើតតំបន់សេដ្ឋកិច្ចផ្ដាច់មុខដែលអាចលាតសន្ធឹងរហូតដល់ចម្ងាយ២០០ម៉ៃល៍ពីឆ្នេរ គ្របដណ្ដប់លើផ្ទៃនៃឈូងសមុទ្រថៃប្រមាណ ៥៥.៦០០ គម២ ត្រូវបានបង្កើតដោយយោងតាមសន្ធិសញ្ញាអង្គការសហប្រជាជាតិ ស្ដីពីច្បាប់ដែនសមុទ្រ[១] និងគាំទ្រដោយអធិបតេយ្យភាពរបស់កម្ពុជាលើធនធានតំបន់ឆ្នេររបស់ខ្លួន។ បើតាមកំណត់សម្គាល់ នៃពុំនូសចែកសណ្ឋានប្រទេសកម្ពុជាពីនិរតីទៅឦសានបានបង្ហាញថាផ្នែកនិរតីប្រទេសជាតំបន់ឈូងសមុទ្រ និងតំបន់ទំនាបឆ្នេរ(តំបន់ឆ្នេរសមុទ្រនិងទំនាបឆ្នេរ) ដែលមានសណ្ឋានងើបឡើងបន្តិចម្ដងៗ ពីតំបន់ឆ្នេរសមុទ្រឆ្ពោះទៅកាន់តំបន់ជួរភ្នំក្រវាញ ប៉ុន្តែក៏នៅមានសណ្ឋានដីខ្ពះៗ ជាលំនាំកូនភ្នំនៅក្នុងតំបន់ទំនាបឆ្នេរនេះដែរ ហើយកន្លែងខ្លះមានកម្ពស់រហូតដល់៤១០ម.(កោះកុង)[២]។

ខេត្តចំនួន៤នៃប្រទេសកម្ពុជា មានទីតាំងនៅជាប់នឹងឈូងសមុទ្រនៃប៉ែកនិរតី ហើយក៏ជាខេត្ត ដែលត្រូវបានចាត់ទុកជាតំបន់អទិភាពនៃធនធានសមុទ្ររបស់ប្រទេសកម្ពុជា រួមមានៈ ទី១-ខេត្តកោះកុង គ្របដណ្ដប់លើផ្ទៃដី១០.០៤៥គម២ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តពោធិសាត់ ខាងកើតជាប់នឹងកំពង់ស្ពឺ ខាងត្បូងជាប់នឹងខេត្តព្រះសីហនុ និងខាងលិចជាប់នឹងឈូងសមុទ្រថៃ ទី២-ខេត្តព្រះសីហនុ គ្របដណ្ដប់លើផ្ទៃដី ២.៦៥៨គម២ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តកោះកុង ខាងកើតជាប់នឹងខេត្តកំពតនិងកំពង់ស្ពឺ ខាងត្បូងនិងខាងលិចជាប់នឹងខេត្តកំពតនិងឈូងសមុទ្រថៃ ទី៣-ខេត្តកំពត គ្របដណ្ដប់លើផ្ទៃដី៤.៨៧៣គម២ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តកំពង់ស្ពឺ ខាងកើតជាប់នឹងខេត្តតាកែវ ខាងត្បូងជាប់នឹង

[១] http://www.wepa-db.net/policies/state/cambodia/seaarea.htm

[២] សាគូ សាម៉ុត *ភូមិវិទ្យាប្រទេសខ្មែរ* ទំព័រ២៦។

ឈូងសមុទ្រ និង ខាងលិចជាប់នឹងខេត្តព្រះសីហនុ និងទី៤-ខេត្តកែប គ្របដណ្តប់លើផ្ទៃដី១៥៨,៦៣គម២ ដែលមានព្រំប្រទល់ដីគោកព័ទ្ធជុំវិញដោយខេត្តកំពត និងព្រំប្រទល់សមុទ្រប្រវែង២៦គ.ម.។ ខេត្តនេះនៅប៉ែកនិរតីប្រទេសដែលមានចម្ងាយប្រមាណ១៧៥គ.ម.ពីរាជធានីភ្នំពេញ[3]។

## ២.១. សណ្ឋានដី

***សណ្ឋានដីនៃតំបន់ទំនាបឆ្នេរកម្ពុជា*** គឺជាតំបន់ដែលស្ថិតនៅចន្លោះឆ្នេរសមុទ្រ និងជួរភ្នំក្រវាញដែលមានចម្ងាយប្រមាណពី២០គ.ម. ទៅ ៣០គ.ម. ពោលគឺមានរយៈកម្ពស់កើនយ៉ាងរហ័សពីសមុទ្រទៅទល់ជើងជួរភ្នំក្រវាញ។ ទោះបីជារបាំងនៃតំបន់ជួរភ្នំក្រវាញ បានខណ្ឌចែកតំបន់ទំនាបឆ្នេរជាមួយនឹងតំបន់ទំនាបកណ្តាលដែលជាបេះដូងនៃប្រទេសកម្ពុជាក៏ដោយ ក៏សណ្ឋានដីនៃតំបន់ទាំងពីរនេះ មានលទ្ធភាពអាចតភ្ជាប់គ្នាតាម***ច្រកសំខាន់ៗ៣*** គឺ[4]៖

ក- ច្រកវាលវែង (មោងឫស្សី-កោះកុង)

ខ- ច្រកតាសី (ពោធិ៍សាត់-ស្រែអំបិល)

គ- ច្រកពេជ្រនិល (កំពង់ស្ពឺ-ស្រែអំបិល)

## ២.២. ប្រព័ន្ធផ្លូវទឹក

មួយភាគប្រាំមួយ(៤៤០គ.ម.) នៃបរិវេណព្រំដែនប្រទេសកម្ពុជា គឺឆ្នេរសមុទ្រ ដែលស្ថិតនៅតាមបណ្តោយឈូងសមុទ្រថៃ ហើយប្រព័ន្ធផ្លូវទឹកនៃតំបន់នេះ ភាគច្រើនជាប្រភេទស្ទឹងតូចៗដែលមានចម្ងាយខ្លីៗ និងមានរបបទឹកឡើងនិងស្រកឆាប់រហ័ស ពោលគឺអាស្រ័យទៅលើទឹកភ្លៀងនៃតំបន់ជួរភ្នំក្រវាញ ដែលជាប្រភពដ៏សំខាន់នៃប្រព័ន្ធផ្លូវទឹកទាំងនេះ។ ផ្លូវទឹកសំខាន់ៗនៃតំបន់នេះ ច្រើនតែហូរធ្លាក់ពីរយៈកម្ពស់៥០០ម. ទៅ៦០០ម. ធ្លាក់ពីល្បាក់មួយទៅកាន់ទំនាបជិតៗ ដោយបត់បែនជាក្បែនដ៏ច្រើន មុននឹងទៅដល់មាត់សមុទ្រ ដែលមានចម្ងាយរហូតទៅដល់ទៅ២០គ.ម.។ ជ្រោះជាច្រើនដែលស្ងួតនៅរដូវប្រាំងតែងតែមានទឹកច្រើននិងហូរយ៉ាងខ្លាំងនៅរដូវវស្សា ពេលខ្លះកម្លាំងទឹកហូរបាននាំមកនូវដុំថ្មធំៗនិងមែកឈើមកជាមួយផងក៏មាន។ ក្រៅអំពីទឹកភ្លៀង ប្រព័ន្ធផ្លូវទឹកនៅក្នុងតំបន់នេះស្ថិតនៅក្រោមឥទ្ធិពលនៃជំនោរសមុទ្រថែមទៀត ពោលគឺនៅរដូវប្រាំងទឹកសមុទ្រតែងតែហូរត្រឡប់ចូលទៅក្នុងប្រព័ន្ធផ្លូវទឹកទាំងនេះតាមកម្រិតនៃនីវ៉ូសមុទ្រ។ ប្រព័ន្ធផ្លូវទឹកសំខាន់ៗនៃតំបន់ឆ្នេរសមុទ្រ ពីជើងទៅត្បូង រួមមាន ស្ទឹងមេទឹក (ប្រភពនៅភ្នំធំ) ស្ទឹងព្រែកតាតី(ប្រភពស្ទឹងកែប) ស្ទឹងជាយអារែង (ប្រភពព្រែកយួននិងព្រែកតាចន្ទ) ព្រែកជីផាត ព្រែកកំពង់សោម ស្ទឹងកំពត (ប្រភពនៅភ្នំដំរី) ស្ទឹងទូកមាស។ ក្រៅពីផ្លូវទឹកសំខាន់ៗខាងលើនេះ តំបន់ឆ្នេរសមុទ្រនៅមានកូនជ្រោះជាច្រើន ដែលតែងតែនាំនូវកម្ទេចកំណាគ្រប់យ៉ាងមកចាក់បំពេញត្រើយសមុទ្រនៅរាល់រដូវភ្លៀង។

---

[3] http://kep.gov.kh/ស្ថានភាពទូទៅខេត្តកែប។

[4] ក្រសួងអប់រំ យុវជន និងកីឡា សៀវភៅសិក្សាសង្គមថ្នាក់៩ ភ្នំពេញ ២០១៧ ទំព័រ២៣។

## ២.៣.ឆ្នេរសមុទ្រនិងឈូងសមុទ្រ

### ២.៣.១.ឆ្នេរសមុទ្រ

*តាមលក្ខណៈភូមិសណ្ឋានបង្ហាញថា ឆ្នេរសមុទ្រកម្ពុជា មាន**ស្ទើរកោះពីរ**យ៉ាងដាច់ពីគ្នា ដោយសារឆកកំពង់សោម ពោលគឺស្ទើរកោះស្មាច់និងស្ទើរកោះវាលរេញ។ ទឹកសមុទ្រកម្ពុជាមិនសូវជ្រៅប៉ុន្មានទេ ដោយមានជម្រៅទឹកមិនលើសពី៧៥ម. ដែលជាកត្តានាំឲ្យមានលទ្ធភាពច្រើនក្នុងការពង្រីកសកម្មភាពសេដ្ឋកិច្ចនានានៅតាមសមុទ្រ។ រាជរដ្ឋាភិបាលបានកសាងកំពង់ផែក្រុងព្រះសីហនុ និងកំពង់ផែរាមនៅតាមឆ្នេរសមុទ្រ នេះក្នុងការធ្វើបម្លាស់ប្តូរពាណិជ្ជកម្មអន្តរជាតិ ហើយ ទីក្រុងនានាដែលស្ថិតនៅតាមឆ្នេរ ក៏ជាផ្នែកសំខាន់សម្រាប់វិស័យទេសចរណ៍ប្រកបដោយសោភណភាពប្រសើរ។ តាមការសិក្សាអំពីភូមិវិទ្យាសេដ្ឋកិច្ច គេអាចបែងចែកតំបន់ឆ្នេរសមុទ្រកម្ពុជា ជា៥តំបន់ គឺ[៥]៖*

*ក. ពីចាំយាមទៅព្រែកគគីរ៖ ឆ្នេរសមុទ្រតំបន់នេះទាបប្រកបទៅដោយភក់និងព្រៃកោងកាង ដែលបង្កលក្ខណៈងាយស្រួលដល់ការតាំងទីលំនៅរបស់មនុស្ស ហើយភាគច្រើនលើសលប់ជាភូមិអ្នកនេសាទ។*

*ខ. ពីព្រែកគគីរទៅជ្រោយសូរិយាវង្ស៖ ទីតាំងនៃឆ្នេរសមុទ្រតំបន់នេះស្ថិតនៅក្បែរជើងភ្នំ និងនៅចំមុខខ្យល់មូសុង ហើយឆ្នេរ មានសណ្ឋានប្រកបទៅដោយថ្ម និងមានរាងរឆិញរធុញ ប៉ុន្តែពុំសូវសម្បូរផ្ទាំងថ្មធំៗទេ មានតែជ្រោយខ្វះៗ ដែលជាជម្រកនៃឆកសមុទ្រប៉ុណ្ណោះ។ តំបន់នេះមានកោះ និងកូនកោះជាច្រើននៅពាយបន្តពីមុខជ្រោយទាំងនោះ ប៉ុន្តែពុំសូវមានមនុស្សរស់នៅទេ។*

*គ. ឆកកំពង់សោម៖ តំបន់នេះព័ទ្ធពីក្រៅដោយកោះភ្នំមួយជួរ និងសម្បូរព្រៃ។ នៅខាងកើតនិងខាងលិចឆកនេះ មានជ្រោយសូរិយាវង្សនិងជ្រោយថ្មស ដែលមានភូមិអ្នកនេសាទ និងជ្រោយវាលរេញ ដែលមានកំពង់ផែកំពង់សោម។ ទិដ្ឋភាពទូទៅនៃឆកកំពង់សោមប្រសើរណាស់ ព្រោះឆកនេះបែរមុខចំខ្យល់មូសុងវស្សាពីទិសនិរតី ដែលមានទទឹងប្រមាណ ៣០គ.ម. ហើយមានឆ្នេរទាបនៅប៉ែកខាងលិចនិងខាងកើត និងមានថ្មប៉ប្រះទឹកត្រង់ផ្នែកខាងត្បូង។ ម្យ៉ាងទៀត ឆកនេះចាប់គោកបន្តិចម្តងៗ ដោយសារល្បាប់ដីច្រើន ដែលចាក់បំពេញដោយប្រព័ន្ធផ្លូវទឹកទាំងឡាយ ហើយក៏ជាទីដ៏ប្រសើរសម្រាប់ជាតំបន់ជីវចម្រុះនានាផងដែរ។*

*ឃ. ពីកំពង់សោមដល់ឆកទឹកសាប៖ តំបន់នេះមានឆ្នេរខ្សាច់ជាច្រើន ជាមួយនឹងប្រភេទរុក្ខជាតិកោងកាងជាច្រើន ដុះឆ្លាស់គ្នានឹងដុំថ្ម ដែលជាទីប្រសើរសម្រាប់ទេសចរណ៍ឆ្នេរសមុទ្រ។ នៅចំកណ្តាលតំបន់នេះ មានឆករាមដែលជាជម្រកយ៉ាងល្អ សម្រាប់កំពង់ផែរាម ហើយអាចគេចផុតពីខ្យល់ព្យុះមូសុង ដែលតែងតែកើតមានស្ទើររាល់ឆ្នាំ។*

---

៥ *ហៃ សុគន្ធា **ភូមិវិទ្យាសេដ្ឋកិច្ចកម្ពុជា** ឯកសារបង្រៀនតាមសាកលវិទ្យាល័យ ២០១៣ ទំព័រ៤៥។*

ង. ពីធកទឹកសាបទៅហាទៀង (ប្រទេសវៀតណាម)៖ តំបន់នេះ មានរាងផតចូលក្នុង ដោយសារធកទឹកសាបនិងធកវាលរេញ ដែលមានឆ្នេរទាបហើយពោរពេញទៅដោយភក់។ នៅក្បែរជើងឆ្នេរចោតនៃភ្នំបូកគោមានឆ្នេររាងជាជង្ហុសម្បូរទៅដោយដើមកោងកាង ហើយផ្នែកខាងកើតពាមសមុទ្រនៃស្ទឹងកំពត ឆ្នេរនៅតែទាបរហូត លើកលែងតែជ្រោយកែប។

## ២.៣.២. តំបន់ឈូងសមុទ្រនិងកោះ

តំបន់ឈូងសមុទ្រនិងកោះ នៃប្រទេសកម្ពុជា គឺមានទីតាំងស្ថិតនៅក្នុងឈូងសមុទ្រថៃ ដែលជា សមុទ្រមិនសូវមានជម្រៅទឹកជ្រៅប៉ុន្មានទេ ពោលគឺមានជម្រៅមធ្យមប្រមាណ១០ម. ហើយជម្រៅអតិបរមាគឺមិនលើសពី៧៥ម.។ ឈូងសមុទ្រនេះ បានកាត់ផ្តាច់ដែនដីកម្ពុជាពីឧបទ្វីបម៉ាឡាកា កោះសូម៉ាត្រា និងកោះជ្វា។ ទឹកនៃតំបន់ឈូងសមុទ្រនេះមានសភាពស្ងប់នៅរដូវប្រាំង (ពីខែធ្នូទៅដល់ខែមេសា) និងមានភាពរញ្ជួយដោយរលកធំៗនៅរដូវវស្សា (ពីខែឧសភាទៅដល់ខែវិច្ឆិកា)។ ភាពស្ងប់ឬភាពរញ្ជួយនៃទឹកសមុទ្រតំបន់នេះ គឺប្រែប្រួលទៅតាមរបបខ្យល់មូសុងដែលបក់មកពីទិសឦសាន ឬ បក់មកពីទិសនិរតី។ ឈូងសមុទ្រនេះ ស្ថិតនៅក្រោមឥទ្ធិពលនៃជំនោរទឹកដូចសមុទ្រដទៃទៀតដែរ គឺក្នុងមួយថ្ងៃ(២៤ម៉ោង) មានជំនោរចំនួនពីរឆ្លាស់គ្នានឹងលំនាចចំនួនពីរ ដែលកើតឡើងដោយការប្រែប្រួលនៃផ្ទៃទឹកសមុទ្រទាំងឡាយក្រោមឥទ្ធិពលនៃទំនាញរវាងព្រះអាទិត្យនិងព្រះចន្ទ។

ខ្យល់មូសុងឦសានក្នុងសមុទ្រចិន បានបង្កឱ្យចរន្តសមុទ្របែរទៅទិសពាយ័ព្យ ដោយមានមួយផ្នែកបែរទៅរកឆ្នេរម៉ាឡាកា រួចបង្វិលមួយជុំស្របទៅនឹងទ្រនិចនាឡិកា។ ចំពោះឆ្នេរសមុទ្រកម្ពុជាវិញ ចរន្តកើតឡើងពីទិសពាយ័ព្យទៅអាគ្នេយ៍ ជាហេតុបណ្តាលឱ្យឆ្នេរនេះគេចផុតពីគ្រោះថ្នាក់ ពោល គឺខ្យល់មូសុងឦសានបង្កើតរដូវនេសាទតាមឆ្នេរសមុទ្រកម្ពុជា។ គេសង្កេតឃើញមានបាតុភូតមួយផ្ទុយទៅវិញ នៅរដូវខ្យល់មូសុងនិរតី គឺចរន្តសមុទ្រចូលមកប៉ះនឹងឆ្នេរសមុទ្រកម្ពុជា រួចឡើងទៅទិសខាងជើង ដែលបង្កឱ្យមានរលកធំៗកណ្តាលសមុទ្រ បក់ផ្ទោះមកតំបន់ឆ្នេរនេះតែម្តង ពោលគឺមូសុងនិរតីនេះហើយ ដែលបង្កើតរដូវយ៉ាងអាក្រក់នៅតំបន់ឈូងសមុទ្រនិងតំបន់ឆ្នេរសមុទ្រ ដែលបណ្តាលឲ្យនាវាចរប្រព្រឹត្តទៅដោយពិបាក និងដោយគ្រោះថ្នាក់។

ដែនដីនៃកោះទាំងឡាយរបស់កម្ពុជា[៦] គឺមានទីតាំងស្ថិតនៅក្នុងឈូងសមុទ្រថៃ ដែលក្នុងនោះមានក្រុមកោះនៅផ្នែកខាងជើង ដូចជា កោះពរ កោះកាពិ កោះថៅលាវ កោះស្តេត។ កូនកោះមួយក្រុម ប្រកបទៅដោយថ្ម មានទីតាំងនៅតាមបណ្តោយជុំវិញជ្រោយស្នាច់ គឺកូនកោះ

---

[៦] សាគូ សាម៉ុត ភូមិវិទ្យាប្រទេសខ្មែរ ភ្នំពេញ ២០១០ ទំព័រ ២៨។

ដំបង កោះព្រះ កោះបួនជាដើម។ កោះរ៉ុង និង កោះរ៉ុងសន្ទឹម ស្ថិតនៅពីមុខឆកកំពង់សោម ហើយក្រុមកោះ នៅខាងមុខស្ទើរកោះវាលរេញ រួមមាន កោះពស់ កោះតាគៀវ កោះឫស្សី កោះត្រែស កោះចន្ទុះ កោះស្រមោច មានកោះថ្មី និង កោះសេះជាដើម។ កោះកុង ជាកោះធំជាងគេនៃ ប្រទេសខ្មែរ (ផ្ទៃដីប្រមាណ៨០គម២) គឺជាកូនភ្នំ មួយកម្ពស់៤១០ម. ដែលដាច់ចេញពីទ្វីប ដោយសារបំណាក់ភ្នំភ្លើង។ កោះត្រល់ (បច្ចុប្បន្ន ជាកោះហ្វូគួក) គឺជាកោះមួយដ៏ធំ ដែលអាច ការពារឆ្នេរពីខ្យល់មូសុងនិរតីហើយក៏ជាបាំង (ទីជម្រកសមុទ្រ) នៃភូមិនេសាទជាច្រើន។ ក្រុមកោះនៅផ្នែកខាងត្បូង រួមមានកោះស្វាយ កោះទន្សាយ កោះត្បាល់ កោះអង្កុញ និងកោះសេះ ជាដើម។ កោះភាគច្រើននៃឈូងសមុទ្រថៃ មានមនុស្សរស់នៅតិចតួចនៅឡើយ កោះខ្លះនៅមាន លក្ខណៈធម្មជាតិស្ទើរតែទាំងស្រុង ប្រកបទៅ ដោយព្រៃក្រាស់ៗ ដែលនៅពុំទាន់បានទាញ យកផលប្រយោជន៍សេដ្ឋកិច្ចនៅឡើយ។

## ៣. ប្រជាសាស្ត្រតំបន់ទំនាបឆ្នេរ និង ឈូងសមុទ្រ

ជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ[៧] បង្ហាញថា ប្រទេសកម្ពុជាមានប្រជាជនប្រមាណ ជា ១៥,២៨លាននាក់ ដែលក្នុងនោះ មានខ្មែរ ប្រមាណជា៩០%។ ជាការពិត ប្រទេសកម្ពុជា ធ្លាប់បានធ្វើជំរឿនប្រជាពលរដ្ឋកម្ពុជា ជាផ្លូវការ លើកទីមួយ គឺនៅក្នុងឆ្នាំ១៩៦២ ដែលមានប្រជាពលរដ្ឋប្រមាណ ៥,៧លាននាក់ ពោលគឺប្រព្រឹត្តឡើងបន្ទាប់ពីប្រទេសកម្ពុជា បានទទួលឯករាជ្យពេញលេញពីអាណានិគមបារាំង។ ចាប់ពីពេល នោះមក កម្ពុជាមិនបានធ្វើជំរឿនប្រជាជនទេ រហូតដល់ឆ្នាំ១៩៩៨ និងមិនមានការធ្វើអង្កេត ថ្នាក់ជាតិទេរហូតដល់ឆ្នាំ១៩៩៣-១៩៩៤។ មិន មានព័ត៌មានជាក់លាក់ណាមួយ ដែលអាច អះអាងបន្ថែមអំពីចំនួនប្រជាពលរដ្ឋកម្ពុជា រហូត ដល់ឆ្នាំ១៩៩២ ទើបអាជ្ញាធរបណ្ដោះអាសន្ន របស់អង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ ថាអ៊ុនតាក់ (UNTAC) បានស្រង់ឈ្មោះអ្នកបោះឆ្នោត អាយុពី១៨ឆ្នាំឡើងទៅមានចំនួនប្រមាណ ជា ៤,២៨លាននាក់។ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានដឹកនាំធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) នៅខែមេសា ឆ្នាំ១៩៩៤ បានប៉ាន់ស្មាន ចំនួនប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាមានចំនួន ប្រមាណ ៩,៨៧លាននាក់។

---

[៧] វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ *ជំរឿនទូទៅ ប្រជាជនកម្ពុជាឆ្នាំ២០១៩* ទំព័រ៩។

ជំរឿនប្រជាជនកម្ពុជាតាមបណ្ដាឆ្នាំ




ជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩ ដដែល បានបង្ហាញអំពីទំហំ និងកំណើនប្រជាជន តាមតំបន់ស្នាក់នៅ មានការប្រែប្រួលប្រចាំតំបន់យ៉ាងទូលាយ ក្នុងការបែងចែកប្រជាជន ដូចជាតំបន់វាលរាប គឺជាតំបន់ដែលប្រជាជនចូលចិត្តរស់នៅច្រើនជាងគេបំផុត បន្តបន្ទាប់ដោយតំបន់ទន្លេសាប តំបន់ឆ្នេរសមុទ្រ និងចុងក្រោយ គឺតំបន់ភ្នំនិងខ្ពង់រាប ដែលមានស្ថានភាពដឹកជញ្ជូនពិបាកជាងគេ។

តារាងទី១៖ ទំហំនិងកំណើនប្រជារាស្ត្រតាមតំបន់និងអត្រាកំណើនប្រចាំឆ្នាំ

| តំបន់តាំងទីលំនៅ | ចំនួនប្រជារាស្ត្រតាមឆ្នាំ | | អត្រាកំណើន (២០០៨-២០១៩) | |
|---|---|---|---|---|
| | ២០០៨ | ២០១៩ | ភាគរយ | ប្រចាំឆ្នាំ |
| តំបន់វាលរាប | ៦.៩៤៧.៩៥៣ | ៧.៨៧៧.៤៤៤ | ១៤,១៩ | ១,២ |
| តំបន់ទន្លេសាប | ៤.៣៥៦.៧០៥ | ៤.៨០១.២៦០ | ១០,២០ | ០,៩ |
| តំបន់ឆ្នេរសមុទ្រ | ៩៦០.៤៨០ | ១.០៦១.១៤៨ | ១០,៤៨ | ០,៩ |
| តំបន់ភ្នំនិងខ្ពង់រាប | ១.៥៣០.៥៤៤ | ១.៩៤៨.៦៣៧ | ២៧,៣១ | ២,២ |
| សរុប | ១៣.៣៩៥.៦៨២ | ១៥.២៨៨.៤៨៩ | ១៤,១២ | ១,២ |

ប្រភព៖ ជំរឿនប្រជាជនកម្ពុជាឆ្នាំ២០១៩

អត្រាកំណើនប្រជាជនមធ្យមប្រចាំឆ្នាំនៃតំបន់ឆ្នេរ គឺមានកម្រិតទាបជាងគេ (ប្រមាណ ០,៩%) បើធៀបទៅនឹងតំបន់ភ្នំនិងខ្ពង់រាបមានអត្រាកំណើនប្រជាជនមធ្យមប្រចាំឆ្នាំ ខ្ពស់ជាងគេ (២,២%) ដោយសារការផ្លាស់ទីចូលមកពីខេត្តដទៃទៀត ដោយមូលហេតុស្វែងរកឱកាសផ្នែកសេដ្ឋកិច្ចផ្សេងៗតាមរយៈធនធានធម្មជាតិ អំណោយផល និងការពង្រីកការបន្ថែមការអភិវឌ្ឍថ្មីៗនៅក្នុងតំបន់ទាំងនេះ។

## ៣.១. ដង់ស៊ីតេប្រជារាស្ត្រកម្ពុជាតាមតំបន់

តាមជំរឿនទូទៅប្រជាជនកម្ពុជា ដង់ស៊ីតេប្រជាជន គឺជាសូចនាករសំខាន់មួយនៃប្រជាជនដែលត្រូវបានវាស់វែងពីការប្រមូលផ្តុំរបស់ប្រជាជន។ សូចនាករនេះ គឺគិតពីចំនួនមនុស្សរស់នៅលើផ្ទៃដីក្នុងមួយគីឡូម៉ែត្រការ៉េ។

ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ បង្ហាញថា ដង់ស៊ីតេប្រជាជនកម្ពុជាគឺមានចំនួន ៨៦នាក់ បានកើនឡើងចំនួន១១នាក់ បើប្រៀបធៀបទៅនឹងដង់ស៊ីតេនៃការធ្វើជំរឿនឆ្នាំ២០០៨

ដែលមានចំនួនតែ៧៥នាក់ប៉ុណ្ណោះ ក្នុងមួយគីឡូម៉ែត្រការ៉េ ទោះបីជាយ៉ាងនេះក្តី ក៏ចំនួននេះនៅមានលក្ខណៈទាបនៅឡើយ បើប្រៀបធៀប ទៅនឹងប្រទេសជិតខាងដូចជា ប្រទេសវៀតណាម (១៦៨នាក់/គម២) ប្រទេសថៃ (១៣៦នាក់/គម២) និងតំបន់អាស៊ីអាគ្នេយ៍ (១៣២នាក់/គម២) ប៉ុន្តែប្រទេសឡាវ គឺជាប្រទេសដែលមានដង់ស៊ីតេទាបជាងគេនៅក្នុងតំបន់ ពោលគឺមានចំនួនតែ២៧នាក់/គម២ ប៉ុណ្ណោះ។ ជាទូទៅ មិនថាតែនៅក្នុងប្រទេសកម្ពុជាងទេ ប្រទេសស្ទើរតែទាំងអស់នៅក្នុងពិភពលោក គឺមានដង់ស៊ីតេប្រជាជននៅតំបន់ទីក្រុងនិងទីប្រជុំជន ខ្ពស់ជាងតំបន់ជនបទ។ នៅចន្លោះឆ្នាំ២០០៨ និងឆ្នាំ២០១៩ ចំនួនប្រជាជន បានកើនឡើងចំនួន១,៨៩លាននាក់ ដែលក្នុងនោះតំបន់ទីប្រជុំជនមានកំណើនចំនួនមនុស្សប្រមាណ ០,៨លាននាក់ (៤១,៤%) រីឯតំបន់ជនបទវិញ មានកំណើនចំនួនមនុស្ស ១,១លាននាក់ (៥៨,៦%)។

តារាងទី២៖ ការបែងចែកតំបន់ ផ្ទៃដី និងដង់ស៊ីតេប្រជាជនឆ្នាំ២០០៨និង២០១៩

| តំបន់តាំងទីលំនៅ | ផ្ទៃដី(គម២) | ប្រជាសាស្ត្រ(%) | | ដង់ស៊ីតេ | |
|---|---|---|---|---|---|
| | | ២០០៨ | ២០១៩ | ២០០៨ | ២០១៩ |
| វាលរាប | ២៥.០៦៩ | ៤៩,២ | ៤៩,២ | ២៦១ | ២៩៨ |
| ទន្លេសាប | ៦៧.៦៦៨ | ៣២,៥ | ៣២,២ | ៦៤ | ៧១ |
| ឆ្នេរសមុទ្រ | ១៧.២៣៧ | ៧,២ | ៧ | ៥៦ | ៦២ |
| ភ្នំ និង ខ្ពង់រាប | ៦៨.០៦១ | ១១,៤ | ១១,៧ | ២២ | ២៩ |
| សរុប | ១៨១.០៣៥* | ១០០ | ១០០ | ៧៥ | ៨៦ |

សម្គាល់: * រាប់បញ្ចូលបឹងទន្លេសាប(៣.០០០ គម២)

ទិន្នន័យជំរឿនប្រជាសាស្ត្រកម្ពុជាឆ្នាំ២០០៨ ក៏ដូចជាជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ បានបង្ហាញថា ដង់ស៊ីតេប្រជាជនកម្ពុជា ប្រែប្រួលពីចំនួនពី៧៥ ទៅចំនួន៨៦ ដែលក្នុងនោះ តំបន់វាលរាបនៅតែមានដង់ស៊ីតេប្រជាសាស្ត្រខ្ពស់ជាងគេដដែល គឺពីចំនួន២៦១នាក់/គម២ នៅឆ្នាំ២០០៨ កើនដល់ ២៩៨នាក់/គម២ នៅឆ្នាំ២០១៩ ហើយតំបន់ដែលមានដង់ស៊ីតេទាបជាងគេ គឺតំបន់ភ្នំនិងខ្ពង់រាបដែលមានចំនួនតែ២២នាក់/គម២ នៅឆ្នាំ២០០៨ និង២៩នាក់/គម២ នៅឆ្នាំ២០១៩។ ដោយឡែកដង់ស៊ីតេប្រជាសាស្ត្រកម្ពុជាតំបន់ឆ្នេរសមុទ្រនៅតែស្ថិតនៅលំដាប់លេខ៣ ក្នុងចំណោមតំបន់តាំងទីលំនៅទាំង៤នៃប្រទេសកម្ពុជាបន្ទាប់ពីតំបន់វាលរាប និងតំបន់ទន្លេសាប ពោល គឺមានប្រជាសាស្ត្រចំនួន៥៦នាក់/គម២ នៅឆ្នាំ២០០៨ និងចំនួន៦២នាក់/គម២ នៅឆ្នាំ២០១៩។

ចំនួនប្រជាជនសរុប នៃខេត្តទាំងបួនរបស់កម្ពុជា ដែលមានទីតាំងនៅជាប់នឹងមាត់សមុទ្រ

មានចំនួន ១,០៦១,១៤៨នាក់[8] គឺស្មើប្រមាណជា៧% នៃប្រជាជនទូទាំងប្រទេស ដែលក្នុងនោះខេត្តកំពតមានប្រជាជនច្រើនគេ ក្នុងចំណោមខេត្តនៅជាប់នឹងសមុទ្រទាំងបួន របស់ព្រះរាជាណាចក្រកម្ពុជា ពោលគឺប្រមាណជា ៤% ខេត្តព្រះសីហនុប្រមាណ២% ខេត្តកោះកុងប្រមាណជា០,៨% និងខេត្តកែបប្រមាណជា ០,៣%។ តាមតារាងខាងលើបង្ហាញថា ដង់ស៊ីតេប្រជាជននៅតំបន់សមុទ្រកម្ពុជា គឺមានត៦២នាក់ ប៉ុណ្ណោះក្នុងមួយគីឡូម៉ែត្រការ៉េ ប៉ុន្តែនៅតែជាតួលេខដែល មានចំនួនតិចនៅឡើយ បើធៀបជាមួយនឹងដង់ស៊ីតេប្រជាជនកម្ពុជា ដែលមានចំនួន៨៦នាក់/គម២។ កោះកុង គឺជាខេត្តដែលមានដង់ស៊ីតេទាបជាងគេនៃតំបន់ គឺប្រមាណ ១២នាក់/គម២ ហើយខេត្តកែប គឺជាខេត្តដែលមានដង់ស៊ីតេខ្ពស់ជាងគេនៃតំបន់ ប្រមាណ ១២៤នាក់/គម២។

តារាងទី៣៖ ចំនួនប្រជារាស្ត្រនៅតំបន់ទំនាបឆ្នេរ និងឈូងសមុទ្រឆ្នាំ២០១៩

| ខេត្ត | ផ្ទៃដី(គម២) | ចំនួនប្រជាជន | %ប្រជាជន |
|---|---|---|---|
| កោះកុង | ១០.០៩០ | ១២៣.៦១៨ | ០,៨៣ |
| ព្រះសីហនុ | ១.៩៣៨ | ៣០២.៨៨៧ | ១,៧០ |
| កំពត | ៤.៨៧៣ | ៥៩២.៨៤៥ | ៤,១៧ |
| កែប | ៣៣៦ | ៤១.៧៩៨ | ០,២៦ |
| សរុប(-កោះ) | ១៧.២៣៧ | ១.០៦១.១៤៨ | ៦,៩៦ |

ប្រភព៖ ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩

បើពិនិត្យលទ្ធភាពខេត្តកោះកុងដែលមានដង់ស៊ីតេតិចនៅឡើយ គឺបានឆ្លុះបញ្ចាំងអំពីវិសាលភាពនៃធនធានធម្មជាតិ របស់ខេត្តមួយនេះ និងសក្តានុពលក្នុងការទាញយកលទ្ធភាពនៃគរូបនីយកម្ម និងវិនិយោគផ្សេងៗតាមលក្ខខណ្ឌសមស្របណាមួយសម្រាប់ចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

## ៣.២. ចលនាប្រវេសន៍តំបន់ទំនាបឆ្នេរ និង ឈូងសមុទ្រ

តាមការសិក្សាស្រាវជ្រាវមួយ ដែលមានការទ្រទ្រង់ថវិកា ដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបង្ហាញថា ខេត្តជាប់មាត់សមុទ្ររបស់កម្ពុជាចំនួន៣ គឺខេត្តកំពត ខេត្តកែប និងខេត្តកោះកុង គឺមានប្រជាជនធ្វើចំណាកស្រុកច្រើន។ ការសិក្សានេះដែរ ក៏បានបង្ហាញពីចំនួនប្រជាពលរដ្ឋភាគច្រើន របស់ខេត្តនៅជាប់ឆ្នេរសមុទ្រកម្ពុជាទាំងនេះ គឺជាជនអន្តោប្រវេសន៍ថ្មីៗទៅកាន់តំបន់នៅតាមបណ្តោយឆ្នេរសមុទ្រ។ ចំនួនប្រជាជននៅជាប់ឆ្នេរសមុទ្រដល់ទៅ៤១% មានលំនៅដ្ឋានចាស់របស់ពួកគេ ស្ថិតនៅក្រៅស្រុកឬខេត្តនៃតំបន់នេះ ហើយប្រហែល៣% នៃចំនួនប្រជាជនខេត្តកំពត បានផ្លាស់ទីលំនៅពីតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា។ ប្រជាពលរដ្ឋជាច្រើន នៅតំបន់តាមបណ្តោយឆ្នេរសមុទ្រកម្ពុជា គឺជាអ្នកចំណាកស្រុកឬផ្លាស់ទីលំនៅមកពីតំបន់

[8] វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ ទំព័រ២៣។

បីផ្សេងទៀត (វាលរាបទន្លេ សាប និងភ្នំនិងខ្ពង់រាប) ដើម្បីសេដ្ឋកិច្ចគ្រួសារ។

ចំណុចទាំងនេះ ត្រូវបានបកស្រាយបន្ថែមនៅក្នុងការសម្ភាសន៍ ដែលធ្វើឡើងដោយ ADB នៃអ្នករស់នៅតាមបណ្តោយឆ្នេរនៃបណ្តាខេត្តទាំងនេះ ដែលបង្ហាញថា ភាគច្រើននៃពួកគេបានផ្លាស់ប្តូរទៅកន្លែងរស់នៅបច្ចុប្បន្ន របស់ពួកគេសម្រាប់ហេតុផលសេដ្ឋកិច្ចឬសន្តិសុខ។ ដូចនេះ តំបន់ឆ្នេរសមុទ្រកម្ពុជា មានទំហំប្រជាពលរដ្ឋច្រើនមធ្យម ដែលធ្វើឱ្យទម្រង់នៃការប្រើប្រាស់ធនធាន អាចនឹងរួមចំណែកដល់សម្ពាធសេដ្ឋកិច្ចលើប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រ។ប្រជាជនប្រមាណ៣៥% នៃប្រជាជនខេត្តកោះកុង បានផ្លាស់ប្តូរទៅទីប្រជុំជននៅក្នុងខេត្ត ក្នុងរយៈពេលប្រមាណមួយទសវត្សរ៍កន្លងមក[៩] ខណៈពេលដែល ៣៦,២% នៃការរកឃើញនោះបង្ហាញថា "ដើម្បីស្វែងរកការងារ" គឺជាមូលហេតុនៃការធ្វើចំណាកស្រុក។ កត្តានេះ គឺជាសូចនាករមួយសម្រាប់ឱកាសជីវភាព ដែលមានមូលដ្ឋានលើធនធានធម្មជាតិ ពោលគឺខេត្តនេះ ពឹងផ្អែកលើជនចំណាកស្រុក មកពីតំបន់ផ្សេងៗទៀតនៅក្នុងប្រទេស។ ប្រជាពលរដ្ឋភាគច្រើននៃខេត្តកោះកុងពឹងផ្អែកលើការនេសាទ កសិកម្ម និងសកម្មភាព ដែលពឹងផ្អែកលើធនធានផ្សេងទៀតដូចជាការផលិតធ្យូងជាដើម។ ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋជាច្រើន នៅក្នុងខេត្តកោះកុង បានកើតឡើងចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំជាមធ្យម១៦%។ការហូរចូលចំនួនប្រជាជនដ៏ច្រើនបំផុតទៅក្នុងតំបន់នេះ គឺបានកើតឡើងក្នុងអំឡុងឆ្នាំ១៩៨៥-១៩៩០។ ពលរដ្ឋនៅក្នុងខេត្តនេះ ជាពិសេសតំបន់ជាប់តាមបណ្តោយមាត់សមុទ្រ គឺពឹងផ្អែកស្ទើរតែទាំងស្រុងលើការនេសាទ សម្រាប់ជីវភាពរស់នៅរបស់ពួកគេ ពោលគឺមានមូលដ្ឋានពីធនធានសមុទ្រតែម្តង។

ដោយឡែក ខេត្តព្រះសីហនុ ត្រូវបានយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ដើម្បីធ្វើការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ ដែលទទួលបានការទាក់ទាញវិនិយោគច្រើនជាងគេ ក្នុងចំណោមខេត្តទាំងបួននៃតំបន់ឆ្នេរសមុទ្រ (ប្រមាណ៧ពាន់លានដុល្លារ រយៈពេល៤ឆ្នាំចុងក្រោយនេះ)។ ប្រជាជនកម្ពុជាជាច្រើននៃតំបន់ផ្សេងទូទាំងប្រទេស បានធ្វើ ចំណាកស្រុកពីតំបន់ផ្សេង ដើម្បីស្វែងរកចំណូលនៅក្នុងតំបន់នេះ ដោយឱកាសការងារ និងចលនាប្រវេសន៍អន្តរជាតិជាច្រើនផងដែរ ហើយភាគច្រើនគឺជាជនជាតិចិន។ ខេត្តព្រះសីហនុ មានចំនួនជនអន្តោប្រវេសន៍អន្តរជាតិច្រើនជាងគេ ពោលគឺចំនួនពាក់កណ្តាលនៃអ្នករស់នៅក្នុងក្រុងព្រះសីហនុ គឺជាជនជាតិចិន (ប្រមាណជា៨០ ០០០នាក់) មុនពេលការផ្ទុះឡើងនៃកូវីដ១៩ ហើយឥឡូវនេះ ជនជាតិនេះ

[៩] ក្រសួងផែនការ ជំរឿនប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨។

*បានថយចំនួនមកត្រឹមប្រមាណជា ១៥ ០០០ នាក់ប៉ុណ្ណោះ ដែលរស់នៅក្នុងទីក្រុង*[១០]*។*

### ៣.៣. យេនឌ័រនិងរបរចិញ្ចឹមជីវិត

*ប្រហែលមួយភាគប្រាំនៃគ្រួសារទាំងអស់ក្នុងប្រទេសកម្ពុជា ត្រូវបានដឹកនាំដោយស្ត្រី* (SIDA 2018)*។ នៅតំបន់ឆ្នេរសមុទ្រ បុរសជាអ្នកទទួលខុសត្រូវចម្បងចំពោះការនេសាទ នៅក្នុងសមុទ្របើកចំហ ខណៈពេលដែលស្ត្រីបានធ្វើសកម្មភាពនេសាទនៅជិតផ្ទះ ក៏ដូចជាការកែច្នៃ ការធ្វើទីផ្សារ ថែទាំស្រះចិញ្ចឹមត្រីនិងទ្រុង និងរក្សាឧបករណ៍នេសាទ។ នៅក្នុងអាជីវកម្មនេសាទគ្រួសារ ស្ត្រីពេលខ្លះអាចមានឥទ្ធិពល ឬសិទ្ធិក្នុងការសម្រេចចិត្តជាងប្តីរបស់ពួកគេ សូម្បីតែក្នុងគ្រួសារដែលក្រីក្រ ក៏ស្ត្រីជួយស្វាមីរបស់ពួកគេ ដូចជា ការជ្រើសរើសក្តាមពីសំណាញ់កែច្នៃ ផលិតផលត្រី ការជួសជុលសំណាញ់ និងគំនរនេសាទលើទូកជាដើម។ រដូវប្រាំង គឺជារដូវដែលមានផលិតភាពច្រើនបំផុតសម្រាប់ប្រជាជនខ្មែរ អ្នកនេសាទតែងតែធ្វើការច្រើនជាង១០ម៉ោងក្នុងមួយថ្ងៃ ដោយមិនរាប់បញ្ចូលការងារផ្ទះសម្បែង។ ចំពោះគ្រួសារដែលមានស្ត្រីធ្វើការងារនេះ គឺពិតពិបាកជាងបុរសៗព្រោះពួកគេត្រូវមើលថែក្មេងៗផង ធ្វើអាជីវកម្មខ្នាតតូចផងការងារថែរក្សាផ្ទះផង ការប្រមូលអុសនិងការចម្អិនផង ។*

*ជាងនេះទៀត ស្ត្រីភាគច្រើនដែលជាមេគ្រួសារនៅក្នុងតំបន់នេះ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការបំពេញតម្រូវសេដ្ឋកិច្ចគ្រួសារប្រចាំថ្ងៃ តាមរយៈធនធានធម្មជាតិអំណោយផល ដូចជាការប្រើប្រាស់ដីត្រូវបានរីករាលដាលយ៉ាងល្អនៅគ្រប់តំបន់ទាំងអស់ ។*

## ៤. របៀបរស់នៅ និង ការចិញ្ចឹមជីវិត

*ប្រហែលជាង៨០% នៃប្រជាជនដែលកំពុងរស់នៅតាមខេត្តជាប់នឹងមាត់សមុទ្រ គឺជាជនជាតិខ្មែរ ហើយក៏មានមានជនជាតិចាម វៀតណាម ចិន ថៃ និងជនជាតិដើមភាគតិចមួយចំនួនទៀតផងដែរ។*

*ក្នុងចំណោមខេត្ត នៅជាប់មាត់សមុទ្រទាំងបួននេះមានតែខេត្តកំពតទេជាខេត្តដែលផលិតស្រូវបានច្រើនជាងគេ ហើយវាក៏ជាប្រភពអាហារចម្បងជាងគេដែរនៅក្នុងសហគមន៍។ ទាំងនេះបង្ហាញឱ្យឃើញ អំពីសារៈសំខាន់ជនបទនៅខេត្តកំពត ដែលបង្ហាញអំពីកាលានុវត្តភាពក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅក្នុងខេត្តកំពត។ ការផលិតម្រេចបានល្អនៅកម្ពុជាដោយសារមានសារជាតុម៉ាញ៉េស៊ីយ៉ូម (លោហៈធាតុអាចដុតបាន) និងដីដែលមានជាតិដែកជាពិសេសខេត្តកំពតនិងខេត្តកែប។ ម្រេចមានតម្លៃណាស់សម្រាប់បន្ថែមទៅក្នុងមុខម្ហូបល្បីៗមួយចំនួនទាំងក្នុងស្រុក និងលើឆាកអន្តរជាតិ។*

*ខេត្តកំពត នៅមានផលិតផលមួយទៀតដែលគេស្គាល់ គឺទុរេនដែលមានរសជាតិឆ្ងាញ់*

[១០] *លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ កាសែត ខ្មែរថែម ថ្ងៃទី ១៧ មិថុនា ២០២០។*

*ប៉ុន្តែក្លិនធុយខ្លាំងណាស់ រហូតទៅដល់ជនបរទេសលោកខាងលិចមួយចំនួន ពិបាកទទួលយកក្លិននេះទៀតផង។ ផលិតផលទុរេន មានការសសើរខ្លាំងពីប្រជាជនទូទៅ រហូតដល់មានការធ្វើនិមិត្តរូបជាផ្លែឈើប្រចាំខេត្តទៀតផង។*

### ៤.១. ការនេសាទ

*ការនេសាទ មានសារៈសំខាន់ណាស់ សម្រាប់ទ្រទ្រង់ជីវភាពប្រជាជន នៅតំបន់ឆ្នេរសមុទ្រ និងតំបន់ឈូងសមុទ្រ។ ការនេសាទ គឺមុខរបរដែលមានតម្លៃមិនអាចកាត់ថ្លៃបាន សម្រាប់ប្រជាជនក្នុងតំបន់ ហើយដីព្រៃកោងជាច្រើនដែលអាចប្រើប្រាស់បានជាតំបន់ជីវៈចម្រុះត្រូវរៀបចំឡើង ដើម្បីសម្រាប់ជួយលើកតម្កើងសេដ្ឋកិច្ចសហគមន៍។*

*ការនេសាទ គឺជាការចិញ្ចឹមជីវិតមួយបែបរបស់ប្រជាជនកម្ពុជាតាមបែបប្រពៃណី និងវប្បធម៌ក្នុងតំបន់ឆ្នេរ ហើយវាក៏បានផ្តល់ផលប្រយោជន៍ដល់វិស័យទេសចរណ៍ ដូចជាមគ្គុទេសសម្រាប់ការនេសាទ ការជ្រមុជទឹកជ្រៅ ការមុជទឹកទៅមើលផ្កាថ្មបាតសមុទ្រ។ ពាក់ព័ន្ធនឹងការពង្រឹងអំពីការនេសាទពីឆ្នាំ១៩៧៩ ច្បាប់បិទនេសាទត្រូវបាត់បង់ក្នុងសម័យខ្មែរក្រហម ដែលជាហេតុធ្វើមានការកើនឡើង នូវទូកនេសាទថៃ និងវៀតណាមក្នុងដែនសមុទ្រកម្ពុជា[១១]។ បន្ថែមលើនេះទៀត ការប្រែប្រួលអាកាសធាតុ ការបំពុលបរិយាកាស គ្រាប់បែក និងការបាត់បង់ជម្រក (ឧទាហរណ៍: ធ្វើឱ្យហិនហោចត្រី ការអភិវឌ្ឍតំបន់ឆ្នេរ...) ការឈ្លានពានពីក្រុមមនុស្សផ្សេង ការរំខាន និងការប្រមូលទិន្នផលជ្រុល នឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផលិតផលនេសាទ។ ការប្រើប្រាស់លើសកំណត់ សកម្មល្មើសច្បាប់ពីប្រទេសជិតខាង ការគ្រប់គ្រងមានកម្រិតទាប (គ្មានច្បាប់អប្បរមា ឬអតិបរមាក្នុងកម្រិតណាមួយ) ដើម្បីការពារកំណើនប្រជាជន និងតំបន់បិទនេសាទដើម្បីការពារនូវពងត្រី និងកង្វះខាតនូវការប្រតិបត្តិច្បាប់ ឱ្យមានប្រសិទ្ធិភាពដើម្បីត្រួតពិនិត្យនៃការនេសាទទាំងនោះ។ ការបំផ្លាញប្រព័ន្ធអេកូឡូស៊ី ដោយសារការដាក់គ្រាប់បែកនិងប្រើប្រាស់សំណាញ់អួសត្រី ធ្វើឱ្យខូចដល់ថ្មប៉ប្រះទឹក និងស្មៅសមុទ្រដោយសកម្មភាពនេសាទខុសច្បាប់ទាំងនោះ។ ការបាត់បង់នូវស្មៅសមុទ្រ នឹងធ្វើឱ្យមានការបាក់ដីដោយសារដីទាប និងការកាប់ព្រៃកោងកាងដើម្បីធ្វើអុសធ្យូងក៏មានផលប៉ះពាល់ដល់ការនេសាទដែរ ដែលនាំទៅប៉ះពាល់ដល់សេដ្ឋកិច្ចនិងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនសហគមន៍។*

*ការនេសាទ និងផលិតផលដទៃទៀតនៃតំបន់ឆ្នេរ មានសារៈសំខាន់ណាស់សម្រាប់ការរស់នៅ និងចំណូលរបស់សហគមន៍នៃតំបន់ឆ្នេរ និងឈូងសមុទ្រ។ ការការពារធនធានសមុទ្រនិងអាហារសមុទ្រដែលមានគុណភាព គឺមានសារៈសំខាន់ណាស់សម្រាប់វិស័យទេសចរណ៍ ព្រោះសកម្មភាពរបស់ទេសចរដូចជា ការមុជទឹក ការ*

[១១] UNEP-DHI Center for Water and Environment, *"ការវិភាគថ្លៃចំណាយនិងផលចំណេញនៃការកែប្រែទម្លាប់ក្នុងកសិកម្មសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ឆ្នេរ"* ទំព័រ ៣៦។

ជ្រមុជទឹកទៅបាតសមុទ្រ និងឧស្សាហកម្មចំណីអាហារ គឺពឹងផ្អែកយ៉ាងសំខាន់ទៅលើផលិតផល និងធនធានមនុស្សផ្នែកសមុទ្រ។

## ៤.២. ប្រជាជននិងផ្ទៃដីកសិកម្ម

តាមជំរឿនកសិកម្ម២០១៣ របស់ក្រសួងផែនការ បង្ហាញថា នៅក្នុងប្រទេសកម្ពុជា មានប្រមាណ២,៦លានគ្រួសារ បានចុះបញ្ជីកាន់កាប់ដីកសិកម្ម ដែលក្នុងនោះមាន២,២ លានគ្រួសារ ឬ៤ក្នុងចំណោម៥ បានចូលរួមក្នុងសកម្មភាពកសិកម្ម។ បើនិយាយអំពីតំបន់ទាំងបួន (វាលរាប ភ្នំនិងខ្ពង់រាប បឹងទន្លេសាប និងតំបន់ឆ្នេរ) នៃសណ្ឋានដីរបស់ប្រទេសកម្ពុជា គឺមានពីរនៅក្នុងបួនតំបន់នៃប្រទេសកម្ពុជា បានបង្ហាញថាបានកាន់កាប់ច្រើនជាង៥០០.០០០ និងបានប្រតិបត្តិតាំងពីឆ្នាំ២០១៣ ពោលគឺតំបន់វាលរាបនិងតំបន់បឹងទន្លេសាប[12]។

តាមតារាងទី៤ បង្ហាញថា សមាមាត្រនៃការកាន់កាប់កសិកម្មនៅតំបន់វាលរាប ធៀបនឹងការកាន់កាប់សរុបទូទាំងប្រទេស គឺមានចំនួនច្រើនជាងគេ រហូតទៅដល់ជិតពាក់កណ្តាល (៤៦,៣៥%) ហើយតំបន់ឆ្នេរវិញ សមាមាត្រនៃការកាន់កាប់កសិកម្មធៀបនឹងការកាន់កាប់សរុបទូទាំងប្រទេស គឺមានចំនួនតិចជាងគេ(៧,៤៣%)។

តារាងទី៤៖ ចំនួននិងសមាមាត្រនៃការកាន់កាប់កសិកម្មជាំដំណាំតាមតំបន់ឆ្នាំ២០១៣

| តំបន់ | ចំនួនការកាន់កាប់កសិកម្ម | ភាគរយ |
|---|---|---|
| វាលរាប | ៨៦៩.៣០៥ | ៤៦,៣៥ |
| តំបន់បឹងទន្លេសាប | ៦១៤.៣៦៩ | ៣២,៧៥ |
| តំបន់ឆ្នេរ | ១៣៩.៤៣៣ | ៧,៤៣ |
| តំបន់ខ្ពង់រាបនិងភ្នំ | ២៥២.៦០៥ | ១៣,៤៧ |
| សរុប | ១.៨៧៥.៧១២ | ១០០ |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ក្រុមបញ្ជីស្ទូលជំរឿនកសិកម្មនៅកម្ពុជា ឆ្នាំ២០១៣

ប្រជាជននៅក្នុងតំបន់ឆ្នេរ មានការកាន់កាប់កសិកម្មតិចជាងគេ បើប្រៀបធៀបទៅនឹងតំបន់ផ្សេងទៀត ព្រោះម្យ៉ាងប្រជាជនមានដែលមានការតាំងទីនៅក្នុងតំបន់តិចស្រាប់ រួមផ្សំជាមួយនឹងផ្ទៃដី ដែលអំណោយផលសម្រាប់វិស័យកសិកម្មនៃតំបន់នេះ ក៏នៅមានកម្រិតនៅឡើយ។ ជាក់ស្តែង ផ្ទៃដីដែលអំណោយផលសម្រាប់កសិកម្មនិងកសិឧស្សាហកម្ម គឺមានតែនៅតំបន់ជាប់ក្បែរមាត់សមុទ្រប៉ុណ្ណោះ ប៉ុន្តែផ្ទៃដីផ្សេងទៀត ដែលនៅក្បែរនិងកៀកទៅនឹងជួរភ្នំក្រវាញ គឺមិនអំណោយផលសម្រាប់កសិកម្មទេ ពោលគឺសម្រាប់ទទួលបានផលប្រយោជន៍ពីអនុផលព្រៃឈើ។

---

[12] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ "**ជំរឿនកសិកម្មនៅកម្ពុជា២០១៣**" ទំព័រ ៦

### ៤.៣. ប្រជាជននិងការប្រើប្រាស់ធនធាន

*ជាការពិត ធនធានតំបន់សមុទ្រផ្តល់លទ្ធភាពសំខាន់ណាស់ សម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជាជន ជាពិសេសអ្នករស់នៅតាមតំបន់ឆ្នេរ និងកោះៗ ទោះបីជារ៉ែប្រេងកាត ដែលមាននៅតាមបណ្តោយឆ្នេរសមុទ្ររបស់កម្ពុជា មិនទាន់បានផ្តល់លទ្ធភាពនៅឡើយក្តី ប៉ុន្តែការប្រើប្រាស់ប្រភេទដី ត្រូវបានរីកពលដាលយ៉ាងល្អប្រសើរ នៅគ្រប់តំបន់ទាំងអស់នៃតំបន់ឆ្នេរ ជាពិសេសខេត្តព្រះសីហនុ។ ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរក៏ជាផ្នែកមួយមានសារៈសំខាន់ដែរ ក្នុងការជួយដល់កម្រិតជីវភាពរបស់ប្រជាជនក្នុងតំបន់ដែរ ជាពិសេសគឺគម្របព្រៃឈើ ដែលត្រូវបានគេរកឃើញនៅតំបន់នៅផ្នែកកណ្តាល និងនៅជិតព្រំដែននៃខេត្ត និងភាគច្រើននៅក្នុងឧទ្យានជាតិរាមស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ នៅក្នុងតំបន់វាងស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងឧទ្យានជាតិរាម គេឃើញមានការប្រើប្រាស់ដីដែលភាគច្រើនជាព្រៃឫស្សី និងព្រៃអនុតំបន់វាលស្មៅនិងដើមឈើ។*

*ដូចគ្នានេះដែរ គម្របការប្រើប្រាស់ដីធ្លីសម្រាប់ខេត្តកែបមានរាប់ពីតំបន់ដីក្រហូង ដែលស្ថិតនៅភាគខាងលិចនៃទីក្រុង ដែលភាគច្រើនជាព្រៃឫស្សី និងព្រៃបន្ទាប់បន្សំដែលត្រូវបានគេរកឃើញនៅតំបន់ការពារ និងតាមបណ្តោយព្រំប្រទល់ខាងត្បូងនៃក្រុងកែប ហើយនៅភាគខាងកើត ការប្រើប្រាស់ដីមានព្រៃកោងកាងរលួយព្រៃឈើស្មៅ និងព្រៃឈើ។*

*ប្រភេទទូលំទូលាយនៃការប្រើប្រាស់ដីធ្លីត្រូវបានកត់ត្រានៅខេត្តកំពត ពោលគឺចាប់ពីតំបន់តាំងទីលំនៅរហូតដល់តំបន់ថ្មៗ គម្របឈើដ៏ធំមួយត្រូវបានរកឃើញនៅក្នុងឧទ្យានជាតិភ្នំបូកគោ ហើយនៅផ្នែកខាងកើតនៃខេត្ត ជាពិសេសនៅស្រុកឈូក ស្រុកអង្គរជ័យ ស្រុកដងទង់ ស្រុកកំពង់ត្រាច និងភូមិខ្វះៗនៃស្រុកកំពង់បាយ និងស្រុកជុំគីរី គឺជាកន្លែងដែលផលិតស្រូវបានច្រើនៗ នៅក្នុងតំបន់ទាំងនេះ មានប្រព័ន្ធផ្លូវទឹកជាច្រើនដែលត្រូវបានប្រើប្រាស់ដើម្បីផ្គត់ផ្គង់ទឹកសម្រាប់ដំណាំស្រូវក្នុងរដូវដាំដុះ។*

*ប្រភេទដីប្រើប្រាស់នៅខេត្តកោះកុង គឺព្រៃឈើ ដែលមានស្ទឹកច្រើននិងមានទំហំច្រើនហិកតា ដែលគ្របដណ្តប់គ្រប់តំបន់រួមមានកូនភ្នំឆ្នេរសមុទ្រ កោះ និងតំបន់ខ្ពង់រាបនៅតាមតំបន់ឆ្នេរសមុទ្រ។ ប្រភេទដីប្រើប្រាស់បន្ទាប់បន្ទាស់ដែលត្រូវបានគេរកឃើញជាទូទៅ គឺព្រៃកោងកាង ដែលនៅរាយប៉ាយតំបន់ទាបៗក្បែរទីប្រជុំជនបុរីសាគរ ក៏ដូចជានៅក្នុងតំបន់ការពារនៃឧទ្យានជាតិបទុមសាគរ និងតំបន់ប្រើប្រាស់ចម្រុះបានច្រើន។*

*ជារួម ប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ឆ្នេរដែលលាតសន្ធឹង ចាប់ពីខេត្តកោះកុងដល់ខេត្តកែប គឺត្រូវបានប្រើប្រាស់សម្រាប់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ រួមមានអេកូឡូស៊ី និង*

ជីវចម្រុះ ដែលអាចបម្រើមួយផ្នែកដល់ការធ្វើនេសាទបន្ទាប់បន្សំ ដាំដំណាំកសិកម្មរួមផ្សំនៅតំបន់ទំនាបក្បែរមាត់សមុទ្រ និងប្រកបរបរផ្សេងទៀត ដើម្បីចិញ្ចឹមជីវិត ជាពិសេសនៅក្នុងតំបន់ជីវចម្រុះនោះតែម្តង។

## គន្ថនិទ្ទេស


1. ក្រសួងផែនការ“ **ជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩** ” ភ្នំពេញ ឆ្នាំ២០២០
2. សាន ប៉េងសែ“ **សង្ខេបព្រំដែនកម្ពុជា**” ប៉ារីស ២០០៤
3. សាគូ សាម៉ុត “**ភូមិវិទ្យាប្រទេសខ្មែរ** ”ភ្នំពេញ ២០១០
4. អ៊ុន យ៉េត “**ភូមិវិទ្យារូបទ្វីបអាស៊ី**” ភ្នំពេញ ២០១១
5. ហៃ សុគន្ធា “**ប្រជាជននិងការអភិវឌ្ឍ**” ភ្នំពេញ ២០១២
6. ហៃ សុគន្ធា“ **ភូមិវិទ្យាសេដ្ឋកិច្ច** ”ភ្នំពេញ ២០១៣
7. **ក្រសួងផែនការ “ជំរឿនកសិកម្មកម្ពុជា ឆ្នាំ២០១៣” ភ្នំពេញ ឆ្នាំ២០១៤**
8. របាយការណ៍ប្រចាំឆ្នាំ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកោះកុង ចំនួន៧ទំព័រ
9. របាយការណ៍ប្រចាំឆ្នាំ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត ចំនួន៥ទំព័រ
10. របាយការណ៍ប្រចាំឆ្នាំ២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ចំនួន៦ទំព័រ
11. ក្រសួងអប់រំ យុវជន និងកីឡា សៀវភៅភូមិវិទ្យាថ្នាក់ទី៩ ភ្នំពេញ ២០១៧ ចំនួន១៧៤
12. ក្រសួងអបរំ យុវជន និងកីឡា សៀវភៅភូមិវិទ្យាថ្នាក់ទី១១ ភ្នំពេញ ២០១៧ ចំនួន២០៤ទំព័រ
13. UNEP-DHI Center for Water and Environment, ការវិភាគថ្លៃចំណាយនិងផលចំណេញនៃការកែប្រែទម្លាប់ក្នុងកសិកម្មសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ឆ្នេរ ,ភ្នំពេញ , ២០១២
14. Bill Cater and Vicky O′ Rourke, គោលការណ៍យុទ្ធសាស្ត្រសម្រាប់វិស័យទេសចរណ៍ប្រកបដោយ និរន្តរភាពស្តីពីឆ្នេរសមុទ្រកម្ពុជា ២០១២ ,ភ្នំពេញ ,
15. Ali Raza Rizvi and Uwe Singer Coastal of Cambodia Analysis, IUCN, Bangkok, 2011
16. http://www.coralcay.org/science-research/scientific-reports
17. https://news.mongabay.com/cambodia-declares-first-ever-marine-protected-area
18. http://www.khmertimeskh.com/news/20284/little-support-for-coastal-master-plan
19. http://www.khmertimeskh.com/news/26165/sea-gates-to-protect-coastline
20. http://www.iucn.org/building-coastal-resilience

# ការប្រតិបត្តិសីលធម៌ក្នុងគ្រួសារខ្មែរបច្ចុប្បន្ន

*ដោយៈ លោក* **ឈុន ផារ៉េង**

*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិទ្យា,វិទ្យាស្ថាន*

*មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*បុព្វបុរសខ្មែរបានបន្សល់ទុកយ៉ាងសម្បូរបែបនូវទ្រឹស្តីដំបូន្មាន ច្បាប់សីលធម៌ និងក្បួនច្បាប់ជាច្រើនសម្រាប់អប់រំសមាជិកសង្គមយកទៅធ្វើការប្រតិបត្តិ[១]។ ទោះបីយ៉ាងនេះក្តី ក៏បញ្ហានៃ**ការប្រតិបត្តិសីលធម៌នៅ**ក្នុងសង្គមគ្រួសារខ្មែរ នាសម័យសាកលភាវូនីយកម្ម[២] ដែលផ្អែកខ្លាំងលើបច្ចេកវិទ្យាព័ត៌មាន និង ទំនាក់ទំនង[៣]នោះ នៅតែជាប្រធានបទស្មុគ្រស្មាញសម្រាប់ការជជែកពិភាក្សាស្វែងរកដំណោះស្រាយដើម្បីរួមចំណែកស្វែងរកសុភមង្គលដល់បុគ្គល ក្រុមគ្រួសារ និងសង្គមជាតិទាំងមូល។ ជាទូទៅសមាជិកសង្គមទាំងឡាយ តែងមានគោលបំណងចង់រួមរស់ក្នុងសង្គមគ្រួសារប្រកបដោយសុភមង្គល ប៉ុន្តែក្នុងដំណើរការរស់នៅ យើងឃើញមានគ្រួសារជាច្រើនបានជួបប្រទះអពមង្គលដោយពិបាករក*

[១] *ការប្រតិបត្តិ ឬការបដិបត្តិ*(practice) *ការប្រព្រឹត្ត,ការអនុវត្តធ្វើតាម។ ពាក្យ ការប្រតិបត្តិ មានន័យខុសពីពាក្យការប្រណិប័តន៍។ ការប្រណិប័តន៍*(respect) *ការសម្តែងសេចក្តីគោរព, ការគំនាប់, ការឱនសំពះ ជាដើម។*

[២] *សាកលភាវូបនីយកម្ម គឺជាដំណើរការនៃអន្តរកម្ម និង សមាហរណកម្មរវាងប្រជាជន ក្រុមហ៊ុន និងរដ្ឋាភិបាលទូទាំងពិភពលោក។ ពាក្យសកលភាវូបនីយកម្ម ត្រូវបានប្រើដើម្បីពិពណ៌នាអំពីការរីកចម្រើនដែលមិនអាចកាត់ផ្តាច់ពីអន្តរជាតិ នៃពិភពសេដ្ឋកិច្ច វប្បធម៌និងប្រជាជនពិភពលោក តាមរយ:ពាណិជ្ជកម្មទំនិញនិងសេវាកម្មឆ្លងដែន បច្ចេកវិទ្យា និង លំហូរនៃការវិនិយោគទុន មនុស្ស និងព័ត៌មានបានឡើយ។* (Globalization is the process of interaction and integration among people, com-panies, and governments worldwide. This word used to describe the growing interdependence of the world's economies, culures, and populations, brought about by crossborder trade in goods and services, technology, and flows of investment, people, and info-rmation)

[៣] *បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង គឺជាហេដ្ឋារចនាសម្ព័ន្ធនិងធាតុផ្សំទាំងឡាយដែលមានសមត្ថភាពគណនាទំនើប*(ICT, inf-ormation and communications technology, is the infrastructurerand components that enable modern computing.

មធ្យោបាយដោះស្រាយបំផុត។ គ្រួសារខ្លះបែកបាក់គ្នាដោយការលែងលះដែលវាបានផ្តល់វិបាកអាក្រក់ជាច្រើនដល់សង្គមជាតិ ប៉ុន្តែការទ្រាំលេបគ្រួសលេបថ្មរស់នៅជាមួយគ្នាដោយមិនចុះសម្រុងគឺជាទារុណកម្មបំផុតសម្រាប់ជីវិតប្តីប្រពន្ធ។ តើសង្គមខ្មែរមានច្បាប់គតិយុត្តិ និងគោលការណ៍សីលធម៌អ្វីខ្លះសម្រាប់ជួយគ្រួសាររស់នៅឲ្យបានប្រសើរ? តើការប្រតិបត្តិសីលធម៌ក្នុងគ្រួសារខ្មែរបច្ចុប្បន្នមានសភាពលក្ខណៈដូចម្តេចខ្លះ? តើគួរធ្វើបែបណាដើម្បីដោះស្រាយបញ្ហាទាំងនេះ?

## ២. អត្ថន័យនៃពាក្យសំខាន់មួយចំនួន

សីលធម៌[4] គឺជាវិន័យបញ្ញត្តិ ឬសិក្ខាបទ ចែងអំពីកិរិយាមារយាទ សណ្តាប់ធ្នាប់ ដែលជាដំបូន្មានប្រាប់ឱ្យប្រព្រឹត្តតាមគន្លងប្រពៃណី គឺឱ្យចៀសវាងអំពើអាក្រក់ ហើយឲ្យប្រព្រឹត្តតែអំពើល្អ។ អាចនិយាយថា សីលធម៌ គឺក្បួនច្បាប់សម្រាប់ទូន្មានមនុស្សឱ្យដឹងអំពីករណីយកិច្ច[5] និងប្រាប់ឱ្យដឹងអំពីវិរតិចេតនា[6] ដែលត្រូវវៀរចាកអំពើខុសឆ្គង និងប្រព្រឹត្ត ត្រឹមត្រូវដោយកាយវាចាចិត្ត ពោលគឺ សីលធម៌គឺក្បួនប្រាប់ពីការប្រព្រឹត្តសុចរិតនិងអហិង្សា[7]។ យើងអាចមានការភាន់ច្រឡំរវាងអត្ថន័យនៃពាក្យសីលធម៌ សុជីវធម៌ និងគុណធម៌។សុជីវធម៌[8] ជាពីជីការក្នុងរស់នៅឱ្យបានល្អ គឺមានសណ្តាប់ធ្នាប់ការដឹងប្រមាណ គួរសមក្នុងកិច្ចការប្រាស្រ័យជាមួយអ្នកដទៃ។ ចំណែកគុណធម៌[9] គឺជាក្បួនប្រាប់ពីដំណើរចម្រើន តាម

---

៤ សីលធម៌(សីលធម្ម moral)ជាក្បួនហាមមិនអោយប្រព្រឹត្តខុសសីលនិយាម និងបញ្ជាអោយធ្វើត្រឹមត្រូវតាមសីលកាព្វកិច្ច ដែលមានជាទម្លាប់តគ្នាយូរមកហើយ។ សីលនិយាម(moral rule)ខុសពីគោលការណ៍សីលធម៌(moral princi-ple)ត្រង់វាមានភាពប្រែប្រួលតាមលក្ខខណ្ឌដោយឡែក និងមានលក្ខណៈ ជាក់លាក់ក្នុងការប្រតិបត្តិ។ សីលនិយាមសាកលសំខាន់ៗមានដូចជា៖ បញ្ចសីលា, សុចរិតជាដើម។ បញ្ចសីលា(five precepts ឬសីល៥, ឬបញ្ចវិរតិ ឬបញ្ចវេរមណី ឬវៀរចាក៥យ៉ាង, ឬបំរាម៥យ៉ាង) ដែលត្រូវវៀរចាកប្រចាំថ្ងៃ(និច្ចសីល) មាន៖ សម្លាប់(បាណាតិបាតាkilling), លួចប្លន់ (អទិន្នាទានាstealing), ខុសក្នុងកាម (កាមេសុមិច្ឆាចារាsexual misconduct),កុហក់(មុសាវាទាfalse spee-ch)គ្រឿងញៀនស្រវឹង(សុរាមេរយមជ្ជប្បមាទដ្ឋានា intox-icants cau-sing heedlessness)។ សុចរិត (good deed, គឺការប្រព្រឹត្តិល្អទាំងកាយ វាចា ចិត្ត។ សីលកាព្វកិច្ច គឺជាករណីយកិច្ចដែលត្រូវបំពេញតាមឋានៈតួនាទីមុខងារ ដែលធម្មជាតិ និងសង្គមផ្តល់អោយ។

៥ ករណីយកិច្ច(ន.)កាតព្វកិច្ច,កិច្ចដែលគួរធ្វើ និងការងារដែលត្រូវតែធ្វើខានពុំបាន។

៦ វិរតិចេតនា( ន.) គំនិតដែលនាំចិត្តឲ្យភ្នកកាន់ត្រណម។ ចេតនានេះជាតួចេតសិកដែលដឹកនាំចិត្តឲ្យចេះគិត។

៧ អហិង្សា គឺ មិនបៀតបៀនអោយអ្នកដទៃលំបាកឈឺចាប់។

៨ សុជីវធម៌(savoir vivre or etiquette គឺរបៀបឬវិធីសម្រាប់ប្រណិប័តន៍ក្នុងការរស់នៅអោយគេស្រឡាញ់ពេញចិត្ត ដូច សុជីវធម៌ក្នុងការដេកដើរឈរអង្គុយ ទំនាក់ទំនងបរិភោគ ទទួលភ្ញៀវ ជាដើម គឺគួរសម្តែងឥរិយាបថបែបណាអោយគេរីករាយសប្បាយចូលចិត្ត។

៩ គុណធម៌(virtue) គឺជាការធ្វើល្អត្រឹមត្រូវលើសពីសីលកាតព្វកិច្ច។ គុណធម៌ មានជាតុមួយចំនួន ដូចជា ព្រហ្មវិហារធម៌, សច្ច, សប្បុរស, កតញ្ញូកតវេទិតាឧបការ, អធ្យាស្រ័យនិង

ជាន់តាមថ្នាក់ខាងអំពើល្អ[10] អាក្រក់[11] ដែលបុគ្គលធ្វើល្អប្រសើរលើសពីសីលកាតព្វកិច្ច។

## ៣. ច្បាប់គតិយុត្តិ និងគោលការណ៍សីលធម៌សម្រាប់គ្រួសារខ្មែរ

ច្បាប់[12] គឺជាការកំណត់នូវវិធានទាំងឡាយណាដែលប្រទេស ឬសហគមន៍មួយទទួលស្គាល់ ដូចជា ការកំរិតសកម្មភាពនៃជនគ្រប់រូបដោយមានលក្ខណៈចាប់បង្ខំឲ្យទទួលខុសត្រូវរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ។ ច្បាប់របស់កម្ពុជាត្រូវបានបែងចែកជា២ គឺច្បាប់គតិយុត្តិ ដែលជាច្បាប់សំខាន់ និង គោលការណ៍សីលធម៌ ដែលជាច្បាប់បន្ទាប់បន្សំ។ ច្បាប់គតិយុត្តិ គឺជាច្បាប់ដែលបង្កើតដោយអាជ្ញាធរមានសមត្ថកិច្ច។ ច្បាប់ទាំងអស់សុទ្ធតែជាបទដ្ឋានគតិយុត្តិដែលបង្កើតឡើងដោយអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋាភិបាលត្រូវបានរក្សាទុកដោយរាជក្រឹត្យ។ គោលការណ៍សីលធម៌[13] មានលក្ខណៈមិនសូវផ្លូវការ មានដូចជាទំនៀមទម្លាប់ប្រពៃណី លទ្ធិនិងសេចក្ដីសំរេចរបស់សង្គម។ ក្នុងរឿងក្ដីរដ្ឋប្បវេណីប្រសិន បើមិនមានច្បាប់ជាលាយលក្ខណ៍អក្សរទេ រឿងក្ដីទាំងឡាយនោះមិនមានភាពច្បាស់លាស់ទេ ហេតុនេះចៅក្រមអាចធ្វើការពិចារណាយោងទៅតាមប្រពៃណី ទំនៀមទម្លាប់ មនសិការ និងសមធម៌។

### ៣.១.ច្បាប់គតិយុត្តិនានាសម្រាប់គ្រួសារ

ច្បាប់គតិយុត្តិដែលអាចបង្ការអំពើហិង្សា ការពារសេចក្ដីថ្លៃថ្នូរ ពង្រឹងសុខដុមរមនា សុកមង្គលគ្រួសារ មានដូចជាៈ ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ,ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពាជនរងគ្រោះឆ្នាំ២០០៥, ច្បាប់ស្ដីពីឯកពន្ធភាពឆ្នាំ២០០៦, ច្បាប់ព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ជាដើម។

---

សន្ដោសប្រោសប្រណី, សាមគ្គី, ទសបារមី, ទសពិធរាជធម៌ ជាដើម។

[10] ល្អ (good) បុណ្យ បុញ្ញ កុសល អ្វីដែលមនុស្សស្រឡាញ់ ពេញចិត្ត(ឃ្លានឆ្ងាញ់ ស្រឡាញ់ល្អ)។

[11] អាក្រក់(bad) បាប អកុសល អ្វីដែលមនុស្សស្អប់ មិនចូលចិត្ត។

[12] ច្បាប់ គឺជាវិធានចែងជាលាយលក្ខណ៍អក្សរដែលបង្ខំឲ្យទទួលខុសត្រូវតាមរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ។ វាត្រូវបានបង្កើតដោយអាជ្ញាធរ រដ្ឋាភិបាល សភាជាតិ ដើម្បីឲ្យមនុស្សទូទៅអនុវត្ត ជាពិសេសតុលាការ។

[13] គោលការណ៍សីលធម៌(moral principle) ជាវិធានបង្កប់ក្នុងទំនៀមទម្លាប់ ប្រពៃណីទ្រឹស្ដីជាដើម។ វាកកើតឡើងដោយការ ទទួលស្គាល់ដោយសមាជិកទូទៅនៃសង្គមពីមួយជំនាន់ៗ។ វាត្រូវបានមនុស្សទូទៅក្នុងសង្គមប្រើជាប្រចាំតាមវិធីលើកទឹកចិត្ត និងត្រិះរិះពិចារណាដោយវិចារណញ្ញាណ គឺវាមិនត្រូវបានគេចាប់បង្ខំឲ្យមនុស្សប្រតិបត្តិដោយការផាកពិន័យឬទណ្ឌកម្ម ជាផ្លូវការអ្វីឡើយ។ វាមានលក្ខណៈទូទៅ និងអរូបី ហើយមានវិសាលភាពគ្រប់កាលៈទេសៈទាំងអស់។

### ៣.១.១. ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ជំពូកទី៣ មាត្រា៣៦ បានបញ្ជាក់ថា ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃ ដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។ មាត្រា៤៥-ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល។ ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់។បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយ ប្រពន្ធមួយ។ មាត្រា៤៧-មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និង អប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ កូនមានករណីយ កិច្ចចិញ្ចឹម និង បីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។

### ៣.១.២. ច្បាប់ស្ដីពីអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១

ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ[១៤] ត្រូវវាបានមោឃភាពដោយមាត្រា៧៨ នៃច្បាប់ស្ដីពីអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១[១៥] ដោយចែងថា ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារត្រូវបាត់បង់អនុភាពចាប់ពីកាលបរិច្ឆេទនៃការអនុវត្តលើកលែងតែបញ្ញត្តិនៃមាត្រា៧៦ មាត្រា៧៧ និងមាត្រា៧៩ ដល់មេត្រា៨១ នៃច្បាប់នោះនៅតែមានអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត រហូតដល់ពេលដែលកំណត់ផ្សេងដោយច្បាប់។(សូមមើលឧបសម្ពន្ធទី១និងឧបសម្ពន្ធទី២)

### ៣.១.៣. ច្បាប់ស្ដីពី ឯកពន្ធភាព ឆ្នាំ២០០៦

ជំពូកទី១ បទប្បញ្ញត្តិទូទៅ,មាត្រា១. ច្បាប់នេះមានគោលបំណងការពារសេចក្ដីថ្លៃថ្នូរ និងពង្រឹង សុខដុមរមនា សុភមង្គលក្នុងគ្រួសារ និងការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងប្ដីនិងប្រពន្ធ ស្របតាមមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តិជាធរមាន។ មាត្រា២.ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្តប្ដីមួយប្រពន្ធមួយដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ចំពោះ

---

[១៤] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបាន រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨៩ នាសម័យប្រជុំសាមញ្ញលើកទី១៧ នីតិកាលទី១។ ច្បាប់នេះមានគោល ដៅដាក់បទបញ្ញា និងការពារការរៀបអាពាហ៍ពិពាហ៍ នឹងជីវភាពគ្រួ សារ ជានាសមភាពរវាងសហព័ន្ធក្នុងអាពាហ៍ ពិពាហ៍និងក្នុងគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្ដាយ ក្នុងការចិញ្ចឹមថែរក្សាកូន និងជុំរុញការបណ្ដុះបណ្ដាលសីលធម៌និងការអប់រំកូនដើម្បី អោយទៅជាពលរដ្ឋល្អមានមនសិការស្នេហាជាតិស្រលាញ់ ការ ងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះ សង្គម។

[១៥] ច្បាប់ស្ដីពីអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ អនុម័តឡើងដើម្បីអនុវត្តក្រមរដ្ឋប្បវេណី ដោយព្រះរាជក្រមចុះថ្ងៃ៨ធ្នូ ២០០៧។

មុខមន្ត្រីអត្រានុកូលដ្ឋានស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ។

ជំពូកទី២ និយមន័យ ពិរុទ្ធភាព និងនីតិវិធី,មាត្រា៣.ឯកពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ ដែលបុរសមានប្រពន្ធតែមួយ ឯស្ត្រីមានប្ដីតែមួយ។ ដែលហៅថាចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថា រួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ ចំណងអាពាហ៍ពិពាហ៍ត្រូវរលាយក្នុងករណីណាមួយដូចខាងក្រោមៈ សហព័ទ្ធណាមួយស្លាប់។ មានសេចក្ដីសម្រេចរំលាយចំណងអាពាហ៍ពិពាហ៍ជាស្ថាពររបស់តុលាការ។ សហព័ទ្ធណាម្នាក់បាត់ខ្លួនហួសពីមួយឆ្នាំ ដោយគ្មានដំណឹងអ្វីសោះ មិនដឹងថាស្លាប់ឬរស់។ មាត្រា៤.ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឯស្ត្រីមានប្ដីពីរ។ ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទ ទ្វេពន្ធភាពបុរស ឬស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត។ អ្នកសមគំនិតត្រូវមានទោសដូចគ្នា។ មាត្រា៥.ត្រូវចាត់ទុកថាស្មន់ បុរស និងស្ត្រីណាដែលជាប់ចំណងជាញាតិលោហិត ឬញាតិពន្ធនឹងគ្នា ហើយរួមសេវនកិច្ចជាមួយគ្នា។ មាត្រា៦.ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទស្មន់ៈ បុរស និងស្ត្រីដែលជាប់ចំណងជាញាតិលោហិតឬញាតិពន្ធក្នុងខ្សែផ្ទាល់ គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្ដីឬជាសាច់ចិញ្ចឹមក្ដី បានរួមសេវនកិច្ចជាមួយគ្នា។ បុរស និងស្ត្រីដែលជាប់ចំណងសាខាញាតិនឹងគ្នា ទោះសាខាញាតិនោះមានខាន់ស្លាក្ដី ឥតខាន់ស្លាក្ដី ចិញ្ចឹមក្ដី រួមម្ដាយក្ដី រួមឪពុកក្ដី រួមម្ដាយឪពុកក្ដី ជាញាតិលោហិតក្ដី ឬ ជាញាតិពន្ធក្ដី រហូតដល់ថ្នាក់ទី៣ រាប់ទាំងថ្នាក់នេះ ផងបានរួមសេវនកិច្ចជាមួយគ្នា។ មិនចាត់ទុកថាមានពិរុទ្ធពីបទស្មន់ទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហព័ទ្ធដែលនៅរស់រួមសេវនកិច្ចជាមួយសាខាញាតិពន្ធថ្នាក់ទី២ ឬថ្នាក់ទី៣។ មាត្រា៧. ត្រូវចាត់ទុកថាផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ ពិពាហ៍មិនទាន់រលាយ ជាមួយបុរសដទៃក្រៅពីប្ដីរបស់ខ្លួន។ ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទផិតៈ បុរសណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយស្ត្រីផ្សេងទៀត។

ស្ត្រីណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយបុរសដទៃទៀត។ មាត្រា៨. ក្នុងករណីដែលមានចែងក្នុងមាត្រា៧ខាងលើ ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបានប្រសិនបើមានបណ្តឹងរបស់សហព័ន្ធណាមួយស្នើសុំកុំឲ្យចោទប្រកាន់។

ជំពូកទី៣ ទោសប្បញ្ញត្តិ មាត្រា៩.ទ្នាទោសណាជនណាប្រព្រឹត្តល្មើសនឹងមាត្រា៤នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែដល់១ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី២០០.០០០ (ពីររយពាន់)រៀល ដល់១.០០០ . ០០០(មួយលាន)រៀលឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ។ មាត្រា១០.ជនណាប្រព្រឹត្តល្មើសនឹងមាត្រា៦ និងមាត្រា៧នៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែដល់១ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី២០០.០០០(ពីរយពាន់)រៀលដល់១.០០០.០០០(មួយលាន) រៀលឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ។

### ៣.១.៤. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥

ជំពូកទី២ មាត្រា២ អំពើហិង្សាក្នុងគ្រួសារគឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើៈ ប្តី ឬ ប្រពន្ធ, កូនក្នុងបន្ទុក, ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ។ មាត្រា ៣ អំពើហិង្សាក្នុងគ្រួសារ ទាមទារឱ្យមានការទប់ស្កាត់ទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព ហើយតម្រូវឱ្យចាត់វិធានការសមស្របបំផុត ដើម្បីការពារជនរងគ្រោះ ឬ ជនអាចនឹងរងគ្រោះ។ អំពើហិង្សារួមមាន ៖ ការប៉ះពាល់ដល់ជីវិត, ការប៉ះពាល់ដល់បូរណភាពរូបកាយ, ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ, ការឈ្លានពានខាងផ្លូវភេទ ។ មាត្រា៤.អំពើប៉ះពាល់ដល់ជីវិតរួមមានៈ- មនុស្សឃាតដោយគិតទុកជាមុន មនុស្សឃាតដោយចេតនា មនុស្សឃាតដោយអចេតនា បណ្តាលមកពីអំពើចេតនាផ្សេងទៀតនៃជនល្មើស មនុស្សឃាតដោយអចេតនា។ មាត្រា៥. អំពើប៉ះពាល់ដល់បូរណភាពរូបកាយ រួមមានៈ ការបំពារបំពានលើរូបកាយដោយប្រើអាវុធ ឬ ឥតអាវុធមានរបួស ឬ គ្មានរបួស, ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ។ មាត្រា៦. អំពើទារុណកម្ម ឬ អំពើឃោរឃៅ រួមមានៈការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្តសតិ អារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ, ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្តនិងលើរូបកាយដែលប្រព្រឹត្តហួសពីសីលធម៌ និងច្បាប់កំណត់។ មាត្រា៧.អំពើឈ្លាន ពានខាងផ្លូវភេទ រួមមានៈ

ការប្រើហិង្សាសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ឈ្មោះ, ការធ្វើអាស្រូវភាស។ មាត្រា៨.ត្រូវទប់ស្កាត់ផងដែរចំពោះអំពើគំរាមកំហែងក្នុងគោលបំណងឱ្យជនរងគ្រោះភ័យខ្លាចតក់ស្លុត និងអំពើប៉ះពាល់ដល់បុគ្គលភាព និងទ្រព្យសម្បត្តិនៃជនដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារតែមួយ។ មិនរាប់បញ្ចូលថាជាការប្រើហិង្សា ឬ សកម្ម ភាពហិង្សាក្នុងគ្រួសារទេរាល់ការប្រៀនប្រដៅដោយផ្តល់ដំបូន្មាន ឬធ្វើការដាស់តឿនក្រើនរំលឹកឬចាត់វិធានការនានាសមស្របដើម្បីឱ្យ សហព័ទ្ធ ឬ កូន ឬ អ្នកនៅក្នុងបន្ទុកដើរក្នុងផ្លូវល្អតាមលក្ខណៈរស់នៅថ្លៃថ្នូរ នឹងទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ ប្រសិនបើការប្រៀនប្រដៅនិងការអប់រំនោះ ធ្វើឡើងប្រកបដោយព្រហ្មវិហារធម៌ និងស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី៧ ទោសប្បញ្ញត្តិ មាត្រា៣៥. អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ មាត្រា៣៦. ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬ បទលហុ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀត ដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌតុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះ តាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ។

**៣.១.៥. គោលការណ៍ភូមិឃុំមានសុវត្ថិភាព**

ភូមិឃុំមានសុវត្ថិភាព រួមមានលក្ខណៈសម្បត្តិ៩យ៉ាង១. គ្មានសកម្មភាពលួចឆក់ប្លន់គ្រប់ប្រភេទ២. គ្មានការផលិតនិងការចែកចាយគ្រឿងញៀនខុសច្បាប់ ៣. គ្មានអំពើរអាណាចរ្យការជួញដូរស្ត្រីកុមារនិងអំពើរហិង្សារនៅក្នុងគ្រួសារ ៤. គ្មានក្មេងទំនើង ៥. គ្មានការលេងល្បែងស៊ីសង ខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ និង បទល្មើសគ្រប់ប្រភេទ៦. គ្មានគ្រោះថ្នាក់ចរាចរណ៍ ៧. គ្មានគ្រោះថ្នាក់ដោយគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ៨. មានវិធានការណ៍ទប់ស្កាត់គ្រប់ប្រភេទ និង ការឆ្លើយតបចំពោះគ្រោះមហន្តរាយ៍ប្រកបដោយប្រសិទ្ធភាព៩.គ្មានកុងត្រូលត្រួតពិនិត្យដោយខុសច្បាប់។

## ៣.២. គោលការណ៍សីលធម៌ខ្មែរសម្រាប់គ្រួសារ

តាំងពីអតីតកាល មនុស្សជាតិដែលរស់នៅក្នុងលោកនេះតែងប្រាថ្នាចង់បានជីវិតរស់នៅប្រកបដោយសុភមង្គល។ វប្បធម៌បុព្វកាលបានចាប់បង្ខំឱ្យមនុស្សទទួលយកទំនៀមទម្លាប់ប្រពៃណី ដែលមានមូលដ្ឋានផ្អែកលើសាសនា និងជំនឿផ្សេងៗ ដើម្បីរក្សាសណ្ដាប់ធ្នាប់ សន្តិសុខ និងវិបុលភាពសម្រាប់សហគមន៍ គ្រួសារ និង បុគ្គល។ ដំណាក់កាលបន្តបន្ទាប់ វប្បធម៌ដែលមានមូលដ្ឋានជំនឿសាសនា ត្រូវចុះថមថយ ឥទ្ធិពល ដោយជំនួសបន្តិចម្តងនូវគោលការណ៍សីលធម៌ប្រកបដោយហេតុផលនៃវិចារណញ្ញាណ។ ទោះយ៉ាងណា ក៏គោលការណ៍ទាំងនោះនៅតែ ពឹងផ្អែកលើទម្រង់នៃសាសនានានា ដើម្បីមានអានុភាពក្នុងការប្រតិបត្តិដដែល ព្រោះប្រព័ន្ធច្បាប់សង្គមមិនទាន់មានសុពលភាពខ្លាំងក្លាគ្រប់គ្រាន់នៅឡើយ។ នៅពេលដែលច្បាប់សង្គម ឬច្បាប់រដ្ឋកាន់តែមានសុក្រិត្យភាពដោយបានបញ្ចូលគោលការណ៍សីលធម៌សំខាន់ៗនោះ សីលធម៌សម្រាប់សង្គម ក៏ដូចសីលធម៌សម្រាប់គ្រួសារហាក់ដូចជាបាត់តម្លៃរបស់ខ្លួនព្រោះនៅក្នុងគោលការណ៍ សីលធម៌ខ្វះប្រត្យក្សភាពក្នុងការកំណត់ទោសទណ្ឌដល់ជនល្មើស។

មនុស្សជាតិជាទូទៅតែងតែមានគ្រួសារ ឬដៃគូដើម្បីបន្តពូជពង្ស និងយឹតយោងគ្នា រួមសុខទុក្ខជាមួយគ្នា ដូចដូនតាខ្មែរពោលថា៖ ស្រីប្រុសទាំងទ្វី ជាគូមានពីបុរាណព្រេងនាយ ស្រីជាប្រពន្ធ ប្រុសទោះសម្មាយបណ្ឌិតទាំងឡាយឲ្យឈ្មោះថាប្តី។ ស្ត្រី និងបុរសក្នុងលោកទាំងអស់ ភរិយាស្វាមី គឺប្តីប្រពន្ធ ហ្នឹងឯងលោកស្ដីជនក្នុងលោកីយ៍ ហៅបានតាមថ្នាក់។ ប្តីជាអ្នករកទ្រព្យធនបានមកប្រពន្ធទុកដាក់ ចាស់ទុំបុរាណ បានពោលបញ្ជាក់ឲ្យនាងឲ្យអ្នកចងចាំគ្រប់ប្រាណ។ សំណាបយោងដីវឹង ស្រីៗយោងប្រុសសាមាន្យទោះមារយាទខ្សោយក៏ដោយបើបានស្រីមានសន្តានខ្ជាប់ខ្ជួនមួនមាំ។ តែងបានចម្រើនទ្រព្យាកើតកើនព្រោះ ស្រីថែទាំ ចាត់ចែងទុកដាក់ ចេះលាក់សន្សំសង្វាត ខិតខំរក្សាឲ្យគង់។ល។

នៅក្នុងសង្គមខ្មែរ មុននិងអំឡុងពេលដែលបារាំងចូលមកធ្វើជាអាណាព្យាបាលនិងអាណានិគមន៍លើខ្មែរនោះក្បួនសីលធម៌ដែលគេហៅថាច្បាប់ក្រម បានដើរតួសំខាន់សម្រាប់ទូន្មានកូនខ្មែរ។ ច្បាប់ទាំងនោះមានច្បាប់ប្រុស ច្បាប់ស្រីច្បាប់ក្រមៗល។ រហូតមកដល់បច្ចុប្បន្ន ច្បាប់ទាំងនោះនៅតែមានតម្លៃ ជាកេរមរតកវប្បធម៌មួយសម្រាប់សង្គមខ្មែរ ទោះបីមានការ

រិះគន់ខ្លះពីឥទ្ធិពលនៃវប្បធម៌បស្ចិមប្រទេសក៏ដោយ។

### ៣.២.១. ច្បាប់ប្រុស

ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ដូរមើលថៃ
ជួន ទោះទ្រព្យរបស់ខ្លួន ឲ្យសួរកូនសួរប្រពន្ធ។
កុំអាងឯងជាប្រុស    ចាយរបស់មិនគិតគន់
មិនដឹងដល់ប្រពន្ធ    ព្រមព្រៀងគ្នាឥតបើថា។
ទោះបីបើបងប្អូន    ពឹងរកខ្លួនទៅណាៗ
ទោះទៅលេងឥតការ    ឥតគេរកដើរឆ្ងាយជិត។
ឲ្យប្រាប់អ្នកនៅផ្ទះ    កុំរលះឥតគំនិត
គេភ័យព្រួយចិត្តគិត    ព្រោះមិនដឹងជាទៅណា។
កូនអើយបាកុំធ្លោយ    កុំធ្លាយឲ្យអាប់កេរ្តិ៍យស
ធម្មតាកើតជាប្រុស    ឲ្យរករៀនច្បាប់មាត្រា។
លោកថាហៅធ្លួតបី    មួយធ្លួតស្រីមួយធ្លួតស្រា
មួយធ្លួតល្បែងពាលា    លេងបៀរប៉ោធួកំតាត់។

### ៣.២.២. គតិ ៥យ៉ាង សម្រាប់បុរសជាប្ដី

ប្ដីមកពីពាក្យបតិ(ម្ចាស់;ប្រុសជាម្ចាស់ផ្ទះ គឺបុរសជាគូគ្នានឹងស្ត្រីជាភរិយា)ប្រុស ជាគូគ្នានឹងស្រីជាប្រពន្ធ។ ព្រះបាទសម្ដេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ (ព្រះ អង្គដួង) ថ្លែងអំពីគតិ៥យ៉ាង ដែលបុរសជាប្ដីត្រូវប្រតិបត្តិចំពោះស្ត្រីជាប្រពន្ធដូចតទៅនេះគឺៈ មួយគឺហៅប្ដីឲ្យប្រើសំដី នឹងប្រពន្ធមាន ពាក្យទន់ពីរោះ ស្មើស្មោះដោយក្សាន្ត សរសើររាប់អានតាមសព្វវាចា។ មួយគឺប្រពន្ធខុសត្តង់ស្រាលធូន់ កុំជេរផ្ដាសាទាត់ធាក់ដៀលដំដូចខ្ញុំ អាត្មាកុំស៊ីដើមថាឲ្យឮសាយស័ព្ទ។ មួយគឺបានធនប្រគល់ប្រពន្ធទុកដាក់រណ្ដាប់ ទាំងគ្រឿងអាហារជាការស្រីផ្ដាប់រៀបចំសម្រាប់ថៃទាំរក្សា។ មួយគឺកុំផ្ចង់កុំខំតែបង្កើតកូនហើយថា ប្រពន្ធសុខចិត្តឲ្យគិតប្រាថ្នារួសរកទ្រព្យាសម្រាប់ឲ្យផង។ មួយគឺឲ្យចាប់ស្រឡាញ់ឲ្យខ្ជាប់កុំជិនណាយហោង បើមានប្រពន្ធទៀតកុំប៉ុនប៉ង ស្រឡាញ់ស្នេហ៍ស្នងឲ្យស្មើមុខឡើយ។ សម្ដែងសេចក្ដីគ្រប់ប្រាំវិធីថែងចប់ស្រេចហើយឲ្យអស់ប្រុសផងចាំចងជាត្រើយ ផ្ចង់កុំកន្តើយចោលច្បាប់បុរាណ។ បើប្រុសឯណាពុំផ្ចង់ចិន្ដា ដូចធម៌ទូន្មាននៅនឹងភរិយាគ្មានជាសុខសាន្តហិនហោចធនធានទាស់ទែងលែងគ្នា។ ឯវិស័យចិត្តអស់ស្រីផងពិតមានប្ដីប្រាថ្នាអំពើទាំងប្រាំ នេះចាំចិន្ដាគ្រប់ចិត្តភរិយានៅនាលោកិយ។ បើខ្វះអំពើណាមួយហើយតើប្រពន្ធថាប្ដីចិត្តពុំត្រូវត្រង់ពុំគង់មេត្រី តូចចិត្តស្វាមី អាក់អន់ពុំស្មោះលោកឲ្យប្រុសផង គន់គិតស្ងួនគ្រង ផ្ចង់ចិត្តសង្គ្រោះប្រពន្ធឲ្យពិតដោយក្រឹត្យប្រាំនោះ ប្រពន្ធក៏ស្មោះចិត្តចូលមូលឯង។ កុំគិតតែយកប្រពន្ធបានមកគ្រាន់ឱបប្រលែងបង្កើតតែកូន សោះសូន្យធនធេង លោកឲ្យគិតក្រែងដំណៀលនិន្ទា។ ធម្មតាជាប្ដី បានទ្រព្យធនអ្វីឬយសសក្ដា តែងនៅសុខសឹងទីពឹងផងគ្នា ព្រោះដ្បិតភរិយា

កាន់ក្តីសុចរិត។ អំពើច្នេះហោងឲ្យអស់ប្រុសផង ចងចាំក្នុងចិត្តតាមធម៌ទូន្មានគ្រប់ប្រាណប្រុស ពិតទុកជាក្រមក្រិត្យច្បាប់ច្បាស់តទៅ។ អង្គអញរចនា សេចក្តីកាព្យាតាមច្បាប់ទុកនៅក្នុងព្រះបាលីសេចក្តីជ្រាលជ្រៅពុំហ៊ានសៅដៅលើកលែងផាយដាយ។ ឧស្សាហ៍ខំប្រុងប្រែរករើសក្នុង គម្ពីរនិកាយអដ្ឋកថា ដីកាបរិយាយនិបាតទាំងឡាយមកផ្សំស្រដី។ ជាច្បាប់ទុកតដំណឹងតំណដំណើរស្ត្រីឲ្យជាក់ប្រាកដដោយបទបាលីគ្រាន់អស់ប្រុសស្រី រើសរៀនរកផ្លូវ។ ច្បាប់នេះប្រសើរដំណឹងដំណើរទំនងនេះគួរជាច្បាប់ប្រាកដដោយបទត្រឹមត្រូវ គួរយើងឥឡូវ ប្រតិបត្តិរក្សា។ គួររៀនឲ្យស្ទាត់ឲ្យចាំរត់មាត់ដាក់ក្នុងចិន្តាគ្រាន់នឹងប្រិតប្រៀនបង្រៀនអាត្មាតាមដោយគាថា នេះឯងតទៅ។

### ៣.២.៣. ច្បាប់ស្រី (សុចរិត៨ ប្រការជាមង្គលរបស់ស្រី)

ច្បាប់ស្រីជាព្រះរាជនិពន្ធនៃព្រះបាទសម្តេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ (ព្រះអង្គដួង) ថ្លែងអំពីសុចរិត ៨ ប្រការជាមង្គលរបស់ស្រី ដូចតទៅ[៦៦]៖

នេះនឹងសម្តែងបរិយាយ ចារចែងដើមបទអដ្ឋាហិ ឋានេហិ សុចរិតា ឥត្ថីលក្ខណា មង្គលច្នេះពិត។ ប្រែថាស្រីជា កើតកបលក្ខណា ដោយនូវសុចរិត មង្គលប្រាំបី ឲ្យស្រីពិនិត្យចាំយកជាក្រឹត្យ គ្រប់រូបស្រីៗ។ ដើមបទព័ណ៌នា លោកថាស្រីជា សុចរិតកក្តី ឫករាបស្រគត់ ផ្គង់ផ្គត់សម្តី ការកេរ្តិ៍ខ្មាសស្រី បរិសុទ្ធមែនមួនៗ លោកថាស្រីត្រង់ កាន់សុចរិត ផ្គង់គំនិតចេះស្ងួន អស់ទ្រព្យសម្បត្តិ ប្រយ័ត្នថែធួន ទុកដាក់ខ្ជាប់ខ្ជួន មិនមានប្រមាទ។

លោកថាស្រីគាប់ កាន់សុចរិតខ្ជាប់ ឧស្សាហ៍សង្វាត ធ្វើការសន្សំ គៀនខ្ញុំឲ្យឃ្នាត ឲ្យខ្មីសង្វាត មិនមានស្បៀមដៃ។ លោកថាស្រីប្រាជ្ញ សុចរិតអង់អាច ចេះអធ្យាស្រ័យញាតិព្រៀងទៅមករាប់រកសួរសៃ ទោះជនដទៃ ក៏រាប់តាមពិត។ លោកថា ស្រីស្អាត សុចរិតគ្មានឃ្វាតមែនមានគំនិត ចេះរៀបអាហារ ភ្នាក់ងារស្រីពិតរណ្តាប់ផ្គាប់ចិត្តប្តីគ្រប់វេលា។ លោកថា ស្រីស្មោះ កាន់សុចរិតឆ្ពោះ ចាំចិត្តស្នេហា តែនឹងអង្គប្តី ឥតបីរេរា ស្ម័គ្រស្មោះស្មើជានិត្យនៅរៀបរៀង។ លោកថា ស្រីស្លូត សុចរិតរហូតអបអត់ឥតល្បៀងតាមពាក្យប្តីផ្តាំចងចាំទុកទៀង ពោលពាក្យមិនឃ្មៀងមិនឃ្វាតសត្យា។ លោកថា ស្រីស្មើ សុចរិតស័រពើ អាចរងជានាទម្ងន់ ចិត្តប្តីទោះបីទុក្ខា ខ្សត់ក្រម្តេចម្តាអាចទទួលប្រាណ។ សុចរិតប្រាំបីជាមង្គលស្រី

[៦៦] ជួន ណាត *វចនានុក្រមខ្មែរ* ការផ្សព្វផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ ទំព័រ ៩២៣។

ប្រសើរក្រមាន អ្វីមកផ្ទឹមផ្ទាល់ឲ្យដល់នេះបាន ស្រីណាអាចធ្យាន ចិត្តចាំរៀនយក៍។ ទាំងប្រាំបីច្បាប់ ហៅស្រីមហាគាប់ លោកីយ៍កម្រ ស្រីកាន់សុចរិត ប្រព្រឹត្តល្អិតល្អ ស្រីណាថាក្រធ្វើតាមពុំបាន។ លោកថា ស្រីនោះចិត្តអាក្រក់ស្មោះ ស្អប់ដំបូន្មាន ផ្សាដោយសារចិត្ត ទុច្ចរិតសន្តាន បង្ហិនធនធាន បើកអាសមាយា។ ក្តីជួប្រើនកល ក្រដឹងចេះដល់លែប ខាយពុតវា បើចិត្តចង់ស្រាប់ ចង់ស្តាប់ហាក់ជាង៉ាយដាយសោះសា ចេះឯងដឹងឯង។ ឯត្រង់ច្បាប់ល្អ តិចទេយល់ក្រ កម្រក្រៃលែងក្រព្រោះមិនចង់ ប្រុងអង្គឲ្យស្ដែង ក្រដោយចិត្តល្បែងចំណង់តណ្ហា។ អំពើសុចរិត អធ្យាស្រ័យចិត្ត សម្អាតឧស្សាហ៍ ស្មើស្មោះស្លូតត្រង់ ផ្គត់ផ្គង់ក្រឹត្យាប្រាំបីនេះណា សុចរិតប្រាកដ។ ឯសុចរិតស្រី ផ្គត់ផ្គង់ស្វាមី លោកឲ្យអត់ឱនអៀនចិត្តទន់ចេះគន់បែបបទ តាមតែចិត្តពត់ម្ដេចៗតាមបាន។ មិនមានប្រកែក មិនមានជជែក ថាធ្វើមិនបាន ទោះអៀនអន់អត់ សង្កត់ចិត្តប្រាណ តាមចិត្តប្ដីធ្យាន ម្ដេចៗមិនថា។ ច្បាប់នេះគួរស្រី នៅនាលោកីយ៍ផ្ចង់ចិត្តឧស្សាហ៍ កាន់ក្ដីសុចរិតជាក្រឹត្យថ្លៃថ្លាឲ្យខ្ជាប់ជាក់ជាចរិតសព្វថ្ងៃ។កាន់បានដូច្នោះ នឹងព្មកេរ្តិ៍ឈ្មោះប្រសើរពេកក្រៃ នឹងបានសាន្តសុខចៀសទុក្ខចង្រៃដល់បរលោកថ្ងៃ សោយសុខសួគ៌សិទ្ធ។ សំដែងសេចក្តីពីមង្គលស្រី ប្រសើរពេកពិតគ្រប់ទាំងប្រាំបីក្រឹត្យស្រីសុចរិតចែងចប់ភាសិតតាមព្រះបាលី។

### ៣.២.៤. ប្រភេទប្រពន្ធ

ប្រពន្ធ (មកពីពាក្យប្រ+ពន្ធ; បា.ប+ពន្ធ "ជាប់ជំពាក់ ចំពាក់ធ្លាក់ ដែលចងរឹតរួត ចំណងចងធ្លាក់រឹតរួត") ប្រពន្ធគឺស្ត្រីជាចំណង គូនឹងបុរស (ភរិយា)។ ព្រះអង្គដួង កាព្យថ្លែងអំពីប្រពន្ធមាន៧ប្រភេទល្អបួនអាក្រក់បី ដូចតទៅ[១៧]៖ នេះគឺ មួយសោតព្រះពុទ្ធ ទេស្នាចំហុតថាវីភរិយា មានប្រាំពីរស្មោះបួននោះចិត្តជាបីនោះមោហាចិត្តខូចង៉ាយដាយ៖ ឯប្រពន្ធជាឯកឈ្មោះមាតាភរិយាដូចម្ដាយ ឈឺឆ្អាលកូនខ្លួន វែងសួនមិនណាយ មិននឹករសាយ ចិត្តចាំអាណិត។ កូនទុក្ខទោសម្ដេច ខ្សត់ក្រច្រើនតិច ខឹងខុសខូចចិត្ត ព្រាត់ប្រាស់យូរលង់ពុំបង់បែកចិត្ត គង់ចាំចិត្តគិត ឈឺឆ្អាលកូនស្មោះ។ ប្រពន្ធណាគាប់ ឈឺឆ្អាលប្ដីខ្ជាប់ ចិត្តចាំកាន់កោះ ដូចម្ដាយស្រឡាញ់កូនពេញពីពោះ ហៅប្រពន្ធនោះ ថ្លៃឥតផ្ទឹមដល់។ ប្រពន្ធជាទី ឈ្មោះហៅទាសីភរិយាដូចកល់ខ្ញុំនឹងអម្ចាស់ប្រើណាស់ខ្វាយខ្វល់អាចមត់ទប់ទល់ទម្ងន់បម្រើ។មិនមាន ទំនេរ ទោះម្ចាស់វាយជេរ អត់ឱនស័រពើតាមតែបង្គាប់ប្រញាប់ចង់ធ្វើ

---

[១៧] ជួន ណាត, *វចនានុក្រមខ្មែរ*, ការផ្សព្វផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ ១៩៦៧ ទំព័រ ៤១០

ចិត្តពុំសើរើ ចៀសវាងក្រោធា។ ប្រពន្ធណាអត់ឱនអង្គអំណត់ ខ្លាចប្ដីអាត្មា ដូចខ្ញុំនឹងម្ចាស់ខ្លាចណាស់ជានាប្រពន្ធនោះជាប្រសើរសុខសូន្យ។ ប្រពន្ធជាត្រី ឈ្មោះភគិនី-ភរិយាដូចប្អូនស្រឡាញ់បងពិតលំអិតលំអូនទទួលដំបូន មានមាត់ពាក្យបង។ ផ្ដាច់ផ្ដួលតែមួយនឹងចងជាត្រួយចិត្តចាំបំណង ពំនាក់ពំនឹងពាក់ពឹងប៉ុនប៉ងតែនឹងអង្គបងឥតម៉ែទីទៃ។ ប្រពន្ធណាចូលនឹងប្ដីមួយមូលចិត្តជាប់អាល័យ ដូចប្អូននឹងបងចាំចងអាស្រ័យ ប្រពន្ធនោះថ្លៃមធ្យមពេកពិត។ ប្រពន្ធចត្វាឈ្មោះហៅសខាភរិយាដូចមិត្រ សំឡាញ់ស្រឡាញ់ អស់អញពេកពិត ស្មើខ្លួនស្មើចិត្ត ស្ម័គ្រស្មោះចិន្តា ។ បើមិត្រទៅបាត់ ស្ងប់ស្ងួតមុខមាត់ ទុក្ខទន់ទយា ឃើញមុខមកបាន ចិត្តក្សាន្តសោះសា ស្រស់ស្រួលកក្រ្កា និរទុក្ខសោកសៅ។ ប្រពន្ធណាចិត្ត ស្រឡាញ់ប្ដីពិត គ្មានក្នុងគ្មានក្រៅ ដូចមិត្រនិងមិត្រ ចងចិត្តជាប់នៅ ប្រពន្ធនោះហៅ ឧត្តមក្រមាន ។ សម្ដែងភរិយាទាំងបួនសឹងជា ក្រស្រីធ្វើបាន បើស្រីណាគិតផ្ចង់ចិត្តសន្ដាន ស្រឡាញ់ប្ដីប្រាណ ដូចធម៌ទេសនា ។ លោកថាស្រីនោះ ព្ទកេរ្ដិ៍ពីរោះ ទូទៅនានា បើអស់ជីវិត នៅឋិតសួគ៌ា ចៀសចាកចតុរា-បាយបាបទុក្ខភ័យ។ ប្រពន្ធពុំជាឈ្មោះវធកា-ភរិយាដូចនៃសត្រូវចាំចងទោសផងសព្វថ្ងៃ ប្រពន្ធចង្រៃ ប្ដីមានតែទុក្ខ បើប្ដីខុសចិត្ត វាគ្មានអាណិត ខេរខឹងប្រអុក ចាំចងទោសប្ដី ស្រដីកិកកុកឲ្យមាត់ឲ្យមុខ វាសវាងភ្លេះភ្លើយ។ សុខទុក្ខសាំទាំ វាមើលបំណាំ នៅស្មៀមព្រងើយ ពុំជួយទុក្ខភ័យ ដោះដៃកន្តើយ ស្លាប់ដោយរស់ដោយគ្មានចិត្តមេត្រី។ ចោរីភរិយា ប្រពន្ធពុំជា លបលួចទ្រព្យប្ដី គ្មានចិត្តករុណា មេត្តាប្រណី របស់ទ្រព្យអ្វី លក់ចាយអស់ធួន។ អយ្យាភរិយា ប្រពន្ធពុំជាតម្កើងតែខ្លួន ចេះតែប្រើប្ដី ឥតបីមានសួត ធ្វើឫកណាំនួន ទុកប្ដីដូចខ្ញុំ។ ប្រពន្ធទាំងបី ធ្លាក់ទៅអវិចី វេងទុក្ខដំណំ ក្នុងខ្ទះភ្លើងក្ដៅ យូរនៅក្រៀមក្រំ ព្រោះចិត្តខ្លួនធំ ជាងប្ដីអាត្មា។ ឯប្រពន្ធបួនមុខនោះគួរសួន យកជាភរិយា នឹងកើតរបស់កេរ្តិ៍យសសក្កា ថ្កើងពូជពង្សា សោយសុខថេរឋិត។ សំដែងបរិ យាយ ភរិយាទាំង ឡាយ ប្រាំពីរចរិតទាំងជួទាំងជាពណ៌នាពោលពិត ចែងចប់ពិនិត្យតាមអត្ថគាថា។ គួរទន្ទេញឲ្យចាំមាត់ឬបង្គាប់កូនចៅតូចៗឲ្យទន្ទេញចាំស្ទាត់ ហើយឲ្យនាំគ្នាសូត្ររឿយៗ ដើម្បីរំលឹកគ្នាក្នុងគ្រួសារ ក៏ជាការប្រពៃណាស់)។

ច្បាប់គតិយុត្តិ និង គោលការណ៍សីលធម៌សម្រាប់គ្រួសារ មានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ជួយបង្ការទប់សង្កាត់ និងជម្រុញជនប្រុសស្រីឱ្យលះបង់អំពើអាក្រក់និងធ្វើការងារដើម្បីសេចក្ដីរីកចម្រើនក្នុងគ្រួសារ ក៏ដូចនៅក្នុងសង្គមជាតិទាំងមូល។ ជាធម្មតាមនុស្សមាន

ការដឹងខុសត្រូវចង់បានសេចក្ដីថ្លៃថ្នូរដោយសារមានសតិគ្រប់គ្រាន់។ ប៉ុន្តែទោះមានទ្រឹស្ដីក្បួនច្បាប់ជួយអប់រំឃុំគ្រងយ៉ាងណាក៏ដោយ ក៏មនុស្សក្មេងចាស់ប្រុសស្រីនៅតែភ្វាត់ប្រព្រឹត្តិកំហុសដោយចេតនា ឬអចេតនាដែរ ដោយសារឥទ្ធិពលនៃកត្តាផ្សេងៗ។ កត្តាទាំងនោះធ្វើឱ្យមនុស្សទៅជាឆ្កួត វិកលចរិតឬខូចចរិត។ កត្តាឆ្កួតមានច្រើនយ៉ាង ដូចជា កាមុម្មត្តកៈ ឆ្កួតកាម; ចិត្តុម្មត្តកៈ ឆ្កួតចិត្ត; ទិដ្ឋុម្មត្តកៈ ឆ្កួតទិដ្ឋិ; បិតុម្មត្តកៈ ឆ្កួតប្រមាត់; យក្ខុម្មត្តកៈ ឬបិសាចុម្មត្តកៈ ឆ្កួតព្រោះខ្មោចចូល; សុរុម្មត្តកៈ ឆ្កួតស្រា; អក្ខធុត្តុម្មត្តកៈ ឆ្កួតល្បែងស៊ីសង; អបាយមុខុម្មត្តកៈ ឆ្កួតអបាយមុខ; ឥត្ថុម្មត្តកៈ ឆ្កួតស្រី ជាដើម។ ការខូចចរិត របស់មនុស្សនាំឱ្យមានការប្រព្រឹត្តិអំពើអសីលធម៌ក្នុងសង្គម និងបណ្ដាលឱ្យតម្លៃសីធម៌ធ្លាក់ចុះ។ ចំពោះគ្រួសាខ្មែរបច្ចុប្បន្ន តើការប្រតិបត្តិសីលធម៌ មានសភាពលក្ខណៈដូចម្ដេចខ្លះ?

## ៤. ការប្រតិបត្តិសីលធម៌ក្នុងគ្រួសារខ្មែរបច្ចុប្បន្ន

គ្រួសារ គឺជាក្រុមមួយដែលមានសមាសភាពប្ដី ប្រពន្ធ កូន និងជាយថាហេតុមានសមាជិក ញាតិវង្ស ដែលមករួមរស់ក្នុងផ្ទះជាមួយគ្នា។ គ្រួសារ គឺជាការសិកានៃសង្គម ជាអ្នកជានាប៉ាប់រងបង្កើតជានិរន្តនៅពូជពង្សមនុស្ស។ ក្រុមគ្រួសារជាអ្នកធានាប៉ាប់រងធ្វើឱ្យបុគ្គលទាំងឡាយចូលរួមក្នុងជីវិតភូមិសាស្ត្រ និងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ,គ្រួសារ គឺជាការដង្ហើមស្ងាប់រស់នៃសង្គម។ សង្គមអន់ថយ ឬរីកចម្រើនក៏អាស្រ័យលើឥរិយាបថនៃសមាជិកគ្រួសារដែរ។ ផ្ទុយមកវិញ សង្គមក៏មានឥទ្ធិពលយ៉ាងខ្លាំងទៅលើគ្រួសារវិញដែរ។ បើសង្គមអាប់អួ ឬរីកចំរើន នោះគ្រួសារក៏ទទួលភាពអាប់អួ ឬរីកចំរើនទៅតាមនោះដែរ។

ក្នុងអតីតកាលសង្គមខ្មែរធ្លាប់មានអារ្យធម៌ខ្ពង់ខ្ពស់, ប្រទេសជាតិសម្បូរណ៍ស្ដុកស្ដម្ភថ្កុំថ្កើងរុងរឿង, មានកិត្យានុភាពល្បីរន្ទឺ,ជាអាណាចក្រដែលមានទឹកដីទូលំទូលាយ។ បន្ទាប់មកក្នុងអំឡុងពីរទសវត្សចុងក្រោយ សង្គមខ្មែរដោយសារទទួលរងឥទ្ធិពលនៃការប្រកួតប្រជែងមនោគមវិជ្ជានយោបាយ នៃប្រទេសជឿនលឿនខាងសេដ្ឋកិច្ចឧស្សាហកម្ម បានធ្លាក់ខ្សិនថយ វិនាសអន្តរាយយ៉ាងដំណំ។ របបខ្មែរក្រហមបន្សល់ទុកនូវការព្រាត់និរាស្ត្របែកបាក់យ៉ាងធំធេងដល់គ្រួសារខ្មែរ។ កុមារកំព្រាស្ត្រីម៉េមាយ បុរសពោះម៉ាយ មនុស្សចាស់ជរាគ្មានទីពឹង មនុស្សបាក់ទ្រុឌទ្រោមកម្លាំងកាយសតិស្មារតីមិនហ្នឹងហ្ន គឺជាបន្ទុកដ៏ធ្ងន់សម្រាប់សាធារណរដ្ឋប្រជាមានិតុកម្ពុជា និងរដ្ឋកម្ពុជា ហើយផលវិបាកទាំងអស់នេះ នៅតែជាវិបត្តិ

បន្តសម្រាប់គ្រួសារខ្មែរបច្ចុប្បន្ន។ ការបំបាត់សាលារៀន មិនឱ្យតម្លៃលើការសិក្សាមេរៀនទ្រឹស្តី, មិនឱ្យតម្លៃសញ្ញាបត្រ ឱ្យតម្លៃតែសញ្ញាឃើញបង្ខំឱ្យពលកម្មជាទាសករ ពួកកុម្មុយនីស្តិខ្មែរក្រហមបានបង្អត់អាហារ និងវាយកាប់សម្លាប់ និងអ្នកចេះដឹង បញ្ញាវន្ត ធនធានមនុស្ស និងបំផ្លិចបំផ្លាញសៀវភៅ ឯកសារក្បួនច្បាប់ ទំនៀមទម្លាប់ ប្រពៃណីវប្បធម៌ ស្ទើរគ្មានសល់។ អ្នកដែលនៅរស់រានមានជីវិតពីរបបអប្រិយ៍នេះ បានស្តារជីវភាពគ្រួសារយ៉ាងតោកយ៉ាក។ ម្នាក់ៗគិតតែរឿងស្តារសេដ្ឋកិច្ចគ្រួសារ និងបន់ស្រន់កុំឱ្យរបបនេះវិលត្រឡប់ជាថ្មីម្តងទៀត។ ដោយខ្វះពេលាម្រាប់អប់រំសិក្សារៀនសូត្រ និងខ្វះអ្នកចេះដឹង ខ្វះគ្រូជំនាញ ខ្វះការអាន ខ្វះការទទួលបានព័ត៌មាន ធ្វើឱ្យពលរដ្ឋខ្មែរភាគច្រើនយល់ដឹងមិនបានគ្រប់គ្រាន់អំពីមរតកវប្បធម៌របស់ខ្លួនឡើយ ។

នៅក្រោយកិច្ចព្រមព្រៀងក្រុងប៉ារីស្ត ឆ្នាំ១៩៩៣ ខ្មែរបានរួបរួមគ្នាដើម្បីឯកភាពជាតិជាមួយបណ្តាភាគីជម្លោះខ្មែរទាំងអស់ក្រោមរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យសេរីពហុបក្ស ប៉ុន្តែជាអកុសល ការមិនទុកចិត្តគ្នាបានកើតមានពាសពេញសង្គមខ្មែរទាំងមូល ទាំងក្នុងក្រុមការងារបក្សពួកនយោបាយ ក្រុមគ្រួសារ និងក្រុមញាតិមិត្ត ដោយសារតែទំនាស់ និងភាពអាត្មានិយម តួឯកនិយម។

បច្ចុប្បន្ន កម្ពុជាការពារបាននូវសន្តិភាព ១០០% ប៉ុន្តែដោយឥទ្ធិពលនៃការមិនទុកចិត្តគ្នានេះ បណ្តាលមានការលំបាកដល់ល្បឿនអភិវឌ្ឍន៍ និងការស្តារកេរ្តិ៍ឈ្មោះមុខមាត់នៃព្រះរាជាណាចក្រអច្ឆរិយៈនៅលើឆាកអន្តរជាតិផងដែរ។ ការអនុវត្តច្បាប់តាមប្រព័ន្ធតុលាការក្នុងការដោះស្រាយបញ្ហាសន្តិសុខសណ្តាប់ធ្នាប់ក្នុងដំណាក់កាលបច្ចុប្បន្នគឺជាយន្តការដើម្បីកាលានុវឌ្ឍនភាពមួយដែលចាំបាច់សម្រាប់អត្ថិភាពសុខដុមនីយកម្មសង្គមខ្មែរទាំងមូល។

## ៤.១. តស្តុតាងខ្លះនៃទំនាស់និងអំពើហិង្សាក្នុងគ្រួសារ

សីលចរិយាទូទៅតម្រូវឱ្យសមាជិកគ្រួសារម្នាក់ៗគោរពករណីយកិច្ចរបស់ខ្លួនដូចជាប្តីប្រពន្ធ ឪពុកម្តាយ កូន បងប្អូនប្រុសស្រី ត្រូវតែបំពេញសីលកាតព្វកិច្ចតាមមុខងារ តួនាទីរៀងៗខ្លួន។ បើប្តីប្រពន្ធមិនបានបំពេញបានត្រឹមត្រូវតាមនិយាមសីលធម៌ទេ ទំទាស់និងអំពើហិង្សានឹងអាចកើតមានឡើង។ អំពើអសីលធម៌ទាំងនេះប្រឈមនឹងការរិះគន់មើលងាយមិនឱ្យតម្លៃពីមហាជនក្នុងសង្គម។

ទំនាស់ និងអំពើហិង្សាគឺជាអំពើអសីលធម៌ ដែលតែងកើតមានឡើងជារឿងៗ ជាធម្មតាក្នុងសង្គមគ្រួសារ ព្រោះថាចានក្នុងរាវតែងមានរណ្តំ ឬអណ្តាតនៅជាមួយធ្មេញលែងអីប៉ះទង្គិចគ្នា។ អំពើអសីលធម៌ គឺជាសកម្មភាពទាំងឡាយដែលផ្ទុយពីសីលនិយាមនិងការព្រងើយកន្តើយចំពោះសីលកាតព្វកិច្ចដែលធ្វើឱ្យអ្នកដទៃមិនពេញចិត្ត ឬធ្វើឱ្យគេទទួលរងនូវការឈឺចាប់។ អំពើហិង្សាក្នុងគ្រួសារ គឺជាឥរិយាបទនៃការប្រព្រឹត្តិអសីលធម៌នៃសមាជិកគ្រួសារ មានប្តីប្រពន្ធ ឪពុកម្តាយ កូន បងប្អូនដែលនៅក្នុងបន្ទុកគ្រួសារ។ ក្នុងសង្គមខ្មែរ អំពើអសីលធម៌ក្នុងគ្រួសារ ភាគច្រើនពាក់ព័ន្ធនឹងអំពើហិង្សាខាងផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និង ផ្លូវសេដ្ឋកិច្ច។ ការរំលោភបំពានលើគោលការណ៍សីលធម៌ មិនប្រតិបត្តិវិន័យគ្រួសារក្នុងជីវិតអាពាហ៍ពិពាហ៍ ដោយបង្ហាញចរិកលក្ខណៈប្រមាថមាក់ងាយ ការរំលោភការបំពានការគំរាមគំហែងលើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច មកលើប្តីប្រពន្ធ ឪពុកម្តាយឬកូនតែងលេចឮសឹងតែរាល់ថ្ងៃនៅតាមបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម នានា។សូមដកស្រង់កស្តុតាងខ្លះៗអំពីអំពើហិង្សា ក្នុងគ្រួសារ ដែលមានលើប្រព័ន្ធផ្សព្វផ្សាយដូចតទៅ៖

**ក.ប្រពន្ធដើមប៉ូលិសស័ក្តិ៣ដែលមានស្រី ទាមទារអ្វីខ្លះពេលនេះ?** [១៨]

ស្ត្រីម្នាក់បានរៀបរាប់ថា ចាប់តាំងពីចាប់ដៃគ្នាជាប្តីប្រពន្ធមក ពួកនាងខិតខំធ្វើការងារគ្រប់បែបយ៉ាងដើម្បីគ្រួសាររហូតប្តីមានឋានន្តរស័ក្តជាលោកអនុសេនីយ៍ឯក(ស័ក្តបី)។ ប្តីគាត់យកប្លង់ដីទៅដាក់ខ្ចីលុយធនាគារឯកជនចំនួន១ម៉ឺនដុល្លារ ដើម្បីមើលជំងឺរបស់គាត់ លុះដល់មើលជំងឺជាហើយ បែរជាប្តីចុះចោលប្រពន្ធកូន យកលុយដែលនៅសល់ ទៅរៀបសែនព្រេនជាមួយគ្រូបង្រៀនម្នាក់ជាស្រីស្នេហ៍ធ្វើជាប្រពន្ធម្នាក់ទៀត។ រូបគាត់និងកូនពីរនាក់រស់នៅឯកការ និងរកលុយដោះបំណុលធនាគារឯកជន។

**ខ.ចាប់ខ្លួនម្ចាស់កាំភ្លើងខ្លីដែលឲ្យបុរសម្នាក់យកទៅបាញ់ប៉ុនប៉ងផ្តាច់ជីវិតគូស្នេហ៍**[១៩]

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ កម្លាំងសមត្ថកិច្ចនគរបាលខេត្តសៀមរាបបានធ្វើការស្រាវជ្រាវឈានដល់ការឃាត់ខ្លួនជនសង្ស័យម្នាក់ទៀត ពាក់ព័ន្ធករណីផ្តល់អាវុធឲ្យទៅបុរសម្នាក់យកទៅបាញ់ប្រហារ

[១៨] ប៉ុក សុខា, កោះសន្តិភាព, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០២ https://kohsantepheapdaily.com.kh/article/1153749.html

[១៩] ឃឹម ប៊ុនណាក់, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០២០, https://kohsantepheapdaily.com.kh/article/1197884.html

ប៉ុនប៉ងផ្តាច់ជីវិតគូស្នេហ៍វ័យក្មេង ដែលនាងទើបមានកូនស្រី១អាយុ៩ខែ។ តាមការបំភ្លឺពីជនរងគ្រោះថាមានការទំនាក់ទំនងស្នេហាជាមួយគ្នាតាំងពីអំឡុងឆ្នាំ២០១៧ រហូតដល់បច្ចុប្បន្នមានកូនស្រីម្នាក់ អាយុ៩ខែ។ ក្រោយមកដោយដឹងថា ប្តីហេងស៊ិយរបស់ខ្លួនមិនទាន់លែងលះប្រពន្ធ ដើមដាច់ស្រេច នាងក៏បានសុំប្តីហេងស៊ិយនោះបែកផ្លូវគ្នាជាច្រើនលើកមកហើយ។ នៅថ្ងៃទី២២ តុលា ឆ្នាំ២០២០ ជនល្មើស បានបើករថយន្តមួយគ្រឿងមួយគ្រឿងដឹករូបនាងនិងកូនៗ ក្រោយឮសម្លេងផ្ទុះអាវុធ នាងមានការឈឺចុកត្រង់ដើមទ្រូងខាងស្តាំនាងបានប្រតាយប្រតប់បើកទ្វាររថយន្តលោតចុះទៅលើថ្នល់ កៅស៊ូខណៈពេលរថយន្តកំពុងតែមានចលនាទៅមុខៗ ជនសង្ស័យឃើញ ដូច្នេះក៏បើករថយន្តថយក្រោយ ក្នុងគោលបំណងកិនរូបនាងឲ្យស្លាប់តែនាងបានលោតចុះទៅ ក្នុងទឹកប្រឡាយ ហើយជនសង្ស័យបានបើកទ្វាររថយន្តចុះ ហើយរត់ទៅធ្វើសកម្មភាពប្រតាយប្រតប់ និងច្របាច់កនាងភ្លាមនោះរូបនាងក៏បានស្រែកឱ្យគេឯងជួយពេលនោះ ក៏មានប្រជាការពារភូមិបានចូលទៅជួយនាងហើយជនសង្ស័យ ក៏បានរត់ឡើងរថយន្តបើកគេចខ្លួន ដោយនាំយកកូនស្រីនាងទៅជាមួយផងដែរ។ក្រោយចាប់ខ្លួនបានជនល្មើសឆ្លើយសារភាពប្រាប់សមត្ថកិច្ចថាខ្លួនពិតជាបានធ្វើសកម្មភាពដូចជនរងគ្រោះរៀបរាប់ខាងលើពិតប្រាកដមែន ដោយសារខ្លួនខឹងជនរងគ្រោះចេះតែទារប្រាក់ជាបន្តបន្ទាប់ ហើយគម្រាមថាបើមិនឲ្យប្រាក់នាងទេនោះនាង និងយកកូនស្រីទៅជួបប្រពន្ធដើមខ្លួន ដែលអាចទៅជាទំនាស់ឈានដល់ការលែងលះគ្នាទៀតផង។

### គ.ប្រពន្ធលេងល្បែងប្តីផឹកស្រាស្រវឹងកាលណាផ្ទះហិង្សាប្រាថ[២០]

ដោយសារឥទ្ធិពលសុរាលាយឡំជាមួយនឹងល្បែងស៊ីសង ធ្វើឲ្យកើតជាអំពើហិង្សា ។ ជាក់ស្តែង បុរសម្នាក់ខឹងប្រពន្ធទៅលេងបៀនៅផ្ទះគេ លុះពេលផឹកស្រាស្រវឹងដោកដាំក៏ទៅស្រែកជេរប្រមាថ និងវាយម្ចាស់ផ្ទះទៀត តែត្រូវម្ចាស់ផ្ទះវាយតបតវិញបណ្តាលឲ្យរងរបួស ។ ការវាយតប់គ្នានេះ សមត្ថកិច្ចក៏បានឃាត់ខ្លួនម្ចាស់ផ្ទះផងដែរ។ហេតុការណ៍នេះ បានកើតឡើងកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រមាណ៨និង៣០នាទីយប់ នៅភូមិត្រពាំងស្នាច់ ឃុំម្កាក់ ស្រុកអង្គ

[២០] ប៊ុនឆដា, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២០, https://kohsantepheapdaily.com.kh/article/1199529.html

ស្ដួល ។ បុរសដែលត្រូវម្ចាស់ផ្ទះវាយឲ្យរបួស មាន អាយុ៣៨ឆ្នាំ មុខរបរលក់ដូរ រស់នៅក្នុង ភូមិ ឃុំ ខាងលើ ។ ចំណែបុរសម្ចាស់ផ្ទះអាយុ ៤០ឆ្នាំ មុខរបរលក់ដូរដូចគ្នា ។ ចំពោះករណី នេះ សមត្ថកិច្ចបានចាត់ការតាមនីតិវិធី។

**ឃ.សង្ស័យមានទំនាស់ក្នុងគ្រួសារ ប្ដីប្រពន្ធបំផ្ទុះគ្រាប់បែកធ្វើអត្តឃាត**[២១]

នៅម៉ោងប្រមាណ២និង៥០នាទី ប្ដីប្រពន្ធបានសម្រេចចិត្តបំផ្ទុះគ្រាប់បែកធ្វើអត្តឃាត។ ហេតុការណ៍ដែលកម្រនេះ បានកើតឡើងនៅរសៀលថ្ងៃទី២១ ខែសីហានេះ ស្ថិតក្នុងភូមិពូទុង ឃុំចុងផ្លាស់ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ សមត្ថកិច្ចថាជនរងគ្រោះជាប្ដីប្រពន្ធ ដោយប្ដីមានអាយុ៣៧ឆ្នាំ មានស្រុកកំណើតនៅទឹកដីខេត្តព្រៃវែង និងប្រពន្ធអាយុ ៣២ឆ្នាំ មានស្រុកកំណើតខេត្តកំពង់ឆ្នាំង។

**ង.គ្មានខាងចា! សាងស្នេហ៍ថ្មី រៀបផែនការជាមួយប្រុសស្នេហ៍ផ្ដាច់ជីវិតប្ដីតាមផ្លូវ**[២២]

ស្ត្រីម្នាក់ដែលផិតប្ដីនិងប្រុសស្នេហ៍របស់ខ្លួន បានត្រូវសមត្ថកិច្ចឃាត់ខ្លួនបញ្ជូនទៅកាន់អយ្យការអមសាលាដំបូងខេត្ត ក្រោយពីពួកគេរៀបគម្រោងសម្លាប់ប្ដីតែមិនបានសម្រេច។ អ្វីដែលជាការហួសចិត្តបំផុតនោះ គឺក្រោយពីផែនការពួកគេមិនបានសម្រេច ក៏បានដឹកដៃគ្នាទៅសាងស្នេហ៍យ៉ាងផ្អែមល្ហែមនៅឯទីរួមខេត្តធ្វើព្រងើយ ហាក់បីដូចជាគ្មានរឿងអ្វីកើតឡើងអ៊ីចឹង។ ជនទាំង២នាក់ ត្រូវបានបញ្ជូនទៅកាន់សាលាដំបូងខេត្ត នៅល្ងាចថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ បន្ទាប់ពីសមត្ថកិច្ចស្រាវជ្រាវនិងឃាត់ខ្លួនកាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ នៅភូមិអង្គតាឯកឃុំភ្នំតូច ស្រុកឧដុង្គ។ ស្ត្រីដែលសមត្ថកិច្ចឃាត់ខ្លួននេះ អាយុ១៨ឆ្នាំ ចំណែកប្រុសស្នេហ៍អាយុ២០ឆ្នាំ។ ឯបុរសជាប្ដីដែលរួចផុតពីការរៀបគម្រោងសម្លាប់ពីសំណាក់ជនសង្ស័យទាំង២នាក់អាយុ ១៧ឆ្នាំ ។

**ច.អត់ឃើញម្ដាយ កូនស្រីសួររក តែឪពុកចុះថាទៅធ្វើការ លុះធុំក្លិនស្អុយទើបដឹង**[២៣]

ស្ត្រីម្នាក់បានបាត់បង់ជីវិតនៅក្នុងបន្ទប់ជួលមួយកន្លែងរហូតមានសភាពហើមស្អុយទៅហើយ ទើបត្រូវបានអ្នកភូមិនិងកូនស្រីដឹងថា បាត់បង់ជីវិត។ ពាក់ព័ន្ធនឹងករណីនេះគេ

[២១] ថ្ងៃ ពុធ ទី ២២ ខែ សីហា ឆ្នាំ ២០១៨, http://apsaracentral.com/article/2521

[២២] https://kohsantepheapdaily.com.kh/article/.1156568html

[២៣] យន់ ស៊ីថា (កែសម្រួលដោយធីតា), ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២០, https://kohsantepheapdaily.com.kh/article/1105135.html

មានការសង្ស័យថា ប្តីចុងរបស់ស្ត្រីរងគ្រោះជាអ្នកប្រព្រឹត្ត ព្រោះបន្ទប់មានចាក់សោរពីខាងក្រៅ ហើយប៉ុន្មានថ្ងៃមកនេះ បុរសជាប្តីនៅផឹកស៊ីក្នុងភូមិនោះរហូត លុះក្រោយពេលមានការភ្ញាក់ផ្អើលថា ស្ត្រីរងគ្រោះបាត់បង់ជីវិត ស្រាប់តែបុរសជាប្តីចុងនោះគេចខ្លួនបាត់តែម្តង។ ហេតុការណ៍ខាងលើនេះបានកើតឡើងកាលពីវេលាម៉ោង១១ព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ នៅបន្ទប់ផ្ទះជួលមួយកន្លែង ស្ថិតក្នុងភូមិគោកខ្សាច់ សង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ។ ស្ត្រីបាត់បង់ជីវិតខាងលើមានអាយុ៤៥ឆ្នាំ មុខរបរកម្មកររោងចក្រ មានទីលំនៅក្នុងភូមិជ្រួល ឃុំបាល័ង្គ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង និងស្នាក់នៅក្នុងបន្ទប់ជួលកើតហេតុខាងលើ ដោយមានប្តីចុងអាយុ៤២ឆ្នាំ មុខរបរកម្មករសំណង់។ អ្នកទាំងពីរបានទទួលយកគ្នាជាប្តីប្រពន្ធអស់រយៈពេល៣ឆ្នាំមកហើយ។ កូនស្រីរបស់ស្ត្រីរងគ្រោះបានឱ្យដឹងថា កន្លងមក ម្តាយរបស់នាង និងប្តីចុងបានស្នាក់នៅបន្ទប់ជួលមួយ ម្តាយនាងមិនសូវមានសេចក្តីសុខ និងសុភមង្គលនោះទេ ព្រោះតែឧស្សាហ៍កើតរឿងឈ្លោះប្រកែក និងវាយតប់គ្នាជាមួយបុរសជាប្តីចុងជាញឹកញាប់។ សូមបញ្ជាក់ថា កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ បុរសជាប្តីចុងខាងលើ ធ្លាប់ត្រូវសមត្ថកិច្ចឃាត់ខ្លួនពាក់ព័ន្ធនឹងករណីប្រើអំពើហិង្សាមកលើស្ត្រីរងគ្រោះជាប្រពន្ធផងដែរ។

### ឆ.ទំនាស់ក្នុងគ្រួសាររវាងម្តាយនិងកូនស្រី រឿងផ្លូវបួនម៉ែត្រ នាំឲ្យម្តាយយកថ្មចាក់បិទផ្លូវផ្ទះកូនស្រី[២៤]

ទំនាស់ក្នុងគ្រួសាររវាងម្តាយ និងកូនស្រី២នាក់ដោយសាររឿងផ្លូវ៤ម៉ែត្រដែលទុកចេញចូលរួម ម្តាយខឹងកូនមិនព្រមឲ្យលុយខ្លះទៅគាត់ទើបបានហៅរថយន្តដឹកកម្ទេចថ្ម០៥រថយន្តមកចាក់បាំងផ្លូវមិនឲ្យកូនស្រី២គ្រួសារនៅខាងក្រោយចេញចូល។ ករណីនេះបង្ករផ្ទុះឡើងកាលពីរសៀលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ស្ថិតនៅក្រុម៥ភូមិភ្នំពេញថ្មីសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ភាគីទំនាស់ទី១គឺ ម្តាយ អាយុ៧១ឆ្នាំ, ភាគី២ឈ្មោះកូនស្រីបង្កើត២នាក់ ម្នាក់អាយុ៤៩ឆ្នាំ និងម្នាក់ទៀតអាយុ៤៤ឆ្នាំ។ ទាំងបីនាក់មានមុខរបរជាមេផ្ទះ។

ស្ត្រីជាកូនទាំង២នាក់ បានប្រាប់ថា តាមពិតទៅដីខាងលើគឺត្រូវបានឪពុកម្តាយគាត់បែងចែកឲ្យម្នាក់១ឡូមែនតាំងពីឪពុកគាត់មិនទាន់ស្លាប់ម្លេះ ដោយកាលនោះបែងចែក៤ឡូរគឺគាត់៣នាក់ជាកូន១ម្នាក់១ឡូរនិងម្តាយឪ

---

[២៤] Postnews, ថ្ងៃសុក្រ ទី24 ខែមិថុនា ឆ្នាំ2016 https://postnews.com.kh/local/35059

ពុកគាត់មួយឡូវដែរតែក្រោយពីឪពុកគាត់ស្លាប់ទៅម្ដាយបានលក់ចំណែករបស់គាត់ទៅហើយក្រោយបានលុយគាត់ទៅនៅជាមួយកូនច្បងដែលមានដីឡូរជាប់គ្នារហូតមកដល់សព្វថ្ងៃ។ ម្ដាយគាត់បានទារលុយពួកគាត់២នាក់ម្នាក់១.៥០០ដុល្លា២នាក់ស្មើ៣.០០០ដុល្លារហើយពួកគាត់បានឲ្យទៅ ម្ដាយជាតំណាក់កាលម្ដងបន្តិចៗអស់១.២០០ដុល្លាហើយតែក្រោយមក ម្ដាយគាត់បានប្រាប់ថាគាត់មិនបានទទួលលុយខាងលើទេ។

### ៤.២. ទម្រង់នៃទំនាស់និងអំពើហិង្សា

យើងសង្កេតឃើញថា សមាជិកនៃក្រុមគ្រួសារ ដែលមានទំនាស់ និងប្រព្រឹត្តិអំពើហិង្សាក្នុងគ្រួសារ ដែលបង្កឱ្យមានរបួសដល់រាងកាយ គ្រាំគ្រាផ្លូវចិត្ត ឬបាត់បង់ជីវិត នោះធ្វើឱ្យគ្រួសារទាំងមូលរស់នៅគ្មានសុភមង្គលឡើយ។ អ្នកដែលទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ ជាញឹកញាប់ជួបប្រទះការផ្លាស់ប្ដូររាងកាយ ផ្លូវចិត្តឬខាងវិញ្ញាណ ដែលអាចស៊ូទ្រាំនិង អាក្រក់ប្រសិនបើពួកគេមិនបានដោះ ស្រាយ។ ការមានទំនួលខុសត្រូវចំពោះអារម្មណ៍ ឬការចេះគ្រប់គ្រងអារម្មណ៍ និងសកម្មភាពរបស់ខ្លួនទាក់ទងនឹងអំពើហិង្សា ដឹងពីវិធីសាស្ត្រគ្រប់គ្រងអារម្មណ៍ ដើម្បីបញ្ចៀសប្រើអំពើហិង្សានៅពេលមានកំហឹង អាចជ្រើសរើសបានដូចជា អានសៀវភៅ ស្ដាប់ចម្រៀង លេងកីឡាពុះអុសផ្ទួតទឹកត្រជាក់ ស្រែកខ្លាំងនៅទីវាល។ល។

អំពើហិង្សាក្នុងគ្រួសារមានទម្រង់បួនប្រភេទគឺអំពើហិង្សា៖

១.ផ្លូវកាយ គឺការបៀតបៀនធ្វើឱ្យឈឺចាប់ដល់រូបរាងកាយទោះមានឬគ្មានស្លាកស្នាម ជួនពិការឬស្លាប់ដោយមធ្យោបាយផ្សេងមានការវាយនឹងដំបងបុកឬបាញ់កាប់ចាក់ជាដើម។

២. ផ្លូវចិត្ត គឺការបៀតបៀនធ្វើអោយឈឺចាប់ផ្លូវចិត្ត ដូចជាការប្រើពាក្យសំដីជេរប្រមាថ គំរាមគំហែង បិទសិទ្ធិសេរីភាព។ល។

៣. ផ្លូវភេទ គឺការបៀតបៀនធ្វើអោយឈឺចាប់ផ្លូវភេទ តាមរយៈការរំលោភផ្លូវភេទការធ្វើអាស្រូវ អាសអាភាស ការបៀតបៀនកេរខ្មាស ដូចជាការបង្ខំរួមភេទជាដើម។

៤. សេដ្ឋកិច្ច គឺគំនាបធ្វើបាបខាងសេដ្ឋកិច្ច ដូចជា បិទសិទ្ធិក្នុងការរកប្រាក់ចំណូល, មិនឲ្យទៅធ្វើការរកប្រាក់ចំណូល, មិនអោយចូលរួមចាត់ចែងទ្រព្យសម្បត្តិ(ទុក្ខប្ដីស្រីកាន់លុយ)។

### ៤.៣.មូលហេតុនៃអំពើហិង្សា

អំពើហិង្សាក្នុងគ្រួសារកើតឡើងដោយសារមូលហេតុ មិនយល់ដឹងច្បាស់លាស់អំពីច្បាប់គតិយុត្តិនិងគោលការណ៍សីលធម៌ដែលមានជាធរមាន ឬមិនដឹងច្បាស់ពីទ្រឹស្ដីសំខាន់នៃសាសនានានាដែលខ្លួនគោរព។ ការមិន

យល់ដឹងនេះធ្វើឱ្យគេមិនខ្លាចមិនគោរពច្បាប់ ឬជំបូន្មានទាំងនោះ។ គេក្លាយខ្លួនជាជនអវិជ្ជា ច្បាប់ឬក្លាយទៅមនុស្សខូចចរិត (ឧម្មត្តក) ដោយហ៊ានប្រើអំណាចត្រួតត្រាលើសមាជិកគ្រួសារ,ការខ្វះវិធីគ្រប់គ្រងកំហឹងរបស់ខ្លួនបង្ខំឱ្យគេគោរពខ្លួន, បង្គាប់បញ្ជាឱ្យគេធ្វើតាមខ្លួន, បញ្ចេញអំណួតថាខ្លួនជាមនុស្សខ្លាំងពូកែ, ប្រកាន់ទស្សនៈមួយចំនួនដូចជាទស្សនៈអាត្មានិយម, បិតាធិបតេយ្យ(ស្ត្រីមិនស្មើនឹងបុរស, ប្រពន្ធជាកម្មសិទ្ធិផ្តាច់មុខរបស់ប្តី, ប្រពន្ធជាទាសកររបស់ប្តីតាមរយៈលុយថ្លៃទឹកដោះ, យល់ថាខ្លួនមាននាទីប្រើហិង្សាលើសមាជិកគ្រួសារដើម្បីដោះការស្រាយបញ្ហា និងប្រើច្បាប់ផ្តាច់ការគ្មានគុណធម៌ជាដើម។

### ៤.៤. ផលវិបាកនៃអំពើហិង្សា

ចំពោះជនរងគ្រោះទទួលរងរបួសស្នាមលើរាងកាយ អាចពិការរយៈខ្លីឬវែងឬរហូតដល់បាត់បង់អាយុជីវិត និងទទួលរងគ្រោះ ផ្លូវចិត្តដោយផ្ទាល់ឬប្រយោល, អាចរត់ចេញពីផ្ទះ ងាយគេអូសទាញ មានការធ្លាក់ទឹកចិត្តឬជំងឺផ្លូវចិត្តឬវិកលចារិកឬធ្វើអត្តឃាត,រៀនសូត្រមិនបាន,ខ្លាចគេ,បាក់ស្បាត,បាត់ភាពក្លាហាន, បាត់បង់នូវភាពកក់ក្តៅពីគ្រួសារ។ ចំពោះជនប្រព្រឹត្តល្មើសទទួលបាននូវការ អាម៉ាស ការមើលងាយ,ឯកោគ្មានគេហ៊ានរាប់អាន,បាត់បង់ក្តីស្រលាញ់ពីប្រពន្ធ កូន បងប្អូន សាច់ញាតិ និងមិត្តភក្តិ,សង្គមមិនចូលចិត្ត, ទទួលទោសតាមផ្លូវច្បាប់ជាធរមាន។ លើសពីនេះ ចំពោះសហគមន៍វិញ ក៏មានបញ្ហាច្រើនពីអំពើហិង្សានេះដែរ គឺបង្កើតនូវអពមង្គលនៅក្នុងសហគមន៍,រំខានដល់អាជ្ញាធរមាន សមត្ថកិច្ច បងប្អូនអ្នកជិតខាងគ្រូពេទ្យ,ជាគំរូអាក្រក់ដល់កុមារដែលពួកគេអាចចម្លងទង្វើនេះបន្តទៀត, និងប៉ះពាល់កិត្តិយល់សហគមន៍ជាដើម។

### ៤.៥. វិធីកាត់បន្ថយអំពើហិង្សា

ក.និយាយពន្យល់ពីផលប៉ះពាល់នៃអំពើហិង្សាដោយបើកចំហជាមួយមិត្តភក្តិ ឪពុកម្តាយ និង សហគមន៍

ខ.ធ្វើការដោយផ្ទាល់ជាមួយសហគមន៍ដើម្បីផ្លាស់ប្តូរឥរិយាបថហិង្សានិងការពារមនុស្សគ្រប់គ្នាក្នុងសហគមន៍

គ.គ្រប់គ្រងការទទួលខុសត្រូវរបស់ខ្លួនលើការប្រើប្រាស់គ្រឿងស្រវឹង

ឃ.ស្វះស្វែងរកវិធីសាស្ត្រដោះស្រាយដោយអហិង្សា

ង.លើកទឹកចិត្តយុវវ័យអោយចេះគោរពខ្លួនឯង និងគោរពគ្នាទៅវិញទៅមក

ច.ធ្វើផែនការដើម្បីការពារខ្លួនអ្នកអោយមានសុវត្ថិភាព ឬចាកចេញពី ស្ថានភាពនៃអំពើហិង្សានោះ, បើអ្នកត្រូវបានគេវាយ ឬ

ទទួលការឈឺចាប់នៅទីណាក្តី ចូរប្រាប់បញ្ហានេះអ្នកណាដែលអាច ទុកចិត្តបាន ដើម្បីឲ្យគេជួយអ្នកស្វែងរកវិធីដោះស្រាយ, ស្វែងរកជំនួយផ្លូវច្បាប់សម្រាប់ជនរងគ្រោះដោយអំពើហិង្សា។

ឆ.អប់រំ ផ្សព្វផ្សាយ អោយប្រជាជនយល់ដឹងអំពីច្បាប់ដែលមានជាធរមាន ដូចជាសេចក្តីប្រកាសជាសកលស្តីអំពី សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ(១៩៤៨), អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ(១៩៩៣), អនុសញ្ញាស្តីពីសិទ្ធិកុមារ(១៩៨៩), និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣, និងអនុវត្តអោយបានត្រឹមត្រូវនូវ ៖ ក្រមព្រហ្មទណ្ឌ (២០០៩), ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ , ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ(២០០៥), ច្បាប់ស្តីអំពីឯកព័ន្ធភាព, គោលនយោបាយភូមិឃុំមានសុវត្ថិភាពជាដើម។

ជ. អប់រំ ផ្សព្វផ្សាយ អោយប្រជាជនយល់ដឹងអំពីគោលការណ៍ច្បាប់សីលធម៌ទាំងអស់ដែលជាកេរមរតកវប្បធម៌របស់ដូនតាខ្មែរ។

## ៥.គន្លឹះមួយចំនួនសម្រាប់ជីវិតប្រកបដោយសុភមង្គល

### ៥.១.គន្លឹះវិភាសម្រាប់គ្រួសារ

លក្ខខណ្ឌដើម្បីអាចរៀបការក្លាយគ្រួសារល្អមួយ វាត្រូវការរយៈពេលសមស្រប។ ការជ្រើសរើសដៃគូរៀបការ ដើម្បីកសាងគ្រួសារ អាស្រ័យលើជីវភាពជាក់ស្តែង ជួនកាលមានការបែងចែកឋានៈទៅតាមធនធានទ្រព្យសម្បត្តិទៀតផង។ ដោយសារជីវភាពខ្សត់ខ្សោយ យុវជនខ្លះមិនហ៊ានរៀបការ, យុវនារីខ្លះចាញ់បោកបុរសដោយសារតែងងប់ងុលសម្ភារៈនិយម។ល។ យុវវ័យខ្មែរភាគច្រើន ចាប់ផ្តើមកំណត់ផែនការថា ទាល់តែខ្លួនគេមានមុខរបរអាចចិញ្ចឹមជីវិតបានប្រសើរ ទើបអាចរៀបការបាន។ ការរៀបការជាមួយមនុស្សបំណុល គឺក្លាយមនុស្សរអកព្វទ្រព្យតដល់កូនចៅ។

មកដល់បច្ចុប្បន្ន ការរៀបចំកសាងគ្រួសារមួយមិនងាយស្រួលទេ។ យុវជនយុវនារីខ្មែរភាគច្រើនជាអ្នកធ្វើការជាកម្មករ ទទួលបានប្រាក់ឈ្នួលកំរិតទាបដែលពិបាកសន្សំយកទៅធ្វើដើមទុនក្នុងការវិនិយោគលើអាជីវកម្មដោយខ្លួនឯងដើម្បីឱ្យមានលំនឹងឬសេរីភាពខាងហិរញ្ញវត្ថុណាស់។ ផែនការកសាងគ្រួសារមិនសូវទទួលបានជោគជ័យតាមបំណងដូចដែលបានគិតទុកឡើយ ដោយសារ លក្ខខណ្ឌផ្សេងៗ ពិសេស

វិបត្តិថវិកា។ ការគ្រប់គ្រងចាត់ចែងថវិកាក្នុងគ្រួសារ ជាកត្តាសំខាន់បំផុតសម្រាប់គ្រួសារ។ ជីវិតគ្រួសារជាប្តីប្រពន្ធ គួរមានសិទ្ធស្មើគ្នា។ ការដែលសំរេចចិត្តរៀបការជាមួយមនុស្សម្នាក់ គឺជាការប្តេជ្ញាចិត្តថាព្រមរួមសុខទុក្ខជាមួយគ្នា អ្វីៗជារបស់រួម ប៉ុន្តែការចាត់ចែងទុកដាក់ទ្រព្យត្រូវមានម្នាក់ក្នុងនោះជាអ្នកទទួលខុសត្រូវ។ បើប្តីឬប្រពន្ធជាមនុស្សកញ្ជើធ្លុះជាអ្នកកាន់កាប់លុយនោះ គ្រួសារទាំងមូលមិនអាចមានជីវភាពធូធារបានឡើយ។

តាមទម្លាប់ គ្រួសារខ្មែរភាគច្រើនក្រោយពេលរៀបអាពាហ៍ពិពាហ៍រួច ជាធម្មតាភរិយាតែងតែគ្រប់គ្រងផ្នែកហិរញ្ញវត្ថុក្នុងគ្រួសារ ពោលគឺប្រពន្ធជាអ្នកទុកដាក់ប្រាក់ចំណូលដែលគ្រួសាររកបាន។ ដោយឡែក មានគ្រួសារខ្លះប្តីជាអ្នកគ្រប់គ្រងលុយកាក់ ពោលគឺប្តីកាន់លុយ។ ប្តីកាន់លុយ ប្រពន្ធខ្លះរងការឈឺចាប់ ពិបាកចិត្តនិយាយមិនរួច ដែលខ្មែរតែងនិយាយថា «ទុក្ខស្រីប្តីកាន់លុយ»។ ទុក្ខស្រីប្តីកាន់លុយ គឺជាទម្រង់នៃអំពើហិង្សាសេដ្ឋកិច្ចមួយសម្រាប់សង្គមខ្មែរ។ ហេតុអ្វីបានប្តីកាន់លុយ? តើមកពីប្តីស្រឡាញ់លុយជាងប្រពន្ធ?។ ពិតមែន មានខ្លះប្តីស្រឡាញ់លុយជាងប្រពន្ធ ប៉ុន្តែចំពោះប្រពន្ធកញ្ជើធ្លុះបើអោយកាន់លុយ វាទៅជា «ទុក្ខប្តីស្រីកាន់លុយ» វិញមិនខាន។

## ៥.២.កត្តាមនោសញ្ចេតនា និង សុខភាពនៃសមាជិកគ្រួសារ

អត្រាកំណើតនិងអត្រារស់រវាងបុរសនិងស្ត្រីខ្មែរ មានគម្លាតគ្នាខ្លាំង។ អត្រាកំណើតនិង អត្រារស់របស់បុរសខ្មែរមានតិចជាស្ត្រី។ អត្រារស់នៅបុរសទាបដោយសារ កត្តាកំណត់ធម្មជាតិ និងសង្គមដែលធ្វើឱ្យសុខភាពចុះខ្សោយដោយសារគ្រឿងញៀនស្រវឹង និងអតុល្យភាពនៃរបបអាហារ ដែលមានផ្ទុកសារជាតិគីមីដែលមានគ្រោះថ្នាក់ ការអត់ងងុយបាក់កម្លាំង និងគ្រោះថ្នាក់ផ្សេងៗ។ ចំពោះបុរសក្ររៀបអាពាហ៍ពិពាហ៍ ដោយសារកត្តាផ្សេងៗ ដូចជា ការចំណាយពេលរៀនសូត្រស្វែងរកចំណេះនិងសញ្ញាបត្រខ្ពស់ជីវភាពនិងប្រាក់ចំណូលការប្រាក់សន្សំសម្រាប់ថ្ងៃបណ្ណាការសុខភាព ពេលវេលាធ្វើការងារ, សេរីភាពក្នុងការស្វែងរកការសប្បាយជាមួយមិត្តភក្តិ, និងការទទួលខុសត្រូវផ្សេងៗទៀត...។ ចំពោះស្ត្រីការរៀបអាពាហ៍ពិពាហ៍ក៏មានបញ្ហាស្មុគស្មាញខ្លាំងក្នុងការសម្រេចបាននូវគោលដៅនិងគោលបំណងរបស់ខ្លួនដែរ។ ការជ្រើសដៃគូសម្រាប់ជីវិតឱ្យសមបំណងសម្រាប់ស្ត្រី គឺមានឱកាសតិចតួច។ ការបង្ហាញសេចក្តីស្រឡាញ់របស់ខ្លួនចំពោះមនុស្សដែលខ្លួនចង់បានជាគូជីវិត មិនដូចអាចលាតត្រដាងដូចបុរសឡើយ។

ស្ត្រីគ្មានបទពិសោធន៍ក្នុងរឿងស្នេហា ពេលចង់ចាប់ផ្ដើមច្រើនតែប៉ះចំប្ដីគេ ឬប៉ះចំពោះម៉ាយឬកម្មោះខ្វះគុណភាព គ្មានកំណើតចោលម្សៀត ឬប្រុសបោកប្រាស់។ ការរៀបការក្នុងវ័យមិនសមស្របក៏នាំឱ្យបាត់បង់ឱកាសមាសសម្រាប់មនោសញ្ចេតនាផ្អែមល្ហែម និងប៉ះពាល់ដល់សុខភាពផងដែរ។ ការរៀបការក្មេងពេកមិនសូវមានបទពិសោធជីវិត ចិត្តគំនិតមិនទាន់នឹងនរ មិនទាន់ចេះទប់អារម្មណ៍ មិនទាន់ចេះដោះស្រាយរឿងតូចធំ រហូតមានទំនាស់បង្កើតជាអំពើហិង្សា, រៀបការក្មេងពេកសុខភាពអាចទ្រុឌទ្រោម ឆាប់ទទួលនូវការឈឺចាប់ដល់ខ្លួនដែលជាម្ដាយទារក។ ផ្ទុយទៅវិញ បើរៀបការក្នុងវ័យចាស់ពេក កូនកើតមកមិនសូវមានសុខភាពពុំសូវរឹងមាំទាំងខាងផ្លូវកាយ ទាំងខាងប្រាជ្ញាស្មារតី។ ការរង់ចាំវ័យចាស់ទើបចាប់ផ្ដើមគិតគូររឿងរៀបការ ជួនកាលក៏នៅតែរកមិនឃើញដៃគូរល្អត្រឹមត្រូវដដែល។ តើគួរសុខចិត្តនៅព្រៅ គ្មានគូរហូតឬយ៉ាងណា?

### ៥.៣. សីលលក្ខខណ្ឌ

ការរស់នៅក្នុងគ្រួសារ ជីវិតប្ដីប្រពន្ធត្រូវមានភក្ដីភាព(សេចក្ដីស្មោះត្រង់) ចេះជួយដោះស្រាយទុក្ខធុរៈគ្នាទាំងផ្លូវកាយ ផ្លូវចិត្ត ពោលគឺត្រូវចេះយកអាសាគ្នាទៅវិញទៅមក និងយកចិត្តទុកដាក់គោរពរាប់អានចំពោះញាតិមិត្តនៃភាគីនីមួយៗ ហើយលើសពីនេះទៀតមិនត្រូវប៉ះពាល់ធ្វើអោយសៅហ្មងដល់អ្វីៗដែលដៃគូររបស់ខ្លួនស្រឡាញ់ឡើយ។ ហេតុអ្វីបានជាជីវិតប្ដីប្រពន្ធ ត្រូវមានភក្ដីភាព(សេចក្ដីស្មោះត្រង់)?

ក.តើមនុស្សប្រុសមានស្រីក្រៅផ្ទះជារឿងធម្មតាឬយ៉ាងណា?[២៥]

មនុស្សភាគច្រើនហាក់យល់ថា ថា មនុស្សប្រុស សឹងទាំងអស់លួចមានស្រី ក្រៅអាពាហ៍ពិពាហ៍ គឺជារឿងធម្មតា។ ស្ត្រីជាប្រពន្ធខ្លះ ថែមទាំងពោលពាក្យថា ក្នុងផ្ទះប្ដីយើង ក្រៅផ្ទះប្ដីគេ, ខ្លះថាបើសិនត្រឹមស៊ីនំឱ្យលុយគឺមិនអីទេ កុំឱ្យតែព្រហើនយកជាប្រពន្ធចុង។ បុរសខ្មែរភាគច្រើនជាអ្នករកលុយផ្គត់ផ្គង់គ្រួសារពួកគេក៏មានលទ្ធភាពនឹងកឹបកេងលុយទុកចាយនៅខាងក្រៅផ្ទះ។ មនុស្សប្រុសមានឪកាសដើរក្រៅផ្ទះហើយ ផឹកស៊ី ស្រីស្រាល្បែងតាមចិត្ត។ នៅក្នុងសង្គម ស្ត្រីខ្មែរ ហាក់មានគំនាបវប្បធម៌ក្នុងការដើរហើរ ព្រោះនៅមានមនុស្សភាគច្រើនគិតថា វាមិនសមទំនងឡើយ បើសិនជាមនុស្សស្រីដើរលេងយប់ ផឹកស៊ីដូច

[២៥] សំណាង, កោះសន្តិភាពថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០២០, https://kohsantepheapdaily.com.kh/article/1033739.html

បុរសៗនោះ។ តើ សីលធម៌មានស្តង់ដារពីរ សម្រាប់ភេទផ្ទុយគ្នាក្នុងសង្គមខ្មែរមែនឬទេ?

ប្រសិនបើ មាននិន្នាការដែលបុរសលួចមានប្រពន្ធចុង ឬស្រីខាងក្រៅផ្ទះថាជារឿងធម្មតា នោះវាអាចជំរុញឱ្យបុរសនៅតែប្រព្រឹត្តិរឿងនេះបន្តទៀត។ ប្រសិនបើប្រពន្ធដើមប្រចណ្ឌនិងប្តឹងប្តល់ នោះជម្លោះគ្រួសារនឹងកើតមានឡើង ហើយអាចឈានដល់ការបែកបាក់។ អ្នកដែលរងគ្រោះជាងគេគឺភរិយា និងកូនៗ កូនខ្លះភាពកក់ក្តៅនៅពេលដែលឪពុកម្តាយលែងលះគ្នា។ ក្នុងករណីជាច្រើន ភរិយាមិនងាយប្តឹងប្តីឡើយ គឺច្រើនតែរកវិធីកំចាត់ស្រីរបស់ប្តី។ មានទស្សនៈមួយលើកឡើងថា កុំច្រណែនឈ្នានីស្តគ្នាអីនោះគឺស្រីប្តីយើងទេតើ។ ទស្សនៈមានការមិនពេញចិត្តខ្លាំងពីសំណាក់ចលនាស្ត្រី និងយេនឌ័រ។ ចលនានេះទាមទារនូវការគោរពសិទ្ធសមធម៌តម្លៃស្ត្រី និង យេនឌ័រ ដោយវាយប្រហារខ្លាំងទៅលើច្បាប់ស្រីផងដែរ។ ចលនានេះ ចាត់ទុកថាបុរស ដែលមានស្រីកំណាន់ច្រើន គឺពិតជានាំមកនូវទារុណ្ណកម្មដល់ស្ត្រី គេឱ្យស្រមៃមើលថា ប្រសិនបើជាស្ត្រីជាប្រពន្ធមានប្រុសកំណាន់ច្រើនបានជម្រុញស្ត្រីជាប្រពន្ធកុំឱ្យមានចិត្តទន់ជ្រាយដោយទទួលស្គាល់ការផិតក្បត់ថាជារឿងធម្មតា ព្រោះគេយល់ថា ការទទួលស្គាល់បែបនេះនឹងធ្វើឱ្យបុរសៗកាន់តែខិលខូច ហើយអ្នករងគ្រោះគឺស្ត្រីជាប្រពន្ធនិងកូនៗ។

**ខ. មតិពិភាក្សា**

ខាងក្រោមនេះជាមតិឆ្លើយឆ្លងក្នុងប្រព័ន្ធបណ្តាញសង្គមៈ

១. **Sothearak Heng** ៖ បើប្តីមានស្ត្រីក្រៅផ្ទះ គឺដោយសារមានបញ្ហាក្នុងគ្រួសារ។ ត្រូវសិក្សាតើបញ្ហានោះជាអ្វី?

២. **Pongsametrey Karath** ៖ បើស្ត្រីនោះជាមនុស្សស្រីល្អគ្រប់គ្រាន់ ទោះបុរសជាប្តីនោះធ្លាប់ខិលខូចពីមុនមកយ៉ាងណាក៏ដោយ ក៏មិនហ៊ានក្បត់ចិត្តប្រពន្ធខ្លួនដែរ។ ហេតុផលវាមានច្រើនករណី មិនអាចយកមកនិយាយជារួមបានទេ។ បើប្រពៃណីខ្មែរឲ្យស្ត្រីរកលុយដណ្តឹងបុរស ហើយពេលរៀបការរួច ខាងស្ត្រីជាអ្នករកស៊ីចិញ្ចឹមបុរសទៀតនោះ នៅពេលដែលមានរឿងឬបញ្ហាជាមួយគ្នា ដែលបណ្តាលឲ្យខាងស្ត្រីមិនសប្បាយចិត្ត ស្ត្រីម្នាក់នោះក៏នឹងធ្វើដូចបុរសសព្វថ្ងៃដែរ ហើយបុរសៗក៏គ្មានសិទ្ធិច្រើនក្នុងការតវ៉ាដែរ។ តើស្ត្រីភាគច្រើនធ្លាប់គិតទេថា ទម្រាំបុរសម្នាក់រកលុយចូលស្តីដណ្តឹងអ្នកវិញ តើអារម្មណ៍បុរសយ៉ាងម៉េចដែរ? គេថា គេខំប្រឹងប្រែងប៉ុណ្ណា ហើយពេលរស់នៅជាមួយគ្នាបុរសភាគច្រើនគាត់ខំរកលុយមកផ្គត់ផ្គង់គ្រួសារ ដោយពេលខ្លះគាត់ខំធ្វើការផង យកលុយមួយចំនួន

ទៅវិនិយោគផង ប៉ុន្តែពេលការងារមិនអាចឆ្លើយតបនិងតម្រូវកាគ្រួសារ ការវិនិយោគមិនបានជោគជ័យ សួរថាតើមានស្ត្រីជាប្រពន្ធប៉ុន្មាននាក់ដែលចេះលើកទឹកចិត្តប្ដី ផ្ទុយទៅវិញស្ត្រីភាគច្រើនមានតែការស្ដីបន្ទោស...។ល។

៣. So Pheap ៖ តែសព្វថ្ងៃនេះ មានតិចណាស់ដែលប្ដីរកលុយតែម្នាក់ឯង។ ទោះខំទាំងពីរនាក់យ៉ាងណា ក៏នៅតែឃើញនៅមានប្ដីផិតក្បត់ ព្រោះសន្ដានកែមិនបាន (សុំទោសដែលសំដីធ្ងន់)

៤. Pongsametrey Karath ៖ So Pheap បាទអរគុណចំពោះការឆ្លើយតប ខ្ញុំមិនដែលប្រកាន់ក្នុងការបញ្ចេញមតិរបស់បុគ្គលម្នាក់ៗទេ ដូចខ្ញុំបាននិយាយហើយថា យើងមិនអាចនិយាយជារួមបានទេ ព្រោះថាមនុស្សយើងទាំងប្រុសទាំងស្រីក៏មានចំណុចខុស ចំណុចត្រូវ ដូចគ្នា។ ពេលខ្លះការក្បត់ផិត មិនមែនទាំងប្រុសស្រី សុទ្ធតែខុសនោះទេ ហើយម្យ៉ាងទៀត ការក្បត់ផិតមិនមែនសុទ្ធតែត្រូវនោះដែរ...(សំខាន់បំផុតគឺការរែកញែករកខុសនិងត្រូវនេះឯង)។

៥. Sothav Hor ៖ ខ្ញុំយល់ស្រប គំនិតដែលនិយាយថាមនុស្សប្រុសអាចរកស្រីក្រៅបាននោះគួបញ្ចប់វាទៅ។ មនុស្សស្រីក៏ជាមនុស្សមានចិត្តមានថ្លើមដែរ។ ស្រមៃមើលថាបើមនុស្សស្រីទៅមានប្រុសផឹកស៊ីក្រៅផ្ទះវិញតើមនុស្សប្រុសគិតយ៉ាងណាដែរ?កុំយកគំនិតដាក់គំនាបមកលើមនុស្សស្រីពេកអី, បើសង្គមអោយតម្លៃទៅលើមនុស្សប្រុសក្នុងភាពផិតក្បត់ការជារឿងធម្មតា ខ្ញុំដូចជាមើលមិនឃើញថាតំលៃមនុស្សប្រុសជាអ្វី រឺមានរឺអត់? ព្រោះថាការដើផឹកស៊ីស្រីញី ក្បត់ប្រពន្ធកូនធ្វើឲ្យស្ត្រីដែលជាម្ដាយរបស់កូនខ្លួន ស្ត្រីដែលបានក្រាបក្បាលដល់កន្ទេលជាមួយគ្នា ត្រូវរងទឹកភ្នែកនឹងឈឺចាប់ថាជារឿងធម្មតានោះ ខ្ញុំពិតជាមើលមិនឃើញថាមនុស្សប្រុសមានន័យអី? ហើយតម្លៃមនុស្សប្រុសនៅត្រង់ណា?

៦. Vannavy Kps ៖ តើគួរកាត់លិង្គប្ដី ដែលហាម និងនិយាយមិនស្ដាប់ មែនទេ?

៧. Sela Sar ៖ គំនិតនាំឲ្យបាត់បង់តម្លៃរបស់ស្ត្រី និងបង្ហាញពីភាពកម្សោយនៃការអប់រំ។

ចំពោះការប្រព្រឹត្តិខុសក្នុងកាម(កាមេសុមិច្ឆាចារ sexual misconduct) របស់បុរសកើតមានលុះត្រាតែប្រព្រឹត្តអំពើអជ្ឈាចារ[២៦] ទៅលើស្ត្រីដែលមានអ្នកគ្រប់គ្រង២០ជំពូក ៖ ១.មាតុរក្ខិតា ស្ត្រីដែលមានមាតាគ្រប់គ្រងរក្សា, ២.បិតុរក្ខិ

តា ស្ត្រីដែលមានបិតាគ្រប់គ្រងរក្សា ៣.មាតាបិតុរក្ខិតាស្ត្រីដែលមានមាតាបិតាគ្រប់ គ្រងរក្សា,៤. ភគិនីរក្ខិតា ស្ត្រីដែលមានបងប្អូនស្រីគ្រប់គ្រងរក្សា ៥.ភាតុរក្ខិតា ស្ត្រីដែលមានបងប្អូនប្រុសគ្រប់គ្រងរក្សា, ៦.ញាតិរក្ខិតា ស្ត្រីដែលមានញាតិគ្រប់គ្រងរក្សា ៧.គោត្តរក្ខិតា ស្ត្រីដែលមានវង្សត្រកូលជាមួយគ្នាឬជាតិសាសន៍ដូចគ្នាគ្រប់គ្រងរក្សា ៨.ធម្មរក្ខិតា ស្ត្រីដែលមានអ្នកបដិបត្តិធម៌គ្រប់គ្រងរក្សា ដូចជាស្ត្រីអ្នកបួសជាបព្វជិតឬបួសជាដូនជីជាដើម។ ៩.សបរិទណ្ឌា ស្ត្រីដែលអ្នកមានអំណាចដូចជាព្រះរាជាជាដើមដាក់រាជ្យអាជ្ញា មិនឲ្យបុរសណាមួយប្រព្រឹត្តកន្លងតាមអំពើចិត្ត។ ១០.សារក្ខា ស្ត្រីដែលមានបុរសគូស្នេហាបានដណ្តឹងហើយ ១១.ធនក្កីតា ស្ត្រីដែលគេទិញឬលួសដោយទ្រព្យទោះតិចក្តីច្រើនក្តីយកមកធ្វើជាភរិយា ឬដែលមាតាបិតាបងប្អូនយកទៅលក់ឲ្យគេ។ ១២.ឆន្ទវាសិនី ស្ត្រីដែលរត់ទៅធ្វើជាភរិយាបុរសដោយសេក្តីពេញចិត្តរបស់ខ្លួន ១៣.ភោគវាសិនី ស្ត្រីដែលទៅធ្វើជាភរិយាបុរសព្រោះតែទ្រព្យសម្បត្តិ ១៤.បដវាសិនី ស្ត្រីដែលនៅជាមួយបុរសព្រោះតែសំពត់ស្បៀក គឺស្ត្រីដែលទាល់ក្រ លុះឲ្យសំពត់ស្បៀកជាដើមទៅ ក៏ព្រមធ្វើជាភរិយាគេតែម្តង។ ១៥.ឱទបត្តកិនី ស្ត្រីដែលគ្រាន់តែពពួកញាតិជាដើមយកដៃជ្រលក់ចុះក្នុងផ្តិលទឹកផ្សំផ្គុំគ្នាជាប្តីប្រពន្ធ។ ១៦.ឱភតចុម្ពដា ស្ត្រីដែលគេដាក់ទ្រនូលពីលើក្បាល គឺស្ត្រីរកអុសជាដើម ដែលមានបុរសណាមួយជួយដាក់ទ្រនូលអំពីក្បាលហើយនាំយកធ្វើជា ភរិយា។ ១៧.ទាសីច ភរិយាចស្ត្រីដែលជាទាសីផង ជាភរិយាផង គឺស្ត្រីធ្វើទាសីរបស់បុរសណាបុរសនោះយកមកធ្វើជាភរិយា។ ១៨.កម្មការីច ភរិយា ចស្ត្រីដែលជាកូនឈ្នួលគេផង ជាភរិយាផង ១៩. ធជាហដា ស្ត្រីដែលពួកសេនាកងទ័ពបានវាយដណ្តើមយកមកអំពីចម្បាំងហើយបុរសណាមួយយកធ្វើជាភរិយារបស់គេ។ ២០.មហុត្តិកា ស្ត្រីដែលមានបុរសគប់ប្រសព្វតែមួយស្របកមួយគ្រា ឬស្ត្រីពេស្យាដែលបុរសកក់ប្រាក់ជាមុន។ ក្រៅពីនេះ គេមិនចាត់ទុកថាខុសក្នុងកាមេទេ លើកលែងតែប្រពន្ធរបស់បុរសជាប្តីហួង ហែងប្រចណ្ឌរករឿង។ ករណីនេះ នៅប្រទេសកម្ពុជា មានច្បាប់ស្តីពីឯកព័ន្ធភាពសម្រាប់ដោះស្រាយបាន ពោលគឺបើប្រពន្ធពេញច្បាប់មិនបានប្តឹងផ្តល់ទេ នោះប្តីមិនត្រូវមានទោសទណ្ឌឬពិន័យអ្វីឡើយ។

ចំណែកការប្រព្រឹត្តិខុសក្នុងកាម (កាមេសុមិច្ឆាចារ sexual misconduct)របស់ស្ត្រីកើតមានលុះត្រាតែប្រព្រឹត្តអំពើអជ្ឈាចារ[27] ដោយ

[២៧] អជ្ឈាចារ អ័ច-ឈាចា បា.(ន.) ការប្រព្រឹត្តកន្លងបញ្ញត្តិ,ការប្រព្រឹត្តខុសច្បាប់; មារយាទអាក្រក់ : មនុស្សមានអជ្ឈាចារគេពិបាកស្តីថាណាស់ ។ ពវ. វីតិក្កមឬវីតិក្រម។

ក្បត់ស្វាមី ពោលគឺបាត់កក្ដីភាព។ ក្រៅពីនេះ គេមិនចាត់ទុកថាខុសក្នុងកាមេទេ ព្រោះមិនដែលមានស្ត្រីណាទៅយកប្ដីគេទេ គឺមានតែបុរសទេដែលទៅផិតក្បត់ ឬយកប្រពន្ធគេ។

ក្នុងដំណើរកសាងជីវិតគ្រួសារមួយឱ្យប្រកបដោយសុភមង្គល មិនមែនជាការងាយស្រួលពេកទេ។ ការខ្វះនូវកត្តា ឬលក្ខខណ្ឌណាមួយនោះ សុភមង្គលវាបាត់ទៅតាមនោះដែរ។ ក្រៅពីកត្តា មនោសញ្ចេតនា, សុខភាព ហិរញ្ញវត្ថុ នៅមានកត្តាដទៃទៀតដែលជួយជីវិតគ្រួសារ ឱ្យចាកផុតពីវិបត្តិនានា កត្តាពិសេសនោះគឺ សីលលក្ខខណ្ឌ។ តាមពិតជម្លោះក្នុងគ្រួសារទាំងអស់វាគ្រាន់តែជាលទ្ធផលនៃហេតុដែលកើតចេញមកពីការខ្វះសីលលក្ខខណ្ឌនោះឯង។ ជារឿយៗយើងឃើញមានជម្លោះក្នុងគ្រួសារលេចចេញមក ធ្វើឱ្យដឹងឮជាសាធារណៈ ហើញដំណឹងអកុសលទាំងនេះត្រូវបានផ្សាយ និងចែកផ្សាយបន្តតាមប្រព័ន្ធផ្សព្វផ្សាយដែលជាការបូកបន្ថែមការឈឺចាប់លើកការឈឺចាប់នាំឱ្យកាន់តែឈឺចាប់។ ការកសាងគ្រួសារមួយដែលមាន សេរីភាពឬលំនឹងហិរញ្ញវត្ថុ, មានសុខភាពល្អ រកបាន គូដែលខ្លួនស្រឡាញ់ទុកចិត្ត និងប្រកបដោយសីលលក្ខខណ្ឌ នោះជាកព្វសំណាងខ្ពស់បំផុតរបស់មនុស្ស។ កត្តាទាំងនេះ វាមិនងាយបានមកដោយឯកឯងទេ គឺវាតម្រូវឱ្យមានការប្រឹងប្រែងខ្លាំងស្របនឹងឱកាសអំណោយផង។

## ៦. គ្រួសារខ្មែរ និង ករណីយកិច្ច

គ្រួសារជាអ្នកជ្រើសរើសសមាជិកនៃសង្គម ហើយទទួលរ៉ាប់រងចិញ្ចឹម ការពារ និងអប់រំសមាជិកថ្មីៗរហូតដល់គេអាយុពេញវ័យ។ គ្រួសារជាមជ្ឈមណ្ឌលនៃសកម្មភាពខាងឧស្សាហកម្ម ខាងពាណិជ្ជកម្ម ខាងសេរីភាព ហើយភារៈរបស់គ្រួសារមិនមែននៅត្រឹមតែត្រង់បង្កើនសកម្មភាពទាំងឡាយនោះទេ គឺសំខាន់នៅត្រង់ការទ្រទ្រង់ជីវិតសម្ព័ន្ធ។ គ្រួសារនេះហើយដែលជាអ្នកបន្តឬបញ្ជូននូវប្រពៃណីខាងសាសនា ខាងនយោបាយ និងជាអ្នកជានាភាពគ្រប់គ្រាន់នៃទម្លាប់ផ្សេងៗ។ គ្រួសារខ្មែរបំពេញបាននូវមុខងារយ៉ាងសំខាន់ ខាងផ្លូវសង្គមនិងខាងផ្លូវសីលវិជ្ជា។

### ៦.១. ការមានកូន

គោលបំណងធំបំផុត នៃធម្មជាតិគ្រួសារគឺការមានកូន។ គ្រួសារដែលគ្មានកូន គឺពិតជាពុំបានបំពេញករណីកិច្ចរបស់ខ្លួនចំពោះ មនុស្សជាតិឡើយ។ ក្នុងស្ថានភាពជីវភាពសង្គមបច្ចុប្បន្ន មានគ្រួសារខ្មែរខ្លះបានប្រើមធ្យោបាយពន្យារកំណើត ឬរំលូតកូន។គ្រួសារខ្មែរភាគច្រើនមានកូនជាមធ្យម ត្រឹមតែពីរនាក់ប៉ុណ្ណោះ

គេមិនហ៊ានមានកូនច្រើនឡើយ ពីព្រោះខ្វះលទ្ធភាពចិញ្ចឹមនិងអប់រំកូនឱ្យមានគុណភាពល្អ។ ការពន្យារកំណើត និងការរំលូតកូន គឺជាអំពើបាបដែលខុសឆ្គងចំពោះសាសនាផង។ ជាទូទៅ អ្នកទើបនឹងរៀបអាពាហ៍ពិពាហ៍ហើយថ្មីៗ ពួកគេនឹងមានកូនយ៉ាងឆាប់រហ័សបន្ទាប់ពីរៀបការរួច នោះវាគឺជាការបាត់បង់ឱកាសរកចំណូលសម្រាប់គូស្រករដែលមានកូនទាំងក្មេងខ្ចីនោះ ហើយពួកគេត្រូវទទួលបន្ទុកច្រើនជាងពួកគូស្រករដែលពុំទាន់មានកូន ឬក៏អ្នកនៅលីវផងដែរ[២៨]។

បច្ចុប្បន្ន ប្រជាជនខ្មែរមានដង់ស៊ីតេទាប និងមានចំនួនតិចបើប្រៀបនឹងប្រទេសជិតខាង។ មនុស្សត្រូវការបន្តពូជពង្សវង្សត្រកូល ហើយសង្គមត្រូវការបង្កើតសមាជិកថ្មីរបស់ខ្លួន មកជំនួសសមាជិកដែលទទួលមរណភាពទៅ។ បើមានមនុស្សស្លាប់ហើយមនុស្សកើតថ្មីមានចំនួនតិចឬគ្មានមនុស្សបន្តវេនទេនោះ សង្គមនឹងត្រូវរលាយ ហើយជាតិក៏នឹងត្រូវលុបរលត់ ឬក៏នាំមកនូវសេចក្តីវិនាសទៅវិញដែរ។ បើគ្រួសារទាំងអស់ឈប់ឱ្យមានកូនឬកូនតិច នោះសង្គមខ្មែរអាចធ្វើដំណើរទៅរកភាពវិនាសសាបសូន្យ។

គ្រួសារឥតកូន ជាគ្រួសារខ្វះលក្ខណៈសម្បត្តិខាងសម្ភារៈ និងខាងសីលវិជ្ជា។ ធម្មតាកាលណាមានកូន ប្តីប្រពន្ធទាំងពីរនាក់ តែងតែប្រែប្រួល ជាពិសេសខាងផ្លូវចិត្តគំនិត គឺអ្នកទាំងពីរចាប់មានសញ្ចេតនាជាថ្មីទៀត ដូចជាសេចក្តីស្រឡាញ់របស់ឪពុកចំពោះខ្លួន សេចក្តីស្រឡាញ់របស់ម្តាយចំពោះកូន គឺជាសញ្ចេតនាមួយ ដែលរួមវិភាគទានជួយរឹតចំណងឲ្យជាប់ខ្លាំងក្នុងគ្រួសារ។ ការមានកូន បុរសចាប់ឃើញច្បាស់ថា ស្ត្រីជាប្រពន្ធខ្លួនផង ជាម្តាយរបស់កូនគេម្នាក់ផង។ ឯស្ត្រីវិញក៏ចាប់ឃើញថាបុរសជាប្តីខ្លួនផងជឪពុកនៃកូនខ្លួនផង។ ដូច្នេះកូនជាចំណងប្រសើរបំផុតចំពោះប្តីប្រពន្ធ។ កាលណាមានកូន ប្តីប្រពន្ធកាន់តែស្គាល់ពីជីវិតខ្លួនឯងនិងកាតព្វកិច្ចក្នុងការចិញ្ចឹមកូន ព្រមទាំងយល់ពីតម្លៃមនោសញ្ចេតនា និងឧបការគុណឪពុកម្តាយ ដែលធ្លាប់ធ្វើមកលើខ្លួន។ ពេលនេះ ការបំពេញករណីយកិច្ចរបស់កូនចំពោះឪពុក ម្តាយ គឺជាអំពើចាំបាច់បំផុត សម្រាប់កូនដែលមានកតញ្ញូកតវេទតាធម៌។

### ៦.២. ការចិញ្ចឹម និង ការអប់រំកូន

តាមធម្មជាតិ និងវប្បធម៌ តម្រូវឱ្យឪពុកម្តាយខ្មែរ ទទួលខុសត្រូវក្នុងការចិញ្ចឹមថែរក្សា និងអប់រំកូនកុំឱ្យខូចឈ្មោះពូជពង្សវង្សត្រកូល ធ្វើយ៉ាងណាឱ្យកូនបានខ្ពស់មុខមាត់ មាន

[២៨] ក្រុមអ្នកស្រាវជ្រាវប្រចាំក្រុមហ៊ុនTNS, របាយការណ៍ ខែតុលា ឆ្នាំ២០១៨, https://www.postkhmer.com/post-plus/

ញាតិមិត្តរាប់អាន ហើយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៧ ក៏បានចែងថា មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និង អប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។ ហេតុនេះហើយ ទើបយើងសង្កេតឃើញថា ម្តាយឪពុកខ្មែរភាគច្រើនខិតខំពុះពារមិនខ្លាចនឿយហត់ ទ្រាំទ្រការងារគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមកូន ពេលខ្លះប្រព្រឹត្តិអំពើអសីលធម៌ក៏មាន។

ការងារកសិកម្ម ការជំនួញដូញដូរទាក់ទងនឹងជីវិតសត្វ គែបន្ទំក្អែកជញ្ជីងជាដើមតែងតែកើតមាននៅគ្រប់តំបន់។ កុំទុកចិត្តមេឃ កុំទុកចិត្តផ្កាយ កុំទុកចិត្ត កុំទុកប្រពន្ធប្តីថាអត់សាហាយ កុំទុកឪពុកម្តាយថាអត់បំណុល។ នៅក្នុងបទស្មូត"ទំនួញប្រេត" និពន្ធដោយលោក ពេជ្រ សុខា បានរៀបរាប់អំពីការប្រព្រឹត្តអំពើអសីធម៌ បាប របស់ឪពុកម្តាយ ក្នុងការខំចិញ្ចឹមកូន ហើយបានកើតទៅជាប្រេតក្រោយពេលស្លាប់។ ប្រជាជនខ្មែរទទួលស្គាល់នូវតថភាពនេះ ហើយតែងស្តាប់ស្មូតនេះនេះនៅ រដូវបុណ្យកាន់បិណ្ឌ។

ដោយសារកាលៈទេសៈ ភាពអវិជ្ជា ខ្វះការអប់រំ និងកត្តាផ្សេងទៀត គឺជាហេតុជម្រុញឱ្យឪពុកម្តាយប្រព្រឹត្តិខុសសីលធម៌ ដើម្បីកូន។ ប៉ុន្តែមានករណីមួយចំនួនដែលឪពុកម្តាយលក់កូនដើម្បីលុយសម្រាប់ប្រយោជន៍ខ្លួនដែរ។

ហេតុនេះហើយទើបមានអន្តរាគមន៍ពីស្ថាប័នមានសមត្ថកិច្ចដើម្បីទប់ស្កាត់បញ្ហាទាំងនេះ។ រដ្ឋបានធានារក្សាការពារសិទ្ធិរបស់កុមារដូចដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និង ការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ និងគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់ កុមារ។

គ្រួសារជាអ្នកផ្តល់នូវការអប់រំដំបូងដែលចាត់ទុជាអាទិភាព ព្រោះការអប់រំដំបូងអាចជាទម្លាប់ល្អអាក្រក់ប្រសិនបើជាល្អ នោះការអប់រំនឹងទៅជាងាយស្រួល តែបើអាក្រក់វិញ ការអប់រំបន្តទៅមុខ វាពិបាកខ្លាំងណាស់ ព្រោះត្រូវចំណាយពេលដើម្បីកំចាត់ទម្លាប់ចាស់ ដែលជាទម្លាប់អាក្រក់នោះចោលចេញសិន។ គ្រួសារជាទីកន្លែងល្អបំផុតដើម្បីបណ្តុះការអប់រំដើម្បីបណ្តុះសីលអំពើ គឺហេតុដូច្នេះហើយបានជាសង្គមត្រូវចាត់ការសព្វយ៉ាងដើម្បីការពារគ្រប់គ្រួសារ ដើម្បីសម្រួលការរស់នៅដើម្បីធានារ៉ាប់រងដល់ការលូតលាស់ និងសន្តិសុខនៃគ្រួសារ។ យល់បែបនេះហើយបាន

*ជាជូនតាខ្មែរផ្តល់ជាពាក្យស្លោកថាដំដែកទាន់នៅក្តៅ ប្រដៅមនុស្សទាន់នៅក្មេង។*

### ៦.៣. ការទុកដាក់កូនចៅឲ្យមានគូ

*ការទុកដាក់កូនចៅឱ្យមានគូ(ប្តីប្រពន្ធ) គឺជាករណីយកិច្ចរបស់ឪពុកម្តាយចំពោះកូន។ ជាទូទៅឪពុកម្តាយខ្មែរ តែងតែខ្វល់ខ្វាយខ្វាំងខ្វាចកូនមិនមានអនាគតល្អ។ ជូនកាល ឪពុកម្តាយប្រើអំណាចរបស់ខ្លួនច្រើនក្នុងការជ្រើសរើស ប្តី ឬប្រពន្ធ ជំនួសកូននិងរ៉ាប់រងលើ ការចំណាយលើពិធីអាពាហ៍ពិពាហ៍ឱ្យកូនថែមទៀត។ ក្នុងករណីស្របគំនិតគ្នាដោយមិនមានការជំទាស់ពីកូននោះភាពរីករាយតែងកើតមានឡើង ប៉ុន្តែប្រសិនបើកូនមិនយល់ព្រមទារុណកម្មផ្លូវចិត្ត ផ្លូវកាយតែងកើតមានឡើង។ មានឪពុកម្តាយភាគច្រើន មិនពេញចិត្តនិងជំទាស់នឹងការស្រឡាញ់គ្នាលួចលាក់ឬ បើកចំហរបស់កូនពួកគាត់នៅមានអារម្មណ៍អាម៉ាសនៅពេលកូនលួចមានសង្សារ[២៩]។ គេគិតថា មុននឹងដេកនៅជាមួយគ្នា ត្រូវតែសំពះរាបក្បាលដល់កន្ទេល គឺត្រូវរៀបការជាមុនសិន។ ការរៀបការឬពិធីអាពាហ៍ពិពាហ៍ខ្មែរបច្ចុប្បន្ន ភាគច្រើនប្រព្រឹត្តិឡើងយ៉ាងឧឡារិក[៣០] អធិកអធម[៣១]និងអធិកអធម្ម[32] នៅផ្ទះខាងស្រីឬនៅតាមទីស្ថាននានា គឺគេមិនសូវឃើញមាន ពិធីអាពាហ៍ពិពាហ៍ រៀបចំឡើងនៅផ្ទះខាងប្រុសឡើយ។ ការចំណាយលើថ្លៃរៀបចំពិធីមានអត្រាខ្ពស់ បើប្រៀបធៀបនឹងប្រាក់ចំណូលរបស់សមីខ្លួន។ ភាគីខាងប្រុស ត្រូវមានលុយសម្រាប់ចូលស្តីដណ្តឹងភាគីខាងស្រីដើម្បីទុកចាត់ចែងរៀបពិធីមង្គលការ ដែលគេហៅថា ប្រាក់បណ្តាការ ហើយខ្លះហៅថាលុយថ្លៃទឹកដោះ។ ខាងស្រីស្នើសុំប្រាក់ បណ្តាការច្រើនឬតិចទៅតាមធនធាន ឋានៈជីវភាព និងស្ថានភាពជាក់ស្តែងរបស់របស់ភាគីរៀងខ្លួន។*

[២៩] *ការមានសង្សារ គឺជាការស្រឡាញ់គ្នារវាងបុរសនិងស្ត្រីមុនរៀបការ។ ការមានសង្សារ ជាអំពើខុសនឹងប្រពៃណី វប្បធម៌ខ្មែរ ដែលគេចាត់ទុកថាជាអំពើអសីលធម៌មួយ ព្រោះបានល្មើសអ្វីដែលគោលការណ៍ដែលសង្គមបានហាមប្រាម ប៉ុន្តែច្បាប់រដ្ឋក្នុងសង្គមខ្មែរ នាបច្ចុប្បន្នមិនបានបញ្ញត្តិហាមឃាត់ទេ ដោយចាត់ទុកថាវាជាផ្នែកមួយនៃសិទ្ធិសេរីភាពរបស់ពលរដ្ឋ យោងតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ហើយឪពុកម្តាយក៏មិនសូវតឹងតែងខ្វាំងចំពោះការមានសង្សារដូចពីអតីតកាលដែរ។ ការស្គាល់ចិត្តថ្លើមមុនរៀបការក៏អាចជួយឱ្យមានការចុះសម្រុងគ្នាក្នុងជីវិតអាពាហ៍ពិពាហ៍ដែរ។*

[៣០] *ឧឡារិក ( គុ. ) ខ្ពង់ខ្ពស់; មានតម្លៃ; ថ្លៃថ្លា; ថ្កើងថ្កាន, ថ្កុំថ្កើង; រុងរឿង; ឧត្តម, ប្រសើរ; លើសលន់; ច្រើន, បរិបូណ៌*

[៣១] *អធិកអធម (អៈ ធិក-អៈធំ)(គុ.) ទាំងអធិកផងទាំងអធមផង គឺទាំងរុងរឿងផង ទាំងរបុិចរប៉ិឬរម៉េះរម៉ោះខ្លះផង។ អធិក(=ក្រៃលែង; លើសលន់; ពន់ប្រមាណ; ក្រៃពេក; រុងរឿង) និងអធម(=ថយថោក, ថោកទាប; មិនរុងរឿង; រម៉េះរម៉ោះ)*

[៣២] *អធិកអធម្ម អៈ ធិក-អៈធ័ម ( គុ.) ដែលខុសធម៌យ៉ាងក្រៃលែង ក្រៅគន្លងធម៌យ៉ាងក្រៃលែង ខុសច្បាប់យ៉ាងក្រៃលែង អាក្រក់យ៉ាងក្រៃលែង។ ប្រើជាអធិកអធម៌ ក៏បាន។*

គ្រួសារខាងស្រីមួយចំនួនអាចទាមទារហួសហេតុ រហូតមានឈ្មោះថាជាអ្នកលក់កូនស៊ី។ ពិធីអាពាហ៍ពិពាហ៍ខ្មែរបច្ចុប្បន្ន ភាគច្រើនបានសង្ខេបមករយៈពេលត្រឹមមួយថ្ងៃប៉ុណ្ណោះ។ កម្មវិធីជាប្រពៃណីមួយចំនួនត្រូវបានកាត់ចោលយោងតាមកាលៈទេសៈ និងទស្សនៈយល់ឃើញ។ ពិធីកូនក្រមុំលាងជើងឱ្យកូនកំឡោះត្រូវលុបចោល ដោយសារចលនាទស្សនៈយេនឌ័រ។ ភ្ញៀវដែលត្រូវអញ្ជើញ ចូលរួម មិនសូវបានចូលរួមក្នុងពិធីជាប្រពៃណីទេ ភ្ញៀវភាគច្រើនបំផុតគ្រាន់តែទៅស៊ីការ(ចូលរួមក្នុងពិធីជប់លៀងទទួលអាហារ)តែប៉ុណ្ណោះ។ ពិធីជប់លៀងការដែលពេញនិយម គឺត្រូវគ្រឿងស្រវឹងនិងប្រភេទអាហារថ្លៃៗ។ ពិធីមង្គលការនីមួយៗមានការចំណាយ ខ្ពស់។ ភ្ញៀវទាំងឡាយចាំបាច់ត្រូវភ្ជាប់ជាមួយចំណងដៃ ដើម្បីជួយទប់ទល់នឹងការចំណាយរបស់ម្ចាស់កម្មវិធី ។

ជាទូទៅនៅក្នុងសង្គមកម្ពុជា គឺក្នុងចំណោម ១ភាគ៣នៃប្រជាជនទាំងអស់ គឺជាមនុស្សពេញវ័យដែលមានអាយុលើសពី ១៨+ ឡើងទៅ។ ស្ទើរតែ៣ភាគ៤ (ប្រហែល ៧១ភាគរយ) នៃប្រជាជនកម្ពុជាដែលមានអាយុចាប់ពី ១៨ដល់ ២៥ឆ្នាំ ជាមនុស្សនៅលីវ។ ដោយឡែកក្រុមមនុស្សដែលមានវ័យចន្លោះពី ២៦ដល់៣៥ឆ្នាំ គឺមានចំនួនត្រឹមតែ ១ភាគ ៥ តែប៉ុណ្ណោះ។ តួលេខភាគរយខ្ពស់បំផុតនៃប្រជាជនពេញវ័យរៀបអាពាហ៍ពិពាហ៍ បានឆ្លុះបញ្ចាំងតាមរយៈវិធីពីរគឺលំនាំប្រពៃណីទំនៀមទម្លាប់នៃការរៀបចំរបស់អាណាព្យាបាលឬក៏ការសម្រេចចិត្តរបស់យុវវ័យទៅតាមការវិវត្តិរបស់សង្គម។ តួលេខនៃអ្នករៀបអាពាហ៍ពិពាហ៍ហើយមានកូន គឺមានចំនួន៥៥ភាគរយជាប្រការគួរកត់សម្គាល់វាគឺអាស្រ័យទៅលើធនធានដែលពួកគេមានលទ្ធភាពអាចចំណាយបាន។[33]

ក្នុងកាលៈទេសៈដែលកំរិតជីវភាពគ្រួសារខ្មែរនៅមានកំរិតទាប ការចំណាយលើអាពាហ៍ពិពាហ៍ បានក្លាយជាវិបត្តិសង្គមមួយដ៏ពុំរ៉ៃ សម្រាប់សមីដើមកម្មវិធីអាពាហ៍ពិពាហ៍និងភ្ញៀវចូលរួម ប៉ុន្តែសម្រាប់អ្នកមានចំណូលខ្ពស់ ឬអ្នកមានលទ្ធភាព ពិធីនេះគឺជាឱកាសមាសសម្រាប់ សម្តែងមនោសញ្ចេតនារីករាយសប្បាយក្នុងការបង្កើនចំណងមិត្តភាព និងកិត្យានុភាពផងដែរ។ ចំពោះអ្នកក្រ អ្នកមធ្យម បើគេអត់អញ្ជើញស៊ីការមានការអន់ចិត្ត ប៉ុន្តែបើគេហៅស៊ីការញយៗ រមែងលួចត្អូញថ្ងូរអំពីវិបត្តិថវិកាគ្រួសារ ជូនកាលសុខចិត្តឱយកូនប្រពន្ធឬប្តី នៅផ្ទះស៊ីសៀង ដើម្បីបានលុយទៅ ចងដៃស៊ីការគេ។ ហើយពេលខ្លះសុខចិត្តខ្ចីលុយគេយកទៅ

៣៣ ក្រុមអ្នកស្រាវជ្រាវក្រុមហ៊ុនTNS, របាយការណ៍ ខែ តុលា ឆ្នាំ២០១៤, https://www.postkhmer.com/post-plus/

ចង់ដៃការ ជាពិសេសនៅពេលជំពាក់ចំណងដៃគេ នោះមិនអាចគេចវេះបានដោយគ្មានបញ្ហាឡើយ។

## ៧. ការវិភាគលើការប្រតិបត្តិសីលធម៌ក្នុងគ្រួសារ

ខាងក្រោមនេះ គឺជាភាពខ្លាំង ឱកាស ភាពខ្សោយ ការប្រឈម សម្រាប់ដោះស្រាយទំនាស់វិបត្តិដែលកើតមានឡើងក្នុងគ្រួសារខ្មែរបច្ចុប្បន្ន។

### ៧.១. ភាពខ្លាំង និង ឱកាស

ទស្សនៈមាតាធិបតេយ្យ ដែលគោរពលើកតម្កើងស្ត្រីជាចម្បង នៅតែរស់រវើកក្នុងសង្គមវប្បធម៌ខ្មែរ ទោះបីកំពុងប្រឈម នឹងទស្សនៈបិតាធិបតេយ្យ និងទស្សនៈយេនឌ័រ ក៏ដោយ។ ទស្សនៈបិតាធិបតេយ្យ និងទស្សនៈយេនឌ័រគ្រាន់តែបាននិងកំពុងដណ្ដើមតួនាទីរបស់ខ្លួនក្នុងសង្គមធម៌ខ្មែរ ដោយសារតែឥទ្ធិពលសេដ្ឋកិច្ច និងនយោបាយមួយខណៈៗប៉ុណ្ណោះ។ ក្នុងជម្រៅនៃដួងចិត្តមនុស្សខ្មែរគឺនៅតែគោរពរបបមេជាធំជានិច្ច។ ម្ដាយនិងផ្ទះដើរតួសំខាន់សម្រាប់គ្រួសារ ដោយលើកជាសុភាសិតថា សូវស្លាប់បា កុំអោយស្លាប់មេ សូវលិចទុកកណ្ដាលទន្លេកុំឱ្យតែភ្លើងឆេះផ្ទះ។ ជនជាតិខ្មែរនៅតែមានឆន្ទៈរក្សាព្រលឹងមរតកវប្បធម៌ដែលជាអត្តសញ្ញាណជាតិឱ្យនៅគង់វង្សជានិច្ច។ នៅពេលអំពើព្រៃអវិជ្ជាត្រូវបណ្ដេញអោយចាកចេញពីខ្លួនតាមរយៈការអប់រំ នោះខ្មែរប្រុសស្រីនឹងកាន់តែយល់ឃើញច្បាស់នូវតម្លៃមរតកវប្បធម៌របស់ខ្លួនជាក់មិនខាន។ ការយល់ដឹងពីតម្លៃមរតកវប្បធម៌របស់ខ្លួនគឺជាមធ្យោបាយសំខាន់មួយជួយឱ្យមនុស្សខ្មែរកាន់តែច្រើនឡើងប្រកាន់ សុចរិតធម៌ អហិង្សាធម៌ គុណធម៌ និងបំពេញករណីកិច្ចតាមតួនាទីរបស់ខ្លួនបានត្រឹមត្រូវកាន់តែប្រសើរឡើងដែរ។

### ៧.២. ភាពខ្សោយ និងបញ្ហាប្រឈម

សង្គមធម៌បច្ចុប្បន្ន បានប្រើប្រាស់កម្មវិធីជាប្រពៃណីប្រចាំរដូវ ពិធីបុណ្យទាននានាពិធីអាពាហ៍ពិពាហ៍ និងជួបជុំជប់លៀងផ្សេងៗដើម្បីសេពគ្រឿងស្រវឹង(ទឹកប្ដូរនិស្ស័យ)ថាជាអំពើកិត្តិយស។ ទឹកប្ដូរនិស្ស័យទាំងនោះ បានបំផ្លាញគ្រួសារខ្មែរអស់ជាច្រើន។ បុថុជ្ជនទូទៅយល់ថា អំពើហិង្សា គឺជាអំពើអសីធម៌មួយដែលតែងកើតមានឡើងជារឿងៗជាធម្មតាក្នុងសង្គមគ្រួសារ ព្រោះថាចានក្នុងរាវតែងមានរណ្ដំអណ្ដាតនៅជាមួយធ្មេញលែងអីប៉ះទង្គិចគ្នា។ ភាពអាត្មានិយម ការខ្វះទំនួលខុសត្រូវ ការមិនស្មោះត្រង់ ការមិនទុកចិត្តគ្នា ការរស់នៅមិនចុះសម្រុងគ្នា ដែលឈានទៅដល់ទំនាស់ ជម្លោះ

បង្កអំពើហិង្សា បណ្ដាលអោយមានរបួសស្នាម គ្រាំគ្រាពុំរ៉ៃ ពិការភាព ស្លាប់ និងរហូតដល់ការលែងលះ ហាក់នៅតែបន្តកើតមានក្នុងសង្គមកម្ពុជាឥតឈប់ឈរ ដែលបន្សល់នូវកុមារអនាថា ជនចាស់ជរាគ្មានទីពឹងដែលជាបន្ទុកដ៏ធំរបស់រដ្ឋ។ ការខ្វះស្ថាប័នទទួលខុសត្រូវលើ កុមារខ្វះទីពឹង ជនចាស់ជរា ជាបញ្ហាប្រឈមដែលត្រូវមានដំណោះស្រាយសមស្របតាមសភាពការណ៍ជាក់ស្ដែង។ ច្បាប់ស្រីដែលមានខ្លឹមសារអប់រំស្ត្រីអោយមានភាពទន់ភ្លន់តាមគន្លងសីលធម៌ខ្មែរ បែរជាត្រូវទទួលរងការរិះគន់ ពីចលនាស្ត្រីដែលមានទំនោរទៅរកយេនឌ័រ ថាច្បាប់នេះតែងដោយមនុស្សប្រុស មិនអោយតម្លៃស្ត្រី និង នាំអោយស្ត្រីទន់ជ្រាយទៅវិញ។

**៨.៣.ដំណោះស្រាយ**

ក.ស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាលវិស័យឯកជន និងពលរដ្ឋខ្មែរទាំងអស់ គួរតែបង្កើនការយល់ដឹងលើ ទស្សនៈមាតាធិបតេយ្យរបស់ខ្មែរ, ទស្សនៈបិតាធិបតេយ្យ និង ទស្សនៈយេនឌ័រ ឱ្យបានត្រឹមត្រូវ។

ខ.បង្កើនការអប់រំនិងផ្សព្វផ្សាយ ច្បាប់គតិយុត្តិ និងច្បាប់ក្រមដែលជាគោលការណ៍សីលធម៌ខ្មែរឱ្យបានទូលំទូលាយ។

គ.ជំរុញស្ថាប័នសាសនាទាំងអស់ ដែលមានវត្តមានលើទឹកដីខ្មែរ ពង្រឹងការប្រតិបត្តិតាមគោលការណ៍សីលធម៌របស់ខ្លួនឱ្យត្រឹមត្រូវ ជាពិសេសការប្រើប្រាស់ គ្រឿងញៀនស្រវឹងនិងគ្រឿងប្លូរនិស្ស័យទាំងឡាយ។

ឃ.ពង្រឹងនិងពង្រីកស្ថាប័នានានាដែលអាចជួយ កុមារកំព្រា ជនចាស់ជរាគ្មានទីពឹងឱ្យបានរៀនសូត្រ និងរស់នៅសមរម្យ។

ង.ដាក់បញ្ចូលចូលច្បាប់ស្រី និងច្បាប់ប្រុសក្នុងកម្មវិធីសិក្សា ។

## សេចក្ដីសន្និដ្ឋាន

គ្រួសារជាមូលដ្ឋាននៃសង្គមមានសារៈសំខាន់សម្រាប់មនុស្សជាតិ។ បច្ចុប្បន្នស្ថានភាពសង្គមកម្ពុជាពោរពេញដោយសន្តិសុខទូទាំងប្រទេស ដែលជាឱកាសល្អសម្រាប់គ្រួសាររស់នៅដោយសុខស្រួលបាន។ ប៉ុន្តែ គ្រួសារមួយចំនួនបែរជាជួបទំនាស់វិបត្តិស្មុគស្មាញ ហើយបានបន្សល់ទុកនូវបញ្ហាជាច្រើនដល់សង្គមជាតិ។

ទំនាស់វិបត្តិគ្រួសារភាគច្រើនបណ្ដាលមកពីការមិនយល់ដឹងសីលវិជ្ជា (ទស្សនវិជ្ជាសីលធម៌) ច្រើនជាងបញ្ហាហិរញ្ញវត្ថុ។ មធ្យោបាយដើម្បីកសាងរៀបចំគ្រួសារខ្មែរឱ្យបានត្រឹមត្រូវប្រកបដោយសុភមង្គល ចៀសផុតពីទំនាស់វិបត្តិនានា គឺត្រូវបង្កើនការអប់រំបណ្ដុះបណ្ដាលដល់ពលរដ្ឋអោយយល់ដឹងអំពីសីល

វិជ្ជា វិធីថែរក្សាសុខភាព និងជំនាញឯកទេស សម្រាប់សម្មាអាជីវៈ ព្រមទាំងរៀបចំការពារ សន្តិសុខសណ្តាប់ធ្នាប់ យុត្តិធម៌ សមធម៌ ក្នុង សង្គមជាតិអោយបានល្អត្រឹមត្រូវ។

ការងារសម្រាប់នាំទៅរកដំណោះស្រាយវិបត្តិខាងលើ គឺជាកាតព្វកិច្ចរបស់សមាជិកទាំងអស់គ្នាក្នុងសង្គម ទាំងអ្នកនយោបាយ អ្នកសាសនា បញ្ញវន្តនិងប្រជាជនគ្រប់ស្រទាប់ ព្រោះប្រសិនបើស្ថានភាពសង្គមត្រឹមត្រូវល្អ គ្រួសារមានសុភមង្គល និងផ្ទុយមកវិញ បើស្ថានភាពសង្គមអាប់អួរពោរពេញដោយអំពើបាយមុខគ្រប់ប្រភេទ ហើយប្រជាជនមិនគោរពករណីកិច្ចជាពលរដ្ឋ ខ្វះភាពស្មោះត្រង់មិនទុកចិត្តគ្នានោះ ការប្រតិបត្តិសីលធម៌ក្នុង គ្រួសារក៏មានទំនោទៅរកធ្លាក់ចុះជាលំដាប់ ដែរ។ ករណីនេះ ប្រព័ន្ធសិក្សាអប់រំគឺជាគន្លឹះសំខាន់មួយដែលជួយមនុស្សឲ្យស្គាល់ពីតម្លៃរបស់ខ្លួន និងក្លាយជាពលរដ្ឋពេញលេញ។ ទោះបីគេខំចំណាយលុយដើម្បីរៀបចំធ្វើពិធីអាពាហ៍ ពិពាហ៍អឹកធឹកយ៉ាងណាក៏ដោយ ក៏សុភមង្គលមិនអាចស្ថិតស្ថេរដែរប្រសិនបើសមាជិកគ្រួសារខ្វះការយល់ដឹងនិងខ្វះការប្រតិបត្តិសីលធម៌។ ហេតុនេះ ការអប់រំសីលវិជ្ជាដល់សមាជិកសង្គមគឺជាការចាំបាច់បំផុត។

## គន្ថនិទ្ទេស


ក.ព្រឹត្តិប័ត្រ, ទស្សនាវដ្តី, សារពត៌មានតាមអន្តរបណ្តាញ

១.Rhac, *ខែមេសា* 28, 2017, rhac.org.kh

២.www.km.wikipedia.org/wiki/*វិគីភីឌាភាសាខ្មែរ*

៣.www.postkhmer.com

៤.www.kohsantepheapdaily.com.kh

៥.www.apsaracentral.com

៦.www.postnews.com.kh

៧. www.opendevelopmentcambodia.net/km/

ខ- ស្នាដៃនិពន្ធជាភាសាខ្មែរ

១.ជួន ណាត, *វចនានុក្រមខ្មែរ*, ការផ្សព្វផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧

២.ឈុន ផារ៉េង, *សីលវិជ្ជាអនុវត្តន៍*, ឆ្នាំ២០១០

៣.រាជកិច្ច, *ឆ្នាំទី១១ លេខ ៤៦ សប្តាហ៍ទី៣* ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១

៤.វិទ្យាស្ថានជាតិខេមរយានកម្មនៃក្រសួងអប់រំជាតិ, *ទស្សនវិជ្ជា* ភាគ១និង ភាគ២, ភ្នំពេញ ១៩៧៤

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ ៖**

*ច្បាប់ស្តីពី ការអនុវត្តក្រមបវេណី ឆ្នាំ២០១១*

***ជំពូក៧ វិសោធនកម្ម និង និរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ជាធរមាន***

***មាត្រា៧៨.*** *និរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ*

*ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ត្រូវបាត់បង់អានុភាពចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែបញ្ញត្តិនៃមាត្រា ៧៦ មាត្រា ៧៧ និង បញ្ញត្តិ ពីមាត្រា ៧៩ ដល់មាត្រា ៨១ នៃច្បាប់នោះនៅតែមានអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត រហូតដល់ពេលដែលកំណត់ផ្សេងដោយច្បាប់។*

**ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ (មាត្រា ៧៦ មាត្រា ៧៧ និង បញ្ញត្តិ ពីមាត្រា ៧៩ ដល់មាត្រា ៨១)**[34]

*ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបានអនុម័តដោយរដ្ឋសភានៃរដ្ឋកម្ពុជា នៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៨៩ នាសម័យប្រជុំសាមញ្ញលើក ទី១៧ នីតិកាលទី១ ដែលន័យខ្លឹមសារដូចតទៅ៖*

…………………………………………..

***មាត្រា៧៦*** : *ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគម្ខាងទៀតបាន។ ភាគីខាងក្រោយនេះ ត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។ កំរិតអាហារកិច្ចត្រូវសំរេចតាមការយល់ព្រមរបស់គូភាគីទាំងសងខាង។ ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនសំរេចសេចក្តី។ បើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតហើយ។*

***មាត្រា៧៧*** : *តុលាការប្រជាជនខេត្ត-ក្រុង អាចកែប្រែដោយបង្កើន ឬបន្ថយកំរិតអាហារកិច្ចបាន បើមានសំណូមពររបស់ភាគីម្ខាង។ ការបង្កើន ឬបន្ថយកំរិតអាហារកិច្ចនោះត្រូវធ្វើឡើងតាមលទ្ធភាពនៃភាគីដែលផ្តល់ អាហារកិច្ចនិងតាមសេចក្តីត្រូវការ នៃភាគីដែលទទួលអាហារកិច្ច។ អាហារកិច្ចអាចផ្តល់ឱ្យជាទឹកប្រាក់ ឬជារបស់។*

***ជំពូកទី៤៖ អំពីអាពាហ៍ពិពាហ៍នៅឯបរទេស និងអាពាហ៍ពិពាហ៍ជាមួយបរទេស***

---

[34] https://data.opendevelopmentcambodia.net/km/laws_record/law-on-marriage-and-family/resource/e3d50a25-eea5-44c2-acfb-31cd02b4bb99

*ផ្នែកទី១៖ អំពីអាពាហ៍ពិពាហ៍*

***មាត្រា៧៩*** : *អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងពលរដ្ឋកម្ពុជាឬរវាងពលរដ្ឋ កម្ពុជានិងជនបរទេស ដែលរស់នៅឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអគ្គរាជទូតកុងស៊ុលនៃស្ថានទូត ឬស្ថានកុងស៊ុលនៃរដ្ឋកម្ពុជាប្រចាំនៅប្រទេសដែលគូភាគី មានទីលំនៅ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងពលរដ្ឋកម្ពុជា និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទំរង់នៃអាពាហ៍ពិពាហ៍ដែលមានចែងក្នុង ច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍នោះ ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជាប្រសិនបើ អាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទបញ្ញត្តិច្បាប់នៃរដ្ឋកម្ពុជា។ លិខិតបញ្ជាក់អាពាហ៍ពិពាហ៍ឬសេចក្តីចំលងលិខិតអាពាហ៍ពិពាហ៍នេះត្រូវយកមកចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៃស្ថានទូតឬស្ថានកុងស៊ុល នៃរដ្ឋកម្ពុជា ឬគូស្វាមីភរិយាមកតាំងទីលំនៅនៅរដ្ឋកម្ពុជា ត្រូវយកមកចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ នៅឃុំឬសង្កាត់ ដែលមកតាំងទីលំនៅនោះ។*

***មាត្រា៨០*** : *អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេសរស់នៅរដ្ឋកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃរដ្ឋកម្ពុជា។*

***ផ្នែកទី២៖ រំលាយអាពាហ៍ពិពាហ៍,***

***មាត្រា៨១*** : *ការរំលាយអាពាហ៍ពិពាហ៍ ដែលធ្វើនៅឯបរទេសរវាងប្រជាពលរដ្ឋកម្ពុជា និងពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និងជនបរទេស ដែលរស់នៅឯបរទេស ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា។ -ការរំលាយអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស ឬការរំលាយអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសនៅរដ្ឋកម្ពុជា ត្រូវធ្វើតាមច្បាប់នៃរដ្ឋកម្ពុជា។ -តុលាការប្រជាជននៃរដ្ឋកម្ពុជា មានសមត្ថកិច្ចសំរេចលើបណ្តឹងសុំរំលាយអាពាហ៍ពិពាហ៍របស់សហព័ទ្ធណាមួយដែលចូលមកតាំងទីលំនៅ នៅរដ្ឋកម្ពុជា។*

**ឧបសម្ព័ន្ធទី២**

**(ច្បាប់ស្តីពីអនុវត្តក្រមរដ្ឋដែលទាក់ទងនឹងអាពាហ៍ពិពាហ៍និងគ្រួសារ)** [35]

***មាត្រា៩៤៩.*** *ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព បុគ្គលដែលមានសហព័ទ្ធហើយពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។*

---

[35] រាជកិច្ច, ឆ្នាំទី១១ លេខ ៤៦ សប្តាហ៍ទី៣ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១, ទំព័រ ៤៦៨៤

**មាត្រា៩៥៤**. ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ៖ ជននៅក្រោមអាណាព្យាបាលទូទៅអាចរៀបអាពាហ៍ពិពាហ៍ បានក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរិមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។

**មាត្រា៩៦៦**. ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក។ ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក។

**មាត្រា៩៦៧**.សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម។ ប្តី ប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈហើយអាចចូលរួមក្នុងសកម្មភាព នយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន។

**មាត្រា៩៧១**.ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍។ ប្តីប្រពន្ធត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូលនិងស្ថានភាពផ្សេងៗទៀត។

**មាត្រា៩៧៤**. ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច។ ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ ៖

ក-សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូនជាអាទិ៍។

ខ-កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀតដែលប្តី ឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្រពន្ធ ឬប្តី ម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ-សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។

**មាត្រា ៩៧៦**. ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ៖

១-បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាច ជៀសវាង បាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីរក្សាជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាង អាចលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបានដោយទទួលការអនុញ្ញាតពីតុលាការ។

៣-ក្នុងករណីដែលប្តី ឬប្រពន្ធណាម្ខាងបានលក់ ឬធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផងនិងគ្មានការអនុញ្ញាតពីតុលាការផងសហព័ទ្ធដែល មិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការ (ចាត់ចែងនោះ ទៅតុលាការបាននៅ ក្នុងអំឡុងពេល២(ពីរ)ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួម ដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុ និងនៅក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីពេលដែល បានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាទ្រព្យសម្បត្តិផ្សេង ។

**មាត្រា៩៧៧**. ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

១-ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ សហព័ទ្ធម្ខាង ទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន។

២-ក្នុងករណីដែលប្តីប្រពន្ធម្ខាងអាស្រ័យនៅអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាង លើនេះ ទោះបីជាសហព័ទ្ធម្ខាងទៀត បានចាត់ចែងអចលនវត្ថុនោះ ក៏ដោយ ក៏អាចបន្តអាយនៅ អចលនវត្ថុនោះបានដែរ។

មាត្រា ៩៧៨. មូលហេតុនៃការលែងលះគ្នា

១-ប្តី ឬ ប្រពន្ធ អាច ដាក់ពាក្យបណ្តឹងលែងលះគ្នា បានតែក្នុងករណីដែលកំណត់ខាងក្រោមនេះ៖

ក-បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ។

ខ-បើបានបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ។

គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង១(មួយ) ឆ្នាំ។

ឃ-បើសហព័ទ្ធ បានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១(មួយ)ឆ្នាំ ផ្ទុយនឹងគោល បំណងនៃអាពាហ៍ពិពាហ៍ ។

ង-ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹង អាចបដិទានឡើងវិញបាន។

*២-ទោះបីជាក្នុងករណី ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបញ្ហាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនក្រលំបាកយ៉ាងខ្លាំងឬមានការឈឺចាប់ដែលពុំអាចទ្រាំទ្របានតុលាការអាចច្រានចោលការទាមទារលែងលះគ្នាដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។*

*៣-ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ឃ ឬចំណុច ង នៃកថាខណ្ឌទី១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះដោយឆន្ទានុសិទ្ធិបាន។*

***មាត្រា ៩៧៩.*** *ការលែងលះដោយការព្រមព្រៀង*

*ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបានក្នុងករណីដែលភាគីសងខាង បានព្រមព្រៀងអំពីការលែងលះគ្នា។ ប៉ុន្តែតុលាការអាចឱ្យលែងលះគ្នាបានក្រោយពីបានយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។*

***មាត្រា៩៨២.*** *ការសាកល្បងផ្សះផ្សា ដោយតុលាការ*

*១-ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយតុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន។*

*២-បើការផ្សះផ្សាពុំអាចសម្រេចបានទេ តុលាការត្រូវយកបណ្ដឹងលែងលះគ្នាមកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម។*

# ប្រវត្តិសាកលវិទ្យាល័យភូមិន្ទកំពង់ចាម
# (ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧០)

History of Royal University of Kampong Cham from 1965 to 1970

Histoire de l'Université Royale de Kampong Cham de 1965 à 1970

*ដោយៈ បណ្ឌិត* **សុង ស៊ីណា**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា*

Email: songsyna888@gmail.com

## សេចក្ដីផ្ដើម

*ការអប់រំនៅប្រទេសកម្ពុជានាសម័យមុនបារាំងមកគ្រប់គ្រងបានធ្វើឡើងនៅតាមទីវត្តអារាមៗ ការសិក្សានាពេលនោះបានផ្ដោត ទៅលើភាសាបាលី ការអានសាស្ត្រា និងអត្ថបទនានាដែលទាក់ទងនឹងព្រះពុទ្ធសាសនា។ ការសិក្សាបែបនេះបានធ្វើឱ្យកូនខ្មែរចេះអាន និងសរសេរអក្សរខ្មែរបានៗ នៅដើមស.វ.ទី២០ បារាំងបានចាប់ផ្ដើមធ្វើកំណែទម្រង់ទាក់ទងនឹងវិស័យអប់រំ ដែលជាបន្តបន្ទាប់គេបានបង្កើតសាលាផ្លូវការតាំងពីកម្រិតបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងរហូតដល់ថ្នាក់ឧត្តមសិក្សា។*

*ចំនួនសាលាមធ្យមសិក្សា នៅទូទាំងប្រទេស និងសិស្សដែលបានបញ្ចប់ការសិក្សានៅថ្នាក់មធ្យមសិក្សាបានកើនឡើង ជាពិសេសសិស្សដែលសិក្សានៅតាមបណ្ដាខេត្តមានមិនលទ្ធភាពមកបន្តការសិក្សានៅភ្នំពេញ។ ការបណ្ដុះបណ្ដាលថ្នាក់ឧត្តមសិក្សានៅមុនឆ្នាំ១៩៦៥ គឺមានតែនៅទីក្រុងភ្នំពេញប៉ុណ្ណោះ។ ដោយពិនិត្យឃើញតម្រូវចាំបាច់នេះ ទើបរដ្ឋាភិបាលតាមរយៈក្រសួងអប់រំជាតិបានរៀបចំបង្កើតឡើងនូវសាកលវិទ្យាល័យចំនួន៣នៅតាមខេត្តគឺ១ ខេត្តកំពង់ចាម២ ខេត្តបាត់ដំបង និង៣ នៅព្រំប្រទល់ខេត្តតាកែវ-កំពត។*

*នៅក្នុងសកលលោក នាសម័យសាកលភាវូបនីយកម្ម ការបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយគុណភាពគឺជាកត្តាគន្លឹះសម្រាប់ការកសាងប្រទេសជាតិ  នីមួយៗប្រទេសដែលមានការអភិវឌ្ឍជឿនលឿនគេបានប្រកាន់នូវទស្សនថាក្នុងសម័យទំនើបនេះគេត្រូវការអ្នកមានចំណេះដឹងពិតប្រាកដ ដើម្បីជួយអភិវឌ្ឍសេដ្ឋកិច្ច  និងសង្គមជាតិរបស់ប្រទេសខ្លួន។ ហេតុនេះទើបគេ*

កំណត់យកនូវចក្ខុវិស័យដ៏សំខាន់មួយគឺសេដ្ឋកិច្ចត្រូវពឹងផ្អែកលើចំណេះដឹងៗ ប្រទេសដែលសម្បូរធនធានមនុស្សប្រកបដោយគុណភាព គឺអាចដណ្តើមយកឧត្តមភាពឈ្នះ និង មានឥទ្ធិពលទៅលើប្រទេសដែលមានប្រព័ន្ធអប់រំទន់ខ្សោយៗ

ការស្រាវជ្រាវនេះ យើងនឹងលើកយកតែការបង្កើតសាកលវិទ្យាល័យភូមិន្ទកំពង់ចាមតែប៉ុណ្ណោះៗ ហេតុដូចនេះ ដើម្បីបានយល់កាន់តែច្បាស់ យើងបានដាក់ជាចំណោទបញ្ហាថា តើមូលហេតុអ្វីបានជាមានការបង្កើតសាកលវិទ្យាល័យភូមិន្ទកំពង់ចាម ហើយសាកលវិទ្យាល័យនេះការវិវត្ត និងមានដំណើរការនៃការបណ្តុះបណ្តាលធនធានមនុស្សយ៉ាងដូចម្តេចខ្លះ?

## ផ្នែក ១
## គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស

### ១.ការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស

គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេក ទេសនៅក្នុងខេត្តកំពង់ចាម ត្រូវបានបង្កើតឡើងតាំងពីសម័យសង្គមរាស្ត្រនិយមៗ គ្រឹះស្ថាននេះមានភារកិច្ចបង្ហាត់បង្រៀនមុខវិជ្ជាបច្ចេកទេសវិជ្ជាជីវៈដើម្បីឱ្យសិស្សនិស្សិតយកចំណេះវិជ្ជានេះទៅជួយអភិវឌ្ឍន៍សង្គមជាតិនិងយកទៅប្រកបមុខរបរចិញ្ចឹមជីវិតរៀងៗខ្លួនៗ ចំណុចនេះជាការយកចិត្តទុកដាក់ដល់យុវជនខ្មែរ ដើម្បីឱ្យពួកគេមានការចាប់អារម្មណ៍មកចាប់យកវិជ្ជាជីវៈជាអ្នកបច្ចេកទេស ជាជាងការផ្តេកផ្តួលតែទៅលើមុខរបរកសិកម្មតែមួយមុខៗ

### ១.១.សាលាបណ្តុះបណ្តាលបច្ចេកទេសខេត្តកំពង់ចាម

ប្រទេសកម្ពុជាបានពឹងផ្អែកលើរបរកសិកម្មជាធំតាំងពីបុរាណកាលមកប៉ុន្តែសម្រាប់បរិបទនៃសម័យទំនើបយើងមិនអាចមើលរំលងលើការបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងវិជ្ជាជីវៈដល់កូនខ្មែរនោះឡើយៗ ការចាប់អារម្មណ៍និងឱ្យតម្លៃលើការបណ្តុះបណ្តាលកូនខ្មែរ លើផ្នែកបច្ចេកទេសនេះមានតាំងពីសម័យអាណាព្យាបាលបារាំងមកម្ល៉េះ គឺនៅពេលនោះគេបានបង្កើតសាលាអនុវត្តន៍ឧស្សាហកម្មនៅទីក្រុងភ្នំពេញៗ សាលាអនុវត្តន៍ឧស្សាហកម្មនៅភ្នំពេញកាន់ តែមានការរីកលូតលាស់ហើយបានក្លាយទៅជាសាលាឫស្សីកែវ (សាលាបច្ចេកទេស) ដែល ស្ថិតខាងជើងទីក្រុងភ្នំពេញៗ សាលាបច្ចេកទេសឫស្សីកែវបានសម្ពោធនៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៣៩ ដោយលោករេស៊ីដង់ ជាន់ខ្ពស់បារាំងប្រចាំនៅកម្ពុជាលោកធីបូដូ (Thi-baudeau)[៩]ៗ ក្រៅពីសាលាបច្ចេកទេសនៅសាលាបច្ចេកទេស នៅតាម

[៩] Inauguration de l´Ecole Pratique d´Industrie à Phnom Penh le 21 octobre 1939, Phnom Penh, 1939, p.12.

ខេត្តនានាផងដែរ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ចាប់ពីឆ្នាំសិក្សា១៩៥៩-១៩៦០ សាលាឧស្សាហកម្ម ខេត្តកំពង់ចាមបានដំឡើងទៅជាគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេសទីក្រុងភ្នំពេញគេក៏បានបង្កើតឱ្យមានដែលមានឈ្មោះថា អនុវិទ្យាល័យបច្ចេកទេសកំពង់ចាម[២]។ អនុវិទ្យាល័យបច្ចេកទេសនេះមានមណ្ឌលមួយសម្រាប់ឱ្យសិស្សអនុវត្តន៍។ អនុទ្យាល័យបច្ចេកទេសកំពង់ចាមមានបេសកកម្មបណ្តុះបណ្តាលសិស្សឱ្យទទួលបាននូវចំណេះដឹង ផ្នែកបច្ចេកទេសឧស្សាហកម្ម និង សិប្បកម្ម។

## ២. ការបង្កើតសាកលវិទ្យាល័យភូមិន្ទកំពង់ចាម

ការបង្កើតសាកលវិទ្យាល័យភូមិន្ទកំពង់ចាមនាឆ្នាំ១៩៦៥ គឺជាការយកចិត្តទុកដាក់ក្នុងការពង្រីកការបណ្តុះបណ្តាលធនធានមនុស្សនៅថ្នាក់ឧត្តមសិក្សា។ ម្យ៉ាងទៀតក៏ជាការឆ្លើយតបទៅនឹងកំណើនសិស្សានុសិស្សដែលបញ្ចប់ថ្នាក់មធ្យមសិក្សា ហើយត្រូវបន្តការសិក្សានៅមហាវិទ្យាល័យ។ គេសង្កេតឃើញថាក្នុងចំណោមសិស្សដែលបានប្រឡងជាប់មធ្យមសិក្សានៅតាមបណ្តាខេត្តនានាតែងជួបការលំបាកក្នុងការមកបន្តការសិក្សារបស់ខ្លួននៅឧត្តមសិក្សាដោយសារតែសាកលវិទ្យាល័យមានតែនៅទីក្រុងភ្នំពេញ។ ដូច្នេះទើបនៅឆ្នាំ១៩៦៥ រដ្ឋាភិបាលតាមរយៈក្រសួងអប់រំជាតិបានសម្រេច បង្កើតសាកលវិទ្យាល័យនៅតាមខេត្តចំនួន៣ គឺខេត្តបាត់ដំបង តាកែវ កំពត និង ដោយឡែកសម្រាប់ភូមិសាស្ត្រខេត្តកំពង់ចាមបង្កើតសាកលវិទ្យាល័យភូមិន្ទកំពង់ចាម។ សាកលវិទ្យាល័យភូមិន្ទកំពង់ចាម(ស.ភ.ក.ច.)បានបង្កើតឡើង តាមព្រះរាជក្រមលេខ២២៧ប.រ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥ អនុម័តដោយរដ្ឋសភានៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៦៤។

សាកលវិទ្យាល័យភូមិន្ទកំពង់ចាមមានទីតាំងស្ថិតនៅទីរួមខេត្តកំពង់ចាម និងស្ថិតក្រោមអាណាព្យាបាល នៃក្រសួងអប់រំជាតិ។ សាកលវិទ្យាល័យនេះទទួលបន្ទុកខាងឧត្តមសិក្សានិងខាងការស្រាវជ្រាវវិទ្យាសាស្ត្រព្រមទាំងជាអ្នកចេញសញ្ញាបត្រសាកលវិទ្យាល័យទៅតាមមុខវិជ្ជា ដែលខ្លួនបានបណ្តុះបណ្តាល។ ទីតាំងអតីតសាកលវិទ្យាល័យភូមិន្ទកំពង់ចាមបច្ចុប្បន្នទីតាំងនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម។

សាកលវិទ្យាល័យភូមិន្ទកំពង់ចាមត្រូវប្រមូលផ្តុំនៅក្រោមការគ្រប់គ្រងរបស់ខ្លួននូវគ្រឹះស្ថានឧត្តមសិក្សា និង ផ្នែកនៃឧត្តមសិក្សាបច្ចេកទេសនានាដែលមានស្រាប់ ឬដែលនឹងបង្កើតថ្មីដូចខាងក្រោម ៖

[២] រាជកិច្ចចេញផ្សាយថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៥៩ ទំព័រ៥០៣៤។

-មហាវិទ្យាល័យយន្តសាស្ត្រ។

-មហាវិទ្យាល័យវប្បកម្មឧណ្ហប្រទេស។

-មហាវិទ្យាល័យវិទ្យាសាស្ត្ររូបនិយមគណិតសាស្ត្រ។

សាកលវិទ្យាល័យភូមិន្ទកំពង់ចាមជាគ្រឹះស្ថានជាតិសាធារណៈ ដែលមាននីតិបុគ្គលិកលក្ខណៈ និងមានស្វ័យភាពផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ និង ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់សាកលវិទ្យាធិការមួយរូបដែលមានឋានៈស្មើនឹងរដ្ឋលេខាធិការ។ ទោះសាកលវិទ្យាល័យភូមិន្ទកំពង់ចាមបានបង្កើតឡើងតាំងពីថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥ មកក៏ដោយ ប៉ុន្តែសាកលវិទ្យាល័យនេះបានចាប់ផ្តើមដំណើរការបណ្តុះបណ្តាលនិស្សិតរបស់ខ្លួននៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៦៥[៣]។

## ២. ១. សាកលវិទ្យាធិការ

នៅក្នុងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាកលវិទ្យាល័យភូមិន្ទកំពង់ចាមចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៦៥ បានចែងថា សាកលវិទ្យាល័យភូមិន្ទកំពង់ចាមត្រូវស្ថិតនៅក្រោមកិច្ចត្រួតត្រានៃសាកលវិទ្យាធិការមួយរូប ដែលមានក្រុមប្រឹក្សាភិបាលអមផង។ សាកលវិទ្យាធិការត្រូវតំណាងឱ្យសាកលវិទ្យាល័យក្នុងកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុជាអ្នកទទួលខុសត្រូវក្នុងការរៀបចំនិងការប្រព្រឹត្តទៅនៃសាកលវិទ្យាល័យដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។

សាកលវិទ្យាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យដែលមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី និងតាមការស្នើសុំពីរដ្ឋមន្ត្រីក្រសួងអប់រំជាតិ។ សាកលវិទ្យាធិការត្រូវបានជ្រើសរើសចេញពីក្នុងចំណោមសាស្ត្រាចារ្យដែលមានសញ្ញាបត្រសាកលវិទ្យាល័យឬឥស្សរជនជាន់ខ្ពស់ដែលមានសមត្ថភាពគ្រប់គ្រាន់។ សាកលវិទ្យាធិការអាចមានអនុសាកលវិទ្យាធិការ(សាកលវិទ្យាធិការរង)អមតាមការស្នើសុំពីសាកលវិទ្យាធិការដែលតែងតាំងឡើងតាមលក្ខណៈដូចគ្នានឹងសាកលវិទ្យាធិការដែរ។

## ២. ២.សាកលវិទ្យាធិការដ្ឋាន

សាកលវិទ្យាធិការដ្ឋាន ត្រូវដឹកនាំដោយប្រធានម្នាក់និងមានអនុប្រធានម្នាក់ឬច្រើនតាមការចាំបាច់។ ប្រធាននិងអនុប្រធានសាកលវិទ្យាធិការដ្ឋាន ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមការស្នើសុំពីរដ្ឋមន្ត្រីក្រសួងអប់រំជាតិ ដោយមានការយល់ព្រមពីសាកល

[៣] Raoul M. Jennar, ***Les clés du Cambodge***, Faits et chiffres, repères historiques, profiles cambodgiens, cartes, Maisonneuve et Larose, 1995, p. 65.

វិទ្យាធិការផង។ សាកលវិទ្យាធិការដ្ឋានមានផ្នែកច្រើនស្ថិតនៅក្រោមចំណុះ។ ប្រធានផ្នែកនិងបុគ្គលិកជំនួយការនៃសាកលវិទ្យាធិការដ្ឋានត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់សាកលវិទ្យាធិការ។ សាកលវិទ្យាធិការដ្ឋានមានភារកិច្ចគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេសនៃសាកលវិទ្យាល័យ។

**យ.ក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យ**

ក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យជាអ្នកទទួលបន្ទុកសម្រេចបញ្ហាផ្សេងៗ ដែលទាក់ទងនឹងអត្ថប្រយោជន៍នៃសាកលវិទ្យាល័យ និងឱ្យយោបល់លើការរៀបចំកម្មវិធីសិក្សា និងបទបញ្ញានៃការសិក្សា។ សាកលវិទ្យាធិការត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យកាលណាមានភាពចាំបាច់ដែលជាប្រយោជន៍នៃសាកលវិទ្យាល័យ។ ក្រុមប្រឹក្សាភិបាលអាចសម្រេចសេចក្តីបានលុះណាតែមានសមាជិកមកប្រជុំយ៉ាងតិចពាក់កណ្តាល។

សមាសភាពក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យភូមិន្ទកំពង់ចាមមានដូចខាងក្រោម ៖

-សាកលវិទ្យាធិការនៃសាកលវិទ្យាល័យប្រធាន

-អនុសាកលវិទ្យាល័យ (សាកលវិទ្យាធិការរង)សមាជិក

-នាយកឧត្តមសិក្សា សមាជិក

-ព្រឹទ្ធាចារ្យ (ព្រឹទ្ធបុរស)មហាវិទ្យាល័យសមាជិក

-ចាងហ្វាងវិជ្ជាស្ថាន សមាជិក

-ចៅហ្វាយខេត្តកំពង់ចាមសមាជិក

-នាយកមុខងារសាធារណៈ ឬ អ្នកតំណាងសមាជិក

-អ្នកតំណាងម្នាក់នៃក្រសួងអប់រំជាតិសមាជិក

-អ្នកតំណាងម្នាក់នៃក្រសួងហិរញ្ញវត្ថុសមាជិក

-អ្នកតំណាងម្នាក់នៃក្រសួងសាធារណការ សមាជិក

-អ្នកតំណាងម្នាក់នៃក្រសួងកសិកម្មសមាជិក

-អ្នកតំណាងម្នាក់នៃក្រសួងឧស្សាហកម្មសមាជិក

-ប្រធានសាកលវិទ្យាធិការដ្ឋានស.ភ.ក.ច.សមាជិករាយការណ៍

សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងអប់រំជាតិ។

បើយោងតាមប្រកាសរបស់ក្រសួងអប់រំជាតិលេខ១៧២០/៦៨ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៦៨ បានតែងតាំងក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យភូមិន្ទកំពង់ចាមដែលមានសមាសភាពដូចខាងក្រោម ៖

-លោក ហាក់ យូលឹម សាកលវិទ្យាធិការស្ដីទីសាកលវិទ្យាល័យភូមិន្ទកំពង់ចាម
ប្រធាន

-លោក អ៊ិន រុន ព្រឹទ្ធាចារ្យ(ព្រឹទ្ធបុរស) មហាវិទ្យាល័យយន្តសាស្ត្រសមាជិក

-លោក ឃាង យន ព្រឹទ្ធាចារ្យ (ព្រឹទ្ធបុរស) មហាវិទ្យាល័យវិទ្យាសាស្ត្រ រូបនិយម គណិតវិទ្យា សមាជិក

-លោក តាំន ប៊ុនស៊ុយ ព្រឹទ្ធាចារ្យ(ព្រឹទ្ធបុរស) មហាវិទ្យាល័យវប្បកម្ម ឧណ្ហប្រទេស សមាជិក

-លោក ញាន ជៀង អភិបាលខេត្តកំពង់ចាម សមាជិក

-លោក គឹម សុន នាយកមុខងារសាធារណៈ សមាជិក

-លោក យ៉ែម យឹម អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សាសាកលវិទ្យាល័យភូមិន្ទ
សមាជិក

-លោក លីវ ជួនសេង នាយក្រុមថវិកាតំណាងក្រសួងហិរញ្ញវត្ថុ សមាជិក

-លោក ឃី តាំងលឹម វិស្វករការងារសាធារណការតំណាងក្រសួងសាធារណការ សមាជិក

-លោក ហ៊ីង អ៊ុន វិស្វករការងារកសិកម្មតំណាងក្រសួងកសិកម្មសមាជិក

-លោក សេវ ហាក់ អគ្គនាយកក្រុមហ៊ុនជាតិវាយនភណ្ឌ តំណាងក្រសួងឧស្សាហកម្ម សមាជិក

-លោក យ៉ង់ ធី អភិបាលនៃសាកលវិទ្យាល័យភូមិន្ទកំពង់ចាម មាជិករាយការណ៍

បន្ទាប់មកនៅចុងឆ្នាំ១៩៦៨ ក្រសួងអប់រំជាតិបានចេញប្រកាសលេខ២៩៣៣/៦៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៦៨ បានតែងតាំងក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យភូមិន្ទកំពង់ចាមជាថ្មីដែលមានសមាសភាពដូចខាងក្រោម ៖

-លោក ហាក់ យូលឹម សាកលវិទ្យាធិការស្ដីទីសាកលវិទ្យាល័យភូមិន្ទកំពង់ចាម
ប្រធាន

-លោកព្រឹទ្ធាចារ្យ (ព្រឹទ្ធបុរស) មហាវិទ្យាល័យយន្តសាស្ត្រ សមាជិក

-លោកព្រឹទ្ធាចារ្យ (ព្រឹទ្ធបុរស) មហាវិទ្យាល័យវិទ្យាសាស្ត្ររូបនិយមគណិតវិទ្យា
សមាជិក

-លោក តាំន ប៊ុនស៊ុយ ព្រឹទ្ធាចារ្យ(ព្រឹទ្ធបុរស) មហាវិទ្យាល័យវប្បកម្មឧណ្ហប្រទេស សមាជិក

-លោក ញាន ជៀង អភិបាលខេត្តកំពង់ចាម សមាជិក

-លោក គឹម សុន នាយកមុខងារសាធារណៈសមាជិក

-លោក យ៉ែម យឹម អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សាសាកលវិទ្យាល័យភូមិន្ទ សមាជិក

-លោក លីវ ផ្ទូនសេង នាយក្រុមថវិកា តំណាងក្រសួងហិរញ្ញវត្ថុសមាជិក

-លោក ឃី តាំងលឹម វិស្វករការងារសាធារណការ តំណាងក្រសួងសាធារណការសមាជិក

-លោក ហ៊ីង អ៊ុន វិស្វករការងារកសិកម្មតំណាងក្រសួងកសិកម្ម សមាជិក

-លោក ឡាយ ផ្ទួន អគ្គនាយកក្រុមហ៊ុនជាតិវាយនភណ្ឌ តំណាងក្រសួងឧស្សាហកម្មសមាជិក

-លោក យ៉ង់ ជី អភិបាលនៃសាកលវិទ្យាល័យភូមិន្ទកំពង់ចាម សមាជិករាយការណ៍

## ២.៤.ព្រឹទ្ធាចារ្យ(ព្រឹទ្ធបុរស) មហាវិទ្យាល័យ

សាកលវិទ្យាល័យភូមិន្ទកំពង់ចាម មានមហាវិទ្យាល័យ និង សាលាជាន់ខ្ពស់ជាចំណុះ។ សាលាបង្រៀនវិជ្ជាបច្ចេកទេស និង មានកន្លែងពិសោធន៍អនុវត្តន៍និងមជ្ឈមណ្ឌលស្រាវជ្រាវក៏អាចភ្ជាប់ទៅនឹសាកលវិទ្យាល័យនេះបានដែរ។ មហាវិទ្យាល័យ និង សាលាជាន់ខ្ពស់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រឹទ្ធាចារ្យ ឬ ចាងហ្វាងមួយរូប និង មានព្រឹទ្ធាចារ្យរង និង ចាងហ្វាង រងអមផង។ ព្រឹទ្ធាចារ្យ ចាងហ្វាង ព្រឹទ្ធាចារ្យរង និង ចាងហ្វាងរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងអប់រំជាតិ និង មានការយល់ព្រមពីសាកលវិទ្យាធិការ។

ព្រឹទ្ធាចារ្យ ព្រឹទ្ធាចារ្យរង ចាងហ្វាង និង ចាងហ្វាងរងត្រូវជ្រើសរើសក្នុងចំណោមសាស្ត្រាចារ្យ ដែលមានសញ្ញាបត្រសាកលវិទ្យាល័យឬក្នុងចំណោមឥស្សរជនដែលមានសមត្ថភាព។

## ២. ៥. ក្រុមប្រឹក្សាហ្វឹកហ្វឺន ឬ ក្រុមប្រឹក្សាភិបាលមហាវិទ្យាល័យ

ព្រឹទ្ធាចារ្យ ឬ ចាងហ្វាងត្រូវមានក្រុមប្រឹក្សាហ្វឹកហ្វឺន ឬ ក្រុមប្រឹក្សាភិបាលមហាវិទ្យាល័យដែលមានសមាសភាពដូចតទៅ ៖

-ព្រឹទ្ធាចារ្យឬចាងហ្វាង ប្រធាន

-សមាជិកម្នាក់ចាត់តាំងដោយសាកលវិទ្យាធិការសមាជិក

-សមាជិកទាំងឡាយនៃបុគ្គលិកសិក្សាដែលក្រុមប្រឹក្សា

សាស្ត្រាចារ្យបានបោះឆ្នោតជ្រើសរើស ហើយចំនួនសមាជិកនេះត្រូវបានកម្រិតតាមសេចក្តីសម្រេចរបស់សាកលវិទ្យាធិការសមាជិក

-មន្ត្រីជាន់ខ្ពស់២រូបនៃផ្នែកឧស្សាហកម្ម ឬកសិកម្មតែងតាំងដោយសេចក្តីសម្រេចរបស់សាកលវិទ្យាធិការ សមាជិក

-ប្រធានរដ្ឋបាលមហាវិទ្យាល័យ សមាជិករាយការណ៍

ក្រុមប្រឹក្សាហ្វឹកហ្វឺនអាចបន្ថែមជាជំនួយរបស់ខ្លួននូវសាស្ត្រាចារ្យមួយរូប ឬច្រើនរូបហើយនឹងតំណាងនិស្សិតមួយរូប ឬច្រើនរូបដើម្បីពិគ្រោះយោបល់។

## ២. ៦. ថវិកាសាកលវិទ្យាល័យ

ថវិកាស្វយ័ត នៃសាកលវិទ្យាល័យត្រូវរៀបចំឡើងដោយសាកលវិទ្យាធិការ និង មានការសម្រេចពីក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងអប់រំជាតិនិងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ។

ថវិកាស្វយ័ត នៃសាកលវិទ្យាល័យភូមិន្ទកំពង់ចាមត្រូវបានផ្គត់ផ្គង់ដោយប្រាក់ចំណូលដែលធ្វើឡើងតាមរយៈ ៖

-ការឧបត្ថម្ភធនគ្រប់បែបយ៉ាងពីរដ្ឋ

-អំណោយទាន និង បច្ច័យទាន

-ប្រាក់ចំណូលក្នុងការចុះឈ្មោះនិស្សិតនៅពេលប្រឡង និង ពេលសិក្សា

-ប្រាក់បានមកពីការខ្ចីសៀវភៅនៅបណ្ណាល័យ និង ពីទីពិសោធន៍

-ប្រាក់ចំណូលវិសាមញ្ញ។

ថ្វីត្បិតតែសាកលវិទ្យាល័យត្រូវទទួលការឧបត្ថម្ភថវិកាពីរដ្ឋក៏ដោយ ប៉ុន្តែតាមការស្រាវជ្រាវបានឱ្យដឹងថា ក្រសួងមហាផ្ទៃបានចេញប្រកាសបង្កើតគណៈកម្មការចាត់ចែងធ្វើឆ្នោតវត្ថុ ដើម្បីប្រមូលថវិកាមកស្ថាបនាសាកលវិទ្យាល័យភូមិន្ទកំពង់ចាម។ ជាក់ស្តែងនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៦៥ ក្រសួងមហាផ្ទៃបានចេញប្រកាសលេខ៦៧១/៦៥ បង្កើតគណៈកម្មការចាត់ចែងធ្វើឆ្នោតវត្ថុដើម្បីប្រមូលថវិកាមកស្ថាបនាសាកលវិទ្យាល័យភូមិន្ទកំពង់ចាម។សមាសភាពនៃគណៈកម្មការនេះមានដូចខាងក្រោម ៖

-លោក ញឹម ស្រគុណ ចាងហ្វាងសាលាដំបូងខេត្តកំពង់ចាម ប្រធាន

-លោក ចៅ គង់ មន្ត្រីប្រៃសណីយ៍ និង ទូរគមនាគមន៍ អនុប្រធាន

-លោក យក់ សាអុន នាយតំបន់បសុពេទ្យ សមាជិក

-លោក ប៊ូ ជុំ នាយខ័ណ្ឌគង្គា រុក្ខា សមាជិក

-លោក ប្រាច់ ថន មេបញ្ជាការកងរាជតម្រួត សមាជិក

-លោក ម៉ាត់ ត្រលន់ ស្នងការក្រុមព្រះនគរបាលជាតិ សមាជិក

-លោក ពេជ យាតសាន ស្នងការក្រុមតម្រួតក្រុង សមាជិក

-លោក ស៊ុក ប៊ន នាយកវិទ្យាល័យព្រះសីហនុ សមាជិក

-លោក ប៉ុល សារេត ចាងហ្វាងអនុវិទ្យាល័យបច្ចេកទេស សមាជិក

-លោក ឈៀង ណាល់ ចាងហ្វាង អប់រំមូលដ្ឋានខេត្ត សមាជិក

-លោក វេង ស្រេង តំណាងជនជាតិចិន សមាជិក

-លោក វ៉ូ វ៉ាន់តី តំណាងជនជាតិវៀតណាម សមាជិក

-លោក ចៅ ស៊ុន ព្រះរាជអាជ្ញា គណនេយ្យ

-លោក កៅឌី យូសុន ពេទ្យនាយក គណនេយ្យ

-លោក ជុំ សារិន ហេរញ្ញិកនាយក គណនេយ្យ

-លោក ទិត សាបូរ អភិបាលពន្ធដារ ហេរញ្ញិក

-លោក ម៉ារ សាវុន មន្ត្រីគយ និង រដ្ឋាករ ហេរញ្ញិករង

-លោក អ៊ា ជា អធិការបឋមសិក្សា អគ្គលេខាធិការ

-លោក សេង ទ្រី លេខាធិការការិយាល័យអគ្គលេខាធិការរង

## ២. ៧. បុគ្គលិកសិក្សា

បុគ្គលិកសិក្សានៅសាកលវិទ្យាល័យភូមិន្ទកំពង់ចាមមានដូចខាងក្រោម ៖

### ក. សាស្ត្រាចារ្យ និង សាស្ត្រាចារ្យសមាគត

ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកមានសញ្ញាបត្របណ្ឌិត និងវិស្វករដែលមានបទពិសោធន៍ខាងការសិក្សាបច្ចេកទេស។ សាស្ត្រាចារ្យ និងសាស្ត្រាចារ្យសមាគតត្រូវតែងតាំងដោយសេចក្តីសម្រេចនៃសាកលវិទ្យាធិការក្រោយពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ។

### ខ.ធារីបង្រៀន ឬ នាយពិនិត្យការអនុវត្ត

ត្រូវបានជ្រើសរើសពីក្នុងចំណោមអ្នកមានសញ្ញាបត្របរិញ្ញាបត្រ។ ប៉ុន្តែអាចត្រូវចាត់តាំងពិសេសឱ្យបំពេញមុខងារនេះបាននូវឥស្សរជនទាំងឡាយដែលមានសមត្ថភាពក្នុងការងារ។ ធារីបង្រៀន ឬ នាយពិនិត្យការអនុវត្តត្រូវតែងតាំងតាមលក្ខណៈដូចសាស្ត្រាចារ្យដែរ។

## ២.៨. អំពីវិន័យ

វិន័យត្រូវអនុវត្តន៍ ចំពោះកំហុសនិស្សិតទាំងឡាយដែលបានចុះឈ្មោះចូលរៀន ឬចុះក្នុងបញ្ជីដោយគិតតាំងពីនិស្សិតបានដាក់ពាក្យសុំចុះឈ្មោះចូលរៀនឬកំហុសបេក្ខជន នៅពេលប្រឡងដែលរៀបចំឡើងដោយមហាវិទ្យាល័យ។ កំហុសទាំងនេះអាចផ្តន្ទាជាបទរដ្ឋប្បវេណីឬជាបទព្រហ្មទណ្ឌ។ ព្រឹទ្ធាចារ្យមហាវិទ្យាល័យមានសិទ្ធិព្រមាន និងស្តីបន្ទោសចំពោះនិស្សិតដែលល្មើសនឹងបទបញ្ជាសិក្សា។ ព្រឹទ្ធាចារ្យមហាវិទ្យាល័យអាចចាត់វិធានការបណ្តោះអាសន្នបានដូចជាការបណ្តេញនិស្សិតចេញពីសាលា និងហាមឃាត់មិនឱ្យចូលមកវិញ

រហូតដល់ពេលដាក់សាមីខ្លួនដែលមានកំហុស នោះឱ្យក្រុមប្រឹក្សាវិន័យជំនុំជម្រះ។ ក្នុងករណីដែលបាត់បង់សណ្តាប់ធ្នាប់ព្រឹទ្ធាចារ្យមហាវិទ្យាល័យ អាចបញ្ឈប់ការបង្រៀនជាបណ្តោះអាសន្ន។ការបញ្ឈប់ការសិក្សាក្នុងរយៈ ពេល១ឆ្នាំអាចធ្វើបាន ដោយរដ្ឋមន្ត្រីក្រសួងអប់រំជាតិតាមការស្នើសុំពីព្រឹទ្ធាចារ្យមហាវិទ្យាល័យ ក្រោយពីទទួលយោបល់សាកលវិទ្យាធិការ។

ក្រុមប្រឹក្សាវិន័យនៃមហាវិទ្យាល័យ មានសមាសភាពដូចតទៅ ៖

-ព្រឹទ្ធាចារ្យឬចាងហ្វាងមហាវិទ្យាល័យ ប្រធាន

-ព្រឹទ្ធាចារ្យរង ឬ ចាងហ្វាងរង អនុប្រធាន

-សាស្ត្រាចារ្យមួយរូប និងជាវីបង្រៀនម្នាក់ដែលសហសេវិកខ្លួនបោះឆ្នោតឱ្យមាជិក

-តំណាងនិស្សិតពីររូប សមាជិក

## ផ្នែក ២ ដំណើរវិវត្តនៃសាកលវិទ្យាល័យ ភូមិន្ទកំពង់ចាម

### ១.ការពង្រីកវិសាលភាពគ្រប់គ្រង របស់សាកលវិទ្យាល័យភូមិន្ទ កំពង់ចាម

មុនឆ្នាំ១៩៥៩ គេបានបង្កើតសាលាបង្រៀនបច្ចេកទេសដែលមានឈ្មោះថា សាលារោងជាង ឬ សាលាឧស្សាហកម្មខេត្តកំពង់ចាម។ នៅឆ្នាំ១៩៥៩ សាលារោងជាងខេត្តកំពង់ចាមបានក្លាយទៅជាអនុវិទ្យាល័យបច្ចេកទេសខេត្តកំពង់ចាម ហើយសាលានេះមានមជ្ឈមណ្ឌលមួយ សម្រាប់អនុវត្តន៍ជាឧបសម្ព័ន្ធ។ ចាប់តាំងពីបវេសន កាលខែកញ្ញា ឆ្នាំ១៩៦៥ តទៅអនុវិទ្យាល័យបច្ចេកទេសខេត្តកំពង់ចាមត្រូវបានបញ្ចូលទៅក្នុងមហាវិទ្យាល័យយន្តសាស្ត្រនៃសាកល វិទ្យាល័យភូមិន្ទកំពង់ចាម ដោយមានឈ្មោះថាផ្នែកឧត្តមបច្ចេកទេសនៃមហាវិទ្យាល័យយន្តសាស្ត្រ[៤]។

នៅឆ្នាំ១៩៦៧ គេបានបង្កើតវិទ្យាស្ថានស្រាវជ្រាវការដាំដំណាំកៅស៊ូ នៅប្រទេសកម្ពុជាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាកលវិទ្យាល័យភូមិន្ទកំពង់ចាម។វិទ្យាស្ថាននេះបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ២៣ ប.រ. ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៦៧។ ការបង្កើតវិទ្យាស្ថានស្រាវជ្រាវដំណាំកៅស៊ូនេះឡើង គឺមានគោលបំណងដើម្បីស្រាវជ្រាវ និង ធ្វើពិសោធន៍បែបវិទ្យាសាស្ត្រ និងបច្ចេកទេសនៃការដាំដំណាំកៅស៊ូ ព្រមទាំងមានកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិលើផ្នែកបច្ចេកទេស ដែលទាក់ទងនឹងដំណាំកៅស៊ូផងដែរ។ មួយវិញទៀត វិទ្យាស្ថានស្រាវជ្រាវការដាំកៅស៊ូ

---

[៤] រាជកិច្ចចេញផ្សាយថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៦៥ ទំព័រ ៨២៦៤-៨២៦៥។

ត្រូវចូលរួមក្នុងការបង្រៀនវិជ្ជាស្ដីពីការដាំកៅស៊ូ នៅក្នុងមហាវិទ្យាល័យវប្បកម្មឧណ្ហប្រទេសទៅតាមកម្មវិធីរបស់មហាវិទ្យាល័យនេះ។ សាកលវិទ្យាល័យភូមិន្ទកំពង់ចាមបានដំណើរការបណ្ដុះបណ្ដាលធនធានមនុស្សចាប់ពីឆ្នាំ១៩៦៥ រហូតដល់កម្ពុជាធ្លាក់ក្នុងសង្គ្រាមឆ្នាំ១៩៧០។ ក្នុងដំណាក់កាលដែលប្រទេសជាតិមានសង្គ្រាមនោះ សាកលវិទ្យាល័យភូមិន្ទកំពង់ចាមមិនអាចដំណើរការបានដោយរលូនឡើយដាក់ស្ដែងនៅយប់ថ្ងៃទី១៥-១៦ ខែឧសភា ឆ្នាំ១៩៧០ ពួកយៀកកុង និង វៀតណាមខាងជើងបានប្រព្រឹត្តអំពើឈ្លានពាន មកលើសាកលវិទ្យាល័យកំពង់ចាមធ្វើឱ្យសាកលវិទ្យាល័យនេះទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ។ ដើម្បីលើកទឹកចិត្តចំពោះលោកសាកលវិទ្យាធិការនិងបុគ្គលិកនៃសាកលវិទ្យាល័យកំពង់ចាម ដែលតស៊ូប្រឆាំងនឹងការឈ្លានពានខាងលើ របបសាធារណរដ្ឋខ្មែរបានចេញក្រឹត្យផ្ដល់ជូននូវលិខិតសរសើរដែលហៅថា សក្ខីភាពសោមនស្ស ជាផ្លូវការជូនមន្ត្រីនៃសាកលវិទ្យាល័យកំពង់ចាមមានរាយនាមដូចខាងក្រោម៖

-លោក ផាន់ ប៊ួយហាក់ សាស្ត្រាចារ្យឧត្ដមសិក្សាជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យកំពង់ចាមបានបញ្ជាយ៉ាងក្លាហានដល់បុគ្គលិក និង និស្សិតនៅសាកលវិទ្យាល័យក្នុងពេលដែលពួកយៀកកុង និង វៀតណាមខាងជើងប្រព្រឹត្តអំពើឈ្លានពានមកលើសាកលវិទ្យាល័យកំពង់ចាមក្នុងយប់ថ្ងៃទី១៥ និង ទី១៦ ខែឧសភា ឆ្នាំ១៩៧០។

-លោក តន់ ប៊ុនស៊ុយ វិស្វករកេរ្យត្រវិទូព្រឹទ្ធបុរសមហាវិទ្យាល័យវប្បកម្មដោយបានប្រឈមមុខយ៉ាងក្លាហានទល់នឹងសត្រូវក្រោមការផ្ទុះនៃគ្រាប់បែកដៃនិងគ្រាប់រ៉ូកែតនាពេលដែលពួកយៀកកុងនិងវៀតណាមខាងជើងប្រព្រឹត្តអំពើឈ្លានពានមកលើសាកលវិទ្យាល័យកំពង់ចាមក្នុងយប់ថ្ងៃទី១៥ និង ទី១៦ ខែឧសភា ឆ្នាំ១៩៧០។

-លោក ឈឹម ឈុំ វិស្វករកេរ្យត្រវិទសាស្ត្រាចារ្យបឋមភូមិអគ្គលេខាធិការនៃមហាវិទ្យាល័យវប្បកម្មដោយបានបញ្ជាយ៉ាងក្លាហានដល់ជួរទ័ពនៅមុខគេ ដើម្បីវាយតបចំពោះការឈ្លានពានរបស់យៀកកុងនិងវៀតណាមខាងជើងប្រព្រឹត្តមកលើសាកលវិទ្យាល័យកំពង់ចាមក្នុងយប់ថ្ងៃទី១៥ និង ទី១៦ ខែឧសភា ឆ្នាំ១៩៧០ សាមីខ្លួនបានរងរបួសជាទម្ងន់ដោយគ្រាប់រ៉ូកែតបច្ចាមិត្ត[៥]។

សូមបញ្ជាក់ថា បើតាមសៀវភៅ **Les clés du Cambodge** របស់ **Raoul M. Jennar, 1995** បានបញ្ជាក់ថា នៅថ្ងៃទី១៦និងទី១៧ ខែឧសភា ឆ្នាំ១៩៧០ យន្តហោះវៀតណាមខាងត្បូងបានមកទម្លាក់គ្រាប់បែកបណ្ដាលឱ្យសាកលល័យ

[៥] ក្រឹត្យលេខ៥៤០/៧០ ប.រ. ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧០។

កំពង់ចាមត្រូវខ្ទេចខ្ទាំយ៉ាងខ្លាំង។ ដូច្នេះ តាំងពីពេលនោះមកសាកលវិទ្យាល័យភូមិន្ទកំពង់ចាមលែងដំណើរការរហូតមកដល់បច្ចុប្បន្ន។

## ២. ថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទកំពង់ចាម

សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកំពង់ចាមពីឆ្នាំ១៩៦៥ រហូតដល់កម្ពុជាធ្លាក់ក្នុងសង្គ្រាមឆ្នាំ១៩៧០ ៖

១-លោក គាត ឈន់ (ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៦៨)[៦]

២-លោក ហាក់ យូលឹម សាកលវិទ្យាធិការស្តីទី (ពីឆ្នាំ១៩៦៨ ដល់ឆ្នាំ១៩៧០?)

៣-លោក ផាន់ ប៊ួយហាក់ សាកលវិទ្យាធិការ (ពីឆ្នាំ១៩៧០? ដល់ឆ្នា

## សន្និដ្ឋាន

ក្រោយពីមានការយល់ដឹងអំពីតម្លៃនៃការអប់រំតាមបែបផ្លូវការ នៅដើមស.វ.ទី២០មក ឪពុក ម្តាយ ឬអាណាព្យាបាលបានបញ្ជូនកូនចៅរបស់ខ្លួនឱ្យទៅរៀនកាន់តែច្រើនឡើងៗ។ ដោយការអប់រំនៅបឋមសិក្សាកាន់តែរីកលូតលាស់គេបានបង្កើតសាលាអនុវិទ្យាល័យ និង បន្តមកទៀតបង្កើតសាលាវិទ្យាល័យ។ ដូច្នេះពីមួយឆ្នាំទៅមួយឆ្នាំយើងសង្កេតឃើញថា ចំនួនសិស្សានុសិស្សចេះតែមានចំនួនកើនឡើងជាលំដាប់។ ដើម្បីឱ្យសិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់មធ្យមសិក្សាអាចមកបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សារដ្ឋាភិបាលតាមរយៈក្រសួងអប់រំបានបង្កើតមហាវិទ្យាល័យនៅទីក្រុងភ្នំពេញ។

ដោយឡែក នៅខេត្តកំពង់ចាម មុនឆ្នាំ១៩៥៩ ក្រៅពីការអប់រំចំណេះទូទៅរដ្ឋាភិបាលបានបង្កើតសាលាបច្ចេកទេសវិជ្ជាជីវៈ គឺសាលាពេងជាង ឬសាលាឧស្សាហកម្មខេត្តកំពង់ចាម។ ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃសង្គមជាតិ និង តាមតម្រូវការចាំបាច់នៅឆ្នាំ១៩៥៩ សាលាឧស្សាហកម្មខេត្តកំពង់ចាមបានប្តូរទៅជាអនុវិទ្យាល័យបច្ចេកទេសខេត្តកំពង់ចាម។ សាលានេះបានដំណើរការរហូតមកដល់ឆ្នាំ១៩៦៥ ទើបបញ្ចូលមកក្នុងមហាវិទ្យាល័យយន្តសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទកំពង់ចាម។

ការបង្កើតសាកលវិទ្យាល័យភូមិន្ទកំពង់ចាម គឺដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ដោយផ្តោតលើជំនាញផ្នែកបច្ចេកទេសផ្នែកកសិកម្ម និងផ្នែកវិទ្យាសាស្ត្រ ដូចជារូបវិទ្យា និងគណិតវិទ្យាជាដើម។ មួយវិញទៀត ការបង្កើតសាកលវិទ្យាល័យនៅខេត្តកំពង់ចាមនាពេលនោះក៏ដើម្បីបង្កលក្ខណៈងាយស្រួលទៅដល់សិស្សនិស្សិតដែលមកពី

[៦] Justin Corfield and Laura Summers, ***Historical Dictionary of Cambodia***, 2003, p. 194.

ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ធំ ព្រៃវែង ។ល។ អាចមកបន្តការសិក្សាកម្រិតឧត្តមសិក្សា នៅក្នុងសាកលវិទ្យាល័យមួយនេះ។

សាកលវិទ្យាល័យភូមិន្ទកំពង់ចាមបានដំណើរការបណ្តុះបណ្តាលនិស្សិត ចាប់ពីឆ្នាំ ១៩៦៥ រហូតដល់កម្ពុជាធ្លាក់ទៅក្នុងសង្គ្រាមឆ្នាំ ១៩៧០។ នៅពេលនោះសង្គ្រាមផ្ទុះឡើងបានធ្វើឱ្យសង្គមកម្ពុជាបាត់លំនឹង និងការបញ្ចប់នូវសកម្មភាពសេដ្ឋកិច្ច ហើយបរិមាណនៃប្រព័ន្ធឧត្តមសិក្សាក៏បានចាប់ផ្តើមធ្លាក់ចុះៗក្នុងដំណាក់កាលនៃសង្គ្រាម សាស្ត្រាចារ្យបរទេសជាច្រើនបានចាកចេញពីប្រទេសកម្ពុជា។ ដើម្បីបំពេញការខ្វះខាតនេះ រដ្ឋាភិបាលបានប្រគល់ភារកិច្ចបង្រៀនទៅឱ្យអ្នកមានសញ្ញាបត្រក្នុងប្រទេសធ្វើការមិនពេញម៉ោងនៅក្នុងសាកលវិទ្យាល័យ។ វិធានការបន្ទាន់នេះ គេមិនបានគិតទៅដល់គុណភាព និងគរុកោសល្យនោះឡើយ។ នៅពេលនោះសាកលវិទ្យាល័យនៅតាមខេត្តត្រូវបិទទ្វារឬដំណើរការរអាក់រអួល។ ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា ក្នុងសម័យសាធារណរដ្ឋខ្មែរនៅរក្សាលក្ខណៈពីរបបសង្គមរាស្ត្រនិយមពីព្រោះប្រទេសស្ថិតក្នុងសង្គ្រាមរដ្ឋាភិបាលពុំមានលទ្ធភាពធ្វើកំណែទម្រង់ឧត្តមសិក្សានោះឡើយ។

ក្នុងបរិបទបច្ចុប្បន្ន ដែលប្រទេសកម្ពុជាកំពុងមានសុខសន្តិភាពនិងការអភិវឌ្ឍផងនោះ រាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និង កីឡា គួរមានការសិក្សា និង ពិនិត្យលទ្ធភាពរៀបចំបង្កើតសាកលវិទ្យាល័យរបស់រដ្ឋនៅក្នុងក្រុងកំពង់ចាមឡើងវិញ។ ប្រសិនបើមានការរៀបចំបង្កើតសាកលវិទ្យាល័យរដ្ឋ នៅខេត្តកំពង់ចាមឡើងវិញនោះ គឺជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សនៅតំបន់ជុំវិញ នៃខេត្តកំពង់ចាម ដើម្បីប្រមូលផ្តុំនូវកម្លាំងបញ្ញាញាណរបស់ជាតិមកអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជាឱ្យកាន់តែមានភាពរីកចម្រើនឡើងថែមទៀត ម្យ៉ាងទៀតក៏ជាពេលវេលាមួយដ៏សមស្របដែលកម្ពុជាកំពុងធ្វើសមាហរណកម្មខ្លួនទៅក្នុងតំបន់ និង ពិភពលោកនាសម័យសាកលភាវូបនីយកម្មនេះ។

## គន្ថនិទ្ទេស ( References )


### ឯកសារដើម

*១-រាជកិច្ច ចេញផ្សាយ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៥៩*

*២-រាជកិច្ច ចេញផ្សាយ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៥*

*៣-រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៦៥*

*៤-រាជកិច្ច ចេញផ្សាយ ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៦៥*

*៥-រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៦៥*

*៦-រាជកិច្ច ចេញផ្សាយ ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៦៨*

*៧-រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦៨*

### ឯកសារស្នាដៃនិពន្ធ

*១-រាជបណ្ឌិត្យសភាកម្ពុជា សន្និសីទជាតិស្ដីពីការបណ្ដុះបណ្ដាលធនធានមនុស្សនៅកម្ពុជា ៖ តុល្យការ និង ចក្ខុវិស័យ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០០*

*២-សុង ស៊ីណា* ***គ្រឹះស្ថានឧត្ដមសិក្សានៅប្រទេសកម្ពុជា ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦១***

*សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ប្រវត្តិវិទ្យា ភ្នំពេញ ឆ្នាំ២០០២*

៣-***Annales de la Faculté de Droit de Phnom Penh,*** 1960.

៤-***Annuaire de l' Université de Phnom Penh***, 1972.

៥-Raoul M. Jennar, ***Les clés du Cambodge***, Faits et chiffres, repères historiques, profiles cambodgiens, cartes, Maisonneuve et Larose, 1995.

៦-Sorn Samnang, ***L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939)***, Thèse d'Histoire, Université Paris 7, octobre 1995.

៧-Justin Corfield and Laura Summers, ***Historical Dictionary of Cambodia***, 2003.